ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩

# របាយការណ៍ជាតិស្តីពីលទ្ធផលចុងក្រោយ


វិទ្យាស្ថានជាតិស្ថិតិ

ក្រសួងផែនការ



ខែតុលា ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩

# របាយការណ៍ជាតិស្តីពីលទ្ធផលចុងក្រោយ

វិទ្យាស្ថានជាតិស្ថិតិ

ក្រសួងផែនការ

ខែតុលា ឆ្នាំ២០២០

# មាតិកា

**ទំព័រ**


បុព្វកថា......ii
អារម្ភកថា......iv
សមាសភាពនៃគណៈកម្មាធិការជាតិជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា......v
សមាសភាពនៃគណៈកម្មការបច្ចេកទេសជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា......vi
សមាសភាពនៃគណៈកម្មការឃោសនាជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា......vii
ផែនទីប្រទេសកម្ពុជា......viii
តួលេខសង្ខេបរបស់ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា......ix
ផ្នែក ១៖ របាយការណ៍ជាតិ......xvi
ជំពូក ១- សេចក្ដីផ្ដើម......១
ជំពូក ២- ទំហំ កំណើន និងការបែងចែកប្រជាជន......១៨
ជំពូក ៣- សមាសភាពភេទ ការបែងចែកអាយុ និងស្ថានភាពអាពាហ៍ពិពាហ៍......៣៤
ជំពូក ៤- អក្ខរភាព និងការអប់រំ......៥៣
ជំពូក ៥- កម្លាំងពលកម្ម និងការងារ......៦៥
ជំពូក ៦- ទេសន្តប្រវេសន៍......៩២
ជំពូក ៧- លទ្ធភាពបង្កើតកូន......១០៤
ជំពូក ៨- មរណភាព......១១៤
ជំពូក ៩- ពិការភាព......១២៣
ជំពូក ១០- លំនៅដ្ឋាន ចរិតលក្ខណៈគ្រួសារ និងសម្ភារៈប្រើប្រាស់ក្នុងគ្រួសារ......១៣៦
ជំពូក ១១- សេចក្ដីសង្ខេប និងការសន្និដ្ឋាន......១៦៩
សន្ទានុក្រម......១៧៩
ផ្នែក ២៖ លទ្ធផលសរុប តាមរាជធានី ខេត្ត......១៩០
ផ្នែក ៣៖ តារាងជ្រើសរើសតាមបណ្ដាខេត្ត......២៧៣
ផ្នែក ៤៖ ឧបសម្ព័ន្ធ......៣១០
ឧបសម្ព័ន្ធ ១ អនុក្រឹត្យស្ដីពីការផ្លាស់ប្ដូរព្រំប្រទល់រដ្ឋបាល......៣១១
ឧបសម្ព័ន្ធ ២ អនុក្រឹត្យស្ដីពីការបរិច្ឆេទ ការរៀបចំ និងការប្រព្រឹត្តទៅនៃជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩......៣២១
ឧបសម្ព័ន្ធ ៣ តារាង ក តារាងសំណួរបញ្ជីផ្ទះ......៣៣២
ឧបសម្ព័ន្ធ ៤ តារាង ខ តារាងសំណួរតាមគ្រួសារ......៣៣៣
ឧបសម្ព័ន្ធ ៥ បញ្ជីតារាងអាទិភាព......៣៣៩
ឧបសម្ព័ន្ធ ៦ ឯកសារយោង......៣៤៥

# បុព្វកថា

ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ បានផ្តល់កាលានុវត្តភាពយ៉ាងសំខាន់ដល់ការវាយតម្លៃសមិទ្ធផលនានាដែលសម្រេចបានក្នុងអតីតកាល និងបានចង្អុលបង្ហាញនូវប្រសិទ្ធភាពនៃការអនុវត្តផែនការ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ទាំងឡាយសម្រាប់អនាគត។ ដោយមើលឃើញអំពីសារៈសំខាន់យ៉ាងធំធេងនៃការងារជំរឿន រាជរដ្ឋាភិបាលកម្ពុជាក្នុងភាពជាម្ចាស់បានបង្កើនការប្រើប្រាស់ថវិកាជាតិដច្រើន ដែលការធ្វើជំរឿនរយៈកាលកន្លងមកពឹងផ្អែកជំនួយហិរញ្ញវត្ថុស្ទើរទាំងស្រុងពីដៃគូអភិវឌ្ឍន៍។

ខ្ញុំពិតជាមានសេចក្តីរីករាយ ដែលជំរឿននេះបានអនុវត្តដោយជោគជ័យ និងបានផ្តល់ទិន្នន័យប្រកបដោយភាពជឿទុកចិត្ត និងទាន់ពេលវេលា សម្រាប់អ្នកតាក់តែងគោលនយោបាយ និងអ្នកធ្វើសេចក្តីសម្រេចនានារបស់រាជរដ្ឋាភិបាល និងសម្រាប់អ្នកប្រើប្រាស់ទូទៅ។ របាយការណ៍ជាតិ ស្តីពីលទ្ធផលចុងក្រោយជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ ជារបាយការណ៍ជាតិដំបូង ហើយក៏នឹងមានរបាយការណ៍លម្អិតតាមប្រធានបទជាច្រើនទៀត ដែលនឹងត្រូវផលិតឡើងដោយវិទ្យាស្ថានជាតិស្ថិតិ ដោយមានការចូលរួមពីសំណាក់អ្នកជំនាញតាមវិស័យនានា ព្រមទាំងពីសំណាក់ស្ថាប័នសិក្សាស្រាវជ្រាវផងដែរ។

ខ្ញុំសូមសម្តែងនូវកតញ្ញូតាធម៌ដជ្រាលជ្រៅបំផុតជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលសម្តេចបានគាំទ្រយ៉ាងពេញទំហឹង និងបានណែនាំដ៏ថ្លៃថ្លាដល់ការអនុវត្តជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ នេះទទួលបានជោគជ័យយ៉ាងត្រចះត្រចង់។ ខ្ញុំសូមគោរពថ្លែងអំណរគុណ ជូនចំពោះ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ ដែលសម្តេចបានផ្តល់អនុសាសន៍ចង្អុលបង្ហាញយ៉ាងច្បាស់លាស់គ្រប់ពេលវេលានៅក្នុងដំណើរការជំរឿនទូទៅនេះ។

ខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយក្រៃលែង ក្នុងនាមក្រសួងផែនការ និងក្នុងនាមប្រធានគណៈកម្មការបច្ចេកទេសជំរឿន និងជាប្រធានគណៈកម្មការឃោសនាជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ និងសូមថ្លែងអំណរគុណផងដែរ ចំពោះសមាជិកនៃគណៈកម្មាធិការជំរឿនថ្នាក់កណ្តាល គណៈកម្មាធិការជំរឿនរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ទាំងអស់ ដែលបានបំពេញការងារយ៉ាងល្អរហូតទទួលបាននូវលទ្ធផលជាផ្លែផ្កាស្របទៅតាមពេលវេលាដែលបានគ្រោងទុក។

ខ្ញុំសូមថ្លែងអំណរគុណដល់មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA) ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ (GIZ) និងទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (Sida) ដែលបានរួមចំណែកផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបានផ្តល់ជំនួយផ្នែកបច្ចេកទេស ក្នុងការរៀបចំផែនការជំរឿន ការរៀបចំបណ្តាញវាយបញ្ចូលទិន្នន័យ និងសម្អាតទិន្នន័យ ការបណ្តុះបណ្តាលមន្ត្រីបច្ចេកទេសក្នុងការវិភាគទិន្នន័យ និងសរសេររបាយការណ៍ និងការរៀបចំរបាយការណ៍ចុងក្រោយសម្រាប់ជំរឿននេះ។

ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ដល់លោកសាស្ត្រាចារ្យបណ្ឌិត Nott Rama Rao បានផ្តល់ជំនួយបច្ចេកទេសក្នុងការរៀបចំផែនការជំរឿន និងបានពិនិត្យរាល់ទិដ្ឋភាពបច្ចេកទេសទាំងអស់របស់ជំរឿន លោកបណ្ឌិត Ricardo Neupert ប្រធានទីប្រឹក្សាបច្ចេកទេសជំរឿនបានជួយដល់ផ្នែកបច្ចេកទេសជំរឿន ជាពិសេសការសរសេររបាយការណ៍ជំរឿនចុងក្រោយនេះ លោកទីប្រឹក្សា Kjell Tambour បានផ្តល់ជំនួយបច្ចេកទេសខាងការកែច្នៃទិន្នន័យ និងលោកបណ្ឌិត Arij Dekker ទីប្រឹក្សាបច្ចេកទេសបានជួយដល់ការសម្អាតទិន្នន័យ និងតារាងអាទិភាពជំរឿន។

ខ្ញុំសូមថ្លែងអំណរគុណជាពិសេស ចំពោះរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ដែលបានផ្តល់ជំនួយជាសម្ភារៈ រួមមានរថយន្ត ទោចក្រយានយន្ត កុំព្យូទ័រលើតុ និងកំព្យូទ័រយួរដៃ ឧបករណ៍បោះពុម្ពអក្សរ ឧបករណ៍ថតចម្លង តាប្លេត (Tablet) ឧបករណ៍ផ្គត់ផ្គង់ព័ត៌មាន (Server) រួមទាំងឧបករណ៍អេឡិចត្រូនិកផ្សេងៗទៀត ដែលមានតម្លៃសរុបប្រមាណ ២,៥ លានដុល្លារសហរដ្ឋអាមេរិក ដើម្បីបម្រើដល់ការធ្វើជំរឿននេះ។

ជាចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ ចំពោះមន្ត្រីវិទ្យាស្ថានជាតិស្ថិតិទាំងអស់ក្រោមការដឹកនាំរបស់លោកជំទាវ ហង់ លីណា ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ ដែលបានសម្របសម្រួលយ៉ាងយកចិត្តទុកដាក់នូវរាល់កិច្ចប្រតិបត្តិការជំរឿន ដោយមានជំនួយការពីអគ្គនាយករងមួយចំនួនគឺ ឯកឧត្តម សុក កុសល ឯកឧត្តម សាំង ឡង់ឌី និងឯកឧត្តម ចឺ ឃាម ទីប្រឹក្សាក្រសួង និងជាប្រធាននាយកដ្ឋានស្ថិតិប្រជាសាស្ត្រ ជំរឿន និងអង្កេត។ ខ្ញុំសូមអរគុណជាពិសេស ជូនចំពោះបងប្អូនជនរួមជាតិទាំងអស់ ដែលបានគាំទ្រ និងចូលរួមសហការ នៅក្នុងដំណើរការនៃប្រតិបត្តិការជំរឿនទូទៅនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ សម្រេចបានជោគជ័យ។

ខ្ញុំមានជំនឿយ៉ាងមុតមាំថា គ្រប់ក្រសួង ស្ថាប័នជាតិ ដៃគូអភិវឌ្ឍន៍ អង្គការជាតិ និងអន្តរជាតិគ្រឹះស្ថានសិក្សាស្រាវជ្រាវ វិស័យឯកជន និងសាធារណជនទូទៅ នឹងទទួលបាននូវអត្ថប្រយោជន៍ពីរបាយការណ៍នេះ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងផែនការ**



**កិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន**

# អារម្ភកថា

ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ ត្រូវបានដឹកនាំប្រតិបត្តិការដោយវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ។ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ គឺជាជំរឿនលើកទី ៤ នៅក្នុងការធ្វើជំរឿនជាបន្តបន្ទាប់នៅព្រះរាជាណាចក្រកម្ពុជា តាំងពីឆ្នាំ១៩៦២ ឆ្នាំ១៩៩៨ និងឆ្នាំ២០០៨។ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ បានធ្វើឡើងចាប់ពីថ្ងៃទី ៣ ដល់ថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០១៩ ហើយរបាយការណ៍នេះបង្ហាញពីលទ្ធផលចុងក្រោយដែលរៀបចំដោយវិទ្យាស្ថានជាតិស្ថិតិ។ តារាងទិន្នន័យរួមមាន លម្អិតអំពីចំនួន ប្រជាជនសរុប អត្រាកំណើនប្រចាំឆ្នាំ និងការបែងចែកប្រជាជន និងដង់ស៊ីតេប្រជាជន រចនាសម្ព័ន្ធអាយុនិងអាពាហ៍ពិពាហ៍ អក្ខរភាពនិងការអប់រំ កម្លាំងពលកម្មនិងការងារ លទ្ធភាពបង្កើតកូន មរណភាព ការផ្លាស់ប្តូរលំនៅដ្ឋាន ពិការភាព និងស្ថានភាពគ្រួសារ និងសម្ភារប្រើប្រាស់ក្នុងផ្ទះសម្បែង។ តារាងទិន្នន័យផ្សេងៗទៀត ដែលមានការវិភាគយ៉ាងលម្អិត នឹងបង្ហាញជូនក្នុងរបាយការណ៍វិភាគស៊ីជម្រៅ ចំនួន ១៧ប្រធានបទ ដែលរំពឹងថានឹងត្រូវបានបោះពុម្ពនិងចេញផ្សាយនៅចុងឆ្នាំ២០២០ ឬដើមឆ្នាំ២០២១ ។

ខ្ញុំសូមថ្លែងអំណរគុណ ដ៏ជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានផ្តល់ការគាំទ្រ ស្ទើរតែទាំងស្រុងផ្នែកហិរញ្ញវត្ថុ។ ខ្ញុំសូមថ្លែងអំណរគុណ ចំពោះមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA) ដែលបានដើរតួនាទី សម្របសម្រួលសម្រាប់ជំរឿន និងការគាំទ្រផ្នែកបច្ចេកទេសនិងថវិកាមួយចំណែក។ សូមថ្លែងអំណរគុណដល់សាធារណរដ្ឋប្រជាមានិតចិន ដែលបានផ្តល់សម្ភារៈចាំបាច់សម្រាប់ដំណើរការជំរឿន រួមមាន រថយន្ត ទោចក្រយានយន្ត ម៉ាស៊ីនកុំព្យូទ័រ ម៉ាស៊ីនថតចម្លង ជាដើម។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណដល់មន្ត្រីនៃវិទ្យាស្ថានជាតិស្ថិតិទាំងអស់ មន្ត្រីជំរឿនរាជធានី-ខេត្ត មន្ត្រីជំរឿនស្រុក-ខណ្ឌ-ក្រុង មន្ត្រីជំរឿនឃុំ-សង្កាត់ មេភូមិ មន្ត្រីត្រួតពិនិត្យ និងមន្ត្រីសម្ភាសន៍ដែលបានខិតខំប្រឹងប្រែងក្នុងការប្រមូលទិន្នន័យតាមមូលដ្ឋាន ដែលអាចឱ្យយើងផលិតបាននូវទិន្នន័យដែលមានគុណភាពខ្ពស់។ ខ្ញុំសូមកោតសរសើរដល់សាធារណជនទូទៅ ដែលបានសហការល្អក្នុងការផ្តល់ព័ត៌មានដ៏មានសារសំខាន់បំផុតដោយគ្មានការលាក់លៀម។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**
**ទទួលបន្ទុកអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ**

**ហាន់ លីណា**

# សមាសភាពនៃគណៈកម្មាធិការជាតិ
# ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩

| | | | |
|---|---|---|---|
| ១. | សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | | ប្រធាន |
| ២. | ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ | | អនុប្រធាន |
| ៣. | ឯកឧត្តម | រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤. | ឯកឧត្តម | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥. | ឯកឧត្តម | រដ្ឋលេខាធិការ ក្រសួងការពារជាតិ | សមាជិក |
| ៦. | ឯកឧត្តម | រដ្ឋលេខាធិការ ក្រសួងផែនការ | សមាជិក |
| ៧. | ឯកឧត្តម | រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៨. | ឯកឧត្តម | រដ្ឋលេខាធិការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៩. | ឯកឧត្តម | រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១០. | ឯកឧត្តម | រដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១១. | ឯកឧត្តម | រដ្ឋលេខាធិការ ក្រសួងសុខាភិបាល | សមាជិក |
| ១២. | ឯកឧត្តម | រដ្ឋលេខាធិការ ក្រសួងព័ត៌មាន | សមាជិក |
| ១៣. | ឯកឧត្តម | រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី | សមាជិក |
| ១៤. | ឯកឧត្តម | រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| ១៥. | ឯកឧត្តម | រដ្ឋលេខាធិការ ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១៦. | ឯកឧត្តម | រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | សមាជិក |
| ១៧. | ឯកឧត្តម | រដ្ឋលេខាធិការ ក្រសួងបរិស្ថាន | សមាជិក |
| ១៨. | ឯកឧត្តម | អនុរដ្ឋលេខាធិការ ក្រសួងផែនការ | សមាជិក |
| ១៩. | លោកជំទាវ ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ | | លេខាធិការ |

# សមាសភាពនៃគណៈកម្មការបច្ចេកទេស
# ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩

| | | |
|---|---|---|
| ១. ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ | | ប្រធាន |
| ២. ឯកឧត្តម | រដ្ឋលេខាធិការ ក្រសួងផែនការ | អនុប្រធាន |
| ៣. ឯកឧត្តម | អនុរដ្ឋលេខាធិការ ក្រសួងផែនការ | សមាជិក |
| ៤. ឯកឧត្តម | អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានប្រជាជន និងការអភិវឌ្ឍ | សមាជិក |
| ៥. លោកជំទាវ | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ | សមាជិកអចិន្ត្រៃយ៍ |
| ៦. ឯកឧត្តម អគ្គនាយកនៃអគ្គនាយកដ្ឋានសុរិយោដី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | | សមាជិក |
| ៧. ឯកឧត្តម | អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ | សមាជិក |
| ៨. ឯកឧត្តម | នាយកខុទ្ទកាល័យ ក្រសួងផែនការ | សមាជិក |
| ៩. លោក | អគ្គនាយករងវិទ្យាស្ថានជាតិស្ថិតិ ទទួលបន្ទុកការងារជំរឿន | លេខា |

# សមាសភាពនៃគណៈកម្មការឃោសនា
# ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩

| | | | |
|---|---|---|---|
| ១. | ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ | | ប្រធាន |
| ២. | ឯកឧត្តម | រដ្ឋលេខាធិការ ក្រសួងផែនការ | អនុប្រធាន |
| ៣. | ឯកឧត្តម | រដ្ឋលេខាធិការ ក្រសួងព័ត៌មាន | សមាជិក |
| ៤. | លោកជំទាវ | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ | សមាជិកអចិន្ត្រៃយ៍ |
| ៥. | ឯកឧត្តម | អគ្គនាយកវិទ្យុ | សមាជិក |
| ៦. | ឯកឧត្តម | អគ្គនាយកទូរទស្សន៍ | សមាជិក |
| ៧. | ឯកឧត្តម | តំណាងក្រសួងមហាផ្ទៃ | សមាជិក |
| ៨. | ឯកឧត្តម | តំណាងក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៩. | ឯកឧត្តម | តំណាងក្រសួងសុខាភិបាល | សមាជិក |
| ១០. | ឯកឧត្តម | តំណាងក្រសួងធម្មការ និងសាសនា | សមាជិក |
| ១១. | ឯកឧត្តម | តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១២. | ឯកឧត្តម | តំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១៣. | ឯកឧត្តម | ប្រធានសម្ព័ន្ធអ្នកសារព័ត៌មាន | សមាជិក |
| ១៤. | ឯកឧត្តម | តំណាងក្រុមហ៊ុនទូរស័ព្ទចល័តវីតែល | សមាជិក |
| ១៥. | ឯកឧត្តម | តំណាងទីភ្នាក់ងារសារព័ត៌មានខ្មែរ | សមាជិក |
| ១៦. | ឯកឧត្តម | តំណាងក្រុមហ៊ុនទូរស័ព្ទចល័តម៉ូប៊ីថែល | សមាជិក |
| ១៧. | ឯកឧត្តម | តំណាងក្រុមហ៊ុនទូរស័ព្ទចល័តស្មាត | សមាជិក |
| ១៨. | លោក | អគ្គនាយករងវិទ្យាស្ថានជាតិស្ថិតិ | លេខាធិការ |

# ផែនទី ព្រះរាជាណាចក្រកម្ពុជា



# ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩
## លទ្ធផលចុងក្រោយ
### តួលេខសង្ខេប

| | | |
|---|---|---|
| ១. | ចំនួនរាជធានី | ១ |
| ២. | ចំនួនខេត្ត | ២៤ |
| ៣. | ចំនួនក្រុង | ២៧ |
| ៤. | ចំនួនខណ្ឌ | ១៤ |
| ៥. | ចំនួនស្រុក | ១៦៣ |
| ៦. | ចំនួនសង្កាត់ | ២៣៧ |
| ៧. | ចំនួនឃុំ | ១.៤០៩ |
| ៨. | ចំនួនភូមិ | ១៤.៥៤៥ |

៩. ចំនួនប្រជាជនតាមទីប្រជុំជន ជនបទ និងតាមភេទ

| តំបន់ | សរុប | ប្រុស | ស្រី |
|---|---|---|---|
| សរុប | ១៥.៥៥២.២១១ | ៧.៥៧១.៨៣៧ | ៧.៩៨០.៣៧៤ |
| ទីប្រជុំជន | ៦.១៣៥.១៩៤ | ២.៩៩៣.៣៣៩ | ៣.១៤១.៨៥៥ |
| ជនបទ | ៩.៤១៧.០១៧ | ៤.៥៧៨.៤៩៨ | ៤.៨៣៨.៥១៩ |

| | | |
|---|---|---|
| ១០. | ភាគរយប្រជាជននៅទីប្រជុំជន | ៣៩,៤ |
| ១១. | អត្រាកំណើនប្រជាជនប្រចាំឆ្នាំ | ១,៤ |
| ១២. | សរុបចំនួនគ្រួសារ | ៣.៥៥៣.០២១ |
| ១៣. | ទំហំគ្រួសារមធ្យម (ផ្អែកលើគ្រួសារធម្មតា ឬគ្រួសារប្រក្រតី) | |
| | សរុប | ៤,៣ |
| | ទីប្រជុំជន | ៤,៣ |
| | ជនបទ | ៤,២ |
| ១៤. | ភាគរយស្ត្រីជាមេគ្រួសារ | ២៥,៦ |
| ១៥. | ដង់ស៊ីតេប្រជាជនក្នុងមួយគីឡូម៉ែត្រការ៉េ | |
| | សរុប | ៨៧ |
| | ទីប្រជុំជន | ៨៧៤ |
| | ជនបទ | ៥៥ |
| ១៦. | ភាគរយនៃប្រជាជនតាមក្រុមអាយុ | |
| | ភាគរយប្រជាជនអាយុ ០-១៤ ឆ្នាំ | ២៩,៤ |
| | ភាគរយប្រជាជនអាយុ ១៥-៥៩ ឆ្នាំ | ៦១,៧ |
| | ភាគរយប្រជាជនអាយុ ៦០ ឆ្នាំឡើង | ៨,៩ |

១៧. ផលធៀបអ្នកក្នុងបន្ទុក

| | |
|---|---|
| សរុប | ៦២,០ |
| ទីប្រជុំជន | ៥១,២ |
| ជនបទ | ៦៩,៩ |

១៨. ផលធៀបភេទ

| | |
|---|---|
| សរុប | ៩៤,៩ |
| ទីប្រជុំជន | ៩៥,៣ |
| ជនបទ | ៩៤,៦ |

១៩ មេដ្យានអាយុ

| | |
|---|---|
| សរុប | ២៧ |
| ទីប្រជុំជន | ២៨ |
| ជនបទ | ២៦ |

២០. ភាគរយប្រជាជនអាយុ ១៥ ឆ្នាំឡើង តាមស្ថានភាពអាពាហ៍ពិពាហ៍(ភាគរយ)

| ភេទ | ស្ថានភាពអាពាហ៍ពិពាហ៍ (ភាគរយ) | | | | |
|---|---|---|---|---|---|
| | មិនដែលរៀបការ | រៀបការហើយ | មេម៉ាយពោះម៉ាយ | លែងលះ | រស់នៅផ្សេងគ្នា |
| សរុប | ២៧,៥ | ៦៦,២ | ៤,០ | ២,២ | ០,១ |
| ប្រុស | ៣១,២ | ៦៥,៩ | ១,៥ | ១,៣ | ០,១ |
| ស្រី | ២៤,១ | ៦៦,៤ | ៦,៣ | ៣,០ | ០,២ |

២១. អាយុមធ្យមរៀបអាពាហ៍ពិពាហ៍ដំបូង

| តំបន់ | សរុប | ប្រុស | ស្រី |
|---|---|---|---|
| សរុប | ២៥,៣ | ២៧,០ | ២៤,០ |
| ទីប្រជុំជន | ២៦,៣ | ២៨,១ | ២៥,០ |
| ជនបទ | ២៤,៣ | ២៦,០ | ២២,៧ |

២២. ភាគរយអក្ខរភាពមនុស្សពេញវ័យ(ប្រជាជនអាយុ ១៥ ឆ្នាំឡើង)

| តំបន់ | សរុប | ប្រុស | ស្រី |
|---|---|---|---|
| សរុប | ៨៧,៧ | ៩០,៩ | ៨៤,៨ |
| ទីប្រជុំជន | ៩៣,៣ | ៩៥,៣ | ៩១,៤ |
| ជនបទ | ៨៣,៨ | ៨៧,៨ | ៨០,២ |

២៣. ភាគរយអក្ខរភាពតាមកម្រិតសិក្សាអប់រំ (ប្រជាជនអាយុ ១៥ ឆ្នាំឡើង)

| កម្រិតសិក្សា | សរុប | ប្រុស | ស្រី |
|---|---|---|---|
| មិនបានបញ្ចប់ថ្នាក់ណាមួយ | ០,០៦ | ០,០៦ | ០,០៦ |
| មិនបានបញ្ចប់ថ្នាក់បឋមសិក្សា | ៣៥,១ | ៣១,៣ | ៣៨,៩ |
| បានបញ្ចប់ថ្នាក់បឋមសិក្សា | ៣១,១ | ៣១,៥ | ៣០,៧ |
| បានបញ្ចប់ថ្នាក់មធ្យមសិក្សាបឋមភូមិ | ២៦,៦ | ២៨,៩ | ២៤,៥ |
| បានបញ្ចប់ថ្នាក់មធ្យមសិក្សា/មានសញ្ញាបត្រទុតិយភូមិ | ២,៩ | ៣,២ | ២,៥ |
| បានបញ្ចប់ថ្នាក់មធ្យមសិក្សាបឋមភូមិមានសញ្ញាបត្របច្ចេកទេស វិជ្ជាជីវៈ/សញ្ញាបត្រទុតិយភូមិមានសញ្ញាបត្របច្ចេកទេសវិជ្ជាជីវៈ | ០,៧ | ០,៧ | ០,៦ |
| សញ្ញាបត្រមហាវិទ្យាល័យ | ២,៩ | ៣,៥ | ២,៤ |
| សញ្ញាបត្រអនុបណ្ឌិត/សញ្ញាបត្របណ្ឌិត | ០,៦ | ០,៨ | ០,៣ |
| វិញ្ញាបនបត្រមុខវិជ្ជាណាមួយផ្សេងទៀត | ០,០៣ | ០,០៤ | ០,០២ |

២៤. ភាគរយកំពុងសិក្សានៅសាលា ឬគ្រឹះស្ថានសិក្សា

| ក្រុមអាយុ | សរុប | ប្រុស | ស្រី |
|---|---|---|---|
| ០៦-១១ | ៩០,៦ | ៩០,១ | ៩១,១ |
| ១២-១៤ | ៩១,៦ | ៩០,៤ | ៩២,៨ |
| ១៥-១៧ | ៦៧,៦ | ៦៦,២ | ៦៩,១ |
| ១៨-២៤ | ២០,៧ | ២២,១ | ១៩,៣ |
| ២៥ ឆ្នាំឡើង | ០,៧ | ០,៨ | ០,៦ |

២៥. ភាគរយប្រជាជនពិការ ធៀបប្រជាជនសរុប

| កម្រិតនៃពិការភាព | សរុប | ប្រុស | ស្រី |
|---|---|---|---|
| លំបាកខ្លះ | ៤,៩ | ៤,២ | ៥,៥ |
| លំបាកខ្លាំង និងមិនអាចធ្វើអ្វីទាំងអស់ | ១,២ | ១,០ | ១,៣ |

២៦. ប្រភេទពិការភាព

| ប្រភេទពិការភាព | | | |
|---|---|---|---|
| លំបាកក្នុងការមើល | សរុប | ប្រុស | ស្រី |
| លំបាកខ្លះ | ២,៩ | ២,៤ | ៣,៤ |
| លំបាកខ្លាំង និងមិនអាចធ្វើអ្វីទាំងអស់ | ០,៦ | ០,៥ | ០,៧ |
| លំបាកក្នុងការស្តាប់ | | | |
| លំបាកខ្លះ | ២,៤ | ២,០ | ២,៩ |
| លំបាកខ្លាំង និងមិនអាចធ្វើអ្វីទាំងអស់ | ០,៥ | ០,៤ | ០,៦ |

| | | | |
|---|---|---|---|
| លំបាកក្នុងការផ្លាស់ទី ឬឡើងជណ្តើរ | | | |
| លំបាកខ្លះ | ២,២ | ១,៧ | ២,៦ |
| លំបាកខ្លាំង និងមិនអាចធ្វើអ្វីទាំងអស់ | ០,៦ | ០,៥ | ០,៧ |
| លំបាកក្នុងការចងចាំ ឬការគិត | | | |
| លំបាកខ្លះ | ២,៣ | ១,៨ | ២,៧ |
| លំបាកខ្លាំង និងមិនអាចធ្វើអ្វីទាំងអស់ | ០,៦ | ០,៤ | ០,៧ |
| លំបាកក្នុងការថែទាំខ្លួន និងស្លៀកពាក់ | | | |
| លំបាកខ្លះ | ១,៨ | ១,៤ | ២,២ |
| លំបាកខ្លាំង និងមិនអាចធ្វើអ្វីទាំងអស់ | ០,៥ | ០,៤ | ០,៦ |
| លំបាកក្នុងការនិយាយ | | | |
| លំបាកខ្លះ | ១,៨ | ១,៥ | ២,២ |
| លំបាកខ្លាំង និងមិនអាចធ្វើអ្វីទាំងអស់ | ០,៥ | ០,៤ | ០,៦ |

២៧. ប្រជាជនអាយុ ៥ ឆ្នាំឡើង តាមស្ថានភាពការងារជាក់ស្តែង

| សកម្មភាពសេដ្ឋកិច្ច | សរុប | ប្រុស | ស្រី |
|---|---|---|---|
| អត្រាចូលរួមកម្លាំងពលកម្ម | ៦២,០ | ៦៥,២ | ៥៩,០ |
| អត្រាមានការងារធ្វើ | ៩៨,៧ | ៩៨,៨ | ៩៨,៥ |
| អត្រាគ្មានការងារធ្វើ | ១,៤ | ១,៣ | ១,៥ |
| អសកម្មជនសេដ្ឋកិច្ច | ៣៨,០ | ៣៤,៨ | ៤១,០ |

២៨. អត្រាចូលរួមកម្លាំងពលកម្មអាយុ ១៥-៥៩ ឆ្នាំ

| តំបន់ | សរុប | ប្រុស | ស្រី |
|---|---|---|---|
| សរុប | ៨១,៧ | ៨៥,៨ | ៧៧,៩ |
| ទីប្រជុំជន | ៧៨,០ | ៨៣,៨ | ៧២,៤ |
| ជនបទ | ៨៤,៥ | ៨៧,២ | ៨១,៩ |

២៩. អត្រាគ្មានការងារធ្វើ អាយុ១៥-៥៩ ឆ្នាំ

| តំបន់ | សរុប | ប្រុស | ស្រី |
|---|---|---|---|
| សរុប | ១,២ | ១,១ | ១,៣ |
| ទីប្រជុំជន | ១,៦ | ១,៥ | ១,៨ |
| ជនបទ | ០,៩ | ០,៩ | ០,៩ |

៣០. អត្រាមានការងារធ្វើតាមវិស័យការងារ

| វិស័យការងារ | សរុប | ប្រុស | ស្រី |
|---|---|---|---|
| វិស័យទី ១ (កសិកម្ម) | ៥៤,៧ | ៥៣,០ | ៥៦,៥ |
| វិស័យទី២ (ឧស្សាហកម្ម) | ១៨,៨ | ១៨,០ | ១៩,៧ |
| វិស័យទី៣ (សេវាកម្ម) | ២៦,៥ | ២៩,០ | ២៣,៨ |

៣១. ភាគរយប្រជាជនផ្លាស់លំនៅដ្ឋាន (លំនៅដ្ឋានពីមុន)

| តំបន់ | សរុប | ប្រុស | ស្រី |
|---|---|---|---|
| សរុប | ២១,៥ | ២៣,១ | ១៩,៩ |
| ទីប្រជុំជន | ៣៥,៣ | ៣៦,៨ | ៣៤,០ |
| ជនបទ | ១២,៤ | ១៤,២ | ១០,៧ |

៣២. ភាគរយប្រជាជនផ្លាស់លំនៅដ្ឋាន តាមតំបន់

| ការផ្លាស់លំនៅដ្ឋាន | សរុប | ប្រុស | ស្រី |
|---|---|---|---|
| ជនបទ ទៅជនបទ | ២៩,០ | ៣០,៧ | ២៧,១ |
| ជនបទ ទៅ ទីប្រជុំជន | ៣៤,០ | ៣២,៤ | ៣៥,៧ |
| ទីប្រជុំជន ទៅជនបទ | ៧,០ | ៧,៦ | ៦,៣ |
| ទីប្រជុំជន ទៅទីប្រជុំជន | ៣០,០ | ២៩,៣ | ៣០,៨ |

៣៣. ភាគរយអាគារ តាមលក្ខណៈសំណង់

| លក្ខណៈសំណង់ | សរុប | ទីប្រជុំជន | ជនបទ |
|---|---|---|---|
| អចិន្ត្រៃយ៍ | ៩១,១ | ៩៥,៤ | ៨៨,៦ |
| ពាក់កណ្ដាលអចិន្ត្រៃយ៍ | ៧,៤ | ៣,៨ | ៩,៤ |
| បណ្ដោះអាសន្ន | ១,៦ | ០,៧ | ២,០ |

៣៤. ភាគរយគ្រួសារបែងចែកតាមប្រភពទឹកសម្រាប់ពិសា

| ប្រភេទប្រភពទឹក | សរុប | ទីប្រជុំជន | ជនបទ |
|---|---|---|---|
| ទឹកម៉ាស៊ីនបណ្ដាញ | ២៥,៥ | ៤៦,៧ | ១២,៨ |
| ទឹកបំពង់បណ្ដាញក្នុងទីធ្លា/បរិវេណលំនៅដ្ឋាន | ៣,៦ | ៤,៩ | ២,៩ |
| ទឹកបំពង់សាធារណៈ | ៣,៩ | ៥,៧ | ២,៨ |
| ទឹកអណ្ដូងស្នប់ | ២៥,២ | ១២,៩ | ៣២,៦ |
| ទឹកអណ្ដូងជីកមានគម្របការពារ | ៤,៥ | ២,២ | ៥,៩ |
| ទឹកអណ្ដូងជីកគ្មានគម្របការពារ | ៥,៩ | ១,៤ | ៨,៦ |
| ទឹកចេញក្រោមដីមានការការពារ | ០,៣ | ០,២ | ០,៤ |
| ទឹកចេញក្រោមដីគ្មានការការពារ | ០,៣ | ០,១ | ០,៥ |
| ទឹកភ្លៀង | ២,៨ | ១,៥ | ៣,៥ |
| ទឹកលើដី (ទន្លេ អូរ បឹង ត្រពាំង....) | ១០,៦ | ៥,៤ | ១៣,៧ |
| ទឹកទិញឡានស៊ីទែន | ៤,៩ | ៤,៨ | ៥,០ |
| ទឹកទិញធុងរទេះ | ៤,៨ | ៤,០ | ៥,៣ |
| ទឹកដប/ទឹកពិសាដប | ៧,១ | ៩,៨ | ៥,៤ |
| ប្រភពទឹកផ្សេងទៀត | ០,៦ | ០,៦ | ០,៧ |

៣៥. ភាគរយគ្រួសារប្រើប្រាស់អគ្គិសនី ជាប្រភពសំខាន់សម្រាប់បំភ្លឺ

| | |
|---|---|
| សរុប | ៨៤,០ |
| ទីប្រជុំជន | ៩៦,៩ |
| ជនបទ | ៧៦,៤ |

៣៦. ភាគរយគ្រួសារបែងចែកតាមឥន្ធនៈចម្អិនអាហារ

| ប្រភេទឥន្ធនៈ | សរុប | ទីប្រជុំជន | ជនបទ |
|---|---|---|---|
| ឧស | ៦០,៩ | ៣១,០ | ៧៨,៨ |
| ធ្យូង | ៧,៨ | ៧,៩ | ៧,៧ |
| ប្រេងកាត | ០,៣ | ០,៤ | ០,៣ |
| ឧស្ម័ន ហ្គាស | ២៧,៧ | ៥៦,២ | ១០,៧ |
| អគ្គិសនី | ៣,០ | ៤,២ | ២,៣ |
| គ្មាន | ០,១ | ០,២ | ០,១ |
| ផ្សេងទៀត | ០,១ | ០,១ | ០,១ |

៣៧. ភាគរយគ្រួសារបានប្រើប្រាស់បង្គន់ និងប្រភេទបង្គន់

| ប្រភេទបង្គន់ | សរុប | ទីប្រជុំជន | ជនបទ |
|---|---|---|---|
| មិនប្រើបង្គន់ | ១៧,២ | ៩,៦ | ២១,៧ |
| បង្គន់ចាក់ទឹក ឬ(ចុចបង្ហូរទឹក)តភ្ជាប់ទៅប្រព័ន្ធលូ | ២៨,៩ | ៤៤,៨ | ១៩,៤ |
| បង្គន់ចាក់ទឹក ឬ(ចុចបង្ហូរទឹក)តភ្ជាប់ទៅអាងស្តុក ឬរណ្តៅ | ៣៧,៨ | ៣៤,៧ | ៣៩,៦ |
| បង្គន់ចាក់ទឹកឬ(ចុចបង្ហូរទឹក)បង្ហូរទៅកន្លែងផ្សេង | ៨,៦ | ៧,១ | ៩,៥ |
| បង្គន់រណ្តៅមានចានបង្គន់ | ៤,៣ | ២,៤ | ៥,៤ |
| បង្គន់រណ្តៅគ្មានចានបង្គន់ | ១,៧ | ០,៦ | ២,៣ |
| បង្គន់បត់ជើងទម្លាក់ ឬក្នុងទឹក (ត្រពាំង/បឹង/ទន្លេ/សមុទ្រ) | ០,៨ | ០៥ | ១,០ |
| បង្គន់ផ្សេងទៀត | ០,៨ | ០,៣ | ១,១ |

៣៨. ភាគរយគ្រួសារប្រើអ៊ីនធឺណិត

| ការប្រើអ៊ីនធឺណិត | សរុប | ទីប្រជុំជន | ជនបទ |
|---|---|---|---|
| មិនបានប្រើ | ៥០,០ | ៣៧,៣ | ៥៧,៥ |
| ប្រើអ៊ីនធឺណិត (ប្រើនៅផ្ទះ ឬទីសាធារណៈ) | ៥០,០ | ៦២,៧ | ៤២,៥ |
| ប្រើនៅផ្ទះ | ៤៥,៤ | ៥៦,៤ | ៣៨,៨ |
| ប្រើនៅទីសាធារណៈ | ២៨,២ | ៣៩,៩ | ២១,២ |
| ប្រើនៅផ្ទះ និងទីសាធារណៈ | ២៣,៦ | ៣៣,៧ | ១៧,៦ |

៣៩. អត្រាលទ្ធភាពបង្កើតកូន

| | |
|---|---|
| សរុប | ២,៥ |
| ទីប្រជុំជន | ២,២ |
| ជនបទ | ២,៨ |

៤០. អត្រាមរណភាពទារក ក្នុង ១.០០០ កំណើតរស់

| | |
|---|---|
| សរុប | ១៨ |
| ទីប្រជុំជន | ១៦ |
| ជនបទ | ១៩ |

៤១. អត្រាមរណភាពកុមារអាយុក្រោម ៥ ឆ្នាំ ក្នុង ១.០០០ នាក់

| | |
|---|---|
| សរុប | ២៨ |
| ទីប្រជុំជន | ២៦ |
| ជនបទ | ៣០ |

៤២. អត្រាមរណភាពមាតា ក្នុង ១០០.០០០ កំណើតរស់ ១៤១

៤៣. អាយុសង្ឃឹមរស់

| តំបន់ | សរុប | ប្រុស | ស្រី |
|---|---|---|---|
| សរុប | ៧៥,៥ | ៧៤,៣ | ៧៦,៨ |
| ទីប្រជុំជន | ៧៥,៦ | ៧៣,៥ | ៧៧,៧ |
| ជនបទ | ៧៤,៥ | ៧២,៨ | ៧៦,៤ |

# ផ្នែក ១

# របាយការណ៍ជាតិ

ជំពូក ១. សេចក្តីផ្តើម

ជំពូក ២. ទំហំ កំណើន និងការបែងចែកប្រជាជន

ជំពូក ៣. សមាសភាពភេទ ការបែងចែកអាយុ និងស្ថានភាពអាពាហ៍ពិពាហ៍

ជំពូក ៤. អក្ខរកម្ម និងការអប់រំ

ជំពូក ៥. កម្លាំងពលកម្ម និងការងារ

ជំពូក ៦. ទេសន្តរប្រវេសន៍

ជំពូក ៧. លទ្ធភាពបង្កើតកូន

ជំពូក ៨. មរណភាព

ជំពូក ៩. ពិការភាព

ជំពូក ១០. លំនៅដ្ឋាន ចរិតលក្ខណៈគ្រួសារ និងសម្ភារៈប្រើប្រាស់ក្នុងគ្រួសារ

ជំពូក ១១. សេចក្តីសង្ខេប និងសន្និដ្ឋាន

# ជំពូក ១
# សេចក្តីផ្តើម

## ១.១. សាវតា

ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ គឺជាជំរឿនលើកទី៤ ដែលបានធ្វើជាបន្តបន្ទាប់នៅព្រះរាជាណាចក្រកម្ពុជា ហើយជំរឿនឆ្នាំ២០១៩ ស្ថិតនៅក្នុងជំរឿនវិលជុំទីដប់នៃជំរឿនពិភពលោកឆ្នាំ២០២០ ដែលផ្តល់អនុសាសន៍ដោយអង្គការសហប្រជាជាតិ។ ការធ្វើជំរឿនលើកដំបូងនៅកម្ពុជាបានធ្វើនៅឆ្នាំ១៩៦២ ជាមួយការអនុវត្តជាបន្តបន្ទាប់ ដែលត្រូវបានធ្វើឡើងនៅឆ្នាំ១៩៩៨ និងឆ្នាំ២០០៨។ ប្រទេសកម្ពុជានៅតែសម្រេចចិត្តប្រើកម្រងសំណួរជាក្រដាស និងខ្មៅដៃក្នុងការប្រមូលទិន្នន័យ។ កិច្ចការនេះតម្រូវឲ្យមានការរៀបចំយ៉ាងហ្មត់ចត់ លើការរៀបចំកម្រងសំណួរ សេចក្តីណែនាំផ្សេងៗ ការបណ្តុះបណ្តាលស្រង់ទិន្នន័យសាកល្បង ការធ្វើជំរឿននាំមុខជាដើម។ល។

ដំណើរការនៃការរៀបចំការងារជំរឿនជាផ្លូវការចាប់ផ្តើមនៅឆ្នាំ២០១៦ តាមរយៈការរៀបចំព្រាងឯកសារស្តីពីផែនការធ្វើជំរឿនដែលត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជា និងគណៈកម្មាធិការជាតិជំរឿននៅឆ្នាំ២០១៧។ យុទ្ធសាស្ត្រនៃការធ្វើជំរឿនត្រូវបានបង្កើតឡើងនៅឆ្នាំ២០១៧ ដែលសម្រេចអនុញ្ញាតអនុវត្តការប្រមូលទិន្នន័យចាប់ផ្តើមនៅថ្ងៃទី ០៣ ខែមីនា ឆ្នាំ២០១៩។ វិទ្យាស្ថានជាតិស្ថិតិបានគូសផែនទីជំរឿន ដោយប្រើផែនទីព្រាងដោយដៃនៅទូទាំងប្រទេសហើយបានកំណត់ជាមណ្ឌលជំរឿន ។

លទ្ធផលសម្រេចបានពីការធ្វើជំរឿនទាំងបីលើក បានផ្តល់ទិន្នន័យប្រជាសាស្ត្រដមានតម្លៃសម្រាប់ជំរឿនបានធ្វើឲ្យរាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាបន្តពង្រឹងសមត្ថភាពតាមរយៈការធ្វើជំរឿន ដែលហៅថា "ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩" ដោយបានដាក់បញ្ចូលទិន្នន័យទាក់ទងប្រជាជន និងលក្ខណៈផ្ទះសំបែងមួយចំនួន សម្រាប់ការវាយតម្លៃនិងរៀបចំផែនការ។

## ១.២. រចនាសម្ព័ន្ធចាត់តាំងជំរឿន

ដូចគ្នាទៅនឹងជំរឿនលើកមុនៗដែរ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ បានបង្កើតគណៈកម្មាធិការជំរឿនចំនួន ៣ (បី) គឺ៖ គណៈកម្មាធិការជាតិជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ ដឹកនាំដោយ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** គណៈកម្មាធិការនេះ គឺជាស្ថាប័នកំពូលដែលមានសមាសភាពកម្រិតមន្ត្រីនយោបាយមកពីក្រសួងពាក់ព័ន្ធនានា មានភារៈទទួលខុសត្រូវក្នុងការសម្រេចចិត្តគ្រប់គោលនយោបាយទាំងអស់ ដែលទាក់ទងទៅនឹងការងារជំរឿន។ គណៈកម្មការបច្ចេកទេសជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ ដឹកនាំដោយ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ** សម្រាប់ដោះស្រាយគ្រប់ភារៈកិច្ចទាំងឡាយណាដែលទាក់ទងនឹងការងារបច្ចេកទេស ដូចជាការរៀបចំកម្រងសំណួរ ឯកសារណែនាំអំពីតួនាទី ភារកិច្ចមន្ត្រីសម្ភាសន៍ និង

មន្ត្រីត្រួតពិនិត្យ វិធីសាស្ត្របង្រៀន សេចក្តីណែនាំសម្ភាសន៍ ដឹកនាំចុះធ្វើជំរឿននាំមុខ ការបណ្តុះបណ្តាល ដឹកនាំយុទ្ធនាការប្រតិបត្តិការប្រមូលទិន្នន័យ ការកែដៃ និងដាក់លេខកូដ ការបញ្ចូលទិន្នន័យក្នុងប្រព័ន្ធកុំព្យូទ័រ និងការវិភាគរបាយការណ៍។ គណៈកម្មាធិការមួយទៀត គឺគណៈកម្មការឃោសនាជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ ដឹកនាំដោយ **ឯកឧត្តមអភិសន្តិសេដ្ឋាបណ្ឌិត ឆាយ ថន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងផែនការ** គណៈកម្មការនេះមានតួនាទីពិនិត្យ និងផ្តល់យោបល់លើការផលិតសម្ភារៈឃោសនា រួមមាន Spot ទូរទស្សន៍ និងសម្ភារៈឃោសនាផ្សេងៗទៀត មានដូចជា បដា សន្លឹកព័ត៌មានជំរឿន អាវយឺត កាបូបជាដើម។

ក្រសួងផែនការទទួលខុសត្រូវរួមលើប្រតិបត្តិការជំរឿន ដែលមានវិទ្យាស្ថានជាតិស្ថិតិ ជាសេនាធិការអនុវត្ត ដូចដែលបានបញ្ជាក់ខាងដើម។

ដោយឡែកមន្ទីរផែនការរាជធានី ខេត្ត ដើរតួនាទីជាការិយាល័យជំរឿនខេត្តក្នុងអំឡុងពេលធ្វើជំរឿន ដែលប្រធានមន្ទីរផែនការរាជធានី ខេត្ត បំពេញតួនាទីជាមន្ត្រីជំរឿនខេត្ត។ មន្ត្រីជំរឿនខេត្តមានជំនួយការម្នាក់ ជាមន្ត្រីជំនួយការជំរឿនខេត្ត។ មន្ត្រីជំរឿនខេត្ត ជាមន្ត្រីជំរឿនដែលមានតួនាទីខ្ពស់ជាងគេ ទទួលបន្ទុកប្រតិបត្តិការជំរឿនក្នុងខេត្ត។ មន្ត្រីជំរឿនថ្នាក់ក្រុង ខណ្ឌ ស្រុក ឃុំ សង្កាត់ និងភូមិ ស្ថិតក្រោមការត្រួតពិនិត្យរួមរបស់មន្ត្រីជំរឿនខេត្ត។ អភិបាលរាជធានី ខេត្ត គឺជាប្រធានគណៈកម្មាធិការជំរឿនថ្នាក់រាជធានី ខេត្ត ដែលមានភារកិច្ចដឹកនាំមន្ត្រីជំរឿនខេត្ត។ មន្ត្រីជំរឿនតំបន់ពីវិទ្យាស្ថានជាតិស្ថិតិ ផ្តល់ជំនួយបច្ចេកទេសដល់មន្ត្រីជំរឿនខេត្ត។


គណៈកម្មាធិការជាតិ
ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩
ក្រសួងផែនការ
គណៈកម្មការបច្ចេកទេសជំរឿន
គណៈកម្មាធិការជំរឿនខេត្ត
អគ្គនាយកជំរឿន
ការិយាល័យជំរឿន ភ្នំពេញ
ការិយាល័យជំរឿនមូលដ្ឋាន
មន្ត្រីជំរឿនតំបន់
មន្ទីរផែនការខេត្ត
មន្ត្រីជំរឿនខេត្ត
ជំនួយការមន្ត្រីជំរឿនតំបន់
អភិបាលស្រុក
មន្ត្រីជំរឿនស្រុក
ប្រធានក្រុមប្រឹក្សាឃុំ
មន្ត្រីជំរឿនឃុំ
១- ផ្នែករដ្ឋបាល
២- ផ្នែកផែនការ និងត្រួតពិនិត្យ
៣- ផ្នែកផែនទី
៤- ផ្នែកវិភាគ និងស្រាវជ្រាវ
៥- ផ្នែកកែច្នៃទិន្នន័យ
មន្ត្រីត្រួតពិនិត្យ
(១នាក់ សម្រាប់មន្ត្រីជំរឿន៤នាក់)
មន្ត្រីជំរឿន

## ១.៣. ការឃោសនាជំរឿន

ការឃោសនាជំរឿន គឺដើម្បីឲ្យសាធារណជនបានទទួល និងយល់ដឹងអំពីព័ត៌មាន និងដំណើរការជំរឿន។ នេះជាការងារចាំបាច់ ដើម្បីធានាឲ្យមានកិច្ចសហប្រតិបត្តិការរវាងប្រជាជនទូទៅ និង មន្ត្រីជំរឿន។ បទពិសោធន៍ល្អដែលទទួលបានពីជំរឿនលើកមុន ការផ្សព្វផ្សាយទូលំទូលាយជាសាធារណៈដល់កម្រិតភូមិ គឺចាំជាការបាច់សម្រាប់ការទទួលបានចម្លើយពិតប្រាកដ សម្រាប់សំណួរសើបមួយចំនួន ដូចជាពិការភាព លទ្ធភាព បង្កើតកូន និងមរណភាពជាដើម។ ភាពចាំបាច់ផងដែរ យុទ្ធនាការផ្សព្វផ្សាយសាធារណៈនេះ ត្រូវផ្តោតខ្លាំងលើការរក្សាភាពសម្ងាត់នៃព័ត៌មានដែលប្រមូលពីបុគ្គល ដើម្បីលើកទឹកចិត្តឲ្យប្រជាជនផ្តល់ចម្លើយដោយមិនភ័យខ្លាចចំពោះការឆ្លើយតបសំណួរផ្ទាល់ខ្លួនក្នុងជំរឿន។ បទពិសោធន៍កន្លងមកក៏បានបង្ហាញផងដែរថា មេភូមិដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួលប្រជាជនក្នុងភូមិឲ្យបានយល់ដឹងអំពីជំរឿន។

ជោគជ័យនៃជំរឿនពឹងផ្អែកយ៉ាងធំធេងលើការយកចិត្តទុកដាក់ ការតម្រង់ផ្លូវ និងការគាំទ្រ ហើយនិងកិច្ចសហការពីសំណាក់អាជ្ញាធរមូលដ្ឋានគ្រប់កម្រិត ព្រមទាំងកិច្ចសហការពីប្រជាជនទូទាំងប្រទេសផងដែរ។ គណៈកម្មការឃោសនាជំរឿនត្រូវបានបង្កើត ដើម្បីដឹកនាំការឃោសនាផ្តល់ព័ត៌មានដល់សាធារណជនអំពីវិសាលភាព និងគោលបំណងជំរឿនតាមរយៈប្រព័ន្ធផ្សព្វផ្សាយនានា ដើម្បីយទទួលបានកិច្ចសហការ។ ការផ្សព្វផ្សាយតាមសារព័ត៌មាន មានភាពមមាញឹកខ្លាំងក្នុងដំណាក់កាលរាប់សម្ភាសន៍។ ដូចគ្នាទៅនឹងជំរឿនកន្លងមកដែរ ការផ្សព្វផ្សាយជំរឿនបានធ្វើតាមប្រព័ន្ធផ្សាយផ្សាយ និងមធ្យោបាយខុសៗគ្នា ដូចជា វិទ្យុ ទូរទស្សន៍ សារជាសំឡេងតាមប្រព័ន្ធទូរស័ព្ទ សន្និសីទសារព័ត៌មាន ផ្ទាំងរូបបដា និងប័ណ្ណព័ត៌មាន សញ្ញាលើអាវយឺត កាតាបជំរឿន។

បណ្តាញជារូបវន្តសំខាន់ៗ ដូចជាក្រសួង ស្ថាប័នពាក់ព័ន្ធ និងក្រុមសាសនា (ជាសំខាន់វត្ត) ក៏ត្រូវបានប្រើប្រាស់ដែរ។ មេភូមិត្រូវបានលើកទឹកចិត្តឲ្យជូនដំណឹងដល់ប្រជាជននៅតាមភូមិរៀងៗខ្លួនអំពីជំរឿន និងស្វែងរកកិច្ចសហប្រតិបត្តិការ។

យុទ្ធនាការឃោសនាព័ត៌មានស៊ីជម្រៅ និងទូលំទូលាយសម្រាប់ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ មានគោលបំណង ៖

- ដើម្បីទទួលបានការគាំទ្រ និងជំនួយពីស្ថាប័នរដ្ឋាភិបាល ភ្នាក់ងារប្រព័ន្ធផ្សព្វផ្សាយ និងអង្គការសង្គមស៊ីវិលតាមរយៈការបង្កើនការយល់ដឹងគ្រប់គ្រាន់អំពីសារៈសំខាន់ និងគោលបំណងនៃការធ្វើជំរឿន។
- ដើម្បីឲ្យសាធារណជនយល់ដឹងអំពីអត្ថប្រយោជន៍នៃការធ្វើជំរឿន ក៏ដូចជាការសម្ងាត់នៃព័ត៌មាន ដើម្បីឲ្យពួកគេយល់ដឹងអំពីសិទ្ធិ និងការទទួលខុសត្រូវរបស់ពួកគេទាក់ទងនឹងជំរឿន ហើយចូលរួមសហការដោយផ្តល់ព័ត៌មានពេញលេញ និងត្រឹមត្រូវ។

ការឃោសនាជំរឿន និងសម្ភារៈផ្សព្វផ្សាយសាធារណៈសម្រាប់ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ មានលក្ខណៈចម្រុះ រួមមានទាំងសម្ភារៈបោះពុម្ព សំឡេង និងរូបភាពផ្សេងៗទៀត។ យុទ្ធនាការផ្សព្វផ្សាយ

ជាសាធារណៈ និងស៊ីជម្រៅបានចាប់ផ្តើមនៅខែធ្នូ ឆ្នាំ២០១៨ ហើយកាន់តែខ្លាំងក្លាក្នុងអំឡុងថ្ងៃជំរឿន ដោយមានព័ត៌មានជំរឿនប្រចាំថ្ងៃ របាយការណ៍ព័ត៌មាន ចម្រៀងជំរឿន បានផ្សាយជារៀងរាល់ថ្ងៃ តាម វិទ្យុ ទូរទស្សន៍ កាសែតទាំងកម្រិតជាតិ និងមូលដ្ឋាន ឬក៏ចាក់ផ្សាយ តាមភូមិ ឬប្រពន្ធ័ ឧបករណ៍បំពងសំឡេង។

## ១.៤. ការរៀបចំកម្រងសំណួរជំរឿន

លទ្ធផលនៃជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាចុងក្រោយ ត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយក្នុងចំណោមដៃគូអភិវឌ្ឍន៍ និងអ្នកប្រើប្រាស់ទិន្នន័យ។ គោលនយោបាយ និងកម្មវិធីអភិវឌ្ឍន៍ជាច្រើនបានប្រើប្រាស់លទ្ធផលជំរឿនយ៉ាងទូលំទូលាយ។ សំណួរភាគច្រើនត្រូវបានរក្សាទុកសម្រាប់ជំរឿន ឆ្នាំ២០១៩ ដូច្នេះលទ្ធផលនៃជំរឿនទាំងពីរអាចប្រៀបធៀបគ្នាបានសម្រាប់វាស់វែងពីវឌ្ឍនភាពនៃសូចនាករសំខាន់ៗមួយចំនួន។

កម្រងសំណួរជំរឿនត្រូវបានរៀបចំឡើង ដើម្បីប្រមូលនូវសូចនាករសេដ្ឋកិច្ច-សង្គម និងព័ត៌មានចាំបាច់ផ្សេងៗទៀតជាច្រើន សម្រាប់ការតាមដាន និងវាយតម្លៃ ដើម្បីឆ្លើយតបផលប្រយោជន៍របស់ប្រជាជន។ ជំរឿនធានានូវភាពមិនលំអៀងលើយេនឌ័រ មិនប្រកាន់ភេទក្នុងការរាប់សម្ភាសន៍ និងឆ្លើយសំណួរជំរឿន។ បទពិសោធន៍កន្លងមកបានបញ្ជាក់ថា ប្រទេសកម្ពុជាមិនមានភាពលំអៀងក្នុងការប្រមូលទិន្នន័យនោះទេ។ ស្ត្រីត្រូវបានជ្រើសរើសជាមន្ត្រីសម្ភាសន៍ និងមន្ត្រីត្រួតពិនិត្យជំរឿនផងដែរ ហើយស្ត្រីមានសមត្ថភាពសួរសំណួរអំពីលទ្ធភាពបង្កើតកូន មរណភាពមាតាយ៉ាងប៉ិនប្រសប់។ កម្រងសំណួរជំរឿនឆ្នាំ២០១៩ត្រូវបានរៀបចំឡើងក្នុងគោលបំណងទទួលបានស្ថិតិយេនឌ័រប្រសើរជាងមុន។

ដើម្បីផ្តល់ជាគំនិតសម្រាប់ខ្លឹមសារនៃកម្រងសំណួរជំរឿន សំណួរដែលបានប្រើក្នុងជំរឿនឆ្នាំ២០០៨ ត្រូវបានយកមកប្រើបន្តទៀតសម្រាប់ជំរឿនឆ្នាំ២០១៩។ មានកម្រងសំណួរចំនួន ២ គឺបញ្ជីផ្ទះ (ទម្រង់ក) និងកម្រងសំណួរគ្រួសារ (ទម្រង់ខ)។ មេគ្រួសារ ឬសមាជិកណាម្នាក់ដែលទទួលខុសត្រូវក្នុងគ្រួសារ ត្រូវឆ្លើយសំណួរជំរឿនៈ

**ទម្រង់ ក ៖** ស្រង់លក្ខណៈពិសេសនៃការកំណត់អត្តសញ្ញាណគ្រួសារ ដូចជា អាគារ/សំណង់ វត្ថុធាតុសំណង់ភាគច្រើនសម្រាប់ជញ្ជាំង ដំបូល និងកម្រាល គោលដៅនៃអាគារ/រចនាសម្ព័ន្ធ គ្រួសារលេខ លក្ខណៈនៃមេគ្រួសារ ជាពិសេស ចំនួនមនុស្សដែលរស់នៅក្នុងគ្រួសារ។

**ទម្រង់ ខ ៖** ស្រង់ឈ្មោះពេញ ទំនាក់ទំនងជាមួយមេគ្រួសារ ភេទ អាយុ ស្ថានភាពអាពាហ៍ពិពាហ៍ ភាសាកំណើត សាសនា ទីកន្លែងកើត ទីកន្លែងពីមុន រយៈពេលស្នាក់នៅ មូលហេតុនៃការផ្លាស់លំនៅដ្ឋាន អក្ខរភាព និងការសិក្សាពេញម៉ោង ពិការភាព សកម្មភាពចម្បង មុខរបរ ស្ថានភាពការងារ កសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម ឬសេវាកម្មវិស័យការងារ សកម្មភាពសេដ្ឋកិច្ច ព័ត៌មានលម្អិតនៃការបង្កើតកូនរបស់ស្ត្រីដែលមានអាយុចាប់ពី ១៥ ឆ្នាំឡើង ជាពិសេស អ្នកស្លាប់ក្នុងគ្រួសារក្នុងរយៈពេល ១២ ខែកន្លងមក។

ក្រៅពីព័ត៌មានគ្រួសារ សំណួរទាក់ទងនឹងស្ថានភាពលំនៅដ្ឋាន និងសម្ភារៈប្រើប្រាស់ក្នុងផ្ទះសំបែង ក៏ត្រូវបានប្រមូលផងដែរពីគ្រួសារធម្មតា ៖ សិទ្ធិកាន់កាប់លំនៅដ្ឋាន ប្រភពបំភ្លឺចម្បង ឥន្ធនៈចម្អិនអាហារចម្បង ការប្រើប្រាស់បង្គន់ ប្រភពទឹកផឹកចម្បង ទីតាំងប្រភពទឹកផឹក ចំនួនបន្ទប់ដែលកាន់កាប់ដោយគ្រួសារ កម្មសិទ្ធិភាពលើវិទ្យុ/ទូរទស្សន៍

ទូរស័ព្ទ (ខ្សែ) ទូរស័ព្ទដៃ កុំព្យូទ័រផ្ទាល់ខ្លួន កង់ ទោចក្រយានយន្ត រថយន្ត/រថយន្តដឹកទំនិញ ត្រាក់ទ័រ និងការប្រើប្រាស់អ៊ីនធឺណិតក៏ត្រូវបានប្រមូលផងដែរ។

## ១.៥. ការរៀបចំកម្រងសំណួរ និងឯកសារជំរឿន

ការិយាល័យស្ថិតិរបស់អង្គការសហប្រជាជាតិ បានផ្តល់អនុសាសន៍ក្នុងការជ្រើសរើសប្រធានបទស្នូល និងប្រធានបទបន្ថែមសម្រាប់បញ្ចូលក្នុងកម្រងសំណួរជំរឿន តាមរយៈការបង្កើតសេចក្តីណែនាំស្តីពី "គោលការណ៍ និងអនុសាសន៍ជំរឿនប្រជាជន និងលំនៅដ្ឋានជំនាន់ ៣" ។ អនុលោមទៅតាមអនុសាសន៍របស់អង្គការសហប្រជាជាតិ សេចក្តីត្រូវការរបស់ប្រទេស និងបទពិសោធន៍ពីអតីតកាលដោយមានជំនួយបច្ចេកទេសពីទីប្រឹក្សាជំរឿន វិទ្យាស្ថានជាតិស្ថិតិបានចងក្រងកម្រងសំណួរ ឯកសារណែនាំនានាសម្រាប់មន្ត្រីជំរឿន មន្ត្រីត្រួតពិនិត្យ ឯកសារបណ្តុះបណ្តាល និងទម្រង់សម្រាប់ត្រួតពិនិត្យគុណភាពគ្រប់ដំណាក់កាលជំរឿន។

ឧបករណ៍ទាំងអស់នេះបានបង្ហាញជូនភាគីពាក់ព័ន្ធ ដើម្បីពិនិត្យលើសំណួរនានា និងផ្តល់ធាតុចូលដែលអាចឲ្យជំរឿនប្រមូលបាននូវទិន្នន័យដែលរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ទាំងអស់ប្រើប្រាស់ ដោយប្រកាន់ខ្ជាប់នូវបទដ្ឋានអន្តរជាតិ។ កម្រងសំណួរព្រាងត្រូវបានធ្វើតេស្ត និងអង្កេតនាំមុខជំរឿន មុនពេលដែលកម្រងសំណួរជំរឿនត្រូវបានអនុម័តដោយគណៈកម្មការបច្ចេកទេស និងគណៈកម្មាធិការជាតិជំរឿន។ កម្រងសំណួរដូចគ្នាសម្រាប់សួរគ្រប់គ្រួសារ ដូចជាគ្រួសារធម្មតា គ្រួសារស្ថាប័ន គ្រួសារគ្មានផ្ទះសំបែង គ្រួសាររស់នៅលើទូកចល័ត និងគ្រួសារឆ្លងកាត់ ជាដើម។

## ១.៦. ការជ្រើសរើសមន្ត្រីជំរឿន

ផ្អែកតាមលទ្ធផលនៃការព្យាករណ៍ទិន្នន័យប្រជាជន និងការគូសផែនទីជំរឿន ការរាប់សម្ភាសន៍ជំរឿនបានប្រើមន្ត្រីសម្ភាសន៍ប្រមាណ ៣៨.៤៤៧នាក់ សម្រាប់សម្ភាសន៍គ្រប់គ្រួសារទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ មន្ត្រីត្រួតពិនិត្យចំនួន ៩.២០០នាក់ ត្រូវបានតែងតាំងសម្រាប់ត្រួតពិនិត្យកិច្ចការរបស់មន្ត្រីសម្ភាសន៍ទាំងអស់។ មន្ត្រីសម្ភាសន៍ និងមន្ត្រីត្រួតពិនិត្យបានជ្រើសចេញពីក្នុងចំណោមគ្រូបង្រៀន និងមន្ត្រីពីស្ថាប័ននានា។ ជាមួយគ្នានោះ សិស្ស និស្សិតក៏ត្រូវបានជ្រើសរើសធ្វើជាមន្ត្រីជំរឿនផងដែរ ដោយបានឆ្លងកាត់ការធ្វើតេស្តជាមូលដ្ឋាន។ ប្រតិបត្តិការមូលដ្ឋានត្រូវបានអនុវត្ត ក្រោមប្រព័ន្ធត្រួតពិនិត្យរដ្ឋបាលយ៉ាងតឹងរ៉ឹង ។

ជំរឿនឆ្នាំ២០១៩ មានមន្ត្រីរាជធានីខេត្តចំនួន ៧៥នាក់ ដឹកនាំប្រតិបត្តិការជំរឿន ដោយមានគ្រូបង្គោលមូលដ្ឋាន ៦០០នាក់ មន្ត្រីជំរឿនស្រុក ក្រុង ខណ្ឌ ៤០០ នាក់ មន្ត្រីជំរឿនឃុំ សង្កាត់ ១.៧០០នាក់ សម្រាប់ជួយការងារមន្ត្រីត្រួតពិនិត្យ និងមន្ត្រីសម្ភាសន៍មណ្ឌលជំរឿននានា។ ក្រៅពីនោះ ជំរឿនបានប្រើមន្ត្រីជំរឿនពិសេសចំនួន ៣.៥០០នាក់ សម្រាប់សម្ភាសន៍មណ្ឌលជំរឿនពិសេស ដូចជាបន្ទាយយោធា បន្ទាយនគរបាល សាលាយោធា សាលានគរបាល ពន្ធនាគារ មន្ទីរពេទ្យយោធា មន្ទីរពេទ្យនគរបាល មជ្ឈមណ្ឌលអប់រំកែប្រែ មណ្ឌលថែទាំកុមារកំព្រា វត្តអារាម និងទីតាំងផ្សេងៗទៀតដែលពិបាកគ្រប់ដណ្តប់។ មន្ត្រីដែលមានបទពិសោធន៍ពីក្រសួងផែនការ នៃវិទ្យាស្ថានជាតិស្ថិតិ បានចូលរួមក្នុងវគ្គបណ្តុះ

បណ្តាលមន្ត្រីមូលដ្ឋាន ហើយចុះអភិបាលកិច្ចការងារមូលដ្ឋាន។ មន្ត្រីខេត្ត ស្រុក ឃុំ និងភូមិ បានជួយសម្រួលក្នុងការរៀបចំវគ្គបណ្តុះបណ្តាល ហើយនិងត្រួតពិនិត្យការរាប់ជំរឿនយ៉ាងតឹងរឹង។

ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋលេខាធិការ និងមន្ត្រីជាន់ខ្ពស់ ផ្សេងទៀតនៃក្រសួងផែនការ ក៏ដូចជាតំណាងនៃដៃគូអភិវឌ្ឍន៍នានា ទីប្រឹក្សាបច្ចេកទេស បានចុះធ្វើទស្សនកិច្ចនៅមូលដ្ឋានដើម្បីត្រួតពិនិត្យដំណើរការជំរឿន និងលើកទឹកចិត្តមន្ត្រីជំរឿនក្នុងពេលបំពេញកិច្ចការដ៏លំបាកនេះ។

## ១.៧. ការបណ្តុះបណ្តាលមន្ត្រីជំរឿន

វគ្គបណ្តុះបណ្តាលធ្វើឡើង ដើម្បីផ្តល់ចំណេះដឹងដល់មន្ត្រីជំរឿនឲ្យអាចដឹកនាំ និងបណ្តុះបណ្តាលបន្តទៅមន្ត្រីប្រតិបត្តិការ និងមន្ត្រីមូលដ្ឋានគ្រប់កម្រិត ចាប់តាំងពីមន្ត្រីត្រួតពិនិត្យដល់មន្ត្រីសម្ភាសន៍។ មន្ត្រីសម្ភាសន៍ត្រូវបំពេញលក្ខខ័ណ្ឌជ្រើសរើស ដូចជាត្រូវមានស្មារតីទទួលខុសត្រូវខ្ពស់ មានសមត្ថភាពក្នុងការសរសេរលេខ និងអក្សរបានច្បាស់លាស់ យ៉ាងហោចណាស់ត្រូវបញ្ចប់ការសិក្សាត្រឹមថ្នាក់ទី១២។ សកម្មភាពសំខាន់មុននឹងចាប់ផ្តើមដំណើរការជំរឿន គឺវគ្គបណ្តុះបណ្តាលមន្ត្រីមូលដ្ឋាន។ ជំនួយបច្ចេកទេសដែលបានផ្តល់ឲ្យក្នុងជំរឿនឆ្នាំ១៩៩៨ និងឆ្នាំ ២០០៨ បានចូលរួមចំណែកយ៉ាងធំធេងក្នុងការអភិវឌ្ឍសមត្ថភាពបុគ្គលិកជាតិ ដែលបានចូលរួមក្នុងសកម្មភាពជំរឿនឆ្នាំ២០១៩។ សមត្ថភាពនេះត្រូវបានបំពេញបន្ថែមដោយកម្មវិធីបណ្តុះបណ្តាល។ ក្រុមការងារបច្ចេកទេសជំរឿនបានធ្វើការបណ្តុះបណ្តាលមន្ត្រីជំរឿនតំបន់ មន្ត្រីជំនួយការតំបន់ និងប្រធានមន្ទីរ អនុប្រធានមន្ទីរ លើកទី ១ ចំនួន ១៧៥នាក់ រយៈពេល ៥ ថ្ងៃ បានចាប់ពីថ្ងៃទី ១៧ ដល់ថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ២០១៨ និងបានធ្វើការបណ្តុះបណ្តាលមន្ត្រីជំរឿនតំបន់ មន្ត្រីជំនួយការតំបន់ និងប្រធានមន្ទីរ អនុប្រធានមន្ទីរឡើងវិញចំនួន ១៧៥នាក់ រយៈពេល ៥ ថ្ងៃ នៅខែតុលា ឆ្នាំ ២០១៨។

ក្រុមការងារបច្ចេកទេសជំរឿនបានធ្វើការបណ្តុះបណ្តាលគ្រូបង្វឹកលើកទីមួយនៅទូទាំងប្រទេស ចំនួន ៦០០ នាក់ ដែលគ្រូបង្វឹកម្នាក់ៗ ត្រូវទទួលការបណ្តុះបណ្តាលបន្តទៅដល់មន្ត្រីត្រួតពិនិត្យ និងមន្ត្រីសម្ភាសន៍ចំនួនពីរថ្នាក់នៅខែកុម្ភៈ ពីថ្ងៃទី ១១ ដល់ ១៤ និងពីថ្ងៃទី ១៨ ដល់ថ្ងៃ ២២ ឆ្នាំ២០១៩។ ជាសង្ខេបឡើងវិញ ការបណ្តុះបណ្តាលបែងចែកជាបួនកម្រិត គឺការបណ្តុះបណ្តាលកម្រិតទី ១ និងកម្រិត ២ សម្រាប់មន្ត្រីវិទ្យាស្ថានជាតិស្ថិតិ ប្រធានមន្ទីរផែនការខេត្ត អនុប្រធានមន្ទីរផែនការខេត្ត ដែលជាមន្ត្រីជំរឿនខេត្ត។ ការបណ្តុះបណ្តាលកម្រិតទី ៣ សម្រាប់គ្រូបង្វឹកបានធ្វើឡើងនៅការិយាល័យជំរឿនតាមខេត្ត ដោយគ្រូបង្គោលចំនួន ៦០០នាក់ ត្រូវបានបណ្តុះបណ្តាល ជាមធ្យមចំនួន ២៥ នាក់ ក្នុងមួយថ្នាក់ (ចំនួននេះ ប្រែប្រួលទៅតាមទំហំនៃខេត្ត)។ ការបណ្តុះបណ្តាលកម្រិតទី ៤ សម្រាប់មន្ត្រីសម្ភាសន៍ និងមន្ត្រីត្រួតពិនិត្យបានប្រព្រឹត្តទៅនៅខែកុម្ភៈ ពីថ្ងៃទី ១១ ដល់ ១៤ និងពីថ្ងៃទី ១៨ ដល់ថ្ងៃ ២២ ខែកុម្ភៈ ឆ្នាំ២០១៩ តាមទីកន្លែងបណ្តុះបណ្តាលជាច្រើនក្នុងស្រុកនានាទូទាំងប្រទេស។

## ១.៨. ដំណាក់កាលរាប់សម្ភាសន៍

ជំរឿនឆ្នាំ២០១៩ បានរាប់សម្ភាសគ្រួសារធម្មតាចំនួន ៣,៦ លានគ្រួសារទូទាំង ២៥ រាជធានី ខេត្ត ដោយបើកយុទ្ធនាការប្រតិបត្តិការចុះបញ្ជីផ្ទះ ពីថ្ងៃទី២៨ រហូតដល់ថ្ងៃទី ២ ខែមីនា ឆ្នាំ២០១៩ និងរាប់សម្ភាសគ្រួសារ (តារាង ខ) ម៉ោង ០០ ឈានចូលថ្ងៃទី ៣ រហូតដល់ថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០១៩ ដោយមានមន្ត្រីសម្ភាសន៍បួនម៉ឺននាក់ និងមន្ត្រីត្រួតពិនិត្យមួយម៉ឺននាក់ បានចុះស្រង់ទិន្នន័យនៅគ្រប់មណ្ឌលជំរឿន ក្នុងភូមិទាំងអស់ ១៤.៥៤៥ ភូមិ និង ៣៨.៤៤៧ មណ្ឌលជំរឿន ហើយនិងមណ្ឌលជំរឿនពិសេស ដូចជាបន្ទាយយោធា បន្ទាយនគរបាល សាលាយោធា សាលានគរបាល ពន្ធនាគារ មន្ទីរពេទ្យយោធា មន្ទីរពេទ្យនគរបាល មជ្ឈមណ្ឌលអប់រំកែប្រែ មណ្ឌលថែទាំកុមារកំព្រា ដោយប្រើមន្ត្រីពិសេសចំនួន ៣.៥០០ នាក់ ។

គ្រួសារនៅទូទាំងប្រទេសត្រូវបានរាប់សម្ភាសក្នុងរយៈពេល ១១ ថ្ងៃ។ ខេត្តចំនួន ២៣ ការរាប់សម្ភាសគ្រួសារ (តារាង ខ) ប្រព្រឹត្តទៅដោយរលូន និងបញ្ចប់ទៅប្រកបដោយជោគជ័យតាមផែនការគ្រោងទុក គឺថ្ងៃទី ១៣ ខែមីនា ឆ្នាំ ២០១៩។ ដោយឡែក ខេត្តព្រះសីហនុត្រូវបានពន្យារយៈពេលរាប់សម្ភាសចំនួនបីថ្ងៃ ដោយប្រើកម្លាំងពិសេសរបស់វិទ្យាស្ថានជាតិស្ថិតិដែលបានបញ្ចប់ពីរាជធានី ខេត្តផ្សេង ដោយសារចំនួនគ្រួសារកើនច្រើនលើសលប់ ជាពិសេសជនជាតិចិន និងគ្រួសារថ្មី។ ដោយឡែក រាជធានីភ្នំពេញក៏ត្រូវបានពន្យាពេលរហូតដល់ថ្ងៃទី ២០ ខែមីនា ឆ្នាំ២០១៩ ដោយសារចំនួនគ្រួសារកើនច្រើនលើសលប់មិនអាចគ្រប់គ្រងបាន ដូចជាសំណង់អាគារ បូរី និងផ្ទះល្វែងរីកលូតលាស់មិនអាចគ្រប់គ្រងបាន។ បន្ថែមលើគ្រួសារដែលមានរស់នៅក្នុងលំនៅដ្ឋានធម្មតា អ្នកដែលស្នាក់នៅក្នុងគ្រួសារស្ថាប័ន ដូចជាផ្ទះសំណាក់ សណ្ឋាគារ វត្តអារាម មន្ទីរពេទ្យ ពន្ធនាគារ។ល។ ត្រូវបានរាប់សម្ភាសផងដែរ។ ប្រជាជនដែលគ្មានផ្ទះសំបែង រស់នៅលើទូកក៏ត្រូវបានរាប់សម្ភាសនៅយប់ជំរឿនផងដែរ។

ទោះជាយ៉ាងណាក៏ដោយ ផ្នែកខ្លះនៃតំបន់ដាច់ស្រយ៉ាល និងតំបន់ព្រៃភ្នំ មន្ត្រីសម្ភាសន៍ត្រូវធ្វើដំណើរថ្មើរជើងក្នុងចម្ងាយផ្លូវយ៉ាងឆ្ងាយ។ ក្នុងករណីចាំបាច់ រថយន្ត យោចក្រយានយន្ត កង់ និងទូក ត្រូវប្រើប្រាស់ដោយមន្ត្រីមូលដ្ឋាន។ ទូរស័ព្ទចល័តបានផ្តល់សារប្រយោជន៍ក្នុងអំឡុងពេលធ្វើជំរឿនឆ្នាំ២០១៩។ ទូរស័ព្ទចល័តបានជួយសម្រួលដល់គ្រូបង្គោល មន្ត្រីត្រួតពិនិត្យ និងមន្ត្រីសម្ភាសន៍អាចទាក់ទងគ្នាបានឆាប់រហ័ស នៅពេលមន្ត្រីសម្ភាស៍ត្រូវការបកស្រាយបញ្ជាក់រាល់កិច្ចការជំរឿន។

### តារាងកាលវិភាគនៃសកម្មភាពជំរឿនសំខាន់ៗ

| កាលបរិច្ឆេទ | សកម្មភាព |
|---|---|
| ថ្ងៃទី ២៨ កុម្ភៈ ដល់ថ្ងៃទី ២ មីនា ឆ្នាំ២០១៩ (៣ថ្ងៃ) | ចុះបញ្ជីលំនៅដ្ឋានក្នុងមណ្ឌលជំរឿន និងធ្វើបច្ចុប្បន្នកម្មផែនទីមណ្ឌលជំរឿន |
| យប់ថ្ងៃទី ៣ មីនា ឆ្នាំ២០១៩ | រាប់សម្ភាសជនគ្មានផ្ទះសំបែង ប្រជាជនឆ្លងកាត់ |
| ថ្ងៃទី ៣ ដល់ថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០១៩ (១១ថ្ងៃ) | រាប់សម្ភាសជំរឿនឆ្នាំ២០១៩ នៅម៉ោង(00:00) ជាម៉ោងយោង |
| ថ្ងៃទី ១៣ ដល់ថ្ងៃទី ១៤ ខែមីនា ឆ្នាំ២០១៩ | ប្រមូលកម្រងសំណួរជំរឿនដែលបំពេញរួចនៅការិយាល័យមូលដ្ឋាន |
| ថ្ងៃទី ១៥ ដល់ថ្ងៃទី ២២ ខែមីនា ឆ្នាំ២០១៩ | ទទួលសំណួរជំរឿនដែលបំពេញរួចនៅវិទ្យាស្ថានជាតិស្ថិតិភ្នំពេញ |

## ១.៩. ការគ្រប់គ្រងឯកសារ

ការគ្រប់គ្រងឯកសារ ជាកិច្ចការដ៏សំខាន់មួយក្នុងប្រតិបត្តិការជំរឿន។ នៅពេលដែលទទួលបានឯកសារជំរឿន វិទ្យាស្ថានជាតិស្ថិតិបានធ្វើតារាងតាមលំដាប់អក្សរ ហើយរក្សាទុកឯកសារជំរឿនទាំងអស់នៅក្នុងឃ្លាំងឯកសារ។ ឃ្លាំងឯកសារត្រូវបានរៀបចំជាធ្នើរៗយ៉ាងល្អ។ នៅពេលដែលបញ្ចេញ ឬទទួលឯកសារជំរឿនគេត្រូវកត់ត្រាចូលក្នុងបញ្ជីកត់ត្រាចេញចូល។ ការកត់ត្រា គឺជាកាទទួលខុសត្រូវរបស់មន្ត្រីផ្នែកកែច្នៃទិន្នន័យ។ ទម្រង់ត្រួតពិនិត្យនានាត្រូវបានប្រើប្រាស់ដើម្បីតាមដានស្ថានភាពនៃឯកសារជំរឿនក្នុងមណ្ឌលជំរឿន។

## ១.១០. ការធានាគុណភាពទិន្នន័យ

ដើម្បីធានាបាននូវគុណភាពទិន្នន័យជំរឿន វិធីសាស្ត្រ និងដំណាក់កាលជាច្រើនត្រូវបានអនុវត្តនៅគ្រប់ដំណាក់កាលនៃជំរឿន។ ដើម្បីធានាគុណភាពលើការងាររាប់សម្ភាសន៍នៅមូលដ្ឋាន ជាសំខាន់គឺការប្រមូលព័ត៌មានប្រកបដោយគុណភាព ដូចបានបញ្ជាក់ក្នុងវគ្គបណ្តុះបណ្តាលមន្ត្រីសម្ភាសន៍ និងមន្ត្រីត្រួតពិនិត្យជំរឿន។ តម្រូវការដើម្បីប្រមូលទិន្នន័យបានពិតត្រឹមត្រូវតាមយេនឌ័រ ក៏ត្រូវបានបញ្ជាក់ផងដែរ។ មន្ត្រីសម្ភាសន៍ចំនួនបួននាក់ ត្រូវគ្រប់គ្រងដោយមន្ត្រីត្រួតពិនិត្យម្នាក់ ដែលបានត្រួតពិនិត្យរាល់កិច្ចការរបស់មន្ត្រីសម្ភាសន៍គ្រប់រូបយ៉ាងហ្មត់ចត់ ដើម្បីធានាបាននូវគុណភាពទិន្នន័យ។ ផ្នែកកែច្នៃទិន្នន័យ បានចាប់ផ្តើមពីការកែដៃ និងដាក់លេខកូដដោយដៃ មុនពេលវាយបញ្ចូលទិន្នន័យក្នុងកុំព្យូទ័រ។ ការកែដោយកុំព្យូទ័រក៏ត្រូវបានអនុវត្តផងដែរ ដើម្បីសម្អាតទិន្នន័យមិនឲ្យមានកំហុស សម្រាប់បម្រើឲ្យការផលិតតារាងទិន្នន័យអាទិភាព និងតារាងទិន្នន័យសម្រាប់វិភាគផ្សេងទៀត។ មន្ត្រីត្រួតពិនិត្យគុណភាពទិន្នន័យ ត្រូវធ្វើកំណត់ត្រាក្នុងតារាង និងតាមដានការងារកែដៃ និងដាក់លេខកូដ ត្រូវធានាឲ្យទាន់ពេលវេលា និងសុវត្ថិភាពទិន្នន័យ។ ការទទួលបាន ការទាក់ទង និងការពេញចិត្តរបស់អ្នកប្រើប្រាស់ទិន្នន័យតាមការផ្សព្វផ្សាយលទ្ធផលជំរឿនត្រូវបានធានា។

ដើម្បីកាត់បន្ថយនូវកម្រិតលំអៀងក្នុងការរាប់សម្ភាសជំរឿន គណៈកម្មការបច្ចេកទេសជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា បានបង្កើតនីតិវិធីច្បាស់លាស់សម្រាប់ធានាគុណភាព និងកាត់បន្ថយកំហុសឆ្គងក្នុងការរាប់មិនអស់ និងការវាយតម្លៃ ការត្រួតពិនិត្យគុណភាពដែលត្រូវធ្វើនៅដំណាក់កាលផ្សេងៗគ្នានៃជំរឿន។ ការត្រួតពិនិត្យគុណភាព និងបច្ចេកទេសត្រួតពិនិត្យត្រូវបានអនុវត្ត ដើម្បីឲ្យការរាប់សម្ភាសប្រកបដោយគុណភាព។ មន្ត្រីត្រួតពិនិត្យបានសម្ភាសន៍គ្រួសារខ្លះដោយឯករាជ្យ ដើម្បីផ្ទៀងផ្ទាត់ជាមួយកំណត់ត្រារបស់មន្ត្រីសម្ភាសន៍ ហើយកែតម្រូវលទ្ធផលក្នុងទម្រង់ដោយឡែក ហើយបានធ្វើការណែនាំមន្ត្រីសម្ភាសន៍ឲ្យកែតម្រូវ។ ការធ្វើជំរឿននាំមុខ ការរាប់សម្ភាសសួន ការត្រួតពិនិត្យដោយមន្ត្រីត្រួតពិនិត្យ ការវាយតម្លៃអំពីការត្រួតពិនិត្យគុណភាពនៃការកែច្នៃទិន្នន័យ រួមទាំងការអង្កេតក្រោយពេលជំរឿន ដើម្បីវាយតម្លៃលទ្ធផលជំរឿនសុទ្ធសឹងតែជានាគុណភាពជំរឿន។

## ១.១១. ការកែច្នៃទិន្នន័យ និងកម្មវិធីសម្រាប់វាយទិន្នន័យ

### ១.១១.១. ការកែដៃ និងដាក់លេខកូដ

គោលបំណងនៃការកែដៃ និងដាក់លេខកូដ គឺដើម្បីបង្កើនគុណភាពទិន្នន័យដោយការរកឲ្យឃើញនូវកំហុសនៅលើកម្រងសំណួរ និងធ្វើការកែតម្រូវឲ្យបានសមស្រប។ ការកែតម្រូវ គឺជាការសម្រួលទិន្នន័យដែលមិនត្រឹមត្រូវ ឬមិនបានបំពេញឲ្យបានសមស្របបំផុតតាមបរិបទត្រឹមត្រូវជាក់ស្តែង។ កំហុសឆ្គងភាគច្រើនដែលត្រូវបានរកឃើញ បានកើតឡើងក្នុងពេលបំពេញការងារនៅឯមូលដ្ឋាន។ ក្នុងអំឡុងពេលសម្ភាសន៍ អ្នកឆ្លើយអាចមិនដឹងចម្លើយត្រឹមត្រូវចំពោះសំណួរមួយចំនួន។ ឧទាហរណ៍ មនុស្សមួយចំនួនអាចមិនចាំអាយុពិតប្រាកដរបស់ពួកគេ។ អ្នកឆ្លើយអាចមិនបានយល់ច្បាស់ពីសំណួរជាក់លាក់ ដូច្នេះហើយបានផ្តល់ចម្លើយខុស។ ករណីផ្សេងទៀត អ្នកឆ្លើយអាចមិនចង់ឆ្លើយសំណួរសម្ភាសន៍។ ជាចុងក្រោយ មន្ត្រីសម្ភាសន៍ខ្លួនឯងក៏អាចចូលរួមចំណែកក្នុងការធ្វើឲ្យមានកំហុស ដោយមិនបានកត់ត្រាចម្លើយបានត្រឹមត្រូវ។ វគ្គបណ្តុះបណ្តាលការកែដៃ និងដាក់លេខកូដសម្រាប់មន្ត្រីដែលមានបទពិសោធន៍ត្រូវបានរៀបចំធ្វើឡើង ហើយមន្ត្រីទាំងនោះបានបណ្តុះបណ្តាលបន្តដល់មន្ត្រីកែដៃ និងមន្ត្រីដាក់លេខកូដដ៏ទៃទៀត។ គោលបំណងនៃដំណើរការកែតម្រូវទិន្នន័យ គឺដើម្បីលុបបំបាត់ភាពមិនត្រូវគ្នា ភាពមិនត្រឹមត្រូវ និងមិនពេញលេញដើម្បីកែលម្អឲ្យប្រសើរឡើងនូវគុណភាពទិន្នន័យដែលប្រមូលបាន។

ចម្លើយខ្លះត្រូវបានកត់ត្រាតាមការរៀបរាប់ ដូចជាទីលំនៅពិតប្រាកដរបស់ភ្ញៀវ ទីកន្លែងនៅយប់ធ្វើជំរឿននៃសមាជិកពិតប្រាកដដែលអវត្តមាននៅយប់ធ្វើជំរឿន ទីកន្លែងកំណើត លំនៅដ្ឋានពីមុន មុខវិជ្ជាចម្បងដែលបានសិក្សា មុខរបរ និងសកម្មភាពសេដ្ឋកិច្ច។ មន្ត្រីដាក់លេខកូដជាអ្នកទទួលខុសត្រូវក្នុងការផ្តល់លេខកូដត្រឹមត្រូវទៅនឹងចម្លើយរៀបរាប់ទាំងនោះ។ លេខកូដសម្រាប់អថេរទាំងនោះ ត្រូវបានផ្តល់ក្នុងសេចក្តីណែនាំសម្រាប់មន្ត្រីដាក់លេខកូដ។

តាមផែនការ មន្ត្រីកែដៃ និងដាក់លេខកូដទាំង ១៥០នាក់ គ្រោងបញ្ចប់ការងារនេះត្រឹមរយៈពេល ១០ ខែ (ដំណាច់ខែមីនា ឆ្នាំ២០២០) ប៉ុន្តែជាក់ស្តែង នៅមានការយឺតយ៉ាវដោយសារតែការរំខានពីជំងឺរាតត្បាតសកលកូវីដ ១៩។ ដើម្បីពន្លឿនកិច្ចការនេះ វិទ្យាស្ថានជាតិស្ថិតិបានស្នើសុំកិច្ចសហការពីអគ្គនាយកដ្ឋាន និងអង្គភាពចំណុះក្រសួងផែនការបញ្ជូនមន្ត្រីមកចូលរួមកែដៃ និងដាក់លេខកូដ ដោយត្រូវឆ្លងកាត់វគ្គបណ្តុះបណ្តាលត្រឹមត្រូវ។ ដោយមានការ

យកចិត្តទុកដាក់ពីមន្ត្រីបច្ចេកទេស និងថ្នាក់ដឹកនាំ ជាលទ្ធផលការកែដៃ និងដាក់លេខកូដ ត្រូវបានបញ្ចប់សព្វគ្រប់នៅចុងខែមិថុនា ឆ្នាំ២០២០។ បន្ទាប់ពីការកែដៃ និងដាក់លេខកូដនៅការិយាល័យ កម្រងសំណួរជំរឿនត្រូវបានបញ្ជូនទៅផ្នែកបញ្ចូលទិន្នន័យ។

### ១.១១.២. កម្មវិធីសម្រាប់វាយទិន្នន័យ និងការវាយទិន្នន័យចូលកុំព្យូទ័រ

កម្មវិធីកែច្នៃជំរឿន និងអង្កេត (CSPro) ត្រូវបានប្រើប្រាស់សម្រាប់វាយបញ្ចូលទិន្នន័យ កែតម្រូវទិន្នន័យដោយប្រើកុំព្យូទ័រ ក៏ដូចជាការរៀបចំតារាងទិន្នន័យ។ មន្ត្រីកែច្នៃទិន្នន័យក៏ត្រូវបានបណ្តុះបណ្តាលដោយអ្នកជំនាញផ្នែកកែច្នៃទិន្នន័យ អំពីការប្រើប្រាស់កម្មវិធីនេះ។ ការកែដៃ និងដាក់លេខកូដលើកម្រងសំណួរជំរឿន ត្រូវបានរៀបចំជាពីរដំណាក់កាល។ ដំណាក់កាលទីមួយ ទាក់ទងនឹងការកែដៃ និងដាក់លេខកូដលើកម្រងសំណួរជំរឿន (តារាង ខ)។ បន្ទាប់មក ការកែដៃលើតារាងបញ្ជីលំនៅដ្ឋាន (តារាង ក) នៅដំណាក់កាលទីពីរ។

មន្ត្រីបញ្ចូលទិន្នន័យចំនួន ១០០នាក់ ត្រូវបានជ្រើសរើស និងបណ្តុះបណ្តាល។ ទិន្នន័យត្រូវបានចាប់ផ្តើមវាយបញ្ចូលក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យមួយខែកន្លះក្រោយការកែដៃ និងដាក់លេខកូដ ដោយសារដំណើរការបច្ចេកទេសរៀបបណ្តាញ ហើយនិងការបញ្ចូលទិន្នន័យត្រូវគ្រោងបញ្ចប់ក្នុងរយៈពេល ៩ ខែ ប៉ុន្តែមានការយឺតយ៉ាវដោយសារការរំខានពីជំងឺរាតត្បាតសកលកូវីដ១៩។ វិទ្យាស្ថានជាតិស្ថិតិបានជ្រើសរើសនិស្សិតសាកលវិទ្យាល័យភ្នំពេញ ចំនួន ២០០ នាក់ ដើម្បីពន្លឿនការបញ្ចូលទិន្នន័យ ប៉ុន្តែនិស្សិតទាំងនោះមិនអាចមកបំពេញការងារបានពេញម៉ោងឡើយ។ ជាលទ្ធផលការបញ្ចូលទិន្នន័យត្រូវបានបញ្ចប់សព្វគ្រប់នៅដំណាច់ខែមិថុនា ឆ្នាំ២០២០។

## ១.១២. ការរៀបចំតារាងទិន្នន័យ

ការវិភាគទិន្នន័យជំរឿនដោយវិទ្យាស្ថានជាតិស្ថិតិ បានពឹងផ្អែកលើតារាងអាទិភាព និងតារាងបន្ថែមមួយចំនួនដែលបានផលិតសម្រាប់ការវិភាគ។ ទោះជាយ៉ាងណាក៏ដោយ ការវិភាគជំរឿនមិនត្រូវបានធ្វើតែរាជរដ្ឋាភិបាលតែម្នាក់ឯងឡើយ។ សាកលវិទ្យាល័យ អ្នកប្រជាសាស្ត្រ អ្នកសិក្សាស្រាវជ្រាវ ស្ថាប័នផ្សេងទៀត និងអ្នកប្រើប្រាស់ទិន្នន័យ ក៏អាចប្រើប្រាស់ និងវិភាគទិន្នន័យ តាមវិធីសាស្ត្រផ្ទាល់ខ្លួនទៅតាមសេចក្តីត្រូវការ និងចំណាប់អារម្មណ៍របស់ពួកគេផងដែរ។ ពួកគេអាចទំនាក់ទំនងជាមួយមជ្ឈមណ្ឌលសេវាកម្មព័ត៌មាន (DUSC) សម្រាប់ព័ត៌មានបន្ថែម តារាងអាទិភាពឬរបាយការណ៍ផ្សេងៗ។ ភាពជំពេងនៃទិន្នន័យ និងចំណាត់ថ្នាក់ និងតារាងទិន្នន័យនានាអាចទាញបានជាមួយតារាងជំរឿន និងមីក្រូទិន្នន័យដែលមានវិសាលភាពគ្មានដែនកំណត់សម្រាប់ការវិភាគជំរឿន។

ជាធម្មតា តារាងអាទិភាពគឺជាតារាងមូលដ្ឋានបង្ហាញតាមអថេរទាំងអស់ ដែលទាក់ទងនឹងការគណនាសូចនាករប្រជាសាស្ត្រ និងសេដ្ឋកិច្ច សង្គម សម្រាប់ធ្វើផែនការ និងគោលនយោបាយ។ តារាងភាគច្រើនត្រូវផលិតនៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ តារាងទាំងនេះត្រូវបានផលិត បន្ទាប់ពីការសម្អាតទិន្នន័យចប់សព្វគ្រប់។ តារាងអាទិភាព គឺជាបញ្ជីតារាងអាទិភាពដែលបានស្នើសុំ។

ចំនួនតារាងត្រូវបានផលិត ប្រហាក់ប្រហែលគ្នាទៅនឹងជំរឿនឆ្នាំ២០០៨។ តារាងទាំងនេះគ្របដណ្ដប់ស្ទើរតែគ្រប់ផ្នែកទាំងអស់នៅក្នុងកម្រងសំណួរជំរឿន និងធ្វើចំណាត់ថ្នាក់តាមប្រភេទ គ្រប់តំបន់ទាំងអស់ តាមតម្រូវការរបស់អ្នកប្រើប្រាស់ទិន្នន័យ។ ទិន្នន័យបន្ថែមដែលអ្នកប្រើប្រាស់ស្នើសុំ និងតារាងទិន្នន័យផ្សេងទៀត ត្រូវបានបង្កើតឡើងសម្រាប់ការវិភាគស៊ីជម្រៅ។

## ១.១៣. ការវាយតម្លៃលទ្ធផលជំរឿន

ជំរឿទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ ធ្វើឡើងដើម្បីរាប់ចំនួនប្រជាជននៅទីកន្លែង ដែលពួកគេស្នាក់នៅយប់ធ្វើជំរឿនចាប់ពីម៉ោងសូន្យ ថ្ងៃអាទិត្យទី ៣ ខែមីនា ឆ្នាំ២០១៩។ អង្កេតក្រោយជំរឿនធ្វើឡើងដើម្បីពិនិត្យគុណភាពនៃការរាប់ចំនួនប្រជាជន។ អង្កេតក្រោយជំរឿនត្រូវបានធ្វើភ្លាមៗ នៅតាមមណ្ឌលជំរឿនដែលបានកំណត់ បន្ទាប់ពីប្រតិបត្តិការជំរឿនចប់បានមួយសប្ដាហ៍។ អង្កេតនេះមានគោលបំណងប៉ាន់ស្មានអំពីកំហុសឆ្គងក្នុងការរាប់ចំនួនប្រជាជន និងព័ត៌មានប្រមូលបានដែលមិនអាចជៀសផុតបាន សម្រាប់ប្រតិបត្តិការដធំធេងដូចជា ជំរឿននេះ។ ចុះទៅដល់ខ្នងផ្ទះ ជាដំបូងមន្ត្រីសម្ភាសន៍បានរាប់ឡើងវិញក្នុងដំណើរការអង្កេតនេះ បន្ទាប់មកធ្វើការផ្ទៀងផ្ទាត់ជាមួយកំណត់ត្រានៅការិយាល័យ ហើយបានចុះទៅមូលដ្ឋានជាលើកទីពីរ ដើម្បីធ្វើការផ្ទៀងផ្ទាត់គំលាត។ សំណាកគំរូចំនួន ១៣០ មណ្ឌលជំរឿន ត្រូវបានជ្រើសរើសក្នុងទំហំគ្រួសារសរុប ១២.៥០០ គ្រួសារ និងប្រជាជនជិត ៦០.០០០ នាក់ ត្រូវបានគ្របដណ្ដប់ក្នុងការអង្កេតក្រោយជំរឿននេះ។ ជាលទ្ធផលនៅកម្រិតជាតិ ប្រជាជនរាប់មិនអស់មាន ២,៥០ ភាគរយ ឬ ៣៩៦.៥៨៧នាក់។ អត្រារាប់មិនអស់ឃើញខ្ពស់នៅរាជធានីភ្នំពេញមាន ៦,៣ ភាគរយ ឬ ១៤១.៩៨៥នាក់ និងខេត្តទាំងអស់ទូទាំងប្រទេសកម្ពុជាក្រៅពីរាជធានីភ្នំពេញ មានប្រមាណ ១,៩ ភាគរយ ឬ ៣៥៤.៦០២នាក់។ ចំនួនប្រជាជនសរុបនៅក្នុងប្រទេសសម្រាប់ថ្ងៃទី ៣ ខែមីនា ឆ្នាំ២០១៩ មានចំនួន ១៥.៦៨៥.០៧៦នាក់ និង ២.២៧១.៣៥៦ នាក់ សម្រាប់រាជធានីភ្នំពេញ។ ជាទូទៅ សន្ទស្សន៍កំហុសឆ្គងដោយការសួរសំណួរមានតិចជាង ឬស្មើ ២០ ភាគរយ ហើយបន្ទាប់ពីបានវាយតម្លៃតាមលក្ខណៈបច្ចេកទេស បានបង្ហាញថា ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ បានទទួលលទ្ធផលល្អប្រសើរជាងជំរឿនកន្លងមក។ ចំពោះលទ្ធផលនៃការវាយតម្លៃលម្អិតនេះនឹងមានក្នុងរបាយការណ៍បោះពុម្ពដោយឡែក ដែលអាចរកបាននៅវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ។

## ១.១៤. ការធ្វើចំណាត់ថ្នាក់ទីប្រជុំជនឡើងវិញ

ការធ្វើចំណាត់ថ្នាក់តំបន់ទីប្រជុំជនឡើងវិញនៅកម្ពុជា ឆ្នាំ២០២០ ត្រូវបានអនុវត្តដោយវិទ្យាស្ថានជាតិស្ថិតិក្នុងអំឡុងខែមិថុនា ដល់ខែកក្កដា ឆ្នាំ២០២០ ដោយប្រើប្រាស់សំណុំទិន្នន័យចុងក្រោយនៃជំរឿនប្រជាជនទូទៅនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩។ ការសិក្សានេះត្រូវបានផ្ដល់អនុសាសន៍អំពីចំណាត់ថ្នាក់នៃទីប្រជុំជន ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យបីយ៉ាង គឺទំហំប្រជាជន ដង់ស៊ីតេប្រជាជន និងអ្នកធ្វើការក្នុងវិស័យមិនមែនកសិកម្ម នៅកម្រិតឃុំ។ បន្ទាប់ពីបានពិចារណាគ្រប់ជ្រុងជ្រោយដោយយកចិត្តទុកដាក់ លើគ្រប់ទិដ្ឋភាពពាក់ព័ន្ធនឹងការសិក្សា និងពិគ្រោះ

យោបល់ជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិ ដោយផ្អែកតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោមទៅលើឃុំនីមួយៗ ដើម្បីចាត់ថ្នាក់ជាទីប្រជុំជន ឬជនបទ ៖

### ១. ទិដ្ឋភាពសេដ្ឋកិច្ច និងប្រជាសាស្ត្រ

- ទំហំប្រជាជនសរុបក្នុងឃុំមានចាប់ពី ២.០០០ នាក់ឡើង
- ដង់ស៊ីតេប្រជាជនក្នុងឃុំមានចាប់ពី ២០០ នាក់ក្នុង ១ គីឡូម៉ែត្រការ៉េ
- អ្នកធ្វើការក្នុងវិស័យមិនមែនកសិកម្មលើសពី ៥០ ភាគរយ

### ២. ទិដ្ឋភាពលក្ខខណ្ឌរដ្ឋបាល

- ទីប្រជុំជនដែលបានកំណត់ត្រូវផ្អែកលើមូលដ្ឋាននៃរដ្ឋបាលតាមច្បាប់ ឬទទួលស្គាល់ដោយអនុក្រឹត្យ និងច្បាប់។ ប្រភេទទីមួយនៃទីប្រជុំជនត្រូវបានទទួលស្គាល់ថាទីប្រជុំជនជាក្រុង។ ទីប្រជុំជនទាំងនេះត្រូវបានទទួលស្គាល់ដោយច្បាប់របស់រដ្ឋាភិបាល ដូចជារាជធានី និងក្រុងជាដើម ដោយមិនគិតពីទិដ្ឋភាពសេដ្ឋកិច្ច និងប្រជាសាស្ត្រឡើយ។

### ៣. ទិដ្ឋភាពជាក់ស្តែង និងការពិគ្រោះយោបល់

បន្ទាប់ពីបានពិចារណាគ្រប់ជ្រុងជ្រោយដោយយកចិត្តទុកដាក់លើគ្រប់ទិដ្ឋភាពពាក់ព័ន្ធនឹងការសិក្សាខាងលើ មន្ត្រីវិទ្យាស្ថានជាតិស្ថិតិបានចុះពិនិត្យស្ថានភាពជាក់ស្តែងលើបណ្តាឃុំដែលចាត់ចូលក្នុងលក្ខណៈវិនិច្ឆ័យ និងបានចូលរួមពិគ្រោះយោបល់ជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិ ជាពិសេសប្រធានមន្ទីរផែនការ និងមន្ត្រីបច្ចេកទេសពាក់ព័ន្ធមួយចំនួន រួមមានក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងមហាផ្ទៃ អង្គការ UNICEF អង្គការ UNFPA និង UNHABITAT។

ការសិក្សានេះត្រូវបានទទួលស្គាល់ដោយរាជរដ្ឋាភិបាលកម្ពុជា ហើយត្រូវបានអនុម័តដោយកិច្ចប្រជុំពិសេសសម្រេចឲ្យប្រើប្រាស់ជាផ្លូវការ ជាពិសេសសម្រាប់ការវិភាគជំរឿនឆ្នាំ២០១៩។ សម្រាប់ព័ត៌មានលម្អិតនៃការសិក្សានេះអាចយោងលើការបោះពុម្ពផ្សាយរបស់វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការស្តីពី "ការធ្វើចំណាត់ថ្នាក់ឡើងវិញនៃតំបន់ទីប្រជុំជននៅប្រទេសកម្ពុជា ឆ្នាំ២០២០"។

## ១.១៥. ការវិភាគ និងសរសេររបាយការណ៍

គោលបំណងសំខាន់នៃការធ្វើជំរឿនឆ្នាំ២០១៩ គឺផ្តល់ទិន្នន័យដែលជាតម្រូវការចាំបាច់សម្រាប់បម្រើសេចក្តីត្រូវការ ហើយលទ្ធផលជំរឿនត្រូវបានវិភាគគ្រប់ជ្រុងជ្រោយ និងត្រឹមត្រូវ សម្រាប់បម្រើឲ្យសេចក្តីត្រូវការក្នុងការរៀបចំផែនការ សម្រាប់ការអភិវឌ្ឍ។ ជំរឿននឹងផ្តល់ទិន្នន័យគោលអាចប្រើប្រាស់ដោយស្ថាប័នដែលធ្វើការនៅក្នុងផ្នែកផ្សេងៗ ដូចជាសេវាសុខភាពបន្តពូជ និងផែនការគ្រួសារ ការអប់រំ និងបណ្តុះបណ្តាល ការសិក្សាស្រាវជ្រាវអំពីប្រជាជន និងការអភិវឌ្ឍ ស្ត្រី និងយេនឌ័រ ។ល។ រាជរដ្ឋាភិបាលនឹងរៀបចំអភិវឌ្ឍប្រព័ន្ធព័ត៌មានអំពីប្រជាជនសម្រាប់ប្រើប្រាស់ក្នុងរយៈពេលយូរអង្វែង ដើម្បីតាមដាន វាយតម្លៃកម្មវិធីនានាទាក់ទងនឹងប្រជាជន។ ទិន្នន័យជំរឿននឹងត្រូវផ្សព្វផ្សាយតាមរយៈ

ការបោះពុម្ពផ្សាយ និងប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិក។ ការបណ្តុះបណ្តាលការវិភាគទិន្នន័យត្រូវបានផ្តល់ជូនមន្ត្រីវិទ្យាស្ថានជាតិស្ថិតិ តាមរយៈសិក្ខាសាលា វគ្គបណ្តុះបណ្តាលផ្សេងៗ។ ការវិភាគទិន្នន័យនឹងត្រូវអនុវត្តដោយមន្ត្រីវិទ្យាស្ថានជាតិស្ថិតិ ក្រោមការតម្រង់ទិសដោយទីប្រឹក្សាបច្ចេកទេស។ របាយការណ៍វិភាគនីមួយៗទាក់ទងនឹងប្រធានបទជាក់លាក់មួយ នឹងត្រូវផ្សព្វផ្សាយបន្ទាប់ពីការវិភាគ។

**ក. របាយការណ៍តួលេខបណ្តោះអាសន្ន ៖** របាយការណ៍នេះផលិតទម្រង់ និងតារាងទិន្នន័យសរុប របាយការណ៍ជំរឿនតួលេខបណ្តោះអាសន្ន ដោយបញ្ចូលតែតារាងទិន្នន័យមួយចំនួនសម្រាប់រាជធានី ខេត្ត តាមកំណត់ត្រាពីតារាងសង្ខេប។ របាយការណ៍តួលេខបណ្តោះអាសន្នត្រូវបានបោះពុម្ព និងផ្សព្វផ្សាយនៅខែសីហា ឆ្នាំ២០១៩។

**ខ. របាយការណ៍ចុងក្រោយ ៖** ការវិភាគទិន្នន័យលម្អិតត្រូវបានទាញចេញ (តារាង ក និង ខ) ហើយចាប់ផ្តើមវិភាគ និងសរសេររបាយការណ៍នៅខែកក្កដា ឆ្នាំ២០២០ បានបោះពុម្ពផ្សព្វផ្សាយនៅខែតុលា ឆ្នាំ២០២០។ របាយការណ៍នេះក៏បានផលិតតារាងទិន្នន័យអាទិភាព និងតារាងទិន្នន័យបន្ថែមផងដែរ។

**គ. ការវិភាគលទ្ធផលរាជធានី ខេត្ត ៖** របាយការណ៍សម្រាប់រាជធានី ខេត្តនីមួយៗនឹងត្រូវបានរៀបចំព្រាងដោយមន្ត្រីវិទ្យាស្ថានជាតិស្ថិតិដែលទទួលបានការបណ្តុះបណ្តាល។ របាយការណ៍វិភាគនេះនឹងចាប់ផ្តើមនៅឆ្នាំ ២០២១ ហើយនឹងបោះពុម្ពផ្សព្វផ្សាយនៅត្រីមាសទី២ ឆ្នាំ២០២១។

**ឃ. ការវិភាគស៊ីជម្រៅតាមប្រធានបទ ៖** របាយការណ៍វិភាគស៊ីជម្រៅចំនួន ១៧ ប្រធានបទផ្សេងគ្នា សម្រាប់បម្រើតម្រូវការរៀបចំផែនការតាមវិស័យ និងដើម្បីគាំទ្រយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា និងជាធាតុចូលសម្រាប់រៀបចំការតាមដានត្រួតពិនិត្យ និងវាយតម្លៃអំពីតម្រូវការជាតិ តំបន់ និងអន្តរជាតិ ជាពិសេសការសម្រេចបានរបស់រាជរដ្ឋាភិបាលកម្ពុជា និងអន្តរជាតិលើគោលនយោបាយអាទិភាព នឹងផលិតនៅត្រីមាសទី៤ ឆ្នាំ២០២១។ របាយការណ៍វិភាគស៊ីជម្រៅតាមប្រធានបទនឹងសហការណ៍ផលិតដោយមន្ត្រីជំនាញរបស់វិទ្យាស្ថានជាតិស្ថិតិ ក្រោមជំនួយបច្ចេកទេសពីអ្នកជំនាញអន្តរជាតិ រួមមាន៖

១. លទ្ធភាពបង្កកំណើត និងអាពាហ៍ពិពាហ៍
២. មរណភាព និងមរណភាពមាតា
៣. កំណើនប្រជាជន និងបម្រែបម្រួលរបាយប្រជាជន
៤. របាយប្រជាជន និងទីប្រជុំជន
៥. សមាសភាពភេទ និងអាយុ
៦. ពិការភាព
៧. ជនជាតិដើមភាគតិច
៨. ចំណាកស្រុក
៩. អក្ខរភាព និងការអប់រំ
១០. កម្លាំងពលកម្ម និងការងារ

១១. សម្ភារៈប្រើប្រាស់ក្នុងគ្រួសារ
១២. ទឹកស្អាត និងអនាម័យ
១៣. ចំណោលប្រជាជនកម្ពុជា
១៤. យេនឌ័រ និងស្ត្រីនៅកម្ពុជា
១៥. មនុស្សចាស់ និងស្ថានភាពរស់នៅ
១៦. ស្ថានភាពកុមារនៅកម្ពុជា
១៧. ផែនទីជំរឿន

## ១.១៦. ផែនការផ្សព្វផ្សាយលទ្ធផលជំរឿន

លទ្ធផលជំរឿនកន្លងមកត្រូវបានផ្សព្វផ្សាយដោយជោគជ័យ ទាំងតាមរយៈផលិតផលអេឡិចត្រូនិក និងរបាយការណ៍បោះពុម្ព និងផ្សព្វផ្សាយតាមរយៈសិក្ខាសាលាផ្សព្វផ្សាយ និងសិក្ខាសាលានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ស៊ីឌីដែលចេញផ្សាយសម្រាប់តារាងទិន្នន័យចំនួនប្រជាជន ត្រូវបានទទួល និងប្រើប្រាស់យ៉ាងទូលំទូលាយដោយក្រសួង បណ្តាញភ្នាក់ងារអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ការិយាល័យផែនការ នៅតាមខេត្តស្រុក និងឃុំ សាកលវិទ្យាល័យ និស្សិតអាហារូបករណ៍ បុគ្គល និងស្ថាប័នអ្នកស្រាវជ្រាវ សិស្ស និងនិស្សិត និងអ្នកប្រើប្រាស់ទិន្នន័យផ្សេងទៀត។ ផលិតផលផ្សព្វផ្សាយសំខាន់ៗមួយចំនួនទៀតបានដាក់បញ្ចូលលើគេហទំព័រ រួមមានព័ត៌មានអំពីការធ្វើជំរឿន លទ្ធផលជំរឿនសំខាន់ៗ និងទំព័រស្នើសុំមួយសម្រាប់អ្នកប្រើប្រាស់ទិន្នន័យអាចទាញយកព័ត៌មានលម្អិតពីជំរឿន។ តារាងជំរឿនក៏ត្រូវបានផ្តត់ផ្គង់ទៅតាមតម្រូវការរបស់អ្នកប្រើប្រាស់ទិន្នន័យផងដែរ។ មជ្ឈមណ្ឌលសេវាកម្មព័ត៌មាន (DUSC) បាននិងកំពុងផ្តល់សេវាកម្មដល់អ្នកប្រើប្រាស់ទិន្នន័យជាប្រចាំ។

### ១.១៦.១. ផ្សព្វផ្សាយតាមរយៈសិក្ខាសាលា

ការរៀបចំជាសិក្ខាសាលាសម្រាប់បង្ហាញលទ្ធផលជំរឿនដល់ក្រសួងពាក់ព័ន្ធ និងអ្នកប្រើប្រាស់ទិន្នន័យផ្សេងទៀត នឹងត្រូវរៀបចំនៅដំណាច់ឆ្នាំ២០២០។ សិក្ខាសាលានេះនឹងត្រូវរៀបចំនៅគ្រប់ខេត្ត ដើម្បីផ្តល់អត្ថប្រយោជន៍ដល់អ្នកចូលរួម។ របាយការណ៍ខេត្តនឹងត្រូវចេញផ្សាយ។ គោលបំណងនៃសិក្ខាសាលាផ្សព្វផ្សាយ គឺដើម្បីផ្តល់ទិន្នន័យជំរឿនដល់អ្នករៀបចំផែនការរដ្ឋបាល និងអ្នកស្រាវជ្រាវនៅថ្នាក់ខេត្ត ស្រុក និងឃុំ។ ការប្រាស្រ័យទាក់ទងដោយផ្ទាល់រវាងអ្នកផលិតទិន្នន័យជំរឿន និងអ្នកប្រើប្រាស់នឹងជួយឲ្យប្រជាជនយល់ដឹងអំពីផលប៉ះពាល់នៃកំណើនប្រជាជនលើវិធានការណ៍សុខុមាលភាពដែលបានអនុវត្តដោយរាជរដ្ឋាភិបាល និងជួយតាមដានវឌ្ឍនភាពនៅក្នុងកម្មវិធីអភិវឌ្ឍន៍ផ្សេងៗនៃប្រទេសកម្ពុជា។

### ១.១៦.២. ផ្សព្វផ្សាយតាមរយៈអេឡិចត្រូនិក

វិទ្យាស្ថានជាតិស្ថិតិមានគេហទំព័រដែលមានព័ត៌មានស្តីពីការធ្វើជំរឿនប្រជាជន លទ្ធផលអង្កេតផ្សេងៗ ។ល។ ត្រូវបានការដាក់បញ្ចូលជាទៀងទាត់លើគេហទំព័រ URL www.nis.gov.kh ហើយព័ត៌មានភាគច្រើនដែលមាននៅលើ

គេហទំព័រនេះ ជាទិន្នន័យដែលផលិតរួច។ ចំពោះការផ្សព្វផ្សាយតាមអ៊ីនធឺណិតនៃលទ្ធផលជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ នឹងមានលក្ខណៈទូលំទូលាយត្រូវបានរំពឹងទុក។ តារាងអាទិភាព និងលទ្ធផលវិភាគត្រូវបានដាក់បញ្ចូលឲ្យមាននៅលើអ៊ីនធឺណិត សម្រាប់ការចូលប្រើកាន់តែមានភាពទូលំទូលាយ និងអាចទាញយកទិន្នន័យបាន។ ជាមួយលទ្ធភាពនៃការទាញយកទិន្នន័យមូលដ្ឋាន និងផែនទីពី SQL នឹងត្រូវប្រើតាមអ៊ីនធឺណិតផងដែរ ដោយអនុលោមតាមច្បាប់ស្តីពីស្ថិតិ ការរក្សាការសម្ងាត់របស់អ្នកឆ្លើយតប។ ទោះជាយ៉ាងណាក៏ដោយ ការផ្ទៀងផ្ទាត់ ការប្រើប្រាស់លេខកូដលើទិន្នន័យរួម ត្រូវបានធ្វើឡើងយ៉ាងយកចិត្តទុកដាក់បំផុត។

## ១.១៧. ផលិតផលជំរឿន

ដូចគ្នានឹងជំរឿនមុនៗដែរ ផលិតផលមួយចំនួនត្រូវបានគ្រោងផលិតសម្រាប់ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ ដើម្បីធានាថាការផ្សព្វផ្សាយនិងប្រើប្រាស់លទ្ធផលជំរឿនបានទូលំទូលាយ៖

**ក. តារាងអាទិភាព ៖** ជាទូទៅត្រូវបានបោះពុម្ពផ្សាយជាសៀវភៅ ដែលមានសំណុំតារាងមូលដ្ឋាន។ នេះជាការបោះពុម្ពផ្សាយសាមញ្ញដោយគ្រប់អថេរទាំងអស់នៃជំរឿន បង្ហាញដោយតារាងទិន្នន័យទាក់ទងនឹងការគណនាសូចនាករប្រជាសាស្ត្រ និងសេដ្ឋកិច្ច សង្គម ជាពិសេសសម្រាប់ធ្វើសេចក្តីសម្រេចផ្នែកគោលនយោបាយ។ តារាងភាគច្រើនបានផ្តល់ទិន្នន័យថ្នាក់ជាតិ ហើយមានតែបន្តិចបន្តួចប៉ុណ្ណោះជាទិន្នន័យរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ខ. ផលិតផលបោះពុម្ព ៖** ការបោះពុម្ពជាក្រដាសនៅតែមាននៅក្នុងប្រទេសភាគច្រើន ហើយក៏ជាជម្រើសមួយសម្រាប់ការផ្សព្វផ្សាយលទ្ធផលជំរឿនផងដែរ។ បច្ចុប្បន្ននេះការបោះពុម្ពផ្សាយបានទៅដល់ដៃអ្នកប្រើប្រាស់ទិន្នន័យជំរឿនមានចំនួនច្រើនបំផុត។ ការផ្សព្វផ្សាយតាមក្រដាសមិនតម្រូវឲ្យអ្នកប្រើប្រាស់មានឧបករណ៍ជាក់លាក់ កម្មវិធី ឬជំនាញបច្ចេកទេសឡើយ។ ផលិតផលដូចបានពិពណ៌នាខាងលើ ដែលត្រូវបោះពុម្ពផ្សាយគឺ៖ តារាងអាទិភាព របាយការណ៍ជំរឿនចុងក្រោយ ប័ណ្ណទិន្នន័យជំរឿន (Poster) កូនសៀវភៅជំរឿន និងរបាយការណ៍តាមប្រធានបទមួយចំនួន។

**គ. ការបោះពុម្ពផ្សាយអេឡិចត្រូនិច ៖** ដូចការបោះពុម្ពដែលបានរៀបរាប់ខាងលើ ប៉ុន្តែនៅក្នុងបណ្ណសារអេឡិចត្រូនិច (ទម្រង់ជា PDF និង DOC)។

**ឃ. ម៉ាក្រូទិន្នន័យឌីណាមិក ៖** អាចទាញយក និងបង្ហាញជាតារាង ផែនទី និងឯកសារផ្សេងៗ ដែលបានរៀបចំទុកជាមុនពីមូលដ្ឋានទិន្នន័យដធំមួយ ដោយផ្អែកលើភូមិសាស្ត្រ ប្រធានបទ និងចំណងជើង។ វាជាឧបករណ៍ផ្សព្វផ្សាយទិន្នន័យដែលមានប្រយោជន៍ខ្លាំង។ ឧបករណ៍ផ្សព្វផ្សាយ DevInfo ត្រូវបានប្រើប្រាស់ ដើម្បីផ្សព្វផ្សាយទិន្នន័យជំរឿន ឆ្នាំ២០០៨ និងអង្កេតដ៏ទៃទៀត (ក្រោមឈ្មោះ CamInfo)។ ប្រព័ន្ធទាញយកតារាងដោយប្រើកម្មវិធី CSPro គឺជាឧទាហរណ៍មួយនៃកម្មវិធីម៉ាក្រូទិន្នន័យ។

**ង. មីក្រូទិន្នន័យឌីណាមិក ៖** អនុញ្ញាតឲ្យចូលប្រើទិន្នន័យបុគ្គល ឬគ្រួសារ។ ឧទាហរណ៍គឺ SPSS, SAS និងកម្មវិធីស្ថិតិសម្រាប់ការវិភាគទិន្នន័យដ៏ទៃទៀតជាច្រើន។ បញ្ហាចម្បងនៃការផ្សព្វផ្សាយមីក្រូទិន្នន័យ គឺការរក្សាការសម្ងាត់។ រាល់ចម្លើយនៃកម្រងសំណួរជំរឿនត្រូវតែរក្សាជាការសម្ងាត់។ ចម្លើយទាំងនោះត្រូវបានប្រើសម្រាប់តែគោល

បំណងស្ថិតិតែប៉ុណ្ណោះ។ យោងតាមច្បាប់ជាធរមាន វិទ្យាស្ថានជាតិស្ថិតិ ការិយាល័យស្ថិតិទាំងអស់ត្រូវការពារ និងរក្សាចម្លើយទាំងនោះជាការសម្ងាត់។ ការទទួលបានទិន្នន័យជំរឿនកម្រិតបុគ្គលម្នាក់ៗ ឬគ្រួសារ ជាការរំលោភលើការសម្ងាត់នេះ។ កម្មវិធីដែលដោះស្រាយបញ្ហានេះបានគឺ REDATAM។ ទិន្នន័យត្រូវបានរក្សាទុកដោយបំប្លែងជាកូដ ដែលមិនអាចនរណាដឹងពីកំណត់ត្រាបុគ្គល ឬគ្រួសារឡើយ។ ទោះជាយ៉ាងណាក៏ដោយ ទិន្នន័យអាចត្រូវបានកែច្នៃក្នុងកម្រិតបុគ្គលបាន។ លើសពីនេះ សិទ្ធិនៃការចូលទៅកាន់តំបន់ភូមិសាស្ត្រអាចត្រូវបានកំណត់ដោយការិយាល័យស្ថិតិ។ ម៉្យាងទៀត REDATAM អនុញ្ញាតឲ្យផលិតតារាង តាមតម្រូវការ (ខុសពីការទាញយកតារាង) តាមកម្រិតភូមិសាស្ត្រ ឬរដ្ឋបាលផ្សេងគ្នា។ បន្ថែមលើតារាង REDATAM អាចបង្កើតក្រាហ្វិក និងផែនទីទិន្នន័យ។ លទ្ធផលសរុប អាចត្រូវបាននាំចេញតាមរយៈកម្មវិធីផ្សេងៗ (ASCII, EXCEL, GIS) ។ ការផ្សព្វផ្សាយដោយប្រើកម្មវិធីនេះ សម្រាប់កែច្នៃមីក្រូទិន្នន័យអន្តរកម្មអាចធ្វើនៅលើស៊ីឌី ឌីវីឌី ឬឧបករណ៍ផ្ទុកទិន្នន័យ។ ដូចគ្នានេះដែរ វាមានសមត្ថភាពក្នុងការដំណើរការកែច្នៃទិន្នន័យ តាមអ៊ីនធឺណិត។

# ជំពូក ២
# ទំហំ កំណើន និងការបែងចែកប្រជាជន

## ២.១. ចំនួនប្រជាជនសរុប

លទ្ធផលចុងក្រោយនៃជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ បង្ហាញថាប្រជាជនសរុប តាមវិធីសាស្ត្រឃើញរាប់ តាមពេលវេលាយោងម៉ោងសូន្យ ថ្ងៃទី ៣ ខែមីនា ឆ្នាំ២០១៩ មានចំនួន ១៥.៥៥២.២១១ នាក់ បានកើនឡើងពី ១៣.៣៩៥.៦៨២ នាក់ នៅនៅឆ្នាំ២០០៨។ ចំនួនប្រជាជនសរុបកើនឡើង ២.១៥៦.៥២៩ ត្រូវជា ១៦,១ ភាគរយ ក្នុងរយៈពេល ១១ ឆ្នាំ គឺពីឆ្នាំ២០០៨ ទៅ ២០១៩។ ចំនួនប្រុសមាន ៧.៥៧១.៨៣៧ នាក់ ស្មើនឹង ៤៨,៧ ភាគរយនៃចំនួនប្រជាជនកម្ពុជាសរុប ខណៈពេលដែលចំនួនស្ត្រីមាន ៧.៩៨០.៣៧៤នាក់ ស្មើនឹង ៥១,៣ ភាគរយនៃចំនួនប្រជាជនសរុប ។

ជំរឿនលើកដំបូងត្រូវបានដំណើរការ បន្ទាប់ពីប្រទេសកម្ពុជាបានទទួលឯករាជ្យពីការគ្រប់គ្រងរបស់បារាំង នៅឆ្នាំ១៩៦២ ដែលប្រជាជនកម្ពុជានៅពេលនោះមាន ៥,៧ លាននាក់។ ទម្រង់ប្រជាសាស្ត្រប្រទេសកម្ពុជាបានផ្លាស់ប្តូរទាំងស្រុងបន្ទាប់ពីជំរឿនលើកដំបូង ដោយសារសង្គ្រាម និងភាពចលាចល។ ក្រោយឆ្នាំ១៩៦២ ប្រទេសកម្ពុជាបានខកខានធ្វើជំរឿនរហូតដល់ឆ្នាំ១៩៩៨។ ទោះជាយ៉ាងណាក៏ដោយ មានការប៉ាន់ចំនួនប្រជាជនដោយអ្នកជំនាញផ្នែកប្រជាសាស្ត្រសម្រាប់បម្រើផែនការ និងគោលនយោបាយមួយចំនួន។ អង្កេតប្រជាសាស្ត្រឆ្នាំ ១៩៧៩-១៩៨០ បានប៉ាន់ស្មានប្រជាជនកម្ពុជា ប្រមាណ ៦,៦ លាននាក់។ ក្រោយមក វិទ្យាស្ថានជាតិស្ថិតិបានដឹកនាំការអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ឆ្នាំ១៩៩៤ បានប៉ាន់ស្មានប្រជាជនរបស់ប្រទេសចំនួន ៩,៩ លាននាក់។ ដោយឡែក វិទ្យាស្ថានជាតិស្ថិតិបានធ្វើអង្កេតប្រជាសាស្ត្រនៅខែមីនា ឆ្នាំ១៩៩៦ បានគ្របដណ្តប់លើគ្រួសារចំនួន ២០.០០០ គ្រួសារ ចំនួនប្រជាជនប៉ាន់ស្មានមាន ១០,៧ លាននាក់។ ចំនួនប្រជាជនកម្ពុជាសរុប ផ្អែកតាមជំរឿនខែមីនា ឆ្នាំ១៩៩៨ មានចំនួន ១១,៤ លាននាក់ កម្ពុជាបានធ្វើអង្កេតចន្លោះជំរឿនប្រជាជនកម្ពុជា ឆ្នាំ២០០៤ ប្រជាជនកម្ពុជាបានកើនដល់ ១២,៨ លាននាក់។ ចំនួនប្រជាជនកម្ពុជាបានកើនឡើងជាលំដាប់ គឺនៅជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៨ ប្រជាជនកម្ពុជាកើនដល់ ១៣,៤ លាននាក់ ហើយត្រូវបានធ្វើបច្ចុប្បន្នកម្មដោយអង្កេតចន្លោះជំរឿនប្រជាជនកម្ពុជា ឆ្នាំ២០១៣ មានចំនួនប្រមាណ ១៤,៧ លាននាក់ និងចុងក្រោយនេះ លទ្ធផលចុងក្រោយជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ តាមវិធីសាស្ត្រឃើញរាប់ (ឃើញរាប់) មានចំនួន ១៥,៦ លាននាក់។

រូប ២.១.១. និន្នាការប្រជាជនកម្ពុជា ពីឆ្នាំ១៩៦២ ដល់ឆ្នាំ២០១៩




ប្រជាជនកម្ពុជារស់នៅទីប្រជុំជននៅឆ្នាំ២០០៨ មាន ២.៦១៤.០២៧នាក់ កើនទៅ ៦.១៣៥.១៩៤នាក់ នៅឆ្នាំ២០១៩។ និន្នាការដូចគ្នានេះ ប្រជាជនកម្ពុជារស់នៅជនបទបានថយចុះពី ១០.៧៨១.៦៥៥នាក់ នៅឆ្នាំ២០០៨ មក ៩.៤១៧.០១៧នាក់ នៅឆ្នាំ២០១៩។ ភាគរយប្រជាជនរស់នៅទីប្រជុំជនបានកើនឡើងពី ១៩,៥ ភាគរយ នៅឆ្នាំ ២០០៨ មក ៣៩,៤ ភាគរយ នៅឆ្នាំ២០១៩។

បើតាមលទ្ធផលចុងក្រោយជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ បង្ហាញថាមានភាពខុសគ្នារវាងតំបន់ភូមិសាស្ត្រទាំងបួន (តារាង ២.១.១) នៅទូទាំងប្រទេស ក្នុងនោះតំបន់ទំនាបកណ្តាលមានប្រជាជនខ្ពស់ជាងគេគឺ ៧.៦៤៤.២៩៥នាក់ ស្មើនឹង ៤៩,២ ភាគរយនៃប្រជាជនសរុប។ តំបន់ទន្លេសាបមានប្រជាជនក្នុងលំដាប់ទីពីរគឺ ៤.៨៥២.៩៦៤នាក់ ត្រូវជា ៣១.២ ភាគរយ។ តំន់ខ្ពង់រាប និងភ្នំមានប្រជាជនក្នុងលំដាប់ទីបី ១.៩៨២.៤៨៤នាក់ ស្មើនឹង ១២,៧ ភាគរយ ភាគរយ។ លំដាប់ចុងក្រោយ គឺតំបន់ឆ្នេរ និងសមុទ្រ ដែលមានប្រជាជនតែ ១.០៧២.៤៦៨នាក់ស្មើនឹង ៦,៩ ភាគរយនៃប្រជាជនទូទាំងប្រទេស។

រូប ២.១.២. ចំនួនប្រជាជនសរុប តាមរាជធានី ខេត្ត កម្ពុជា ឆ្នាំ២០១៩




បើតាមលទ្ធផលចុងក្រោយបង្ហាញថា ក្នុងចំណោមរាជធានី ខេត្តទាំង ២៥ រាជធានីភ្នំពេញមានប្រជាជនខ្ពស់ជាងគេចំនួន ២.២៨១.៩៥១នាក់ (១៤,៧ ភាគរយ) បន្ទាប់មកខេត្តកណ្ដាល ១.២០១.៥៨១នាក់ (៧,៧ ភាគរយ) ព្រៃវែង ១.០៥៧.៧២០នាក់ (៦,៨ ភាគរយ) សៀមរាប ១.០១៤.២៣៤នាក់ (៦,៥ ភាគរយ) បាត់ដំបង ៩៩៧,១៦៩នាក់ (៦,៤ ភាគរយ) តាកែវ ៩០០.៩១៤នាក់ (៥,៨ ភាគរយ) និងកំពង់ចាម ៨៩៩,៧៩១នាក់ (៥,៨ ភាគរយ) ចំណែកខេត្តកែបមានប្រជាជនទាបបំផុត ៤២.៦៦៥នាក់ ឬ (០,៣ ភាគរយ)។

## តារាង ២.១.១. ចំនួនប្រជាជនសរុប តាមភេទ តំបន់ រាជធានី ខេត្ត កម្ពុជា ឆ្នាំ២០១៩

| រាជធានី/ខេត្ត | ប្រុស | ស្រី | សរុប |
|---|---|---|---|
| (១) | (២) | (៣) | (៤) |
| **សរុប** | **៧.៥៧១.៨៣៧** | **៧.៩៨០.៣៧៤** | **១៥.៥៥២.២១១** |
| **ទីប្រជុំជន** | **២.៩៩៣.៣៣៩** | **៣.១៤១.៨៥៥** | **៦.១៣៥.១៩៤** |
| **ជនបទ** | **៤.៥៧៨.៤៩៨** | **៤.៨៣៨.៥១៩** | **៩.៤១៧.០១៧** |
| **ទំនាបកណ្តាល** | **៣.៦៧៦.២១១** | **៣.៩៦៨.០៨៤** | **៧.៦៤៤.២៩៥** |
| **ទន្លេសាប** | **២.៣៨០.២៥៦** | **២.៤៧២.៧០៨** | **៤.៨៥២.៩៦៤** |
| **ឆ្នេរ និងសមុទ្រ** | **៥៣៣.៥៦០** | **៥៣៨.៩០៨** | **១.០៧២.៤៦៨** |
| **ខ្ពង់រាប និងភ្នំ** | **៩៨១.៨១០** | **១.០០០.៦៧៤** | **១.៩៨២.៤៨៤** |
| បន្ទាយមានជ័យ | ៤២៧.៩៤៥ | ៤៣៣.៩៣៨ | ៨៦១.៨៨៣ |
| បាត់ដំបង | ៤៩០.៤២៤ | ៥០៦.៧៤៥ | ៩៩៧.១៦៩ |
| កំពង់ចាម | ៤៣១.៣២៧ | ៤៦៨.៤៦៤ | ៨៩៩.៧៩១ |
| កំពង់ឆ្នាំង | ២៥២.១៨៥ | ២៧៤.៨៤២ | ៥២៧.០២៧ |
| កំពង់ស្ពឺ | ៤២៥.១០២ | ៤៥២.៤២១ | ៨៧៧.៥២៣ |
| កំពង់ធំ | ៣៣០.៦០២ | ៣៥០.៩៤៧ | ៦៨១.៥៤៩ |
| កំពត | ២៨៧.៥៩០ | ៣០៦.២៣៩ | ៥៩៣.៨២៩ |
| កណ្តាល | ៥៨១.៥៦៣ | ៦២០.០១៨ | ១.២០១.៥៨១ |
| កោះកុង | ៦៣.៤៤៤ | ៦២.៤៥៨ | ១២៥.៩០២ |
| ក្រចេះ | ១៨៦.៦៥៨ | ១៨៨.០៩៧ | ៣៧៤.៧៥៥ |
| មណ្ឌលគិរី | ៤៧.២៤២ | ៤៤.៩៧១ | ៩២.២១៣ |
| ភ្នំពេញ | ១.១០៥.៦៧៣ | ១.១៧៦.២៧៨ | ២.២៨១.៩៥១ |
| ព្រះវិហារ | ១២៨.៤៣៦ | ១២៦.៣៩១ | ២៥៤.៨២៧ |
| ព្រៃវែង | ៤៩៨.៧១១ | ៥៥៩.០០៩ | ១.០៥៧.៧២០ |
| ពោធិ៍សាត់ | ២០៤.១៧២ | ២១៥.៧៨០ | ៤១៩.៩៥២ |
| រតនគិរី | ១០៩.៩៧៨ | ១០៧.៤៧៥ | ២១៧.៤៥៣ |
| សៀមរាប | ៤៩៧.៤៥០ | ៥១៦.៧៨៤ | ១.០១៤.២៣៤ |
| ព្រះសីហនុ | ១៦១.៤៦២ | ១៤៨.៦១០ | ៣១០.០៧២ |
| ស្ទឹងត្រែង | ៨៤.៣៩៤ | ៨១.៣១៩ | ១៦៥.៧១៣ |
| ស្វាយរៀង | ២៤៩.៥៨១ | ២៧៥.៩១៦ | ៥២៥.៤៩៧ |
| តាកែវ | ៤៣១.២៦៦ | ៤៦៩.៦៤៨ | ៩០០.៩១៤ |
| ឧត្តរមានជ័យ | ១៣៩.៣៧៨ | ១៣៦.៦៦០ | ២៧៦.០៣៨ |
| កែប | ២១.០៦៤ | ២១.៦០១ | ៤២.៦៦៥ |
| ប៉ៃលិន | ៣៨.១០០ | ៣៧.០១២ | ៧៥.១១២ |
| ត្បូងឃ្មុំ | ៣៧៨.០៩០ | ៣៩៨.៧៥១ | ៧៧៦.៨៤១ |

**សម្គាល់ ៖** របាយការណ៍លទ្ធផលសន្និបាតបូកសរុបការងារ ឆ្នាំ២០១៨ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មិនរាប់បញ្ចូលពលករ ពលការិនី ធ្វើការក្រៅប្រទេស ចំនួន ១.២៣៥.៩៩៣នាក់ (ថៃ ១.១៤៦.៦៨៥នាក់ សាធារណរដ្ឋកូរ៉េ ៤៩.០៩៥នាក់ ជប៉ុន ៩.១៩៥នាក់ ម៉ាឡេស៊ី ៣០.១១៣នាក់ សឹង្ហបុរី ៨៣១នាក់ ហុងកុង ៤៥នាក់ និងអារ៉ាប់ប៊ីសេអូឌីត ១៦នាក់)។

ផែនទី ២.១.១. ចំនួនប្រជាជនសរុប តាមរាជធានី ខេត្ត កម្ពុជា ឆ្នាំ២០១៩




## ២.២. កំណើនប្រជាជនប្រចាំឆ្នាំ

កំណើនចំនួនប្រជាជនត្រូវបានប្រើក្នុងន័យទូលំទូលាយ ដើម្បីគ្របដណ្តប់លើការបំរែបំរួលចំនួនប្រជាជនដែលរស់នៅក្នុងប្រទេស ឬតំបន់ ក្នុងអំឡុងពេលជាក់លាក់ដោយមិនគិតការបំរែបំរួលផ្លាស់ប្តូរវិជ្ជមាន ឬអវិជ្ជមាន។ បំរែបំរួលនេះត្រូវបានវាស់វែង ដោយគិតជាភាគរយ។

លទ្ធផលចុងក្រោយនៃជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ តាមវិធីសាស្ត្រឃើញរាប់ចំនួនប្រជាជនកម្ពុជាសរុបកើនឡើងត្រឹមតែ ២.១៥៦.៥២៩នាក់ ត្រូវនឹង ១៦,១ ភាគរយ ក្នុងរយៈពេល ១១ ឆ្នាំចន្លោះឆ្នាំ២០១៨ និង ២០១៩ ក្នុងអត្រាកំណើនប្រចាំឆ្នាំ ១,៤ ភាគរយ។ អត្រាកំណើនប្រជាជនប្រចាំឆ្នាំបានធ្លាក់ចុះអាចដោយសារអត្រានៃលទ្ធភាពបង្កើតកូនធ្លាក់ចុះ និងការធ្វើចំណាកស្រុករបស់ប្រជាជនកម្ពុជាទៅកាន់ប្រទេសផ្សេងជាពិសេសប្រទេសជិតខាង។

អត្រាកំណើនប្រចាំឆ្នាំខ្ពស់បំផុតមាន ២,៤ ភាគរយ ក្នុងមួយឆ្នាំ មាននៅតំបន់ខ្ពង់រាប និងភ្នំ ដែលមានខេត្តភាគច្រើននៅភូមិភាគឦសាន ហើយបន្ទាប់មកតំបន់ទំនាបកណ្តាលមានអត្រាកំណើនប្រចាំឆ្នាំមាន ១,៤ ភាគរយ។ ដោយឡែក តំបន់ឆ្នេរ និងសមុទ្រ និងតំបន់ទន្លេសាបមានអត្រាកំណើនប្រចាំឆ្នាំប្រមាណតែ ១,០ ភាគរយប៉ុណ្ណោះ។

បើធៀបក្នុងទសវត្សមុន អត្រាប្រជាជនប្រចាំឆ្នាំមានកំណើនតិចតួចតំបន់ឆ្នេរ និងសមុទ្រ (០,៨ ភាគរយ មក ០,១ ភាគរយ) និងតំបន់ភ្នំ និងខ្ពង់រាប (២,២ ភាគរយ មក ២,៤ ភាគរយ)។ ខណៈដែលតំបន់ទន្លេសាបធ្លាក់ចុះគួរឲ្យកត់សម្គាល់។

នៅកម្រិតរាជធានី ខេត្ត តាមលទ្ធផលចុងក្រោយនៃជំរឿនទូទៅប្រជាជនកម្ពុជា ឆ្នាំ២០១៩ (កំណើនប្រជាជនច្រើនជាង ៣,០ ភាគរយ) អត្រាកំណើនប្រជាជនខ្ពស់នៅរាជធានីភ្នំពេញ (៤,៩ ភាគរយ) ខេត្តមណ្ឌលគីរី (៣,៧ ភាគរយ) ឧត្តរមានជ័យ (៣,៦ ភាគរយ) ខេត្តព្រះវិហារ (៣,៦ ភាគរយ) ស្ទឹងត្រែង (៣,៦ ភាគរយ) រតនគីរី (៣,៣ ភាគរយ) ព្រះសីហនុ (៣,១ ភាគរយ) និងខេត្តបន្ទាយមានជ័យ (២,២ ភាគរយ)។ ខេត្តទាំងនេះមានអត្រាលទ្ធភាពបង្កើតកូនខ្ពស់ និងស្រូបយកការធ្វើចំណាក ស្រុកមកពីបណ្តាខេត្តផ្សេងទៀតសម្រាប់ការតាំងលំនៅថ្មី និងធ្វើកសិកម្ម ឱកាសសេដ្ឋកិច្ច និងការអភិវឌ្ឍ។ ដោយឡែក រាជធានីភ្នំពេញ និងខេត្តព្រះសីហនុ ជាខេត្តដែលមានសក្តានុពលចាប់យកឱកាសការងារសេដ្ឋកិច្ច និងការអភិវឌ្ឍខ្ពស់ ជាពិសេសកំណើនវិស័យឧស្សាហកម្មកាត់ដេរ សំណង់ សណ្ឋាគារ ទេសចរណ៍ និងអប់រំ ដែលទាក់ទាញស្រូបយកប្រជាជនពីខេត្តផ្សេងៗ ជាពិសេសប្រជាជនក្នុងវ័យកណ្តាល។ រាជធានីភ្នំពេញ និងខេត្តព្រះសីហនុ មានអត្រាកំណើនមធ្យមប្រចាំឆ្នាំតាមលំដាប់រៀង (៤,៩ ភាគរយ) និង (៣,១ ភាគរយ)។ ខេត្តបន្ទាយមានជ័យនៅតែជាគោលដៅទាក់ទាញយកការធ្វើចំណាកស្រុកមកពីបណ្តាខេត្តផ្សេងសម្រាប់ឱកាសការងារ សេដ្ឋកិច្ច និងការអភិវឌ្ឍ ជាពិសេសក្រុង (ប៉ោយប៉ែត)។ អត្រាកំណើនប្រជាជនបានកើនឡើងគ្រប់រាជធានីខេត្ត និងក្រុងទាំងអស់ ក្នុងអត្រាតិច ឬច្រើន លើកលែងតែខេត្តកំពង់ចាម ខេត្តបាត់ដំបង និងខេត្តកណ្តាល អត្រាកំណើនប្រជាជនបានថយចុះ (អត្រាកំណើនអវិជ្ជមាន)។ បើប្រៀបធៀបទៅនឹងអំឡុងឆ្នាំកន្លងមក ឆ្នាំ១៩៩៨-២០០៨ អត្រាកំណើនប្រចាំឆ្នាំបានថយចុះតិច ឬច្រើន។ ភ្នំពេញ កោះកុង បន្ទាយមានជ័យ ព្រៃវែង ព្រះសីហនុ ស្ទឹងត្រែង ស្វាយរៀង មានអត្រាកំណើនប្រជាជនប្រចាំឆ្នាំ ។

## តារាង ២.២.១. អត្រាកំណើនប្រជាជនប្រចាំឆ្នាំ តាមរាជធានី ខេត្ត តំបន់ កម្ពុជា ឆ្នាំ២០០៨-២០១៩

| រាជធានី ខេត្ត | ចំនួនប្រជាជនសរុប | | អត្រាកំណើនប្រចាំឆ្នាំ | |
|---|---|---|---|---|
| | ២០០៨ | ២០១៩ | ១៩៩៨-២០០៨ | ២០០៨-២០១៩ |
| (១) | (២) | (៣) | (៤) | (៥) |
| **សរុប** | ១៣.៣៩៥.៦៨២ | ១៥.៥៥២.២១១ | ១,៥ | ១,៤ |
| **ទីប្រជុំជន** | ២.៦១៤.០២៧ | ៦.១៣៥.១៩៤ | ២,០ | ៧,៨ |
| **ជនបទ** | ១០.៧៨១.៦៥៥ | ៩.៤១៧.០១៧ | ១,៣ | -១,២ |
| **ទំនាបកណ្តាល** | ៦.៥៤៧.៩៥៣ | ៧.៦៤៤.២៩៥ | ១,០ | ១,៤ |
| **ទន្លេសាប** | ៤.៣៥៦.៧០៥ | ៤.៨៥២.៩៦៤ | ២,១ | ១,០ |
| **ឆ្នេរ និងសមុទ្រ** | ៩៦០.៤៨០ | ១.០៧២.៤៦៨ | ០,៨ | ១,០ |
| **ខ្ពង់រាប និងភ្នំ** | ១.៥៣០.៥៤៤ | ១.៩៨២.៤៨៤ | ២,២ | ២,៤ |
| បន្ទាយមានជ័យ | ៦៧៧.៨៧២ | ៨៦១.៨៨៣ | ១,៦ | ២,២ |
| បាត់ដំបង | ១.០២៥.១៧៤ | ៩៩៧.១៦៩ | ២,៣ | -០,៣ |
| កំពង់ចាម | ៩២៥.៩៩២ | ៨៩៩.៧៩១ | ០,៤ | -០,៣ |
| កំពង់ឆ្នាំង | ៤៧២.៣៤១ | ៥២៧.០២៧ | ១,២ | ១,០ |
| កំពង់ស្ពឺ | ៧១៦.៩៤៤ | ៨៧៧.៥២៣ | ១,៨ | ១,៨ |
| កំពង់ធំ | ៦៣១.៤០៩ | ៦៨១.៥៤៩ | ១,០ | ០,៧ |
| កំពត | ៥៨៥.៨៥០ | ៥៩៣.៨២៩ | ១,០ | ០,១ |
| កណ្តាល | ១.២៦៥.២៨០ | ១.២០១.៥៨១ | ១,៦ | -០,៥ |
| កោះកុង | ១១៧.៤៨១ | ១២៥.៩០២ | ០,១ | ០,៦ |
| ក្រចេះ | ៣១៩.២១៧ | ៣៧៤.៧៥៥ | ១,៩ | ១,៥ |
| មណ្ឌលគីរី | ៦១.១០៧ | ៩២.២១៣ | ៦,៣ | ៣,៧ |
| ភ្នំពេញ | ១.៣២៧.៦១៥ | ២.២៨១.៩៥១ | ២,៨ | ៤,៩ |
| ព្រះវិហារ | ១៧១.១៣៩ | ២៥៤.៨២៧ | ៣,៦ | ៣,៦ |
| ព្រៃវែង | ៩៤៧.៣៧២ | ១.០៥៧.៧២០ | ០,០ | ១,០ |
| ពោធិ៍សាត់ | ៣៩៧.១៦១ | ៤១៩.៩៥២ | ០,៧ | ០,៥ |
| រតនគីរី | ១៥០.៤៦៦ | ២១៧.៤៥៣ | ៤,៧ | ៣,៣ |
| សៀមរាប | ៨៩៦.៤៤៣ | ១.០១៤.២៣៤ | ២,៥ | ១,១ |
| ព្រះសីហនុ | ២២១.៣៩៦ | ៣១០.០៧២ | ២,៥ | ៣,១ |
| ស្ទឹងត្រែង | ១១១.៦៧១ | ១៦៥.៧១៣ | ៣,២ | ៣,៦ |
| ស្វាយរៀង | ៤៨២.៧៨៨ | ៥២៥.៤៩៧ | ០,១ | ០,៨ |
| តាកែវ | ៨៤៤.៩០៦ | ៩០០.៩១៤ | ០,៧ | ០,៦ |
| ឧត្តរមានជ័យ | ១៨៥.៨១៩ | ២៧៦.០៣៨ | ៨,៦ | ៣,៦ |
| កែប | ៣៥.៧៥៣ | ៤២.៦៦៥ | ២,២ | ១,៦ |
| ប៉ៃលិន | ៧០.៤៨៦ | ៧៥.១១២ | ១១,២ | ០,៦ |
| ត្បូងឃ្មុំ | ៧៥៤.០០០ | ៧៧៦.៨៤១ | ០,៤ | ០,៣ |

**សម្គាល់ ៖** តួលេខនេះមិនរាប់បញ្ចូលពលករចំណាកស្រុកទៅក្រៅប្រទេស

ផែនទី ២.២.១. អត្រាកំណើនប្រជាជនប្រចាំឆ្នាំ តាម រាជធានី ខេត្ត កម្ពុជា ឆ្នាំ ២០១៩




## ២.៣. ការបែងចែករបាយប្រជាជន

តារាង ២.៣.១ ផ្ដល់ភាគរយប្រជាជនសរុបចុងក្រោយ (ឃើញរាប់) តាមតំបន់ និងភេទនៃជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ បង្ហាញថាប្រជាជនកម្ពុជាចូលចិត្តប្រមូលផ្ដុំរស់នៅតំបន់ទំនាបកណ្ដាលប្រទេស ប្រមាណ ៧.៦៤៤.២៩៥នាក់ ត្រូវជា ៤៩,២ ភាគរយ ដោយសារតំបន់ប្រមូលផ្ដុំដោយខេត្តធំៗមានការអភិវឌ្ឍខ្ពស់។ តំបន់ទន្លេសាបជាតំបន់ដែលមានប្រជាជនច្រើនលំដាប់ទី ២ ដែលមានប្រជាជនចំនួន ៤.៨៥២.៩៦៤នាក់ ឬស្មើនឹង ៣១,២ ភាគរយនៃប្រជាជនសរុប ខណៈដែលតំបន់ខ្ពង់រាប និងភ្នំឈរក្នុងលំដាប់លេខរៀងទី ៣ មានប្រជាជន ១.៩៨២.៤៨៤នាក់ ឬស្មើនឹង ១២,៧ ភាគរយ និងតំបន់ឆ្នេរ និងសមុទ្រមាន ១.០៧២.៤៦៨នាក់ ស្មើនឹង ៦,៩ ភាគរយ។ ទម្រង់និន្នាការរបាយប្រជាជនហាក់នៅថេរមិនប្រែប្រួលរវាងឆ្នាំ២០០៨ និងឆ្នាំ២០១៩។ សម្រាប់តំបន់ខ្ពង់រាប និងភ្នំមានរបាយប្រជាជនកើនឡើងតិច សម្រាប់ឱកាសការងារ និងដីលំនៅដ្ឋាន។ ដោយឡែកតំបន់ទន្លេសាបដែលមានទីតាំង (ជុំវិញបឹងទន្លេសាប និងជាប់ព្រំដែនថៃ) ហាក់ធ្លាក់ចុះ ដោយសារការធ្វើចំណាកស្រុករបស់ប្រជាជនទៅកាន់តំបន់ផ្សេងៗ ជាពិសេសប្រទេសជិតខាង រីឯតំបន់ឆ្នេរ និងសមុទ្របានធ្លាក់ចុះបន្តិច ប៉ុន្តែខេត្តព្រះសីហនុមានរបាយប្រជាជនកើនឡើង។

តារាង ២.៣.១ បង្ហាញភាគរយប្រជាជនសរុបចុងក្រោយ តាមរាជធានី ខេត្ត និងភេទ កម្ពុជា ឆ្នាំ២០០៨-២០១៩។ តាមលទ្ធផលប្រជាជនសរុបចុងក្រោយ ឆ្នាំ២០១៩ ក្នុងចំណោមរាជធានី ខេត្តនៅព្រះរាជាណាចក្រកម្ពុជា ភ្នំពេញមាន

ប្រជាជនខ្ពស់ជាងគេ (១៤,៧ ភាគរយ) បន្ទាប់មកខេត្តកណ្តាល (៧,៧ ភាគរយ) ព្រៃវែង (៦,៨ ភាគរយ) សៀមរាប (៦,៥ ភាគរយ) បាត់ដំបង (៦,៤ ភាគរយ) តាកែវ (៥,៨ ភាគរយ) និងកំពង់ចាម (៥,៨ ភាគរយ) ចំណែកខេត្តកែបវិញមានប្រជាជនទាបបំផុត (០,៣ ភាគរយ)។

បើប្រៀបធៀបទៅនឹងឆ្នាំ២០០៨ របាយប្រជាជនកម្ពុជាមានទម្រង់ដូចគ្នាទៅនឹងឆ្នាំ២០១៩ ដែរ។ ភាគរយនៃរបាយប្រជាជនក្នុងខេត្តកណ្តាល ខេត្តព្រៃវែង ខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តកំពង់ចាម កំពង់ឆ្នាំង កំពង់ធំ កំពត កោះកុង ពោធិ៍សាត់ ស្វាយរៀង ខេត្តតាកែវ និងត្បូងឃ្មុំបានថយចុះ លើកលែងខេត្តបន្ទាយមានជ័យ កំពង់ស្ពឺ រាជធានីភ្នំពេញ ឧត្តរមានជ័យ មណ្ឌលគីរី ក្រចេះ ព្រះវិហារ ព្រះសីហនុ រតនគីរី និងស្ទឹងត្រែង ភាគរយនៃរបាយប្រជាជនបានកើនឡើង។ ខេត្តកែប និងខេត្តប៉ៃលិន ហាក់មានភាគរយថេរ។ ទោះជាយ៉ាងណាក៏ដោយខេត្តព្រះសីហនុ បានបង្ហាញអំពីកំណើនភាគរយប្រជាជន។

**តារាង ២.៣.១. ភាគរយប្រជាជនសរុប តាមភេទ តំបន់ រាជធានី ខេត្ត កម្ពុជា ឆ្នាំ២០០៨-២០១៩**

| រាជធានី ខេត្ត | ឆ្នាំ ២០០៨ | | | ឆ្នាំ ២០១៩ | | |
|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) |
| **សរុប** | **១០០** | **១០០** | **១០០** | **១០០** | **១០០** | **១០០** |
| **ទីប្រជុំជន** | **១៩,៥** | **១៩,៣** | **១៩,៧** | **៣៩,៤** | **៣៩,៥** | **៣៩,៤** |
| **ជនបទ** | **៨០,៥** | **៨០,៧** | **៨០,៣** | **៦០,៦** | **៦០,៥** | **៦០,៦** |
| **ទំនាបកណ្តាល** | **៤៨,៩** | **៤៨,៤** | **៤៩,៤** | **៤៩,២** | **៤៨,៦** | **៤៩,៧** |
| **ទន្លេសាប** | **៣២,៥** | **៣២,៨** | **៣២,៣** | **៣១,២** | **៣១,៤** | **៣១,០** |
| **ឆ្នេរ និងសមុទ្រ** | **៧,២** | **៧,២** | **៧,១** | **៦,៩** | **៧,០** | **៦,៨** |
| **ខ្ពង់រាប និងភ្នំ** | **១១,៤** | **១១,៦** | **១១,៣** | **១២,៧** | **១៣,០** | **១២,៥** |
| បន្ទាយមានជ័យ | ៥,១ | ៥,១ | ៥,០ | ៥,៥ | ៥,៧ | ៥,៤ |
| បាត់ដំបង | ៧,៧ | ៧,៨ | ៧,៥ | ៦,៤ | ៦,៥ | ៦,៣ |
| កំពង់ចាម | ៦,៩ | ៦,៩ | ៦,៩ | ៥,៨ | ៥,៧ | ៥,៩ |
| កំពង់ឆ្នាំង | ៣,៥ | ៣,៥ | ៣,៦ | ៣,៤ | ៣,៣ | ៣,៤ |
| កំពង់ស្ពឺ | ៥,៤ | ៥,៣ | ៥,៤ | ៥,៦ | ៥,៦ | ៥,៧ |
| កំពង់ធំ | ៤,៧ | ៤,៧ | ៤,៧ | ៤,៤ | ៤,៤ | ៤,៤ |
| កំពត | ៤,៤ | ៤,៤ | ៤,៤ | ៣,៨ | ៣,៨ | ៣,៨ |
| កណ្តាល | ៩,៤ | ៩,៤ | ៩,៥ | ៧,៧ | ៧,៧ | ៧,៨ |
| កោះកុង | ០,៩ | ០,៩ | ០,៨ | ០,៨ | ០,៨ | ០,៨ |
| ក្រចេះ | ២,៤ | ២,៤ | ២,៣ | ២,៤ | ២,៥ | ២,៤ |
| មណ្ឌលគីរី | ០,៥ | ០,៥ | ០,៤ | ០,៦ | ០,៦ | ០,៦ |
| ភ្នំពេញ | ៩,៩ | ៩,៦ | ១០,២ | ១៤,៧ | ១៤,៦ | ១៤,៧ |
| ព្រះវិហារ | ១,៣ | ១,៣ | ១,២ | ១,៦ | ១,៧ | ១,៦ |
| ព្រៃវែង | ៧,១ | ៧,០ | ៧,២ | ៦,៨ | ៦,៦ | ៧,០ |
| ពោធិ៍សាត់ | ៣,០ | ៣,០ | ៣,០ | ២,៧ | ២,៧ | ២,៧ |
| រតនគីរី | ១,១ | ១,២ | ១,១ | ១,៤ | ១,៥ | ១,៣ |
| សៀមរាប | ៦,៧ | ៦,៨ | ៦,៦ | ៦,៥ | ៦,៦ | ៦,៥ |
| ព្រះសីហនុ | ១,៧ | ១,៧ | ១,៦ | ២,០ | ២,១ | ១,៩ |
| ស្ទឹងត្រែង | ០,៨ | ០,៩ | ០,៨ | ១,១ | ១,១ | ១,០ |

| រាជធានី ខេត្ត | ប្រជាជនឆ្នាំ ២០០៨ | | | ប្រជាជនឆ្នាំ ២០១៩ | | |
|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) |
| ស្វាយរៀង | ៣,៦ | ៣,៦ | ៣,៧ | ៣,៤ | ៣,៣ | ៣,៥ |
| តាកែវ | ៦,៣ | ៦,៣ | ៦,៣ | ៥,៨ | ៥,៧ | ៥,៩ |
| ឧត្តរមានជ័យ | ១,៤ | ១,៤ | ១,៣ | ១,៨ | ១,៨ | ១,៧ |
| កែប | ០,៣ | ០,៣ | ០,៣ | ០,៣ | ០,៣ | ០,៣ |
| ប៉ៃលិន | ០,៥ | ០,៦ | ០,៥ | ០,៥ | ០,៥ | ០,៥ |
| ត្បូងឃ្មុំ | ៥,៦ | ៥,៧ | ៥,៦ | ៥,០ | ៥,០ | ៥,០ |

**សម្គាល់ ៖** តួលេខនេះមិនរាប់បញ្ចូលពលករចំណាកស្រុកទៅក្រៅប្រទេស

### ផែនទី ២. ៣.១. ភាគរយប្រជាជនសរុប តាមរាជធានី ខេត្ត កម្ពុជា ឆ្នាំ២០១៩




## ២.៤. ដង់ស៊ីតេប្រជាជន

ដង់ស៊ីតេប្រជាជន គឺជាសន្ទស្សន៍ដ៏សំខាន់មួយនៃសូចនាករប្រជាសាស្ត្រដែលត្រូវបានវាស់វែងពីការប្រមូលផ្តុំរបស់ប្រជាជន។ សន្ទស្សន៍ជាចំនួនមនុស្សរស់នៅក្នុងបរិវេណដីក្នុងមួយគីឡូម៉ែត្រការ៉េ។ យោងតាមលទ្ធផលចុងក្រោយ

នៃជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ តាមវិធីសាស្រ្តឃើញរាប់ ដង់ស៊ីតេប្រជាជនកម្ពុជាមាន ៨៧នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ កើនឡើង ១២នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ ពី ៧៥នាក់ នៅឆ្នាំ២០០៨ ។

ដង់ស៊ីតេប្រជាជនតាមតំបន់សម្រាប់ឆ្នាំ២០០៨ និងឆ្នាំ២០១៩ លទ្ធផលចុងក្រោយបានបង្ហាញថា ដង់ស៊ីតេប្រជាជនមានការប្រែប្រួលយ៉ាងខ្លាំងនៅតាមតំបន់ភូមិសាស្រ្តនៃព្រះរាជាណាចក្រកម្ពុជា។ ដង់ស៊ីតេប្រជាជននៅតំបន់វាលទំនាបមានចំនួនខ្ពស់បំផុត ៣០៥នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ បន្ទាប់មកតំបន់ទន្លេសាប ៧២នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ តំបន់ឆ្នេរ និងសមុទ្រមាន ៦២នាក់ ខណៈដែលតំបន់ខ្ពង់រាប និងភ្នំមានដង់ស៊ីតេទាបជាងគេ ២៩នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េប៉ុណ្ណោះ។

បើធៀបទៅនឹងឆ្នាំ២០០៨ ដង់ស៊ីតេប្រជាជនគ្រប់តំបន់ទាំងអស់ ជាពិសេសទំនាបកណ្តាលបានកើនឡើងពីចំនួន ២៦១នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ ទៅ ៣០៥នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ ឬកើន ៤៤នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ តំបន់ទន្លេសាបកើន ១៥នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ និងតំបន់ឆ្នេរ និងសមុទ្រ ខ្ពង់រាប និងភ្នំ កើន ៦នាក់ និង ៧នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ តាមលំដាប់រៀង។

តារាង ២.៤.១ បង្ហាញពីដង់ស៊ីតេប្រជាជនតាមរាជធានី ខេត្ត ឆ្នាំ២០០៨ និងឆ្នាំ២០១៩។ រាជធានីភ្នំពេញដែលជាបេះដូងនៃព្រះរាជាណាចក្រកម្ពុជា ជាតំបន់ប្រមូលផ្តុំដោយមជ្ឈមណ្ឌលពាណិជ្ជកម្ម សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលជាប្រភពទាក់ទាញស្រូបយកការធ្វើចំណាកស្រុកមកពីបណ្តាខេត្តផ្សេងៗ ដោយសារការផ្តល់ប្រភពការងារ និងការរីកចម្រើនខាងវិស័យឧស្សាហកម្មកាត់ដេរ សំណង់ សណ្ឋាគារ ទេសចរណ៍ និងអប់រំ។ល។ នៅរាជធានីភ្នំពេញមានដង់ស៊ីតេប្រជាជនខ្ពស់ជាងគេ ៣.៣៦១នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ បន្ទាប់មកខេត្តកណ្តាល តាកែវ ព្រៃវែង កំពង់ចាម ស្វាយរៀង ព្រះសីហនុ ដែលមានដង់ស៊ីតេយ៉ាងហោចណាស់ ១៥០ នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ។ ខេត្តកោះកុង និងខេត្តមណ្ឌលគីរី ជាខេត្តមានដង់ស៊ីតេប្រជាជនទាបជាងគេ ១២នាក់ និង ៦នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ តាមលំដាប់រៀង បើប្រៀបធៀបនិងឆ្នាំ២០០៨ ដង់ស៊ីតេប្រជាជនកើនឡើងស្ទើរតែគ្រប់ខេត្ត នៅក្នុងឆ្នាំ២០១៩ ដោយសារកំណើនប្រជាជន។

## តារាង ២.៤.១. ការបែងចែករបាយផ្ទៃដី និងដង់ស៊ីតេប្រជាជន តាមតំបន់ រាជធានី ខេត្ត កម្ពុជា ឆ្នាំ២០០៨-២០១៩

| រាជធានី/ខេត្ត | ចំនួនប្រជាជនសរុប | | ផ្ទៃដី* | ដង់ស៊ីតេប្រជាជន/គម² | |
|---|---|---|---|---|---|
| | ២០០៨ | ២០១៩ | គិតជា គម² | ២០០៨ | ២០១៩ |
| (១) | (២) | (៣) | (៤) | (៥) | (៦) |
| **សរុប** | ១៣.៣៩៥.៦៨២ | ១៥.៥៥២.២១១ | ១៨១.០៣៥ | ៧៥ | ៨៧ |
| **ទីប្រជុំជន** | ២.៦១៤.០២៧ | ៦.១៣៥.១៩៤ | ៧.០២២ | ៣៧២ | ៨៧៤ |
| **ជនបទ** | ១០.៧៨១.៦៥៥ | ៩.៤១៧.០១៧ | ១៧១.០១៣ | ៦៣ | ៥៥ |
| **ទំនាបកណ្តាល** | ៦.៥៤៧.៩៥៣ | ៧.៦៤៤.២៩៥ | ២៥.០៦៩ | ២៦១ | ៣០៥ |
| **ទន្លេសាប** | ៤.៣៥៦.៧០៥ | ៤.៨៥២.៩៦៤ | ៦៧.៦៦៨ | ៥៧ | ៧២ |
| **ឆ្នេរ និងសមុទ្រ** | ៩៦០.៤៨០ | ១.០៧២.៤៦៨ | ១៧.២៣៧ | ៥៦ | ៦២ |
| **ខ្ពង់រាប និងភ្នំ** | ១.៥៣០.៥៤៤ | ១.៩៨២.៤៨៤ | ៦៨.០៦១ | ២២ | ២៩ |
| បន្ទាយមានជ័យ | ៦៧៧.៨៧២ | ៨៦១.៨៨៣ | ៦.៦៧៩ | ១០១ | ១២៩ |
| បាត់ដំបង | ១.០២៥.១៧៤ | ៩៩៧.១៦៩ | ១១.៧០២ | ៨៨ | ៨៥ |
| កំពង់ចាម | ៩២៥.៩៩២ | ៨៩៩.៧៩១ | ៤.៥៤៩ | ២០២ | ១៩៨ |
| កំពង់ឆ្នាំង | ៤៧២.៣៤១ | ៥២៧.០២៧ | ៥.៥២១ | ៨៦ | ៩៥ |
| កំពង់ស្ពឺ | ៧១៦.៩៤៤ | ៨៧៧.៥២៣ | ៧.០១៧ | ១០២ | ១២៥ |
| កំពង់ធំ | ៦៣១.៤០៩ | ៦៨១.៥៤៩ | ១៣.៨១៤ | ៤៦ | ៤៩ |
| កំពត | ៥៨៥.៨៥០ | ៥៩៣.៨២៩ | ៤.៨៧៣ | ១២០ | ១២២ |
| កណ្តាល | ១.២៦៥.២៨០ | ១.២០១.៥៨១ | ៣.១៧៩ | ៣៤៣ | ៣៧៨ |
| កោះកុង | ១១៧.៤៨១ | ១២៥.៩០២ | ១០.០៩០ | ១២ | ១២ |
| ក្រចេះ | ៣១៩.២១៧ | ៣៧៤.៧៥៥ | ១១.០៩៤ | ២៩ | ៣៤ |
| មណ្ឌលគីរី | ៦១.១០៧ | ៩២.២១៣ | ១៤.២៨៨ | ៤ | ៦ |
| ភ្នំពេញ | ១.៣២៧.៦១៥ | ២.២៨១.៩៥១ | ៦៧៩ | ២.២១២ | ៣.៣៦១ |
| ព្រះវិហារ | ១៧១.១៣៩ | ២៥៤.៨២៧ | ១៣.៧៨៨ | ១២ | ១៨ |
| ព្រៃវែង | ៩៤៧.៣៧២ | ១.០៥៧.៧២០ | ៤.៨៨៣ | ១៩៤ | ២១៧ |
| ពោធិ៍សាត់ | ៣៩៧.១៦១ | ៤១៩.៩៥២ | ១២.៦៩២ | ៣១ | ៣៣ |
| រតនគីរី | ១៥០.៤៦៦ | ២១៧.៤៥៣ | ១០.៧៨២ | ១៤ | ២០ |
| សៀមរាប | ៨៩៦.៤៤៣ | ១.០១៤.២៣៤ | ១០.២៩៩ | ៨៧ | ៩៨ |
| ព្រះសីហនុ | ២២១.៣៩៦ | ៣១០.០៧២ | ១.៩៣៨ | ១១៤ | ១៦០ |
| ស្ទឹងត្រែង | ១១១.៦៧១ | ១៦៥.៧១៣ | ១១.០៩២ | ១០ | ១៥ |
| ស្វាយរៀង | ៤៨២.៧៨៨ | ៥២៥.៤៩៧ | ២.៩៦៦ | ១៦៣ | ១៧៧ |
| តាកែវ | ៨៤៤.៩០៦ | ៩០០.៩១៤ | ៣.៥៦៣ | ២៣៧ | ២៥៣ |
| ឧត្តរមានជ័យ | ១៨៥.៨១៩ | ២៧៦.០៣៨ | ៦.១៥៨ | ៣០ | ៤៥ |
| កែប | ៣៥.៧៥៣ | ៤២.៦៦៥ | ៣៣៦ | ១០៦ | ១២៧ |
| ប៉ៃលិន | ៧០.៤៨៦ | ៧៥.១១២ | ៨០៣ | ៨៨ | ៩៤ |
| ត្បូងឃ្មុំ | ៧៥៤.០០០ | ៧៧៦.៨៤១ | ៥.២៥០ | ១៤៤ | ១៤៨ |

**សម្គាល់** ៖តួលេខនេះមិនរាប់បញ្ចូលពលករចំណាកស្រុកទៅក្រៅប្រទេស ហើយ ការគណនានេះដកផ្ទៃបឹងទន្លេសាបចេញ ៣.០០០ គម² ។

ផែនទី ២.៤.១. ដង់ស៊ីតេប្រជាជន តាមរាជធានី ខេត្ត កម្ពុជា ឆ្នាំ ២០១៩




## ២.៥. ការបែងចែកប្រជាជនតាមសាសនា

នៅប្រទេសកម្ពុជាប្រមាណ ៩៧ ភាគរយ កាន់ព្រះពុទ្ធសាសនា។ ក្រុមសាសនាដែលធំជាងគេបន្ទាប់ គឺអ្នកកាន់សាសនាឥស្លាមមានប្រមាណជា ២ ភាគរយ។ សាសនាគ្រឹស្ទ និងសាសនាផ្សេងទៀតមាន ០,៨ ភាគរយ។ អ្នកកាន់សាសនាគ្រឹស្ទមានភាគរយតិចក្នុងចំណោមប្រជាជនសរុប។ គំរូនៃការបែងចែកប្រជាជនតាមសាសនា មានច្រើន ឬតិចនៅឆ្នាំ ២០០៨ និងឆ្នាំ២០១៩។

### តារាង ២.៥.១. ការបែងចែកភាគរយប្រជាជនតាមសាសនា តាមតំបន់ រាជធានី ខេត្ត កម្ពុជា ២០០៨-២០១៩

| រាជធានី/ខេត្ត | ឆ្នាំ ២០០៨ | | | | ឆ្នាំ ២០១៩ | | | |
|---|---|---|---|---|---|---|---|---|
| | ព្រះពុទ្ធ | ឥស្លាម | គ្រិស្ត | សាសនាផ្សេង | ព្រះពុទ្ធ | ឥស្លាម | គ្រិស្ត | សាសនាផ្សេង |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨ | (៨) |
| **កម្ពុជា** | **៩៦,៩** | **១,៩** | **០,៤** | **០,៨** | **៩៧,១** | **២,០** | **០,៣** | **០,៥** |
| **ទីប្រជុំជន** | **៩៧,៤** | **១,៦** | **០,៨** | **០,២** | **៩៧,៧** | **១,៦** | **០,៤** | **០,២** |
| **ជនបទ** | **៩៦,៨** | **២,០** | **០,៣** | **០,៩** | **៩៦,៧** | **២,៣** | **០,២** | **០,៨** |
| បន្ទាយមានជ័យ | ៩៩,២ | ០,៥ | ០,៣ | ០,០ | ៩៩,៣ | ០,៤ | ០,២ | ០,០ |
| បាត់ដំបង | ៩៨,៣ | ១,៣ | ០,៣ | ០,០ | ៩៨,៣ | ១,៤ | ០,៣ | ០,០ |
| កំពង់ចាម | ៩៧,៦ | ២,៣ | ០,១ | ០,០ | ៩៧,៦ | ២,៣ | ០,១ | ០,០ |
| កំពង់ឆ្នាំង | ៩៤,៧ | ៤,២ | ០,៤ | ០,៧ | ៩៣,១ | ៥,៨ | ០,៣ | ០,៩ |
| កំពង់ស្ពឺ | ៩៩,៧ | ០,១ | ០,២ | ០,០ | ៩៩,៨ | ០,១ | ០,១ | ០,០ |
| កំពង់ធំ | ៩៩,០ | ០,៦ | ០,៤ | ០,០ | ៩៨,៦ | ១,០ | ០,៣ | ០,០ |
| កំពត | ៩៧,១ | ២,៧ | ០,២ | ០,០ | ៩៦,៩ | ២,៨ | ០,២ | ០,០ |
| កណ្ដាល | ៩៨,០ | ១,២ | ០,៧ | ០,១ | ៩៨,៣ | ១,២ | ០,៤ | ០,១ |
| កោះកុង | ៩៥,២ | ៤,៦ | ០,២ | ០,០ | ៩៥,១ | ៤,៦ | ០,២ | ០,០ |
| ក្រចេះ | ៩៤,០ | ៥,៦ | ០,៤ | ០,១ | ៩៣,១ | ៦,៦ | ០,២ | ០,១ |
| មណ្ឌលគិរី | ៥៤,៧ | ៥,៥ | ៤,៤ | ៣៥,៥ | ៧០,៤ | ៤,៤ | ៤,០ | ២១,២ |
| ភ្នំពេញ | ៩៧,៥ | ១,៥ | ០,៨ | ០,១ | ៩៧,៨ | ១,៦ | ០,៥ | ០,១ |
| ព្រះវិហារ | ៩៩,៤ | ០,៣ | ០,៣ | ០,០ | ៩៩,១ | ០,៥ | ០,៣ | ០,០ |
| ព្រៃវែង | ៩៩,៥ | ០,១ | ០,២ | ០,១ | ៩៩,៥ | ០,២ | ០,៣ | ០,០ |
| ពោធិ៍សាត់ | ៩៧,៤ | ២,៤ | ០,២ | ០,០ | ៩៦,៩ | ៣,០ | ០,១ | ០,០ |
| រតនគិរី | ៤៩,៣ | ១,៣ | ២,៣ | ៤៧,២ | ៧៣,៤ | ១,៣ | ២,១ | ២៣,២ |
| សៀមរាប | ៩៩,៧ | ០,២ | ០,១ | ០,០ | ៩៩,៣ | ០,២ | ០,៤ | ០,១ |
| ព្រះសីហនុ | ៩៤,៥ | ៤,៧ | ០,៧ | ០,១ | ៩៦,២ | ៣,៦ | ០,២ | ០,០ |
| ស្ទឹងត្រែង | ៩៦,១ | ១,៣ | ០,៤ | ២,២ | ៩៣,៦ | ៤,៧ | ០,៤ | ១,៣ |
| ស្វាយរៀង | ៩៩,៧ | ០,១ | ០,២ | ០,០ | ៩៩,៨ | ០,១ | ០,១ | ០,១ |
| តាកែវ | ៩៩,១ | ០,៧ | ០,២ | ០,០ | ៩៩,២ | ០,៦ | ០,១ | ០,០ |
| ឧត្តរមានជ័យ | ៩៩,៨ | ០,១ | ០,១ | ០,០ | ៩៩,៥ | ០,២ | ០,៣ | ០,០ |
| កែប | ៩៨,៧ | ១,២ | ០,០ | ០,០ | ៩៧,៥ | ១,៧ | ០,៧ | ០,១ |
| ប៉ៃលិន | ៩៩,១ | ០,៧ | ០,២ | ០,០ | ៩៨,៣ | ១,០ | ០,៧ | ០,០ |
| ត្បូងឃ្មុំ | ៨៨,៩ | ១១,០ | ០,១ | ០,០ | ៨៨,១ | ១១,៨ | ០,១ | ០,០ |

**សម្គាល់ ៖** តួលេខនេះមិនរាប់បញ្ចូលពលករចំណាកស្រុកទៅក្រៅប្រទេស

## ២.៦. ការបែងចែកប្រជាជនតាមទីកន្លែងកើត

និន្នាការរួមត្រូវបានសង្កេតឃើញថាទាំងក្នុងឆ្នាំ២០០៨ និងឆ្នាំ២០១៩ ភាគច្រើននៃប្រជាជនបានសម្ភាសន៍ក្នុងជំរឿន (៧៨,៥ ភាគរយ) ជាអ្នកបានកើតនៅទីកន្លែងធ្វើសម្ភាសន៍ (តារាង ២.៦.១)។ ដូច្នេះ អ្នកធ្លាប់បានផ្លាស់

លំនៅដ្ឋានក្នុងអតីតកាលមុនធ្វើជំរឿន (អ្នកដែលមិនរស់នៅទីកន្លែងកំណើត) មានតែ ២១,៧ ភាគរយនៃប្រជាជននៅថ្នាក់ជាតិ។

### តារាង ២.៦.១. ការបែងចែកប្រជាជន តាមទីកន្លែងកើត និងភេទ កម្ពុជា ឆ្នាំ២០០៨-២០១៩

| ទីកន្លែងកើត | ២០០៨ | | | ២០១៩ | | |
|---|---|---|---|---|---|---|
| | ទាំងពីរភេទ | បុរស | ស្ត្រី | ទាំងពីរភេទ | បុរស | ស្ត្រី |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) |
| **ចំនួន** | **១៣.៣៩៥.៦៨២** | **៦.៥១៦.០៥៤** | **៦.៨៧៩.៦២៨** | **១៥.៥៥២.២១១** | **៧.៥៧១.៨៣៧** | **៧.៩៨០.៣៧៤** |
| **សរុប** | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |
| A. **កើតនៅកម្ពុជា** | ៩៩,៤ | ៩៩,៤ | ៩៩,៣ | ៩៩,១ | ៩៩,០ | ៩៩,៣ |
| ១. ក្នុងខេត្តសម្ភាសន៍ | ៨៥,៨ | ៨៥,៤ | ៨៦,៣ | ៨៥,៥ | ៨៤,៦ | ៨៦,៤ |
| (ក) ទីកន្លែងសម្ភាសន៍ | ៧៥,២ | ៧៤ | ៧៩,៣ | ៧៨,៥ | ៧៦,៩ | ៨០,១ |
| (ខ) កន្លែងផ្សេងទៀតក្នុងស្រុកសម្ភាសន៍ | ៤,៧ | ៥,២ | ២,៤ | ២,៥ | ២,៩ | ២,០ |
| (គ) ស្រុកផ្សេងទៀតនៃខេត្តសម្ភាសន៍ | ៥,៩ | ៦,២ | ៤,៦ | ៤,៧ | ៥,២ | ៤,៣ |
| ២. ខេត្តផ្សេងក្រៅពីខេត្តសម្ភាសន៍ | ១៣,៧ | ១៤ | ១៣,០ | ១៣,៦ | ១៤,៤ | ១២,៩ |
| B. **កើតនៅបរទេស** | ០,៦ | ០,៧ | ០,៧ | ០,៩ | ១,១ | ០,៧ |
| ១. ក្នុងចំណោមប្រទេសអាស៊ី | ០,៦ | ០,៦ | ០,៧ | ០,៨ | ១,០ | ០,៧ |
| ២. ប្រទេសផ្សេងទៀត | ០,០៣ | ០,០៤ | ០,០២ | ០,០៤ | ០,០៦ | ០,០៣ |

**សម្គាល់ ៖** តួលេខនេះមិនរាប់បញ្ចូលពលករចំណាកស្រុកទៅក្រៅប្រទេស

## ២.៧. ការបែងចែកប្រជាជនតាមភាសាកំណើត

នៅក្នុងជំរឿន គ្រប់សមាជិកទាំងអស់នៅក្នុងគ្រួសារត្រូវបានសាកសួរ ដើម្បីឆ្លើយប្រាប់អំពីភាសាកំណើតរបស់ខ្លួន។ ព័ត៌មានបានបង្ហាញក្នុងតារាង ២.៧.១ បានឲ្យដឹងថា ភាសាខ្មែរគឺជាភាសាកំណើតច្រើនលើសលុបនៅក្នុងប្រទេស (៩៥,៨ ភាគរយ) ឆ្នាំ២០១៩។ អ្នកនិយាយភាសាកំណើតជនជាតិដើមភាគតិចមាន ២,៩ ភាគរយ។ អ្នកដែលមានភាសាបរទេសជាភាសាកំណើត រួមមាន ១,៣ ភាគរយ។

## តារាង ២.៧.១. ការបែងចែកភាគរយនៃប្រជាជន តាមភាសាកំណើត ភេទ កម្ពុជា ឆ្នាំ២០១៩

| ភាសាកំណើត | ចំនួន | | | ភាគរយ | | |
|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) |
| **សរុប** | **១៥.៥៥២.២១១** | **៧.៥៧១.៨៣៧** | **៧.៩៨០.៣៧៤** | **១០០** | **១០០** | **១០០** |
| ខ្មែរ | ១៤.៨៩៣.១៣៤ | ៧.២៣៩.៨២៥ | ៧.៦៥៦.១២១ | ៩៥,៨ | ៩៥,៦ | ៩៥,៩ |
| វៀតណាម | ៧៨.០៩០ | ៣៩.៦៥៧ | ៣៨.៤៤៧ | ០,៥ | ០,៥ | ០,៥ |
| ចិន | ៩៤.៤៥០ | ៥៤.៧៥៦ | ៣៩.៧១២ | ០,៦ | ០,៧ | ០,៥ |
| ឡាវ | ១៣.៦៣៦ | ៦.៩៤០ | ៦.៦៩៨ | ០,១ | ០,១ | ០,១ |
| ថៃ | ៦.៦៥០ | ៣.៤២១ | ៣.២៣០ | ០,០ | ០,០ | ០,០ |
| ភាសាផ្សេងទៀត | ១៧.៩៦៩ | ១០.៤០០ | ៧.៥៧៣ | ០,១ | ០,១ | ០,១ |
| ភាសាជនជាតិភាគតិច | ៤៤៨.២៨២ | ២១៨.៤៣៩ | ២២៩.៩២៨ | ២,៩ | ២,៩ | ២,៩ |

**សម្គាល់ ៖** តួលេខនេះមិនរាប់បញ្ចូលពលករចំណាកស្រុកទៅក្រៅប្រទេស

# ជំពូក ៣
# សមាសភាពភេទ ការបែងចែកក្រុមអាយុ និង ស្ថានភាពអាពាហ៍ពិពាហ៍

## ៣.១. ទស្សនទាន

ការបន្តផ្លាស់ប្តូរនៃសមាសភាពភេទ និងអាយុរបស់ប្រជាជននៅក្នុងភូមិសាស្ត្រតែងតែកើតឡើងស្ទើរតែគ្រប់ប្រទេសទាំងអស់នៅលើពិភពលោក។ ឧទាហរណ៍ការផ្លាស់ប្តូរទាំងនេះ មូលហេតុដំបូងគឺការធ្លាក់ចុះមរណភាព និងការធ្លាក់ចុះនៃលទ្ធភាពបង្កើតកូន។ រចនាសម្ព័ន្ធ អាយុ និងភេទរបស់ប្រជាជនតាមនិន្នាការបច្ចុប្បន្ន និងអតីតកាលចំពោះលទ្ធភាពបង្កើតកូន មរណភាព និងការផ្លាស់លំនៅដ្ឋាន បានប៉ះពាល់ដល់រចនាសម្ព័ន្ធសេដ្ឋកិច្ច សង្គម និងគោលនយោបាយប្រជាជន។ ការផ្លាស់ប្តូររចនាសម្ព័ន្ធអាយុបានធ្វើឲ្យប៉ះពាល់ដល់កម្លាំងពលកម្មនៅក្នុងសេដ្ឋកិច្ចនាពេលអនាគត ថវិកាសាធារណៈ និងផ្ទាល់ខ្លួន វប្បធម៌ និងរចនាសម្ព័ន្ធគ្រួសារ។

អាយុ គឺអថេរដ៏សំខាន់នៃប្រជាជន ដែលអ្នកធ្វើផែនការស្ទើរតែទាំងអស់ត្រូវតែយកចិត្តទុកដាក់លើអថេរមួយនេះ។ ទំនាក់ទំនងរវាងរចនាសម្ព័ន្ធភេទ និងអាយុ និងគោលនយោបាយត្រូវបានបង្ហាញដោយឧទាហរណ៍។ ក្នុងសម័យទំនើប ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រាក់ចំណូលមធ្យមកម្រិតទាបមួយចំនួន ដូចជាប្រទេសកម្ពុជាមានគោលនយោបាយដើម្បីអភិវឌ្ឍន៍ធនធានមនុស្ស និងសេដ្ឋកិច្ច ដោយលើកកម្ពស់ការចុះឈ្មោះចូលរៀន និងធ្វើឲ្យប្រសើរឡើងខាងការសិក្សាអប់រំសម្រាប់អ្នកចុះឈ្មោះចូលរៀន។

ដើម្បីសម្រេចបាននូវគោលនយោបាយទាំងនេះ ការធ្វើចំណោលនៃអាយុចូលរៀនតាមគ្រប់កម្រិតរដ្ឋបាលត្រូវបានអនុវត្តតាមព័ត៌មាននៃការបែងចែកអាយុ និងភេទនៃប្រជាជនដែលបានមកពីជំរឿន។ ផ្អែកលើតម្រូវការរបស់គ្រឹះស្ថានសិក្សាក្នុងផ្នែកផ្សេងៗរបស់ប្រទេស អាគារ គ្រូបង្រៀន និងហេដ្ឋារចនាសម្ព័ន្ធត្រូវបានគ្រោងទុក។

ដោយយោងតាមនិយមន័យរបស់អង្គការសហប្រជាជាតិ អាយុរបស់មនុស្សដែលបានកត់ត្រាក្នុងជំរឿន គឺតាម "ចន្លោះឃ្លាតនៃកាលបរិច្ឆេទកំណើត និងកាលបរិច្ឆេទនៃជំរឿនគិតជាឆ្នាំសូរិយគតិពេញលេញ"។ ក្នុងនោះក៏បានចែងថា ព័ត៌មានអំពីអាយុអាចគិតតាមកាលបរិច្ឆេទកំណើត (ថ្ងៃ ខែ ឆ្នាំកំណើត) ឬសួរដោយផ្ទាល់អំពីអាយុនៅខួបកំណើតចុងក្រោយ។

អនុសាសន៍ទាំងនេះ ត្រូវបានអនុវត្តក្នុងការប្រមូលទិន្នន័យនៃអាយុនៅក្នុងជំរឿនមុនៗ និងអង្កេតបច្ចុប្បន្ននៅប្រទេសកម្ពុជា។ ព័ត៌មានអាយុគិតជាឆ្នាំពេញដោយផ្អែកលើខួបកំណើតចុងក្រោយដែលបានទទួលពីអ្នកឆ្លើយ។ ដូច្នេះ វាមានការងាយស្រួលក្នុងការសួរពីព័ត៌មានអាយុនេះ ប៉ុន្តែពេលខ្លះពិបាកក្នុងការប្រមូលទិន្នន័យបានត្រឹមត្រូវអំពីអាយុចំពោះអ្នកមិនចេះអក្សរ ឬចាស់ជរា។ ជំហានដ៏សមស្របមួយសម្រាប់ប្រមូលទិន្នន័យអំពីអាយុឲ្យមានភាពសុក្រិតនឹងអាចធ្វើទៅបានចំពោះអ្នកឆ្លើយ។ ប្រតិទិនខ្មែរត្រូវបានយកមកប្រើប្រាស់ដោយមន្ត្រីសម្ភាសន៍ ដើម្បីសួរឲ្យបាននូវអាយុ

ពេញលេញពីអ្នកឆ្លើយ ចំពោះអ្នកដែលមិនអាចប្រាប់អាយុរបស់ពួកគេបាន។ មន្ត្រីសម្ភាសន៍ត្រូវបានផ្តល់ឲ្យនូវតារាងព្រឹត្តិការណ៍ជាតិ និងអន្តរជាតិសំខាន់ៗក៏ត្រូវបានប្រើប្រាស់ ដើម្បីជួយឲ្យអ្នកឆ្លើយនឹកឃើញពីអាយុរបស់ពួកគាត់ឡើងវិញ។

## ៣.២. ការវាយតម្លៃទិន្នន័យអាយុ

ការប្រមូលទិន្នន័យមិនអាចត្រឹមត្រូវមួយរយភាគរយបានឡើយ ដោយសារហេតុផលមួយចំនួន បើទោះបីមានការប្រុងប្រយ័ត្ននៅពេលប្រមូលទិន្នន័យក៏ដោយ ដូច្នេះចាំបាច់វាយតម្លៃទិន្នន័យទាំងនោះមុននឹងយកមកប្រើប្រាស់។ សន្ទស្សន៍បទដ្ឋានប្រជាសាស្ត្រត្រូវបានគណនា សម្រាប់គោលបំណងនៃការប្រមូលទិន្នន័យអាយុនិងភេទក្នុងជំរឿនឆ្នាំ២០១៩។

### តារាង ៣.២.១. ការវាយតម្លៃកត់ត្រាអាយុ និងភេទជំរឿនប្រជាជន កម្ពុជា ឆ្នាំ ២០១៩

| ភេទ | សន្ទស្សន៍ Myer | សន្ទស្សន៍ Whiple | |
|---|---|---|---|
| | | ០ | ៥ |
| **ទាំងពីរភេទ** | ៣,៣ | ១០៦ | ១១៣ |
| ប្រុស | ៣,៣ | ១០៤ | ១១៣ |
| ស្រី | ៣,៣ | ១០៨ | ១១៣ |
| សន្ទស្សន៍សហប្រជាជាតិ | ៣២,០ | | |

### សន្ទស្សន៍ Myer

សន្ទស្សន៍ Myer ត្រូវបានប្រើដើម្បីវាស់វែងលើអាយុប្រជាជនតាមខ្ទង់ចុងក្រោយ។ ការកត់ត្រាពីអាយុយោងដែលអាចកើតឡើងជំនួសឲ្យអាយុពិត ពិសេសនៅខ្ទង់ចុងក្រោយ។ សន្ទស្សន៍ Myer គឺមានតម្លៃពី ០ ទៅ ១៨០ ដែលចាប់ផ្តើមពីតម្លៃទាបបំផុត ០ នៅពេលដែលមិនមានរាយការណ៍អំពីអាយុយោងក្នុងតម្លៃណាមួយ និងតម្លៃខ្ពស់បំផុតស្មើ ១៨០ នៅពេលអាយុដែលបានរាយការណ៍មានតម្លៃយោងទោលណាមួយ។ សន្ទស្សន៍ Myer ត្រូវបានគណនាសម្រាប់ជំរឿនឆ្នាំ២០១៩ មានតម្លៃស្មើ ៣,៣។ នេះបញ្ជាក់ថាការកត់ត្រាពីអាយុក្នុងជំរឿនមានលក្ខណៈពិតប្រាកដខ្ពស់ ដោយមិនមាននិន្នាការយោងនៅអាយុចុងក្រោយឡើយ។

### សន្ទស្សន៍ Whipple

ការកត់ត្រាពីអាយុត្រូវបានពិនិត្យ និងវាស់វែងលេខនៅខ្ទង់ចុងក្រោយ។ ការគណនាលើអាយុលេខយោងចុងក្រោយត្រូវបានប្រើតាមសន្ទស្សន៍ Whipple។ សន្ទស្សន៍ Whipple វាស់វែងអាយុលេខយោងខ្ទង់ចុងក្រោយដែលមានតម្លៃលេខ ០ និង ៥ ។ តម្លៃលេខក្នុងរង្វង់ ១០០ ដែលបញ្ជាក់ថាជំរឿនមិនមានចំណូលចិត្តនូវលេខអាយុយោងចុងក្រោយស្មើ ០ ហើយបើលេខ ៥ ដល់ ៥០០ បញ្ជាក់ថាមានចំណូលចិត្តរាយការណ៍តែលេខអាយុខ្ទង់ចុងក្រោយ ០ និង ៥ ត្រូវបានរាយការណ៍។ សន្ទស្សន៍ Whipple នៅក្នុងជំរឿនមានតម្លៃស្មើ ១០៦ សម្រាប់លេខយោងអាយុចុងក្រោយស្មើ ០ ដែលបញ្ជាក់ថាស្ទើរតែមិនមានការរាយការណ៍អាយុយោងលេខចុងក្រោយស្មើនឹង ០។ ការគណនាមានតម្លៃ

១១៣ សម្រាប់លេខយោងអាយុចុងក្រោយស្មើ ៥ ដែលបញ្ជាក់ថាស្ទើរតែមិនមានការរាយការណ៍អាយុយោងលេខចុងក្រោយស្មើនឹង ៥ នៅក្នុងជំរឿនឡើយ។ នេះបញ្ជាក់ថាការកត់ត្រាពីអាយុក្នុងជំរឿនមានលក្ខណៈពិតប្រាកដខ្ពស់ហើយមិនមាននិន្នាការយោងនៅអាយុចុងក្រោយឡើយ។

### សន្ទស្សន៍ភាពត្រឹមត្រូវនៃអាយុ និងភេទរបស់សហប្រជាជាតិ

អង្គការសហប្រជាជាតិបានបង្កើតសន្ទស្សន៍នៃភាពត្រឹមត្រូវអាយុ និងភេទដែលមានភាពខុសគ្នាពីក្រុមអាយុទៅនឹងក្រុមអាយុក្នុងការរាយការណ៍អំពីអត្រាភេទដោយមិនគិតទៅលើសញ្ញា ដែលត្រូវបានវាស់វែងអំពីភាពត្រឹមត្រូវនៃអត្រាភេទ ដោយផ្អែកលើការសន្មតការផ្លាស់ប្តូរពីអាយុមួយទៅអាយុមួយផ្សេងទៀត ដែលតម្លៃនេះគួរប្រហាក់ប្រហែលឬស្មើនឹង ០។ សន្ទស្សន៍នេះត្រូវបានគណនាដោយផ្អែកលើជាតុផ្សំសរុបនៃ (i) គំលាតមធ្យមនៃអត្រាភេទរបស់មនុស្សប្រុសពី ១០០ (ii) គំលាតមធ្យមនៃអត្រាភេទរបស់មនុស្សស្រីពី ១០០ និង (iii) បីដងពីអាយុមួយទៅអាយុរាយការណ៍ខុសនៃអត្រាភេទ។ សម្រាប់គោលបំណងនេះ អត្រាអាយុគឺជាផលធៀបប្រជាជនក្នុងក្រុមអាយុដែលបានសិក្សាទៅនឹងតម្លៃពាក់កណ្តាលនៃប្រជាជនសរុបក្នុងក្រុមអាយុមុន និងក្រុមអាយុដែលបានសិក្សា។

គណនាតាមវិធីសាស្ត្រនេះមានសន្ទស្សន៍ ៣២,០។ បើសន្ទស្សន៍មានតម្លៃស្មើ ឬទាបជាង ២០ អាចវាយតម្លៃបានថាមានភាពត្រឹមត្រូវខ្ពស់នៃទិន្នន័យអាយុ និងភេទ។ សន្ទស្សន៍នេះត្រូវបានគេសិក្សានៅពេលដែលមិនមាននិន្នាការនៃការធ្លាក់ចុះអត្រាភេទ ជាមួយការកើនឡើងនៃអាយុ និងភាពមិនប្រក្រតីនៃការបែងចែកក្រុមអាយុ ដោយសារការផ្លាស់លំនៅដ្ឋាន បញ្ហាសង្គ្រាម។ល។ ជាងនេះទៀត គឺការប្រែប្រួលភាពជម្មតានៃអត្រាកំណើត។ ផ្អែកលើកត្តាទាំងឡាយដែលមានឥទ្ធិពលលើទិន្នន័យអាយុ និងភេទនៅកម្ពុជា តម្លៃនេះលើស ២០។ ផ្អែកលើមូលដ្ឋានដែលបានសិក្សាវាយតម្លៃខាងលើអាចសន្និដ្ឋានបានថា ជារួមការកត់ត្រាអាយុពីជំរឿនឆ្នាំ២០១៩ មានភាពត្រឹមត្រូវបង្គួរដែលអាចទទួលយកបាន ទោះបីមានភាពមិនប្រក្រតីមួយចំនួនក៏ដោយ។

## ៣.៣. រចនាសម្ព័ន្ធអាយុ

រចនាសម្ព័ន្ធអាយុត្រូវបានកំណត់ដោយកត្តា ៣ ដែលធ្វើឲ្យប៉ះពាល់អត្រាកំណើនប្រជាជន ដូចជាលទ្ធភាពបង្កើតកូន មរណភាព និងការផ្លាស់ប្តូរលំនៅដ្ឋាន។ ការសិក្សារចនាសម្ព័ន្ធប្រជាជនតាមការបែងចែកភាគរយប្រជាជនតាមក្រុមអាយុ និងការបង្ហាញតាមក្រាហ្វិកពីរ៉ាមីតអាយុ គឺជាការសង្ខេបខ្លីនៃប្រវត្តិប្រជាសាស្ត្ររបស់ប្រជាជន។

## តារាង ៣.៣.១. ការបែងចែកតាមក្រុមអាយុរាយ តាមភេទ តំបន់ កម្ពុជា ឆ្នាំ២០១៩

| អាយុ | សរុប | | | ទីប្រជុំជន | | | ជនបទ | | |
|---|---|---|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨) | (៩) | (១០) |
| **សរុប** | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |
| ០ | ១,៥ | ១,៥ | ១,៤ | ១,៣ | ១,៣ | ១,២ | ១,៦ | ១,៧ | ១,៥ |
| ១ | ១,៧ | ១,៨ | ១,៦ | ១,៥ | ១,៦ | ១,៤ | ១,៨ | ១,៩ | ១,៧ |
| ២ | ២,០ | ២,១ | ១,៩ | ១,៨ | ១,៩ | ១,៨ | ២,២ | ២,៣ | ២,១ |
| ៣ | ២,១ | ២,២ | ២,០ | ១,៩ | ២,០ | ១,៨ | ២,២ | ២,៤ | ២,១ |
| ៤ | ២,០ | ២,២ | ១,៩ | ១,៨ | ១,៩ | ១,៧ | ២,២ | ២,៣ | ២,០ |
| **០-៤** | **៩,៣** | **៩,៩** | **៨,៨** | **៨,៤** | **៨,៨** | **៧,៩** | **១០,០** | **១០,៥** | **៩,៤** |
| ៥ | ២,០ | ២,១ | ១,៩ | ១,៨ | ១,៨ | ១,៧ | ២,១ | ២,២ | ២,០ |
| ៦ | ២,០ | ២,១ | ១,៩ | ១,៨ | ១,៩ | ១,៧ | ២,១ | ២,៣ | ២,០ |
| ៧ | ១,៩ | ២,០ | ១,៨ | ១,៧ | ១,៨ | ១,៦ | ២,០ | ២,១ | ១,៩ |
| ៨ | ១,៨ | ១,៩ | ១,៧ | ១,៦ | ១,៦ | ១,៥ | ២,០ | ២,១ | ១,៩ |
| ៩ | ១,៨ | ១,៩ | ១,៧ | ១,៥ | ១,៦ | ១,៤ | ២,០ | ២,១ | ១,៩ |
| **៥-៩** | **៩,៥** | **១០,០** | **៩,០** | **៨,៣** | **៨,៧** | **៧,៩** | **១០,៣** | **១០,៨** | **៩,៧** |
| ១០ | ២,៣ | ២,៤ | ២,១ | ១,៩ | ២,០ | ១,៨ | ២,៥ | ២,៦ | ២,៣ |
| ១១ | ២,០ | ២,១ | ១,៩ | ១,៧ | ១,៨ | ១,៦ | ២,២ | ២,៣ | ២,០ |
| ១២ | ២,៣ | ២,៤ | ២,២ | ១,៩ | ២,០ | ១,៨ | ២,៥ | ២,៦ | ២,៤ |
| ១៣ | ២,១ | ២,២ | ២,០ | ១,៧ | ១,៨ | ១,៦ | ២,៣ | ២,៥ | ២,២ |
| ១៤ | ២,០ | ២,០ | ១,៩ | ១,៧ | ១,៧ | ១,៦ | ២,២ | ២,២ | ២,១ |
| **១០-១៤** | **១០,៦** | **១១,១** | **១០,១** | **៩,០** | **៩,៤** | **៨,៦** | **១១,៦** | **១២,២** | **១១,១** |
| ១៥ | ២,០ | ២,១ | ១,៩ | ១,៧ | ១,៨ | ១,៦ | ២,២ | ២,៣ | ២,០ |
| ១៦ | ១,៧ | ១,៨ | ១,៦ | ១,៦ | ១,៦ | ១,៦ | ១,៨ | ១,៩ | ១,៧ |
| ១៧ | ១,៧ | ១,៨ | ១,៦ | ១,៦ | ១,៧ | ១,៦ | ១,៧ | ១,៨ | ១,៧ |
| ១៨ | ១,៩ | ១,៩ | ១,៩ | ២,០ | ២,០ | ២,០ | ១,៨ | ១,៩ | ១,៨ |
| ១៩ | ១,៨ | ១,៨ | ១,៧ | ២,០ | ២,០ | ២,០ | ១,៦ | ១,៧ | ១,៦ |
| **១៥-១៩** | **៩,១** | **៩,៤** | **៨,៨** | **៨,៩** | **៩,១** | **៨,៨** | **៩,២** | **៩,៦** | **៨,៧** |
| ២០ | ១,៧ | ១,៨ | ១,៧ | ១,៩ | ១,៩ | ២,០ | ១,៦ | ១,៦ | ១,៦ |
| ២១ | ១,៥ | ១,៥ | ១,៥ | ១,៧ | ១,៧ | ១,៧ | ១,៤ | ១,៤ | ១,៣ |
| ២២ | ១,៦ | ១,៦ | ១,៦ | ១,៨ | ១,៨ | ១,៨ | ១,៤ | ១,៤ | ១,៤ |
| ២៣ | ១,៦ | ១,៦ | ១,៧ | ១,៩ | ១,៩ | ២,០ | ១,៥ | ១,៥ | ១,៥ |
| ២៤ | ១,៧ | ១,៦ | ១,៧ | ២,០ | ១,៩ | ២,០ | ១,៥ | ១,៥ | ១,៥ |
| **២០-២៤** | **៨,១** | **៨,១** | **៨,១** | **៩,៣** | **៩,២** | **៩,៤** | **៧,៣** | **៧,៤** | **៧,២** |
| ២៥ | ២,០ | ២,១ | ២,០ | ២,៤ | ២,៤ | ២,៤ | ១,៨ | ១,៨ | ១,៨ |
| ២៦ | ១,៨ | ១,៨ | ១,៨ | ២,០ | ២,០ | ២,១ | ១,៦ | ១,៦ | ១,៦ |
| ២៧ | ១,៨ | ១,៨ | ១,៨ | ២,១ | ២,២ | ២,១ | ១,៦ | ១,៦ | ១,៦ |
| ២៨ | ១,៨ | ១,៨ | ១,៨ | ២,២ | ២,២ | ២,២ | ១,៦ | ១,៦ | ១,៦ |
| ២៩ | ១,៧ | ១,៨ | ១,៧ | ២,០ | ២,១ | ២,០ | ១,៥ | ១,៦ | ១,៥ |
| **២៥-២៩** | **៩,២** | **៩,២** | **៩,១** | **១០,៨** | **១០,៨** | **១០,៨** | **៨,១** | **៨,២** | **៨,១** |

| អាយុ | សរុប | | | ទីប្រជុំជន | | | ជនបទ | | |
|---|---|---|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨) | (៩) | (១០) |
| ៣០ | ១,៩ | ១,៩ | ១,៩ | ២,២ | ២,២ | ២,២ | ១,៧ | ១,៧ | ១,៧ |
| ៣១ | ១,៧ | ១,៧ | ១,៦ | ១,៩ | ១,៩ | ១,៩ | ១,៥ | ១,៥ | ១,៥ |
| ៣២ | ១,៨ | ១,៨ | ១,៧ | ២,១ | ២,១ | ២,១ | ១,៥ | ១,៦ | ១,៥ |
| ៣៣ | ១,៦ | ១,៦ | ១,៦ | ១,៨ | ១,៨ | ១,៨ | ១,៥ | ១,៤ | ១,៥ |
| ៣៤ | ១,៥ | ១,៥ | ១,៥ | ១,៧ | ១,៧ | ១,៧ | ១,៣ | ១,៣ | ១,៣ |
| **៣០-៣៤** | **៨,៤** | **៨,៤** | **៨,៣** | **៩,៧** | **៩,៨** | **៩,៧** | **៧,៥** | **៧,៥** | **៧,៥** |
| ៣៥ | ១,៩ | ១,៩ | ១,៨ | ២,១ | ២,២ | ២,១ | ១,៧ | ១,៧ | ១,៧ |
| ៣៦ | ១,៦ | ១,៦ | ១,៦ | ១,៨ | ១,៨ | ១,៨ | ១,៥ | ១,៥ | ១,៥ |
| ៣៧ | ១,៧ | ១,៧ | ១,៦ | ១,៩ | ១,៩ | ១,៩ | ១,៥ | ១,៥ | ១,៥ |
| ៣៨ | ១,៧ | ១,៧ | ១,៧ | ១,៩ | ១,៩ | ១,៨ | ១,៦ | ១,៦ | ១,៦ |
| ៣៩ | ១,៦ | ១,៦ | ១,៥ | ១,៨ | ១,៩ | ១,៧ | ១,៥ | ១,៥ | ១,៤ |
| **៣៥-៣៩** | **៨,៤** | **៨,៥** | **៨,៣** | **៩,៥** | **៩,៧** | **៩,៣** | **៧,៧** | **៧,៨** | **៧,៦** |
| ៤០ | ១,៥ | ១,៥ | ១,៥ | ១,៦ | ១,៧ | ១,៦ | ១,៥ | ១,៤ | ១,៥ |
| ៤១ | ០,៩ | ០,៩ | ០,៩ | ០,៩ | ០,៩ | ០,៨ | ០,៩ | ០,៩ | ០,៩ |
| ៤២ | ០,៩ | ០,៩ | ០,៩ | ០,៩ | ០,៩ | ០,៨ | ០,៩ | ០,៩ | ០,៩ |
| ៤៣ | ០,៨ | ០,៨ | ០,៨ | ០,៨ | ០,៨ | ០,៧ | ០,៨ | ០,៨ | ០,៨ |
| ៤៤ | ០,៨ | ០,៨ | ០,៨ | ០,៨ | ០,៨ | ០,៨ | ០,៨ | ០,៨ | ០,៨ |
| **៤០-៤៤** | **៤,៨** | **៤,៨** | **៤,៨** | **៤,៩** | **៥,០** | **៤,៨** | **៤,៨** | **៤,៧** | **៤,៩** |
| ៤៥ | ១,១ | ១,១ | ១,១ | ១,០ | ១,១ | ១,០ | ១,១ | ១,១ | ១,១ |
| ៤៦ | ០,៩ | ០,៩ | ០,៩ | ០,៩ | ០,៩ | ១,០ | ០,៩ | ០,៩ | ០,៩ |
| ៤៧ | ១,០ | ១,០ | ១,០ | ១,០ | ០,៩ | ១,០ | ១,០ | ១,០ | ១,០ |
| ៤៨ | ១,១ | ១,១ | ១,១ | ១,០ | ១,១ | ០,៩ | ១,១ | ១,០ | ១,១ |
| ៤៩ | ១,០ | ១,០ | ១,០ | ១,០ | ១,០ | ១,០ | ១,០ | ១,០ | ១,១ |
| **៤៥-៤៩** | **៥,១** | **៥,០** | **៥,១** | **៥,០** | **៥,០** | **៤,៩** | **៥,១** | **៥,០** | **៥,២** |
| ៥០ | ១,១ | ១,០ | ១,១ | ១,០ | ១,០ | ១,០ | ១,១ | ១,០ | ១,២ |
| ៥១ | ០,៩ | ០,៩ | ០,៩ | ០,៨ | ០,៨ | ០,៨ | ០,៩ | ០,៩ | ០,៩ |
| ៥២ | ០,៩ | ០,៩ | ១,០ | ០,៩ | ០,៨ | ០,៩ | ១,០ | ០,៩ | ១,០ |
| ៥៣ | ០,៩ | ០,៩ | ០,៩ | ០,៨ | ០,៨ | ០,៨ | ១,០ | ០,៩ | ១,០ |
| ៥៤ | ០,៨ | ០,៨ | ០,៩ | ០,៨ | ០,៧ | ០,៨ | ០,៩ | ០,៨ | ០,៩ |
| **៥០-៥៤** | **៤,៦** | **៤,៤** | **៤,៨** | **៤,៣** | **៤,២** | **៤,៤** | **៤,៨** | **៤,៥** | **៥,១** |
| ៥៥ | ១,០ | ០,៩ | ១,០ | ០,៩ | ០,៨ | ០,៩ | ១,១ | ១,០ | ១,១ |
| ៥៦ | ០,៨ | ០,៨ | ០,៩ | ០,៨ | ០,៨ | ០,៨ | ០,៩ | ០,៨ | ០,៩ |
| ៥៧ | ០,៨ | ០,៨ | ០,៨ | ០,៧ | ០,៧ | ០,៨ | ០,៩ | ០,៨ | ០,៩ |
| ៥៨ | ០,៨ | ០,៧ | ០,៩ | ០,៧ | ០,៧ | ០,៨ | ០,៩ | ០,៨ | ០,៩ |
| ៥៩ | ០,៧ | ០,៧ | ០,៧ | ០,៧ | ០,៧ | ០,៧ | ០,៧ | ០,៧ | ០,៨ |
| **៥៥-៥៩** | **៤,១** | **៣,៩** | **៤,៣** | **៣,៨** | **៣,៦** | **៣,៩** | **៤,៣** | **៤,១** | **៤,៦** |
| ៦០ | ០,៨ | ០,៧ | ០,៩ | ០,៧ | ០,៦ | ០,៨ | ០,៨ | ០,៧ | ០,៩ |
| ៦១ | ០,៦ | ០,៥ | ០,៧ | ០,៥ | ០,៥ | ០,៦ | ០,៦ | ០,៥ | ០,៧ |
| ៦២ | ០,៦ | ០,៥ | ០,៧ | ០,៦ | ០,៥ | ០,៧ | ០,៦ | ០,៥ | ០,៧ |

| អាយុ | សរុប | | | ទីប្រជុំជន | | | ជនបទ | | |
|---|---|---|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨) | (៩) | (១០) |
| ៦៣ | ០,៦ | ០,៥ | ០,៧ | ០,៥ | ០,៤ | ០,៦ | ០,៦ | ០,៥ | ០,៧ |
| ៦៤ | ០,៥ | ០,៤ | ០,៦ | ០,៥ | ០,៤ | ០,៦ | ០,៥ | ០,៤ | ០,៦ |
| **៦០-៦៤** | **៣,០** | **២,៥** | **៣,៥** | **២,៩** | **២,៤** | **៣,៣** | **៣,១** | **២,៥** | **៣,៦** |
| ៦៥ | ០,៦ | ០,៥ | ០,៧ | ០,៦ | ០,៥ | ០,៧ | ០,៦ | ០,៥ | ០,៨ |
| ៦៦ | ០,៤ | ០,៤ | ០,៥ | ០,៤ | ០,៣ | ០,៥ | ០,៤ | ០,៤ | ០,៥ |
| ៦៧ | ០,៥ | ០,៤ | ០,៥ | ០,៤ | ០,៤ | ០,៥ | ០,៥ | ០,៤ | ០,៦ |
| ៦៨ | ០,៤ | ០,៣ | ០,៥ | ០,៤ | ០,៣ | ០,៥ | ០,៥ | ០,៤ | ០,៥ |
| ៦៩ | ០,៤ | ០,៣ | ០,៤ | ០,៤ | ០,៣ | ០,៤ | ០,៤ | ០,៣ | ០,៤ |
| **៦៥-៦៩** | **២,៣** | **១,៩** | **២,៧** | **២,២** | **១,៨** | **២,៥** | **២,៤** | **២,០** | **២,៨** |
| ៧០ | ០,៤ | ០,៣ | ០,៥ | ០,៤ | ០,៣ | ០,៥ | ០,៤ | ០,៤ | ០,៥ |
| ៧១ | ០,៣ | ០,២ | ០,៣ | ០,៣ | ០,២ | ០,៣ | ០,៣ | ០,៣ | ០,៤ |
| ៧២ | ០,៣ | ០,៣ | ០,៤ | ០,៣ | ០,២ | ០,៤ | ០,៣ | ០,៣ | ០,៤ |
| ៧៣ | ០,៣ | ០,២ | ០,៣ | ០,៣ | ០,២ | ០,៣ | ០,៣ | ០,២ | ០,៣ |
| ៧៤ | ០,២ | ០,២ | ០,៣ | ០,២ | ០,២ | ០,៣ | ០,៣ | ០,២ | ០,៣ |
| **៧០-៧៤** | **១,៦** | **១,៣** | **១,៨** | **១,៤** | **១,២** | **១,៧** | **១,៦** | **១,៣** | **១,៩** |
| **៧៥+** | **២,០** | **១,៦** | **២,៤** | **១,៨** | **១,៤** | **២,១** | **២,២** | **១,៧** | **២,៦** |

រចនាសម្ព័ន្ធអាយុរបស់ប្រជាជនកម្ពុជាកំពុងឈានចូលដល់វ័យចំណាស់ ដែលប្រជាជនអាយុក្រោម ១៥ ឆ្នាំ មាន ២៩,៤ ភាគរយ និងអាយុ ៦០ ឆ្នាំឡើង មានប្រមាណ ៨,៩ ភាគរយ។ តារាងបង្ហាញអំពីមេដ្យានអាយុ ២៧ ឆ្នាំ នៅឆ្នាំ២០១៩ (តារាង ៣.៣.២)។ មេដ្យានអាយុនៃជំរឿនឆ្នាំ២០០៨ មានតែ ២២ឆ្នាំ ដូច្នេះមេដ្យានអាយុប្រជាជន មានអាយុកើនឡើង ៥ ឆ្នាំ ក្នុងរយៈពេល ១១ ឆ្នាំ។ នេះជាលទ្ធផលនៃការថយចុះអត្រានៃប្រជាជនអាយុ ០-១៤ ឆ្នាំ ចន្លោះឆ្នាំ២០០៨ និង ២០១៩ (ដោយសារការធ្លាក់ចុះចំនួនមធ្យមនៃកំណើតក្នុងស្ត្រីម្នាក់) ហើយជាមួយគ្នានេះដែរ ការកើនឡើងនៃអត្រាប្រជាជនអាយុ ១៥-៥៩ ឆ្នាំ។

ការបែងចែកតាមតំបន់ទីប្រជុំជន ជនបទ ក្រុមអាយុក្នុងកំលាំងពលកម្មនៅតំបន់ទីប្រជុំជន មានច្រើនជាង ជនបទ ចំណែកឯក្រុមអាយុវ័យក្មេង និងវ័យចាស់ មានភាគរយតិចជាងជនបទ។ ទម្រង់នេះបង្ហាញអំពីភាពខុសគ្នានៃ ការរួមបញ្ចូលគ្នានៃការធ្លាក់ចុះអត្រាលទ្ធភាពបង្កើតកូននៅតំបន់ទីប្រជុំជន និងជនបទ ជាពិសេសការធ្វើបម្លាស់ទីរបស់ប្រជាជន។

## តារាង ៣.៣.២. ការបែងចែកប្រជាជនតាមក្រុមអាយុ ផលធៀបក្នុងបន្ទុក មេដ្យានអាយុ និងផលធៀបភេទ តាមតំបន់ កម្ពុជា ២០០៨-២០១៩

| ចរិតលក្ខណៈ | ២០០៨ | | | ២០១៩ | | |
|---|---|---|---|---|---|---|
| | សរុប | ទីប្រជុំជន | ជនបទ | សរុប | ទីប្រជុំជន | ជនបទ |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) |
| សរុប | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |
| ០-១៤ | ៣៣,៧ | ២៥,៤ | ៣៥,៧ | ២៩,៤ | ២៥,៦ | ៣១,៨ |
| ១៥-៥៩ | ៦០,០ | ៦៩,១ | ៥៧,៨ | ៦១,៧ | ៦៦,២ | ៥៨,៩ |
| ៦០ + | ៦,៣ | ៥,៥ | ៦,៥ | ៨,៩ | ៨,២ | ៩,៣ |
| ផលធៀបក្នុងបន្ទុក ១៥-៥៩ | ៦៦,៨ | ៤៤,៨ | ៧៣,១ | ៦២,០ | ៥១,២ | ៦៩,៩ |
| មេដ្យានអាយុ | ២២ | ២៤ | ២១ | ២៧ | ២៨ | ២៦ |
| ផលធៀបភេទ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |

**សម្គាល់ ៖** តួលេខនេះមិនរាប់បញ្ចូលពលករចំណាកស្រុកទៅក្រៅប្រទេស

### ៣.៣.១. ផលធៀបអាយុនៅក្នុងបន្ទុក

វិធីសាស្ត្រសាមញ្ញពិពណ៌នាអំពីរចនាសម្ព័ន្ធអាយុប្រជាជនត្រូវបានគណនាដោយសន្ទស្សន៍ ហៅថាផលធៀបអាយុអ្នកនៅក្នុងបន្ទុក។ សន្ទស្សន៍នេះជាសមាមាត្រនៃប្រជាជនដែលពឹងអាស្រ័យលើផលិតភាពប្រជាជនដែលជាសកម្មជនសេដ្ឋកិច្ច។ ជាការសន្មត ចំនួនកុមារ (០-១៤ ឆ្នាំ) បូកនឹងចំនួនមនុស្សចាស់ (៦០ ឆ្នាំឡើង) ចែកនឹងចំនួនប្រជាជនអាយុស្ថិតក្នុងកម្លាំងពលកម្ម (១៥-៥៩ ឆ្នាំ) គុណនឹង ១០០។

ជាទូទៅអាយុផលធៀបអាយុក្នុងបន្ទុក (តារាង ៣.៣.២) បង្ហាញអំពីនិន្នាការធ្លាក់ចុះក្នុងអំឡុងឆ្នាំ២០០៨-២០១៩ នៃចំនួនអ្នកនៅក្នុងបន្ទុក។ ផលធៀបអាយុក្នុងបន្ទុករបស់ប្រទេសកម្ពុជានៅឆ្នាំ២០១៩ មាន ៦២។ មានន័យថាក្នុងចំណោមមនុស្ស ១០០នាក់ មានអាយុស្ថិតក្នុងកម្លាំងពលកម្មមាន ៦២នាក់ ជាប្រជាជនមានអាយុក្នុងបន្ទុកពឹងអាស្រ័យ។ ផលធៀបអាយុក្នុងបន្ទុកបានថយចុះពីជំរឿនឆ្នាំ២០០៨ ដែលមានអត្រា ៦៧ នាក់។ នៅឆ្នាំ១៩៩៨ មានអត្រា ៨៦នាក់។ អត្រាអ្នកនៅក្នុងបន្ទុកនៅទីប្រជុំជនមាន ៥១នាក់ ក្នុងចំណោមក្រុមអាយុស្ថិតក្នុងកម្លាំងពលកម្ម ១០០នាក់។ អត្រាអ្នកនៅក្នុងបន្ទុកជាទូទៅ មានអត្រាខ្ពស់នៅតំបន់ជនបទ។

### ៣.៣.២. ពីរ៉ាមីតអាយុ

រូប ៣.៣.២.១ ៣.៣.២.២ និង ៣.៣.២.៣ បានបង្ហាញពីរ៉ាមីតអាយុប្រជាជន (សរុប ទីប្រជុំជន និងជនបទ កម្ពុជា ឆ្នាំ២០០៨ និង ២០១៩) រួមនឹងភាគរយប្រុស និងស្រីតាមក្រុមអាយុ ៥ ឆ្នាំ ចាប់ផ្តើមពីក្រុមអាយុក្មេងបំផុតដែលស្ថិតនៅផ្នែកខាងក្រោម និងបន្តកំណើនអាយុទៅផ្នែកខាងលើនៃពីរ៉ាមីត។ ភាគរយនៃប្រុសបានបង្ហាញនៅខាងឆ្វេងដៃ និងភាគរយនៃស្រីបង្ហាញនៅខាងស្តាំដៃនៃពីរ៉ាមីត។ តំបន់ស្រមោលបង្ហាញពីតំណាងភាគរយប្រជាជននៃជំរឿនឆ្នាំ២០០៨ ខណៈដែលតំបន់គំនូសក្រាស់បង្ហាញពីការភាគរយប្រជាជនជំរឿនឆ្នាំ២០១៩។

ការប្រៀបធៀបពីរ៉ាមីតអាយុឆ្នាំ២០០៨ និង ២០១៩ តាមក្រុមអាយុនីមួយៗ បានបង្ហាញពីលក្ខណៈពិសេសនៃការបែងចែកអាយុ។ សមាមាត្រនៃក្រុមអាយុ ០-៤ ឆ្នាំ ទាបជាងក្រុមអាយុ ៥-៩ ឆ្នាំ ដែលជាលទ្ធផលនៃការកែលម្អស្ថានភាពសុខភាពរបស់ប្រទេស រួមជាមួយការធ្លាក់ចុះនៃលទ្ធភាពបង្កើតកូន និងមរណភាព ក្នុងអំឡុងពេលនេះ។

ពីរ៉ាមីតអាយុប្រជាជនឆ្នាំ២០១៩ បង្ហាញពីទម្រង់ទូទៅនៃការធ្លាក់ចុះនៃសមាមាត្រ ជាមួយការកើនឡើងនៃក្រុមអាយុ ។ ពីរ៉ាមីតបានបង្ហាញថា ក្រុមអាយុលើស ៣០ឆ្នាំ មានសមាមាត្រកើនឡើង លើកលែងក្រុមអាយុ ៤០-៤៤ ឆ្នាំ។ ពីរ៉ាមីតបានបង្ហាញពីការធ្លាក់ចុះនៃសមាមាត្រក្រុមអាយុ ៣០-៣៤ ឆ្នាំ នៅឆ្នាំ២០០៨ ដែល ១១ ឆ្នាំ ក្រោយមកក្នុងក្រុមអាយុ ៤០-៤៤ ឆ្នាំ បានទទួលរងផលប៉ះពាល់ដោយអត្រាលទ្ធភាពបង្កើតកូនទាប និងអត្រាមរណភាពខ្ពស់ក្នុងអំឡុងរបបខ្មែរក្រហមរវាងឆ្នាំ១៩៧៥-៧៩។

ដើមឆ្នាំ១៩៧០ ប្រទេសកម្ពុជាមានសង្គ្រាមស៊ីវិល និងនៅចុងទសវត្សរ៍ឆ្នាំ១៩៧០ ក្នុងរបបខ្មែរក្រហម ដែលប្រជាជនកម្ពុជាបានទទួលរងការសម្លាប់យ៉ាងរង្គាល។ ភាពខុសគ្នាក្នុងរចនាសម្ព័ន្ធភេទ និងអាយុលើសពី ៤០ ឆ្នាំ ក្នុងរវាងឆ្នាំ២០០៨ និងឆ្នាំ២០១៩ បានឆ្លុះបញ្ចាំងពីកម្រិតមរណភាពខ្ពស់ ជាពិសេសក្នុងចំណោមបុរសក្នុងអំឡុងពេលនោះ។

### រូប ៣.៣.២.១. ពីរ៉ាមីតអាយុប្រជាជន កម្ពុជា សរុប ឆ្នាំ២០០៨ និង ២០១៩




ពីរ៉ាមីតនៅទីប្រជុំជន ឆ្នាំ២០១៩ បង្ហាញពីការថយចុះនៃក្រុមអាយុយុវជនសម្រាប់ប្រុស ស្រី ក្នុងក្រុមអាយុ ១៥-២៩ ឆ្នាំ។ មូលហេតុចម្បងនៃនិន្នាការនេះ អាចមកពីការវិលត្រឡប់មកលំនៅដ្ឋានអចិន្ត្រៃយ៍របស់ក្រុមកម្មកររោង

ចក្រកាត់ដេរជាច្រើនពាន់នាក់នៅជនបទដែលភាគច្រើនជាក្មេងស្រី ដោយសារតែការបិទរោងចក្រកាត់ដេរមួយចំនួនក្នុងអំឡុងពេលជំរឿនចុងក្រោយ។

រូប ៣.៣.២.២. ពីរ៉ាមីតអាយុប្រជាជន កម្ពុជា ទីប្រជុំជន ២០០៨ និង ២០១៩




រូប ៣.៣.២.៣. ពីរ៉ាមីតអាយុប្រជាជន កម្ពុជា ជនបទ ២០០៨ និង ២០១៩



តាមការសង្កេតបានឲ្យដឹងថា ភាពខុសគ្នាគួរឲ្យកត់សម្គាល់រវាងពីរ៉ាមីតរចនាសម្ព័ន្ធអាយុនៅតំបន់ទីប្រជុំជន និងជនបទ ដូចក្នុងរូប ៣.៣.២.៤។ តំបន់ជនបទមានក្រុមអាយុវ័យក្មេង និងជាពិសេសក្រុមអាយុវ័យចាស់ច្រើន។ និយាយដោយឡែក នៅទីប្រជុំជនមានប្រជាជនក្នុងក្រុមអាយុកម្លាំងពលកម្មជាសកម្មជនសេដ្ឋកិច្ចច្រើន (១៥-៥៩)។ និន្នាការ នេះអាចដោយសារបំលាស់ទីរបស់ប្រជាជនពីជនបទទៅទីប្រជុំជន ដើម្បីរកការងារធ្វើនៅទីប្រជុំជន។ ពីរ៉ាមីតនៅទីប្រជុំជនរីកកណ្ដាលហើយមានលក្ខណៈរួមចង្អៀតនៅខាងចុង អាចបញ្ជាក់បានថាមានសមាមាត្រប្រជាជនក្នុងក្រុមអាយុកម្លាំងពលកម្មច្រើន និងមានក្រុមមនុស្សចាស់តិច។ ផ្ទុយមកវិញ ពីរ៉ាមីតនៅជនបទមានការរីកទូលាយនៅក្នុងក្រុមប្រជាជន វ័យក្មេង និងតូចចង្អៀតនៅក្បាលពីរ៉ាមីតមិនដូចនៅទីប្រជុំជនឡើយ។ នេះបង្ហាញយ៉ាងច្បាស់ថា តំបន់ជនបទមានប្រជាជនវ័យក្មេង និងប្រជាជនវ័យចាស់ច្រើន។ ទម្រង់នេះត្រូវបានកត់សម្គាល់នៅជំរឿនទាំងពីរ ឆ្នាំ ២០០៨ និង២០១៩។

រូប ៣.៣.២.៤. ពីរ៉ាមីតអាយុប្រជាជន កម្ពុជា ទីប្រជុំជន ជនបទ ២០១៩




## ៣.៤. សមាសភាពភេទ

សមាសភាពភេទ គឺជាសូចនាករមូលដ្ឋានចម្បងរបស់ប្រជាសាស្ត្រ មានសារៈសំខាន់សម្រាប់ការវិភាគអំពីប្រជាជន សេដ្ឋកិច្ច និងសង្គម។ ការផ្លាស់ប្ដូរសមាសភាពភេទភាគច្រើនឆ្លុះបញ្ចាំងពីទម្រង់សេដ្ឋកិច្ច វប្បធម៌ និងសង្គមតាមបែបផ្សេងៗគ្នា។

ផលធៀបភេទ ឬអត្រាភេទត្រូវកំណត់ដោយចំនួនប្រជាជនបុរសក្នុងចំណោមស្ត្រី ១០០។ បើផលធៀបភេទលើសពី ១០០ មានន័យថាចំនួនបុរសលើសចំនួនស្ត្រី ផ្ទុយមកវិញបើផលធៀបភេទតិចជាង ១០០ បញ្ជាក់ថាចំនួនស្ត្រី

មានលើសចំនួនបុរស ដែលបង្ហាញអំពីចរិតលក្ខណៈសង្គមដសំខាន់ក្នុងការវាស់វែងសមាមាត្រនៃសមធម៌ទូទៅរវាងបុរស និងស្ត្រីនៅក្នុងសង្គម និងមានឥទ្ធិពលដោយផ្ទាល់ទៅលើការស្វែងរកដៃគូអាពាហ៍ពិពាហ៍ ព្រមទាំងកម្មវិធីអភិវឌ្ឍន៍ ហើយក៏អាចប៉ះពាល់ខុសគ្នាទៅលើគុណភាពនៃជីវិតរបស់បុរស និងស្ត្រីផងដែរ។ សូចនាករនេះត្រូវបានប្រើសម្រាប់សិក្សាអំពីផលធៀបភេទរបស់ប្រជាជនកម្ពុជា (ផលធៀបភេទ)។

ព័ត៌មានមូលដ្ឋាននេះត្រូវបានប្រមូលតាមរយៈជំរឿនទាំងនៅឆ្នាំ១៩៩៨ និងឆ្នាំ២០០៨ ជំរឿននៅប្រទេសកម្ពុជាត្រូវបានបញ្ចូលពត៌មានបុរស និងស្ត្រី ហើយបានផលិតសម្រាប់ប្រធានបទស្ទើរតែទាំងអស់។ នេះគឺជាតម្រូវការមូលដ្ឋានមួយនៅក្នុងការកសាងផែនការ ដែលអាចជួយកំណត់នូវផលប៉ះពាល់យេនឌ័រ ក្នុងសកម្មភាពអភិវឌ្ឍន៍ និងជួយឆ្លើយតបដមានប្រសិទ្ធភាពចំពោះបញ្ហាយេនឌ័រ។ លទ្ធផលចុងក្រោយនៃចំនួនប្រជាជននៅក្នុងជំរឿនទូទៅប្រជាជននៅកម្ពុជាឆ្នាំ២០១៩ មានប្រជាជនចំនួន ១៥.៥៥២.២១១នាក់ ក្នុងនោះ ៤៨,៧ ភាគរយ ជាបុរស និង ៥១,៣ ភាគរយជាស្ត្រី។

ជាទូទៅ ចំនួនកំណើតបុរស និងចំនួនកំណើតស្ត្រីមិនមានសមភាពទេក្នុងបណ្តាប្រទេសទាំងអស់។ ការសិក្សាអំពីការផ្តល់កំណើតកូនបានបង្ហាញថា ចំនួនកំណើតបុរសតែងតែច្រើនជាងចំនួនកំណើតរបស់ស្ត្រី។ ផលធៀបភេទពីកំណើតប្រែប្រួលក្នុងរង្វង់ ១០២ ទៅ ១១០ នៅប្រទេសភាគច្រើន (Haupt et al., 2011)។ ផលធៀបភេទនៅកម្ពុជាដែលបានប៉ាន់ស្មាននៅពេលកើត ប្រមាណ ១០៥។

ផលធៀបភេទ ឬអត្រាភេទនៅកម្ពុជាមាន ៩៤,៩ យោងតាមលទ្ធផលចុងក្រោយជំរឿនទូទៅនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩។ ចំនួនស្ត្រីមានច្រើនជាងចំនួនបុរស ក្នុងចំណោមប្រជាជនកម្ពុជា។ នៅប្រទេសភាគច្រើនមានផលធៀបភេទស្ថិតក្នុងចន្លោះពី ៩៥ ទៅ ១០៥។ ផលធៀបភេទ ឬអត្រាភេទកម្ពុជា ហាក់ស្ថិតនៅស្ថេរតាំងពីឆ្នាំ ២០០៨។

ផលធៀបភេទនៅកម្ពុជាមានភាពខុសគ្នាពីខេត្តមួយទៅខេត្តមួយ (តារាង ៣.៤.១)។ នៅឆ្នាំ២០១៩ ខេត្តចំនួន ៨ មានផលធៀបភេទខ្ពស់លើសពី ១០០ ខេត្តទាំងនោះរួមមាន ខេត្តព្រះសីហនុ (១០៨,៦) មណ្ឌលគីរី (១០៥,០) ស្ទឹងត្រែង (១០៣,៨) ប៉ៃលិន (១០២,៩) រតនគីរី (១០២,៣) ឧត្តរមានជ័យ (១០២,០) កោះកុង និងព្រះវិហារ (១០១,៦)។ ផលធៀបភេទនៅរាជធានីភ្នំពេញមានតែ ៩៤,០។ ខេត្តដែលមានផលធៀបភេទទាបជាងគេគឺខេត្តព្រៃវែង ដោយសារបុរសពេញវ័យជាច្រើនទៅធ្វើការនៅរោងចក្រ ឬវិស័យសេដ្ឋកិច្ចផ្សេងៗ ឬផ្លាស់ប្តូរទៅកន្លែងផ្សេងនៅក្នុងប្រទេសកម្ពុជា ឬចំណាកស្រុកទៅប្រទេសជិតខាង។

## តារាង ៣.៤.១. ការបែងចែករបាយប្រជាជន តាមរាជធានី ខេត្ត កម្ពុជា ឆ្នាំ២០០៨-២០១៩

| រាជធានី ខេត្ត | ២០០៨ | | ២០១៩ | | ផលធៀបភេទ | |
|---|---|---|---|---|---|---|
| | ប្រុស | ស្រី | ប្រុស | ស្រី | ២០០៨ | ២០១៩ |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) |
| **សរុប** | **៦.៥១៦.០៥៤** | **៦.៨៧៩.៦២៨** | **៧.៥៧១.៨៣៧** | **៧.៩៨០.៣៧៤** | **៩៤,៧** | **៩៤,៩** |
| **ទីប្រជុំជន** | **១.២៥៥.៥៧០** | **១.៣៥៨.៤៥៧** | **២.៩៩៣.៣៣៩** | **៣.១៤១.៨៥៥** | **៩២,៤** | **៩៥,៣** |
| **ជនបទ** | **៥.២៦០.៤៨៤** | **៥.៥២១.១៧១** | **៤.៥៧៨.៤៩៨** | **៤.៨៣៨.៥១៩** | **៩៥,៣** | **៩៤,៦** |
| បន្ទាយមានជ័យ | ៣៣១.៧១៥ | ៣៤៦.១៥៧ | ៤២៧.៩៤៥ | ៤៣៣.៩៣៨ | ៩៥,៨ | ៩៨,៦ |
| បាត់ដំបង | ៥០៦.៣៥១ | ៥១៨.៨២៣ | ៤៩០.៤២៤ | ៥០៦.៧៤៥ | ៩៧,៦ | ៩៦,៨ |
| កំពង់ចាម | ៤៥០.៣២៩ | ៤៧៥.៦៦៣ | ៤៣១.៣២៧ | ៤៦៨.៤៦៤ | ៩៤,៧ | ៩២,១ |
| កំពង់ឆ្នាំង | ២២៧.០០៧ | ២៤៥.៣៣៤ | ២៥២.១៨៥ | ២៧៤.៨៤២ | ៩២,៥ | ៩១,៨ |
| កំពង់ស្ពឺ | ៣៤៨.៥១២ | ៣៦៨.៤៣២ | ៤២៥.១០២ | ៤៥២.៤២១ | ៩៤,៦ | ៩៤,០ |
| កំពង់ធំ | ៣០៧.៧២៤ | ៣២៣.៦៨៥ | ៣៣០.៦០២ | ៣៥០.៩៤៧ | ៩៥,១ | ៩៤,២ |
| កំពត | ២៨៤.១២៣ | ៣០១.៧២៧ | ២៨៧.៥៩០ | ៣០៦.២៣៩ | ៩៤,២ | ៩៣,៩ |
| កណ្ដាល | ៦១២.៦៩២ | ៦៥២.៥៨៨ | ៥៨១.៥៦៣ | ៦២០.០១៨ | ៩៣,៩ | ៩៣,៨ |
| កោះកុង | ៥៩.៣២៧ | ៥៨.១៥៤ | ៦៣.៤៤៤ | ៦២.៤៥៨ | ១០២,០ | ១០១,៦ |
| ក្រចេះ | ១៥៩.១៤៦ | ១៦០.០៧១ | ១៨៦.៦៥៨ | ១៨៨.០៩៧ | ៩៩,៤ | ៩៩,២ |
| មណ្ឌលគីរី | ៣១.៣៧២ | ២៩.៧៣៥ | ៤៧.២៤២ | ៤៤.៩៧១ | ១០៥,៥ | ១០៥,០ |
| ភ្នំពេញ | ៦២៥.៥៤០ | ៧០២.០៧៥ | ១.១០៥.៦៧៣ | ១.១៧៦.២៧៨ | ៨៩,១ | ៩៤,០ |
| ព្រះវិហារ | ៨៥.៣១៩ | ៨៥.៨២០ | ១២៨.៤៣៦ | ១២៦.៣៩១ | ៩៩,៤ | ១០១,៦ |
| ព្រៃវែង | ៤៥៣.០៨២ | ៤៩៤.២៩០ | ៤៩៨.៧១១ | ៥៥៩.០០៩ | ៩១,៧ | ៨៩,២ |
| ពោធិ៍សាត់ | ១៩២.៩៥៤ | ២០៤.២០៧ | ២០៤.១៧២ | ២១៥.៧៨០ | ៩៤,៥ | ៩៤,៦ |
| រតនគីរី | ៧៦.១១៥ | ៧៤.៣៥១ | ១០៩.៩៧៨ | ១០៧.៤៧៥ | ១០២,៤ | ១០២,៣ |
| សៀមរាប | ៤៣៩.៩៨២ | ៤៥៦.៤៦១ | ៤៩៧.៤៥០ | ៥១៦.៧៨៤ | ៩៦,៤ | ៩៦,៣ |
| ព្រះសីហនុ | ១១០.៧៧៧ | ១១០.៦១៩ | ១៦១.៤៦២ | ១៤៨.៦១០ | ១០០,១ | ១០៨,៦ |
| ស្ទឹងត្រែង | ៥៥.៦៣៤ | ៥៦.០៣៧ | ៨៤.៣៩៤ | ៨១.៣១៩ | ៩៩,៣ | ១០៣,៨ |
| ស្វាយរៀង | ២៣១.៥៧៨ | ២៥១.២១០ | ២៤៩.៥៨១ | ២៧៥.៩១៦ | ៩២,២ | ៩០,៥ |
| តាកែវ | ៤១០.៧៨២ | ៤៣៤.១២៤ | ៤៣១.២៦៦ | ៤៦៩.៦៤៨ | ៩៤,៦ | ៩១,៨ |
| ឧត្ដរមានជ័យ | ៩៣.៦៤៦ | ៩២.១៧៣ | ១៣៩.៣៧៨ | ១៣៦.៦៦០ | ១០១,៦ | ១០២,០ |
| កែប | ១៧.៦៧៤ | ១៨.០៧៩ | ២១.០៦៤ | ២១.៦០១ | ៩៧,៨ | ៩៧,៥ |
| ប៉ៃលិន | ៣៦.៣៤០ | ៣៤.១៤៦ | ៣៨.១០០ | ៣៧.០១២ | ១០៦,៤ | ១០២,៩ |
| ត្បូងឃ្មុំ | ៣៦៨.៣៣៣ | ៣៨៥.៦៦៧ | ៣៧៨.០៩០ | ៣៩៨.៧៥១ | ៩៥,៥ | ៩៤,៨ |

**សម្គាល់ ៖** តួលេខនេះមិនរាប់បញ្ចូលពលករចំណាកស្រុកទៅក្រៅប្រទេស

## ផែនទី ៣.៤.១. ផលធៀបភេទ តាមរាជធានី ខេត្ត កម្ពុជា ឆ្នាំ២០១៩




ផលធៀបភេទខុសគ្នាតាមក្រុមអាយុ (តារាង ២.៤.២)។ ក្នុងឆ្នាំ២០០៨ និងឆ្នាំ២០១៩ មានស្រីក្រុមអាយុ ២០-២៤ ឆ្នាំឡើង មានចំនួនច្រើន និងមានការកត់សម្គាល់នៃចំនួនប្រុសច្រើនជាងស្រីក្នុងក្រុមអាយុក្មេង។

តារាង ៣.៤.២ បង្ហាញចំនួនប្រជាជនស្រីច្រើនជាងប្រុសនៅកម្ពុជា លើកលែងតែក្រុមអាយុទាបជាង ២០ឆ្នាំ។

តារាង ៣.៤.២. ការបែងចែកផលធៀបភេទ តាមក្រុមអាយុ ភេទ កម្ពុជា ឆ្នាំ២០០៨-២០១៩

| ក្រុមអាយុ | ផលធៀបភេទ | | |
|---|---|---|---|
| | ឆ្នាំ ១៩៩៨ | ឆ្នាំ ២០០៨ | ឆ្នាំ ២០១៩ |
| (១) | (២) | (៣) | (៤) |
| **សរុប** | **៩៣,០** | **៩៤,៧** | **៩៤,៩** |
| ០ - ៤ | ១០៣,៩ | ១០៥,០ | ១០៥,៩ |
| ៥ - ៩ | ១០៤,០ | ១០៤,៧ | ១០៤,៧ |
| ១០ - ១៤ | ១០៥,៥ | ១០៦,០ | ១០៤,៧ |
| ១៥ - ១៩ | ៩៧,៧ | ១០៦,៣ | ១០១,៦ |
| ២០ - ២៤ | ៩០,៤ | ៩៥,៦ | ៩៥,០ |
| ២៥ - ២៩ | ៩២,៥ | ៩៦,៥ | ៩៥,៧ |
| ៣០ - ៣៤ | ៨៩,៧ | ៩៣,៥ | ៩៦,០ |
| ៣៥ - ៣៩ | ៨៧,៨ | ៩៣,៥ | ៩៧,៨ |
| ៤០ - ៤៤ | ៦៧,២ | ៨៧,៦ | ៩៤,៩ |
| ៤៥ - ៤៩ | ៧២,៧ | ៨៤,៣ | ៩៣,១ |
| ៥០ - ៥៤ | ៧៣,៥ | ៦៦,៥ | ៨៦,៤ |
| ៥៥ - ៥៩ | ៧៥,១ | ៧១,០ | ៨៥,៨ |
| ៦០ - ៦៤ | ៧៣,២ | ៧២,៦ | ៦៧,៩ |
| ៦៥ - ៦៩ | ៧៣,៤ | ៧១,៧ | ៦៧,៤ |
| ៧០ - ៧៤ | ៧១,៥ | ៦៧,៣ | ៦៦,៣ |
| ៧៥ + | ៦៧,៦ | ៦៣,២ | ៦២,៦ |

**សម្គាល់ ៖** តួលេខនេះមិនរាប់បញ្ចូលពលករចំណាកស្រុកទៅក្រៅប្រទេស

# ៣.៥. ស្ថានភាពអាពាហ៍ពិពាហ៍ និងអាយុមធ្យមរៀបការលើកដំបូង

## ៣.៥.១. ស្ថានភាពអាពាហ៍ពិពាហ៍

ស្ថានភាពអាពាហ៍ពិពាហ៍គឺជាកត្តាសំខាន់នៅក្នុងសក្ដានុពលរបស់ប្រជាជន ដោយសារវាមានឥទ្ធិពលដល់លទ្ធភាពបង្កើតកូន មរណភាព និងការផ្លាស់ប្ដូរលំនៅដ្ឋាន។ តារាង ៣.៥.១ ខាងក្រោមបង្ហាញពីការបែងចែកប្រជាជនប្រុស និងស្រីដែលមានអាយុចាប់ពី ១៥ ឆ្នាំឡើង តាមប្រភេទនៃស្ថានភាពអាពាហ៍ពិពាហ៍។ សំណួរស្ដីពីស្ថានភាពអាពាហ៍ពិពាហ៍នៅក្នុងជំរឿនឆ្នាំ២០១៩ ត្រូវបានបែងចែកជាក្រុមដូចជា៖ មិនដែលរៀបការ បច្ចុប្បន្នរៀបការ មេម៉ាយ/ពោះម៉ាយ លែងលះ និងទំនាស់រស់នៅផ្សេងគ្នា។ មនុស្សម្នាក់ត្រូវបានគេចាត់ទុកថាបច្ចុប្បន្នរៀបការ ប្រសិនបើតាមច្បាប់ ឬទំនៀមទម្លាប់ និងទំនៀមទម្លាប់ក្នុងស្រុកគាត់ ត្រូវបានគេទទួលស្គាល់ថាបានរៀបការ ឬរស់នៅជាមួយអ្នកដែលមានភេទផ្ទុយគ្នាជាប្ដី និងប្រពន្ធ។

ជំរឿនឆ្នាំ២០១៩ បច្ចុប្បន្នរៀបការមានសមាមាត្រខ្ពស់ជាងគេប្រមាណ ៦៦,២ ភាគរយនៃចំនួនប្រជាជនអាយុចាប់ពី ១៥ ឆ្នាំឡើង។ ប្រជាជនមិនដែលរៀបការមាន ២៧,៥ ភាគរយនៃប្រជាជនអាយុចាប់ពី ១៥ ឆ្នាំឡើង។ សមាមាត្រស្ត្រីមេម៉ាយមានប្រមាណ ៦,៣ ភាគរយ។ ទោះជាយ៉ាងណាក៏ដោយ ស្ត្រីមេម៉ាយ លែងលះគ្នា និងទំនាស់

រស់នៅផ្សេងគ្នាមានចំនួនច្រើនជាងបុរស។ ជាលទ្ធផលបុរសមានអត្រាស្លាប់ខ្ពស់ជាងស្ត្រី។ លើសពីនេះទៀតបានបញ្ជាក់ថាបុរសមានទំនោរក្នុងការរៀបការម្តងទៀតច្រើនជាងស្ត្រី ដោយសារកណីមួយចំនួនដូចជាបុរសពឹងផ្អែកលើស្ត្រីចំពោះការទទួលខុសត្រូវក្នុងគ្រួសារ ហើយបាតុភូតនេះស្ទើរតែមានគ្រប់ប្រទេសទាំងអស់នៅលើពិភពលោក។

### តារាង ៣.៥.១. ប្រជាជនអាយុ ១៥ ឆ្នាំឡើង តាមស្ថានភាពអាពាហ៍ពិពាហ៍ ភេទ និងតំបន់ កម្ពុជា ឆ្នាំ២០០៨- ២០១៩

| ស្ថានភាពអាពាហ៍ពិពាហហ៍ | ឆ្នាំ | | | | | |
|---|---|---|---|---|---|---|
| | ២០០៨ | | | ២០១៩ | | |
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) |
| **ចំនួន** | | | | | | |
| **សរុប** | ៨.៨៨១.៨៩០ | ៤.២០១.២៤៨ | ៤.៦៨០.៦៤២ | ១០.៩៧៧.៩១២ | ៥.២២៧.៨៩៩ | ៥.៧៥០.០១៣ |
| មិនដែលរៀបការ | ២.៩០៥.២៧៦ | ១.៥៥៤.៥១៤ | ១.៣៥០.៧៦២ | ៣.០១៧.៨១៦ | ១.៦២៩.២២៧ | ១.៣៨៨.៥៨៩ |
| បានរៀបការហើយ | ៥.៣៤៣.៧០៦ | ២.៥៥៤.៦៤៤ | ២.៧៨៩.០៦២ | ៧.២៦៦.០៣៦ | ៣.៤៤៧.៤១៣ | ៣.៨១៨.៦២៣ |
| មេម៉ាយ/ពោះម៉ាយ | ៤៤៣.៥៦៨ | ៥៤.១៧៧ | ៣៨៩.៣៩១ | ៤៤១.១៨៣ | ៧៩.៣៤៧ | ៣៦១.៨៣៦ |
| លែងលះ | ១៧៩.០១៦ | ៣៥.១៧៨ | ១៤៣.៨៣៨ | ២៣៨.២៦១ | ៦៦.៣៥២ | ១៧១.៩០៩ |
| ទំនាស់រស់នៅផ្សេងគ្នា | ១០.៣២៤ | ២.៧៣៥ | ៧.៥៨៩ | ១៤.៦១៦ | ៥.៥៦០ | ៩.០៥៦ |
| **ទីប្រជុំជន** | ១.៩៤៩.៦៧៦ | ៩១៥.៨១៤ | ១.០៣៣.៨៦២ | ៤.៥៦១.២៤០ | ២.១៨៧.១២៧ | ២.៣៧៤.១១៣ |
| មិនដែលរៀបការ | ៨០៩.៨៩៥ | ៤១០.១៥១ | ៣៩៩.៧៤៤ | ១.៤១៧.១៩៧ | ៧៥០.៤១២ | ៦៦៦.៧៨៥ |
| បានរៀបកាហើយ | ១.០២១.៣០១ | ៤៨៨.៨៦៧ | ៥៣២.៤៣៤ | ២.៨៥០.២២២ | ១.៣៦២.២១៧ | ១.៤៨៨.០០៥ |
| មេម៉ាយ/ពោះម៉ាយ | ៧៩.១៥៧ | ៨.៧២៥ | ៧០.៤៣២ | ១៧០.៦៤៩ | ៣៥.៦៧១ | ១៣៤.៩៧៨ |
| លែងលះ | ៣៦.៧៩៧ | ៧.៣៣៥ | ២៩.៤៦២ | ១១៤.៧៥០ | ៣៥.៣៣០ | ៧៩.៤២០ |
| ទំនាស់រស់នៅផ្សេងគ្នា | ២.៥២៦ | ៧៣៦ | ១.៧៩០ | ៨.៤២២ | ៣.៤៩៧ | ៤.៩២៥ |
| **ជនបទ** | ៦.៩៣២.២១៤ | ៣.២៨៥.៤៣៤ | ៣.៦៤៦.៧៨០ | ៦.៤១៦.៦៧២ | ៣.០៤០.៧៧២ | ៣.៣៧៥.៩០០ |
| មិនដែលរៀបការ | ២.០៩៥.៣៨១ | ១.១៤៤.៣៦៣ | ៩៥១.០១៨ | ១.៦០០.៦១៩ | ៨៧៨.៨១៥ | ៧២១.៨០៤ |
| បានរៀបការហើយ | ៤.៣២២.៤០៥ | ២.០៦៥.៧៧៧ | ២.២៥៦.៦២៨ | ៤.៤១៥.៨១៤ | ២.០៨៥.១៩៦ | ២.៣៣០.៦១៨ |
| មេម៉ាយ/ពោះម៉ាយ | ៣៦៤.៤១១ | ៤៥.៤៥២ | ៣១៨.៩៥៩ | ២៧០.៥៣៤ | ៤៣.៦៧៦ | ២២៦.៨៥៨ |
| លែងលះ | ១៤២.២១៩ | ២៧.៨៤៣ | ១១៤.៣៧៦ | ១២៣.៥១១ | ៣១.០២២ | ៩២.៤៨៩ |
| ទំនាស់រស់នៅផ្សេងគ្នា | ៧.៧៩៨ | ១.៩៩៩ | ៥.៧៩៩ | ៦.១៩៤ | ២.០៦៣ | ៤.១៣១ |
| **ភាគរយ** | | | | | | |
| **សរុប** | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |
| មិនដែលរៀបការ | ៣២,៧ | ៣៧,០ | ២៨,៩ | ២៧,៥ | ៣១,២ | ២៤,១ |
| បានរៀបការហើយ | ៦០,២ | ៦០,៨ | ៥៩,៦ | ៦៦,២ | ៦៥,៩ | ៦៦,៤ |
| មេម៉ាយ/ពោះម៉ាយ | ៥,០ | ១,៣ | ៨,៣ | ៤,០ | ១,៥ | ៦,៣ |
| លែងលះ | ២,០ | ០,៨ | ៣,១ | ២,២ | ១,៣ | ៣,០ |
| ទំនាស់រស់នៅផ្សេងគ្នា | ០,១ | ០,១ | ០,២ | ០,១ | ០,១ | ០,២ |
| **ទីប្រជុំជន** | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |
| មិនដែលរៀបការ | ៤១,៥ | ៤៤,៨ | ៣៨,៧ | ៣១,១ | ៣៤,៣ | ២៨,១ |
| បានរៀបការហើយ | ៥២,៤ | ៥៣,៤ | ៥១,៥ | ៦២,៥ | ៦២,៣ | ៦២,៧ |
| មេម៉ាយ/ពោះម៉ាយ | ៤,១ | ១,០ | ៦,៨ | ៣,៧ | ១,៦ | ៥,៧ |
| លែងលះ | ១,៩ | ០,៨ | ២,៨ | ២,៥ | ១,៦ | ៣,៣ |

| ស្ថានភាពអាពាហ៍ពិពាហ៍ | ឆ្នាំ | | | | | |
|---|---|---|---|---|---|---|
| | ២០០៨ | | | ២០១៩ | | |
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) |
| ទំនាស់រស់នៅផ្សេងគ្នា | ០,១ | ០,១ | ០,២ | ០,២ | ០,២ | ០,២ |
| **ជនបទ** | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |
| មិនដែលរៀបការ | ៣០,២ | ៣៤,៨ | ២៦,១ | ២៤,៩ | ២៨,៩ | ២១,៤ |
| បានរៀបការហើយ | ៦២,៤ | ៦២,៩ | ៦១,៩ | ៦៨,៨ | ៦៨,៦ | ៦៩,០ |
| មេម៉ាយ/ពោះម៉ាយ | ៥,៣ | ១,៤ | ៨,៧ | ៤,២ | ១,៤ | ៦,៧ |
| លែងលះ | ២,១ | ០,៨ | ៣,១ | ១,៩ | ១,០ | ២,៧ |
| ទំនាស់រស់នៅផ្សេងគ្នា | ០,១ | ០,១ | ០,២ | ០,១ | ០,១ | ០,១ |

***សម្គាល់៖*** *គណនាដោយមិនរាប់បញ្ចូលស្ថានភាពអាពាហ៍ពិពាហ៍ដែលមិនបានរាយការណ៍*

រូប ៣.៥.១ បង្ហាញថាមិនដែលរៀបការ ឬនៅលីវក្នុងក្រុមអាយុ ១៥-១៩ ឆ្នាំ ប្រុសមាន ៩៨,២ និងស្រីមាន ៩១,៥ ភាគរយ។ ក្នុងក្រុមអាយុ ៣០-៣៤ ឆ្នាំ អត្រាមិនដែលរៀបការ ឬនៅលីវប្រុសបានថយចុះមកប្រមាណ ១៧,៩ ភាគរយ ធៀបជាមួយស្រី ១២,២ ភាគរយ។ ប្រជាជនដែលមានអាយុលើស ៥០ ឆ្នាំ មិនដែលរៀបការ មានភាគច្រើនមិនដែលរៀបការក្នុងជីវិតរបស់គាត់។ ស្រីមិនដែលរៀបការ ឬនៅលីវមានច្រើនជាងប្រុសនៅពេលមានអាយុកាន់តែច្រើន។ ទោះជាយ៉ាងណាក៏ដោយ អត្រារបស់ស្ត្រីមិនដែលរៀបការ ឬនៅលីវបានធ្លាក់ចុះខ្លាំងនៅក្នុងអាយុ ២០ ឆ្នាំ។ អត្រាបុរសមិនដែលរៀបការ ឬនៅលីវមានខ្ពស់ជាងអត្រាស្ត្រីមិនដែលរៀបការ ឬនៅលីវ នៅគ្រប់ក្រុមអាយុក្រោម ៣០ ឆ្នាំ។ ចាប់ពីក្រុមអាយុ ៣០-៣៤ ឆ្នាំ អត្រាទាបស្រាប់របស់បុរសនៅលីវគ្រប់ក្រុមអាយុ មានទាបជាងអត្រារបស់ស្ត្រី ទាំងឆ្នាំ ២០០៨ និងឆ្នាំ២០១៩។

## រូប ៣.៥.១. ភាគរយមិនទាន់រៀបការអាយុ១៥ ឆ្នាំឡើង តាមភេទ ឆ្នាំ២០០៨-២០១៩




ជាទូទៅ អាយុបានរៀបអាពាហ៍ពិពាហ៍របស់បុរសខ្ពស់។ បុរសស្ទើរតែទាំងអស់បានរៀបការយ៉ាងតិចម្តងក្នុងមួយជីវិតរបស់ពួកគេ។ ក្រុមអាយុ ៥០-៥៤ ឆ្នាំ បុរសតែមួយភាគរយដែលមិនបានរៀបការ ខណៈដែលស្ត្រីស្ថិតក្នុង

ក្រុមអាយុដូចគ្នាមានដល់ទៅ ៥ ភាគរយ។ ស្ត្រីភាគច្រើនអាចរៀបការមុនបុរស។ សមាមាត្ររៀបការរបស់ស្ត្រីខ្ពស់ជាងបុរស ក្នុងគ្រប់ក្រុមអាយុក្រោម ៣០-៣៤ ឆ្នាំ ។ នៅក្រុមអាយុ ៣០-៣៤ ឆ្នាំ របត់មួយបានបង្ហាញភាពខុសគ្នារវាងសមាមាត្ររបស់ប្រុស និងស្រី។ បន្ទាប់ពីក្រុមអាយុនេះ បុរសមានសមាមាត្រខ្ពស់ជាងស្ត្រី ដែលបានរៀបការ ហើយគំលាតនៃសមាមាត្រនេះកាន់តែធំ។

## រូប ៣.៥.២. ភាគរយបច្ចុប្បន្នរៀបការអាយុ១៥ ឆ្នាំឡើង តាមភេទ ឆ្នាំ២០០៨-២០១៩




អត្រាមេម៉ាយ ឬពោះម៉ាយមានលក្ខណៈវិជ្ជមានទៅនឹងអាយុ ជាមួយអត្រាកើនឡើងបន្តិចនៅពេលអាយុកើនឡើង។ អត្រាមេម៉ាយ ឬពោះម៉ាយ លែងលះគ្នា និងរស់នៅផ្សេងគ្នាមានប្រមាណ ៦,៣ ភាគរយ ក្នុងចំណោមប្រជាជនពេញវ័យអាយុ ១៥ ឆ្នាំឡើង បុរសមាន ២,៩ ភាគរយ ធៀបនឹងស្ត្រី ៩,៤ ភាគរយ។ ដោយឡែកសមាមាត្រមេម៉ាយ ឬពោះម៉ាយ/រស់នៅផ្សេងគ្នា ក្នុងចំណោមប្រជាជនអាយុ ៦០ ឡើង សមាមាត្រនៃស្ត្រីមេម៉ាយមានច្រើនជាង ៣ ដងនៃសមាមាត្របុរសពោះម៉ាយក្នុងវ័យនេះ (៣២,៩ ភាគរយ និង ៩,៤ ភាគរយ តាមលំដាប់រៀង)។ មូលហេតុនៃការខុសគ្នានេះជាទូទៅ បណ្តាលមកពីមរណភាពខ្ពស់របស់បុរសនៅក្នុងរបបខ្មែរក្រហម រួមជាមួយការរៀបការជាលើកទីពីររបស់បុរសពោះម៉ាយ។

### រូប ៣.៥.៣. ភាគរយមេម៉ាយ ឬពោះម៉ាយ លែងលះគ្នា និងរស់នៅផ្សេងគ្នាអាយុ១៥ ឆ្នាំឡើង តាមភេទ ឆ្នាំ២០០៨-២០១៩




## ៣.៥.២. អាយុរៀបការលើកដំបូង

សំណួរដោយផ្ទាល់ពីអាយុរៀបការលើកដំបូងត្រូវបានស្រង់នៅក្នុងជំរឿន២០១៩ផងដែរ ប៉ុន្តែសំណួររំលឹកឡើងវិញពីអាពាហ៍ពិពាហ៍មានការខុសគ្នាខ្លាំងធៀបនឹងការគណនាដោយប្រយោល ដូច្នេះអាយុរៀបការមធ្យមត្រូវបានប៉ាន់ស្មានដោយវិធីសាស្ត្រប្រយោលពីទិន្នន័យស្ថានភាពអាពាហ៍ពិពាហ៍តាមអាយុ។ អាយុមធ្យមរៀបការលើកទីមួយ SMAM (Hajnal ឆ្នាំ១៩៥៣ ) គឺជាការប៉ាន់ស្មានអាយុមធ្យមដែលបានរស់នៅក្នុងក្រុមរបស់ស្ត្រី ឬបុរសមុនពេលពួកគេរៀបការជាលើកដំបូង។

អាយុរៀបការដំបូង (SMAM) ត្រូវបានទាញយកពីសមាមាត្ររបស់ប្រជាជនមិនទាន់រៀបការក្នុងក្រុមអាយុនីមួយៗបន្តគ្នា។ ការសន្មតទាក់ទងនឹងការគណនានេះ គឺការប្តូរក្នុងសមាមាត្រមិនទាន់រៀបការពីអាយុ X ទៅ X+1 ជារង្វាស់សមាមាត្រកំណើតក្នុងក្រុមបានរៀបការនៅអាយុ X ។ វិធីសាស្ត្រនេះអាចគណនាអាយុរៀបការជាមធ្យមរបស់ប្រជាជន (បុរស ឬស្ត្រី) អាយុ ១៥ ឆ្នាំឡើង មុនពេលពួកគេដល់អាយុ ៥០ ឆ្នាំ។ បន្ថែមពីនេះទៀត វាក៏បានផ្តល់ការប៉ាន់ស្មានអាយុមធ្យមរបស់ប្រជាជនមិនដែលបានរៀបការ បានរៀបការមុនអាយុ ៥០ ឆ្នាំផងដែរ។

ទោះជាយ៉ាងណាក៏ដោយ អាយុមធ្យមរៀបការលើកទីមួយនៅកម្ពុជា SMAM បានគណនាឃើញ ២៧,០ សម្រាប់បុរស និង ២៤,០ សម្រាប់ស្ត្រី ដោយផ្អែកលើការបែងចែកអាយុក្នុងជំរឿនឆ្នាំ២០១៩ របស់ប្រជាជនមិនដែលរៀបការនៅកម្ពុជា។ អាយុមធ្យមរៀបការលើកទីមួយ តាម SMAM បុរសខ្ពស់ជាងស្ត្រី។ សមាមាត្រស្ត្រីរៀបការនៅវ័យក្មេងខ្ពស់ជាង បើប្រៀបធៀបនឹងបុរសក្នុងក្រុមអាយុដូចគ្នា ដែលបង្ហាញជាទូទៅស្ត្រីរៀបការនៅវ័យក្មេងជាងបុរស (តារាង ៣.៥.២)។ បើប្រៀបធៀបនឹងឆ្នាំ២០០៨ អាយុជាមធ្យមនៃអាពាហ៍ពិពាហ៍បានកើនឡើង ១,៤ ឆ្នាំ និង ០,៧ ឆ្នាំ សម្រាប់បុរស និងស្ត្រី តាមលំដាប់រៀង។

ភាពខុសគ្នាទីប្រជុំជន និងជនបទ បានសង្កេតឃើញក្នុង SMAM។ សម្រាប់ទាំងបុរស និងស្ត្រី SMAM នៅតំបន់ទីប្រជុំជនខ្ពស់ជាងនៅតំបន់ជនបទ។ នៅឆ្នាំ២០១៩ SMAM ក្នុងចំណោមបុរសនៅទីប្រជុំជនមានអត្រាខ្ពស់ជាងបុរសនៅជនបទ ២,១ ឆ្នាំ។ ភាពខុសគ្នានេះ ក្នុងចំណោមស្ត្រីនៅទីប្រជុំជន និងស្ត្រីនៅជនបទមាន ២,៣ ឆ្នាំ។ បុរសនៅទីប្រជុំជនហាក់ដូចជាមាននិន្នាការរៀបការយឺតជាងបុរសនៅជនបទ។

### តារាង ៣.៥.២. អាយុមធ្យមរៀបការលើកទីមួយ តាមភេទ និងតំបន់ កម្ពុជា ឆ្នាំ ២០០៨ និង ២០១៩

| តំបន់ | ឆ្នាំ ២០០៨ | | | ឆ្នាំ ២០១៩ | | |
|---|---|---|---|---|---|---|
| | ប្រុស | ស្រី | គំលាតអាយុរៀបការដំបូង | ប្រុស | ស្រី | គំលាតអាយុរៀបការដំបូង |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) |
| សរុប | ២៥,៦ | ២៣,៣ | ២,៣ | ២៧,០ | ២៤,០ | ៣,០ |
| ទីប្រជុំជន | ២៨,០ | ២៥,៥ | ២,៥ | ២៨,១ | ២៥,០ | ៣,១ |
| ជនបទ | ២៤,៨ | ២២,៥ | ២,៣ | ២៦,០ | ២២,៧ | ៣,៣ |

## ៣.៦. អាយុរៀបការយុវវ័យ

សមាមាត្រអាយុរៀបការរបស់យុវវ័យក្នុងចំណោមប្រុស និងស្រីស្ទើរតែដូចគ្នាទាំងឆ្នាំ២០០៨ និង ២០១៩ នៅថ្នាក់ជាតិ។ ទោះជាយ៉ាងណាក៏ដោយ នៅតំបន់ទីប្រជុំជនបានធ្លាក់ចុះបន្តិច ហើយបានកើនឡើងបន្តិចនៅតំបន់ជនបទ។ សម្រាប់ប្រុស និងស្រី សមាមាត្ររៀបការនៅយុវវ័យអាយុពី ១៥-១៩ ឆ្នាំ នៅជនបទ ខ្ពស់ជាងនៅតំបន់ទីប្រជុំជន (តារាង ៣.៦.១)។ សមាមាត្រដែលបានរៀបការក្នុងចំណោមស្រីអាយុពី ២០-២៤ ឆ្នាំ នៅជនបទមានពីរដងបើប្រៀបធៀបនឹងតំបន់ទីប្រជុំជន។

### តារាង ៣.៦.១. អាយុមធ្យមរៀបការដំបូង សមាមាត្រធ្លាប់រៀបការ តាមភេទ អាយុ និងតំបន់ កម្ពុជា ឆ្នាំ ២០០៨ -២០១៩

| តំបន់ | ប្រុស | | | | ស្រី | | | | អាយុមធ្យមរៀបការដំបូង ប្រុស និងស្រី |
|---|---|---|---|---|---|---|---|---|---|
| | អាយុមធ្យមរៀបការដំបូង | ភាគរយអ្នកធ្លាប់រៀបការ | | | អាយុមធ្យមរៀបការដំបូង | ភាគរយអ្នកធ្លាប់រៀបការ | | | |
| | | ១៥–១៩ | ២០-២៤ | ៤៥-៤៩ | | ១៥–១៩ | ២០-២៤ | ៤៥-៤៩ | |
| ២០០៨ | | | | | | | | | |
| សរុប | ២៥,៦ | ១,៧ | ២៨,៥ | ៦៨,០ | ២៣,៣ | ៨,៤ | ៤៨,៨ | ៧៤,៤ | ២,៣ |
| ទីប្រជុំជន | ២៨,០ | ១,១ | ១៥,៥ | ៤៩,៣ | ២៥,៥ | ៥,០ | ៣០,៨ | ៦១,៨ | ២,៥ |
| ជនបទ | ២៤,៨ | ១,៨ | ៣៣,១ | ៧៤,៣ | ២២,៥ | ៩,៤ | ៥៥,៩ | ៧៨,៨ | ២,៣ |
| ២០១៩ | | | | | | | | | |
| សរុប | ២៧,០ | ១,៨ | ២៦,២ | ៩៣,៣ | ២៤,០ | ៨,២ | ៤៨,១ | ៨៤,៨ | ៣,០ |
| ទីប្រជុំជន | ២៨,១ | ១,៥ | ២២,០ | ៨៨,៩ | ២៥,០ | ៦,៣ | ៣៩,៦ | ៨០,៧ | ៣,១ |
| ជនបទ | ២៦,០ | ២,០ | ២៩,៧ | ៩៦,១ | ២២,៧ | ៩,៥ | ៥៥,៣ | ៨៧,៣ | ៣,៣ |

# ជំពូក ៤
# អក្ខរភាព និងការអប់រំ

## ៤.១. ទស្សនទាន

ការអប់រំមានសារៈសំខាន់សម្រាប់បុគ្គល និងជាធនធានសម្រាប់អភិវឌ្ឍជាតិ។ ការអប់រំជាសិទ្ធិពីកំណើតរបស់បុគ្គលម្នាក់ៗ។ ការអប់រំជាការអភិវឌ្ឍសមត្ថភាពមនុស្សជាតិ ដើម្បីលប់បំបាត់វិសមភាពក្នុងសេដ្ឋកិច្ច សង្គម វប្បធម៌ គ្រួសារ/បុគ្គល ច្បាប់ នយោបាយ និងចិត្តវិទ្យា។ ការអប់រំគឺជាប្រទីបនាំផ្លូវ ដើម្បីឲ្យមានសមត្ថភាពស្វែងរកការងារធ្វើ និងមានសិទ្ធិក្នុងការសម្រេចចិត្តបានត្រឹមត្រូវ។ ការអប់រំមានឥទ្ធិពលលើចរិតលក្ខណៈប្រជាសាស្ត្រទាក់ទងនឹងការរៀបការ លទ្ធភាពបង្កើតកូន មរណភាព ការផ្លាស់ប្តូរលំនៅដ្ឋាន និងទាំងការចូលរួមក្នុងកម្លាំងពលកម្ម។ ការសិក្សាស្រាវជ្រាវជាច្រើនបានបង្ហាញថា ការអប់រំមានទំនាក់ទំនងជាអវិជ្ជមានរវាងកម្រិតអប់រំរបស់ស្ត្រី និងលទ្ធភាពបង្កើតកូន។ អាយុស្ត្រីនៅពេលរៀបការត្រូវបានទទួលឥទ្ធិពលពីការទទួលបានកម្រិតចូលសិក្សាអប់រំ។ មរណភាពទារកគឺនៅតែជាអថេរទទួលឥទ្ធពលពីស្ថានភាពអប់រំរបស់ម្តាយ។ ជាទូទៅ ការទទួលបានការសិក្សាអប់រំ បានប្រាប់ឲ្យដឹងអំពីគុណភាពនៃប្រជាជនចេះអក្សរ ហើយមានសារៈសំខាន់ណាស់ក្នុងការប្រតិបត្តិកម្មវិធីអភិវឌ្ឍន៍ និងគោលនយោបាយប្រជាជន។

ការអប់រំជាអាទិភាពយ៉ាងសំខាន់ក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (CSDGs)។ ពួកគេស្ថិតក្នុងស្ថានភាពជប្រសើរមួយ ដើម្បីបង្កើតការងារដោយខ្លួនឯង និងសម្រាប់អ្នកដទៃ ដើម្បីទទួលបានការងារជាផ្លូវការផងដែរ។ ការអប់រំត្រូវចាប់ផ្តើមជាចាំបាច់ក្នុងការអភិវឌ្ឍចក្ខុវិស័យនៃផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ ឆ្នាំ២០១៩-២០២៣។ ដើម្បីកំណត់កម្រិតសិក្សា ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ បានសួរសំណួរអំពីការចូលរៀននៅសាលា និងកម្រិតថ្នាក់ខ្ពស់ចុងក្រោយដែលបានសិក្សា។ សំណួរនេះត្រូវបានសួរគ្រប់មនុស្សទាំងអស់ដែលមានអាយុ ៦ ឆ្នាំឡើង។ សំណួរអំពីអក្ខរភាព និងការសិក្សា ជាផ្នែកសំខាន់មួយនៃកម្រងសំណួរ ទាំងនៅក្នុងជំរឿនឆ្នាំ២០០៨ និងជំរឿនឆ្នាំ២០១៩។

ដើម្បីទទួលបានទិន្នន័យពេញលេញអំពីការសិក្សាពេញលេញរបស់ប្រជាជន សំណួរចំនួន ៦ ត្រូវបានសួរនៅក្នុងជំរឿន២០១៩ ដើម្បីប្រមូលព័ត៌មានអំពីអក្ខរភាព និងការសិក្សាពេញម៉ោង។ សំណួរទាក់ទងនឹងអក្ខរភាពភាសាខ្មែរ អក្ខរភាពភាសាដទៃទៀត ការចូលរៀនសាលា ថ្នាក់កំពុងរៀនបច្ចុប្បន្ន ថ្នាក់បានបញ្ចប់ខ្ពស់បំផុត និងមុខវិជ្ជាចម្បងដែលបានសិក្សា។ គ្រប់សំណួរទាំងអស់ លើកលែងតែកម្រិតកំពុងសិក្សា និងមុខវិជ្ជាចម្បងដែលបានសិក្សាត្រូវបានសួរនៅក្នុងជំរឿនឆ្នាំ២០០៨ ផងដែរ។ សំណួរថ្មីពីរដែលបានដាក់បញ្ចូលក្នុងជំរឿន ឆ្នាំ២០១៩ មានបំណងដើម្បីបំពេញតម្រូវការរបស់ប្រព័ន្ធអប់រំជាតិ។

អក្ខរភាពគឺជាសមត្ថភាពក្នុងការអាន និងសរសេរ ដោយមានការយល់ដឹងជាភាសាណាមួយ។ មនុស្សម្នាក់អាចអានសរសេរភាសាសាមញ្ញត្រូវចាត់ទុកថាជាអក្ខរជន ហើយមនុស្សម្នាក់ដែលមិនអាចអាន និងសរសេរពាក្យសាមញ្ញត្រូវបានគេចាត់ទុកថាអនក្ខរជន។ មនុស្សត្រូវបានចាត់ទុកថាមិនចេះអក្សរផងដែរ ប្រសិនបើមនុស្សនោះមានសមត្ថភាពអាន

សរសេរតែឈ្មោះ ឬលេខផ្ទាល់ខ្លួនក៏ដូចជាមនុស្សដែលចេះអានតែមិនចេះសរសេរ ឬក៏ផ្ទុយមកវិញ។ អត្រាអក្ខរភាព គឺជាសូចនាករសំខាន់នៃលទ្ធផលអប់រំ និងត្រូវបានកំណត់ជាភាគរយអក្ខរភាពក្នុងចំណោមប្រជាជនតាមក្រុមអាយុដែលបានកំណត់។ ក្នុងជំរឿនឆ្នាំ២០០៨ និង ២០១៩ កុមារអាយុក្រោម ៦ ឆ្នាំ ត្រូវបានកំណត់ថាជាអនក្ខរជន បើទោះជាពួកគេបានចូលរៀន ឬក៏អាចអាន និងសរសេរពាក្យខ្លះក្នុងភាសាណាមួយក៏ដោយ។

## ៤.២. កម្រិតអក្ខរភាព

លទ្ធផលចុងក្រោយជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ ក្នុងតារាង ៤.២.១ បង្ហាញថា អត្រាអក្ខរភាពសម្រាប់ភាសាណាមួយក្នុងចំណោមប្រជាជនកម្ពុជា អាយុ ៧ ឆ្នាំឡើង បានកើនឡើងពី ៧៨,៤ ភាគរយ នៅឆ្នាំ២០០៨ ទៅ ៨៨,៥ នៅឆ្នាំ២០១៩។ ក្នុងរយៈពេល ១១ ឆ្នាំ អត្រាអក្ខរភាពរបស់ស្ត្រីបានកើនឡើងប្រមាណ ១៣,១ ភាគរយ បើធៀបទៅនឹងការកើនឡើងប្រមាណ ៧,១ ភាគរយ សម្រាប់បុរស។ ទោះជាយ៉ាងណាក៏ដោយ គំលាតដ៏ធំរវាងអក្ខរភាពបុរស និងស្ត្រី (៩១,១ ភាគរយ សម្រាប់បុរស និង ៨៦,២ ភាគរយ សម្រាប់ស្ត្រីក្នុងឆ្នាំ២០១៩) ខ្ពស់នៅជនបទ។ ជាទូទៅ វិសមភាពរវាងបុរស និងស្ត្រី លើការអប់រំជាមូលដ្ឋាន គឺជាបញ្ហាចម្បងមួយរបស់រាជរដ្ឋាភិបាលដែលត្រូវពិចារណាជាបន្ទាន់។

រូប ៤.២.១.ភាគរយអក្ខរភាពអាយុ ៧ឆ្នាំឡើង តាមភេទ កម្ពុជា ឆ្នាំ២០០៨-២០១៩




អត្រាអក្ខរភាពភាសាណាមួយ នៅទីប្រជុំជនខ្ពស់ជាងនៅជនបទ ដោយសារកម្រិតនៃការអភិវឌ្ឍរវាងតំបន់ទាំងពីរ។ ទោះជាយ៉ាងណាក៏ដោយ បច្ចុប្បន្ននេះ ដោយសារគោលនយោបាយសម្រាប់ការអប់រំសកល និងការលុបបំបាត់អនក្ខរភាព គំលាតក្នុងអត្រាចេះអាន និងសរសេររវាងតំបន់ទីប្រជុំជន និងជនបទ បានថយចុះទាបជាបណ្តើរៗមានតែ ៧,៩ ភាគរយ (៩៣,៣ ភាគរយ នៅតំបន់ទីប្រជុំជន និង ៨៥,៤ ភាគរយ នៅជនបទ នៅឆ្នាំ២០១៩) ដូចគ្នានេះដែរ គំលាតមានចំនួន ១៤,៩ ភាគរយ នៅឆ្នាំ២០០៨។

### តារាង ៤.២.១. ភាគរយអក្ខរភាពអាយុ ៧ ឆ្នាំឡើង តាមភាសា ភេទ និងតំបន់ កម្ពុជា ឆ្នាំ២០០៨ -២០១៩

| តំបន់ | ប្រជាជនអាយុ ៧ ឆ្នាំឡើង | ចំនួនអក្ខរភាព | | ភាគរយអក្ខរភាព | |
|---|---|---|---|---|---|
| | | ភាសាណាមួយ | តែភាសាខ្មែរ | ភាសាណាមួយ | តែភាសាខ្មែរ |
| (១) | (២) | (៣) | (៤) | (៥) | (៧) |
| **២០០៨** | | | | | |
| **សរុប** | ១១.៤៣៤.៩៤៦ | ៨.៩៥៩.៣៨៣ | ៨.២៤៣.២៤៤ | ៧៨,៤ | ៧២,១ |
| ប្រុស | ៥.៥១២.៣៨៨ | ៤.៦២៩.៧០២ | ៤.២១៣.៣៨០ | ៨៤,០ | ៧៦,៤ |
| ស្រី | ៥.៩២២.៥៥៨ | ៤.៣២៩.៦៨១ | ៤.០២៩.៨៦៤ | ៧៣,១ | ៦៨,០ |
| **ទីប្រជុំជន** | ២.៣២៥.១៩៨ | ២.០៩៦.៦៤១ | ១.៦៤៥.២៩២ | ៩០,២ | ៧០,៨ |
| ប្រុស | ១.១០៧.៦០២ | ១.០៣៥.២០៨ | ៧៧៦.៧៧៤ | ៩៣,៥ | ៧០,១ |
| ស្រី | ១.២១៧.៥៩៦ | ១.០៦១.៤៣៣ | ៨៦៨.៥១៨ | ៨៧,២ | ៧១,៣ |
| **ជនបទ** | ៩.១០៩.៧៤៨ | ៦.៨៦២.៧៤២ | ៦.៥៩៧.៩៥២ | ៧៥,៣ | ៧២,៤ |
| ប្រុស | ៤.៤០៤.៧៨៦ | ៣.៥៩៤.៤៩៤ | ៣.៤៣៦.៦០៦ | ៨១,៦ | ៧៨,០ |
| ស្រី | ៤.៧០៤.៩៦២ | ៣.២៦៨.២៤៨ | ៣.១៦១.៣៤៦ | ៦៩,៥ | ៦៧,២ |
| **២០១៩** | | | | | |
| **សរុប** | ១៣.៤៨៧.៥៩១ | ១១.៩៤០.៨៣១ | ១០.៨៤៩.៩៩៩ | ៨៨,៥ | ៨០,៤ |
| ប្រុស | ៦.៥១០.៧០៥ | ៥.៩២៨.៧៦២ | ៥.៣៥០.៤៩៤ | ៩១,១ | ៨២,២ |
| ស្រី | ៦.៩៧៦.៨៨៦ | ៦.០១២.០៦៩ | ៥.៤៩៩.៥០៥ | ៨៦,២ | ៧៨,៨ |
| **ទីប្រជុំជន** | ៥.៤០៦.៥៦៧ | ៥.០៤៣.៤៥៦ | ៤.៣២២.៩៣១ | ៩៣,៣ | ៨០,០ |
| ប្រុស | ២.៦១៨.៧៧២ | ២.៤៨៥.៩០៦ | ២.០៩៧.៥៥១ | ៩៤,៩ | ៨០,១ |
| ស្រី | ២.៧៨៧.៧៩៥ | ២.៥៥៧.៥៥០ | ២.២២៥.៣៨០ | ៩១,៧ | ៧៩,៨ |
| **ជនបទ** | ៨.០៨១.០២៤ | ៦.៨៩៧.៣៧៥ | ៦.៥២៧.០៦៨ | ៨៥,៤ | ៨០,៨ |
| ប្រុស | ៣.៨៩១.៩៣៣ | ៣.៤៤២.៨៥៦ | ៣.២៥២.៩៤៣ | ៨៨,៥ | ៨៣,៦ |
| ស្រី | ៤.១៨៩.០៩១ | ៣.៤៥៤.៥១៩ | ៣.២៧៤.១២៥ | ៨២,៥ | ៧៨,២ |

**សម្គាល់ ៖** ការគណនាអត្រាអក្ខភាពមិនរាប់បញ្ចូលអក្ខភាពមិនបានរាយការណ៍។

តារាង ៤.២.១ បង្ហាញថា សមាមាត្រអក្ខរភាពសម្រាប់ភាសាណាមួយក្នុងចំណោមប្រជាជនអាយុ ៧ឆ្នាំឡើង មាន ១១.៩៤០.៨៣១នាក់ (៨៨,៥ ភាគរយ) នៅឆ្នាំ២០១៩ ធៀបនឹងឆ្នាំ២០០៨ មាន ៨.៩៥៩.៣៨៣នាក់ (៧៨,៤ ភាគរយ)។ តារាង ៤.២.២ ផ្តល់ព័ត៌មានអំពីការបែងចែកអត្រាអក្ខរភាពតាមភាសា ភេទ និងតំបន់ កម្ពុជា ឆ្នាំ ២០០៨-២០១៩។ ក្រៅពីភាសាខ្មែរ ប្រជាជនកម្ពុជាមួយចំនួនក៏ចេះភាសាផ្សេងទៀតផងដែរ ក្នុងនោះភាសាផ្សេងទៀតក្រៅពីភាសាខ្មែរ ១,៥ ភាគរយ សម្រាប់ចេះតែភាសាខ្មែរមាន ៩០,៩ ភាគរយ ភាសាខ្មែរ និងអង់គ្លេសមាន ៥,១ ភាគរយ ខ្មែរនិងភាសាផ្សេងទៀត ក្រៅពីភាសាអង់គ្លេសមាន ២,៥ ភាគរយ (តារាង ៤.២.២)។ ដូចគ្នានេះដែរ នៅឆ្នាំ ២០០៨ ភាសាខ្មែរ និងអង់គ្លេសមាន ៤,៩ ភាគរយ ខ្មែរ និងភាសាផ្សេងទៀតក្រៅពីភាសាអង់គ្លេសមាន ២,២ ភាគរយ។ ក្នុងរយៈពេល ១១ ឆ្នាំ ពីឆ្នាំ២០០៨-២០១៩ កំណើនប្រជាជនកម្ពុជាដែលអាចប្រើភាសាបរទេសមានសមាមាត្រតិចតួច ជាពិសេសភាសាអង់គ្លេស។ ទោះជាយ៉ាងណាក៏ដោយ សមាមាត្រអ្នកដែលចេះអក្សរខ្មែររួមនឹងភាសាផ្សេងទៀត បុរសខ្ពស់ជាងស្ត្រីទាំងនៅតំបន់ទីប្រជុំជន និងជនបទ។ មានអត្រាខ្ពស់ក្នុងចំណោមប្រជាជននៅតំបន់ទីប្រជុំជន ដែលចេះភាសាខ្មែរ និងភាសាផ្សេងទៀត (១២ ភាគរយ) ខ្ពស់ជាងជនបទ (៤,៤ ភាគរយ) ។

### តារាង ៤.២.២. ការបែងចែកភាគរយអក្ខរភាពអាយុ ៧ឆ្នាំឡើង តាមភាសា ភេទ និងតំបន់ កម្ពុជា ឆ្នាំ២០០៨ និង ២០១៩

| តំបន់ | ប្រជាជនអាយុ ៧ ឆ្នាំឡើងចេះភាសាណាមួយ | ភាសា | | | |
|---|---|---|---|---|---|
| | | ខ្មែរ | ខ្មែរ-អង់គ្លេស | ភាសាខ្មែរ និងភាសាផ្សេងទៀត លើកលែងភាសាអង់គ្លេស | ភាសាណាមួយក្រៅពីភាសាខ្មែរ |
| (១) | (២) | (៣) | (៤) | (៥) | (៦) |
| **២០០៨** | | | | | |
| **សរុប** | **៨.៩៥៩.៣៨៣** | **៩២,០** | **៤,៩** | **២,២** | **១,០** |
| ប្រុស | ៤.៦២៩.៧០២ | ៩១,០ | ៥,៧ | ២,៤ | ០,៩ |
| ស្រី | ៤.៣២៩.៦៨១ | ៩៣,១ | ៤,០ | ១,៩ | ១,១ |
| **ទីប្រជុំជន** | **២.០៩៦.៦៤១** | **៧៨,៥** | **១៤,៨** | **៥,០** | **១,៧** |
| ប្រុស | ១.០៣៥.២០៨ | ៧៥,០ | ១៧,៨ | ៥,៥ | ១,៧ |
| ស្រី | ១.០៦១.៤៣៣ | ៨១,៨ | ១១,៩ | ៤,៦ | ១,៧ |
| **ជនបទ** | **៦.៨៦២.៧៤២** | **៩៦,១** | **១,៨** | **១,៣** | **០,៧** |
| ប្រុស | ៣.៥៩៤.៤៩៤ | ៩៥,៦ | ២,២ | ១,៥ | ០,៦ |
| ស្រី | ៣.២៦៨.២៤៨ | ៩៦,៧ | ១,៤ | ១,០ | ០,៩ |
| **២០១៩** | | | | | |
| **សរុប** | **១១.៩៤០.៨៣១** | **៩០,៩** | **៥,១** | **២,៥** | **១,៥** |
| ប្រុស | ៥.៩២៨.៧៦២ | ៩០,២ | ៥,៥ | ២,៧ | ១,៥ |
| ស្រី | ៦.០១២.០៦៩ | ៩១,៥ | ៤,៦ | ២,៤ | ១,៥ |
| **ទីប្រជុំជន** | **៥.០៤៣.៤៥៦** | **៨៥,៧** | **៩,២** | **២,៨** | **២,៣** |
| ប្រុស | ២.៤៨៥.៩០៦ | ៨៤,៤ | ១០,១ | ៣,០ | ២,៥ |
| ស្រី | ២.៥៥៧.៥៥០ | ៨៧,០ | ៨,២ | ២,៧ | ២,១ |
| **ជនបទ** | **៦.៨៩៧.៣៧៥** | **៩៤,៦** | **២,១** | **២,៣** | **០,៩** |
| ប្រុស | ៣.៤៤២.៨៥៦ | ៩៤,៥ | ២,២ | ២,៥ | ០,៨ |
| ស្រី | ៣.៤៥៤.៥១៩ | ៩៤,៨ | ២,០ | ២,២ | ១,០ |

**សម្គាល់ ៖** ការគណនាអត្រាអក្ខភាពមិនរាប់បញ្ចូលអក្ខភាពមិនបានរាយការណ៍។

## ៤.៣. អត្រាអក្ខរភាពមនុស្សពេញវ័យ

អត្រាអក្ខរភាពមនុស្សពេញវ័យត្រូវបានកំណត់សម្រាប់អាយុ ១៥ ឆ្នាំឡើង ដែលចេះអាន និងចេះសរសេរឃ្លាសាមញ្ញជាភាសាណាមួយ។ អត្រាអក្ខរភាពមនុស្សពេញវ័យបានកើនឡើងរវាងឆ្នាំ ២០០៨-២០១៩ (តារាង ៤.៣.១)។ អត្រានេះបានកើនឡើងបន្តិចនៅតំបន់ជនបទ (៧៤,០ភាគរយ ក្នុងឆ្នាំ ២០០៨ ទៅ៨៣,៣ ភាគរយក្នុងឆ្នាំ២០១៩) ហើយស្ត្រីមានកំណើនខ្ពស់ជាងបុរសរវាងឆ្នាំ ២០០៨ និង ២០១៩ ។ មានការផ្លាស់ប្តូរគួរឲ្យកត់សម្គាល់នៅក្នុងតំបន់ទីប្រជុំជនដែលអត្រាអក្ខរភាពមនុស្សពេញវ័យឆ្នាំ ២០០៨ មាន ៩០,៤ ភាគរយ និងកើនដល់៩៣,៣ ភាគរយនៅឆ្នាំ ២០១៩ ។

ទិន្នន័យបង្ហាញថាអត្រាអក្ខរភាពនៅកម្ពុជាមានភាពប្រសើរឡើងគួរឲ្យកត់សម្គាល់ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍កន្លងមកនេះ។ ក្រុមអាយុវ័យក្មេងកាន់តែច្រើនមានអត្រាអក្ខរភាពខ្ពស់ និងគំលាតប្រុស ស្រីកាន់តែតូចជាងមុន ។ អត្រាអក្ខរភាពប្រុស និងស្រីតាមក្រុមអាយុវ័យក្មេងមានប្រហាក់ប្រហែលគ្នា ប៉ុន្តែកាន់តែមានគំលាតខ្លាំងចាប់ពីក្រុមអាយុ ២៥ ឆ្នាំឡើងទៅ ដែលអាចបង្ហាញបានថាកាលពីអតីតកាលស្រីមានឱកាសតិចជាងប្រុស ក្នុងការទទួលបានការសិក្សា។ ប៉ុន្តែវិសមភាពនេះត្រូវបានកាត់បន្ថយគួរឲ្យកត់សម្គាល់ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។

**តារាង ៤.៣.១. ស្ថានភាពអក្ខរភាពប្រជាជនពេញវ័យ (ចេះអាន និងសរសេរ) អាយុ ១៥ ឆ្នាំឡើង តាមក្រុមអាយុ ភេទ និងតំបន់ កម្ពុជា ឆ្នាំ២០០៨-២០១៩**

| ក្រុមអាយុ | ២០០៨ | | | ២០១៩ | | |
|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) |
| **សរុប** | | | | | | |
| ១៥ + | ៧៧,៦ | ៨៥,១ | ៧០,៩ | ៨៧,៧ | ៩០,៩ | ៨៤,៨ |
| ១៥-១៩ | ៩០,១ | ៩០,៩ | ៨៩,៤ | ៩៥,៩ | ៩៥,៥ | ៩៦,៣ |
| ២០-២៤ | ៨៤,៣ | ៨៧,៥ | ៨១,២ | ៩៣,៤ | ៩៣,២ | ៩៣,៥ |
| ២៥-៥៩ | ៧៥,៨ | ៨៣,៥ | ៦៩,១ | ៨៧,៥ | ៩០,៣ | ៨៤,៨ |
| ៦០ + | ៥៣,៤ | ៧៧,៣ | ៣៦,៨ | ៧៥,២ | ៨៥,៩ | ៦៨,១ |
| **ទីប្រជុំជន** | | | | | | |
| ១៥ + | ៩០,៤ | ៩៤,៥ | ៨៦,៨ | ៩៣,៣ | ៩៥,៣ | ៩១,៤ |
| ១៥-១៩ | ៩៥,៧ | ៩៦,២ | ៩៥,៣ | ៩៧,៦ | ៩៧,៣ | ៩៧,៩ |
| ២០-២៤ | ៩៤,៤ | ៩៥,៧ | ៩៣,៤ | ៩៦,៧ | ៩៦,៥ | ៩៦,៨ |
| ២៥-៥៩ | ៩០,២ | ៩៤,៣ | ៨៦,៤ | ៩៣,៦ | ៩៥,៣ | ៩២,០ |
| ៦០ + | ៦៩,៣ | ៨៨,២ | ៥៦,៩ | ៨២,៦ | ៩០,៨ | ៧៧,០ |
| **ជនបទ** | | | | | | |
| ១៥ + | ៧៤,០ | ៨២,៥ | ៦៦,៣ | ៨៣,៨ | ៨៧,៨ | ៨០,២ |
| ១៥-១៩ | ៨៨,៦ | ៨៩,៦ | ៨៧,៦ | ៩៤,៨ | ៩៤,៤ | ៩៥,៣ |
| ២០-២៤ | ៨០,៥ | ៨៤,៧ | ៧៦,៥ | ៩០,៦ | ៩០,៥ | ៩០,៧ |
| ២៥-៥៩ | ៧១,៨ | ៨០,៤ | ៦៤,៥ | ៨៣,០ | ៨៦,៦ | ៧៩,៦ |
| ៦០ + | ៥០,១ | ៧៥,២ | ៣២,៦ | ៧១,០ | ៨៣,១ | ៦៣,១ |

**សម្គាល់ ៖** ការគណនាអត្រាអក្ខភាពមិនរាប់បញ្ចូលអក្ខភាពមិនបានរាយការណ៍។

## ៤.៤. កម្រិតសិក្សាអប់រំ

កម្រិតអប់រំគឺជាសូចនាករសំខាន់មួយនៃគុណភាពប្រជាជន។ នៅក្នុងជំរឿនឆ្នាំ២០១៩ ថ្នាក់បញ្ចប់ខ្ពស់បំផុតសម្រាប់អ្នកដែលធ្លាប់ចូលរៀននៅសាលា ឬគ្រឹះស្ថានសិក្សា ហើយបច្ចុប្បន្នកំពុងរៀនថ្នាក់ត្រូវបានប្រមូលក្នុងជំរឿន។ របាយការណ៍វិភាគនេះបានរៀបចំឡើង សម្រាប់អ្នកដែលបានរាយការណ៍ពីកម្រិតថ្នាក់ដែលបានបញ្ចប់ពេញលេញ។ កម្រិតថ្នាក់ដែលបានបញ្ចប់ពេញលេញត្រូវបានចំណាត់លេខកូដ ដូចជា ១= មិនបានបញ្ចប់ថ្នាក់ណាមួយ ២= មិនបានបញ្ចប់បឋមសិក្សា (ថ្នាក់ទី ១ ដល់ថ្នាក់ទី ៥) ៣= បានបញ្ចប់បឋមសិក្សា (ថ្នាក់ទី ៦ ដល់ថ្នាក់ទី ៨) ៤= មធ្យម

សិក្សាបឋមភូមិ (ថ្នាក់ទី ៩ និងមានសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ) ៥= បានបញ្ចប់មធ្យមសិក្សា/មានសញ្ញាបត្រ (បានបញ្ចប់មធ្យមសិក្សា/មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សញ្ញប័ត្រមធ្យមសិក្សាបឋមភូមិមានបច្ចេកទេស/វិជ្ជាជីវៈ សញ្ញប័ត្រមធ្យមសិក្សាទុតិយភូមិមានបច្ចេកទេស/វិជ្ជាជីវៈ លេខកូដ ១៤ ដល់ ១៦) ៦= ក្រោយមធ្យមសិក្សា (សញ្ញាបត្រថ្នាក់មហាវិទ្យាល័យ សញ្ញាបត្រថ្នាក់អនុបណ្ឌិត និងសញ្ញាបត្រថ្នាក់បណ្ឌិត លេខកូដ ១៧ ដល់ ១៩)។

**រូប ៤.៤.១. ភាគរយប្រជាជនអក្ខរភាពអាយុ៧ឆ្នាំឡើង តាមកម្រិតសិក្សាអប់រំ កម្ពុជា ឆ្នាំ២០០៨-២០១៩**




នៅកម្រិតថ្នាក់ជាតិ លទ្ធផលជំរឿនឆ្នាំ២០១៩ (តារាង ៤.៤.១) បង្ហាញថា ២៩,១ ភាគរយនៃប្រជាជនអាយុ ៧ ឆ្នាំឡើង ដែលធ្លាប់បានចូលរៀននៅសាលា ឬគ្រឹះស្ថានសិក្សាណាមួយបានបញ្ចប់ថ្នាក់បឋមសិក្សា ហើយ ២១,៨ ភាគរយ បានបញ្ចប់ថ្នាក់មធ្យមសិក្សាបឋមភូមិ មាន ២,៩ ភាគរយ បានបញ្ចប់មធ្យមសិក្សា/មានសញ្ញាបត្រ (បានបញ្ចប់មធ្យមសិក្សា/មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សញ្ញប័ត្រមធ្យមសិក្សាបឋមភូមិមានបច្ចេកទេស/វិជ្ជាជីវៈ សញ្ញប័ត្រមធ្យមសិក្សាទុតិយភូមិមានបច្ចេកទេស/វិជ្ជាជីវៈ) និងបានបញ្ចប់ក្រោយមធ្យមសិក្សា (សញ្ញាបត្រថ្នាក់មហាវិទ្យាល័យ សញ្ញាបត្រថ្នាក់អនុបណ្ឌិត និងសញ្ញាបត្រថ្នាក់បណ្ឌិត) មានតែ ២,៨ ភាគរយ។ មានប្រមាណ ៤២,៣ ភាគរយនៃប្រជាជនកម្ពុជាអាយុ ៧ ឆ្នាំឡើង មិនបានបញ្ចប់ថ្នាក់បឋមសិក្សា ខណៈដែលមានសមាមាត្រតិច (១,១ ភាគរយ) នៃប្រជាជនអក្ខរភាពមិនបានបញ្ចប់ថ្នាក់ណាមួយ។ ប្រៀបធៀបនឹងជំរឿនឆ្នាំ២០០៨ មានការកែលម្អផ្នែកកម្រិតសិក្សាអប់រំក្នុងចំណោមប្រជាជនអក្ខរភាព។ លទ្ធផលបង្ហាញថាសមាមាត្របានថយចុះក្នុងចំណោមប្រជាជនមិនបានបញ្ចប់ថ្នាក់បឋមសិក្សាពី ៤៨,៩ ភាគរយ នៅឆ្នាំ២០០៨ មក ៤២,៣ ភាគរយ នៅឆ្នាំ២០១៩ ចំណែកឯអ្នកបានបញ្ចប់ថ្នាក់បឋមសិក្សាមានភាគរយខុសគ្នាបន្តិច។ រីឯបញ្ចប់ថ្នាក់មធ្យមសិក្សាបឋមភូមិបានកើនឡើងពី ១៧,០ ទៅ ២១,៨ ភាគរយ ខណៈដែលបានបញ្ចប់មធ្យមសិក្សា/មានសញ្ញាបត្រ (បានបញ្ចប់មធ្យមសិក្សា/មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិមានបច្ចេកទេស/វិជ្ជាជីវៈ សញ្ញប័ត្រមធ្យមសិក្សាទុតិយភូមិមានបច្ចេកទេស/វិជ្ជាជីវៈ) បានកើនឡើងពី ១,៦ ភាគរយ ទៅ ២,៩ ភាគរយ និងបានបញ្ចប់ក្រោយមធ្យមសិក្សា (សញ្ញាបត្រ ថ្នាក់មហាវិទ្យាល័យ សញ្ញាបត្រថ្នាក់អនុបណ្ឌិត និងសញ្ញាបត្រថ្នាក់បណ្ឌិត) កើនពី ១,៥ ភាគរយទៅ ២,៨ភាគរយ ផងដែរ។

# តារាង ៤.៤.១. កម្រិតសិក្សាអប់រំប្រជាជនអាយុ ៧ឆ្នាំឡើង តាមក្រុមអាយុ ភេទ  តំបន់ កម្ពុជា ឆ្នាំ២០០៨-២០១៩

| តំបន់ | ចំនួនអក្ខរភាព | ភាគរយតាមកម្រិតសិក្សាអប់រំ | | | | | | |
|---|---|---|---|---|---|---|---|---|
| | | សរុប | គ្មាន | មិនបាន បញ្ចប់ បឋមសិក្សា | បញ្ចប់បឋម សិក្សា | បញ្ចប់មធ្យម សិក្សា បឋមភូមិ | សញ្ញាបត្រ មធ្យមសិក្សា បឋមភូមិ/ សញ្ញាប័ត្រ | ក្រោយមធ្យម សិក្សា |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨) | (៩) |
| | | | | ២០០៨ | | | | |
| **ទាំងពីរភេទ** | ៨.៩៥២.៧២៦ | **១០០** | ២,៤ | ៤៨,៩ | ២៨,៦ | ១៧,០ | ១,៦ | ១,៥ |
| ៧-១៤ | ២.០៦៧.៩០៦ | ១០០ | ១,៧ | ៧៦,៥ | ២១,០ | ០,៩ | ០,០ | ០,០ |
| ១៥-១៩ | ១.៤៥៩.៣៣២ | ១០០ | ១,៣ | ២៧,០ | ៤២,៨ | ២៧,៨ | ០,៦ | ០,៥ |
| ២០-២៤ | ១.១៥៣.៦៧១ | ១០០ | ១,៩ | ៣៣,៥ | ៣១,១ | ២៥,៩ | ៣,៦ | ៤,០ |
| ២៥-៥៩ | ៣.៨២០.៣១៤ | ១០០ | ២,៨ | ៤៦,៥ | ២៧,៣ | ១៩,១ | ២,៣ | ២,០ |
| ៦០ + | ៤៥១.៥០៣ | ១០០ | ៦,៩ | ៥២,៩ | ២២,៧ | ១៥,៧ | ១,១ | ០,៦ |
| **ប្រុស** | ៤.៦២៥.៣០៩ | **១០០** | ២,០ | ៤៥,១ | ២៩,៤ | ១៩,៦ | ២,០ | ១,៩ |
| ៧-១៤ | ១.០៥៤.៩៩៣ | ១០០ | ១,៨ | ៧៧,៦ | ១៩,៨ | ០,៨ | ០,០ | ០,០ |
| ១៥-១៩ | ៧៥៧.៩៨២ | ១០០ | ១,៤ | ២៦,៧ | ៤២,៣ | ២៨,៦ | ០,៥ | ០,៥ |
| ២០-២៤ | ៥៨៥.៤៤៥ | ១០០ | ១,៧ | ២៩,៥ | ២៩,៩ | ៣០,៣ | ៤,០ | ៤,៦ |
| ២៥-៥៩ | ១.៩៥៩.៦៨៧ | ១០០ | ២,២ | ៣៨,៩ | ២៩,៧ | ២៣,២ | ៣,១ | ២,៩ |
| ៦០ + | ២៦៧.២០២ | ១០០ | ៣,៨ | ៤៨,១ | ២៧,៣ | ១៨,៥ | ១,៥ | ០,៨ |
| **ស្រី** | ៤.៣២៧.៤១៧ | **១០០** | ២,៧ | ៥៣,០ | ២៧,៨ | ១៤,៣ | ១,២ | ១,០ |
| ៧-១៤ | ១.០១២.៩១៣ | ១០០ | ១,៥ | ៧៥,៣ | ២២,២ | ១,០ | ០,០ | ០,០ |
| ១៥-១៩ | ៧០១.៣៥០ | ១០០ | ១,៣ | ២៧,៣ | ៤៣,៤ | ២៧,០ | ០,៦ | ០,៥ |
| ២០-២៤ | ៥៦៨.២២៦ | ១០០ | ២,១ | ៣៧,៦ | ៣២,៣ | ២១,៤ | ៣,៣ | ៣,៤ |
| ២៥-៥៩ | ១.៨៦០.៦២៧ | ១០០ | ៣,៣ | ៥៤,៦ | ២៤,៧ | ១៤,៨ | ១,៥ | ១,១ |
| ៦០ + | ១៨៤.៣០១ | ១០០ | ១១,៥ | ៥៩,៩ | ១៦,១ | ១១,៧ | ០,៦ | ០,៣ |
| **ទីប្រជុំជន** | ២.០៩៣.២៤៧ | **១០០** | ២,៨ | ៣១,៥ | ២៧,៥ | ២៨,៦ | ៤,៣ | ៥,៤ |
| ៧-១៤ | ៣៣៣.៦៨៨ | ១០០ | ២,០ | ៦៧,៦ | ២៨,០ | ២,៤ | ០,០ | ០,០ |
| ១៥-១៩ | ៣២៧.៦២០ | ១០០ | ១,៥ | ១៧,៧ | ៣៣,៩ | ៤៣,៣ | ១,៩ | ១,៨ |
| ២០-២៤ | ៣៤៩.៦២២ | ១០០ | ១,៩ | ១៩,៧ | ២៥,៧ | ៣៣,៧ | ៧,៧ | ១១,៣ |
| ២៥-៥៩ | ៩៨២.៧៦១ | ១០០ | ៣,១ | ២៧,២ | ២៦,៣ | ៣១,២ | ៥,៤ | ៦,៧ |
| ៦០ + | ៩៩.៥៥៦ | ១០០ | ៨,៧ | ៣៩,៩ | ២២,៩ | ២៣,២ | ៣,០ | ២,២ |
| **ប្រុស** | ១.០៣៣.០១៨ | **១០០** | ២,៤ | ២៧,២ | ២៦,០ | ៣១,៩ | ៥,២ | ៧,៣ |
| ៧-១៤ | ១៦៩.៨៤៧ | ១០០ | ២,២ | ៦៨,៧ | ២៧,០ | ២,១ | ០,០ | ០,០ |
| ១៥-១៩ | ១៥៥.១៧១ | ១០០ | ១,៦ | ១៥,៩ | ៣២,៨ | ៤៦,០ | ១,៩ | ១,៩ |
| ២០-២៤ | ១៦៦.០២១ | ១០០ | ១,៧ | ១៥,៤ | ២២,៤ | ៣៨,២ | ៨,៨ | ១៣,៦ |
| ២៥-៥៩ | ៤៩១.៦៩៧ | ១០០ | ២,៦ | ១៩,៨ | ២៤,៩ | ៣៦,០ | ៧,០ | ៩,៨ |
| ៦០ + | ៥០.២៨២ | ១០០ | ៥,០ | ៣២,៨ | ២៥,៩ | ២៨,៤ | ៤,៤ | ៣,៥ |
| **ស្រី** | ១.០៦០.២២៩ | **១០០** | ៣,១ | ៣៥,៧ | ២៨,៩ | ២៥,៣ | ៣,៣ | ៣,៦ |
| ៧-១៤ | ១៦៣.៨៤១ | ១០០ | ១,៨ | ៦៦,៥ | ២៩,១ | ២,៦ | ០,០ | ០,០ |
| ១៥-១៩ | ១៧២.៤៤៩ | ១០០ | ១,៤ | ១៩,៣ | ៣៤,៨ | ៤០,៩ | ១,៩ | ១,៧ |
| ២០-២៤ | ១៨៣.៦០១ | ១០០ | ២,០ | ២៣,៧ | ២៨,៧ | ២៩,៧ | ៦,៨ | ៩,២ |

| តំបន់ | ចំនួនអក្ខរភាព | ភាគរយតាមកម្រិតសិក្សាអប់រំ | | | | | | |
|---|---|---|---|---|---|---|---|---|
| | | សរុប | គ្មាន | មិនបាន បញ្ចប់ បឋមសិក្សា | បញ្ចប់បឋម សិក្សា | បញ្ចប់មធ្យម សិក្សា បឋមភូមិ | សញ្ញាបត្រ មធ្យមសិក្សា បឋមភូមិ/ សញ្ញាប័ត្រ | ក្រោយមធ្យម សិក្សា |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨) | (៩) |
| ២៥-៥៩ | ៤៩១.០៦៤ | ១០០ | ៣,៧ | ៣៤,៦ | ២៧,៨ | ២៦,៤ | ៣,៨ | ៣,៧ |
| ៦០ + | ៤៩.២៧៤ | ១០០ | ១២,៥ | ៤៧,២ | ១៩,៨ | ១៨,០ | ១,៦ | ០,៩ |
| **ជនបទ** | ៦.៨៥៩.៤៧៩ | **១០០** | ២,៣ | ៥៤,២ | ២៨,៩ | ១៣,៥ | ០,៨ | ០,៣ |
| ៧-១៤ | ១.៧៣៤.២១៨ | ១០០ | ១,៦ | ៧៨,២ | ១៩,៦ | ០,៦ | ០,០ | ០,០ |
| ១៥-១៩ | ១.១៣១.៧១២ | ១០០ | ១,៣ | ២៩,៧ | ៤៥,៤ | ២៣,៤ | ០,២ | ០,១ |
| ២០-២៤ | ៨០៤.០៤៩ | ១០០ | ១,៩ | ៣៩,៤ | ៣៣,៤ | ២២,៥ | ១,៩ | ០,៩ |
| ២៥-៥៩ | ២.៨៣៧.៥៥៣ | ១០០ | ២,៦ | ៥៣,២ | ២៧,៦ | ១៤,៩ | ១,៣ | ០,៣ |
| ៦០ + | ៣៥១.៩៤៧ | ១០០ | ៦,៤ | ៥៦,៦ | ២២,៧ | ១៣,៦ | ០,៦ | ០,១ |
| **ប្រុស** | ៣.៥៩២.២៩១ | **១០០** | ១,៩ | ៥០,២ | ៣០,៣ | ១៦,១ | ១,១ | ០,៤ |
| ៧-១៤ | ៨៨៥.១៤៦ | ១០០ | ១,៧ | ៧៩,៣ | ១៨,៤ | ០,៦ | ០,០ | ០,០ |
| ១៥-១៩ | ៦០២.៨១១ | ១០០ | ១,៣ | ២៩,៥ | ៤៤,៧ | ២៤,២ | ០,២ | ០,១ |
| ២០-២៤ | ៤១៩.៤២៤ | ១០០ | ១,៧ | ៣៥,១ | ៣២,៨ | ២៧,២ | ២,១ | ១,១ |
| ២៥-៥៩ | ១.៤៦៧.៩៩០ | ១០០ | ២,១ | ៤៥,៣ | ៣១,៣ | ១៩,០ | ១,៨ | ០,៦ |
| ៦០ + | ២១៦.៩២០ | ១០០ | ៣,៥ | ៥១,៧ | ២៧,៦ | ១៦,២ | ០,៩ | ០,១ |
| **ស្រី** | ៣.២៦៧.១៨៨ | **១០០** | ២,៦ | ៥៨,៦ | ២៧,៤ | ១០,៧ | ០,៥ | ០,១ |
| ៧-១៤ | ៨៤៩.០៧២ | ១០០ | ១,៤ | ៧៧,០ | ២០,៩ | ០,៧ | ០,០ | ០,០ |
| ១៥-១៩ | ៥២៨.៩០១ | ១០០ | ១,២ | ២៩,៩ | ៤៦,២ | ២២,៤ | ០,២ | ០,១ |
| ២០-២៤ | ៣៨៤.៦២៥ | ១០០ | ២,១ | ៤៤,២ | ៣៤,១ | ១៧,៤ | ១,៦ | ០,៦ |
| ២៥-៥៩ | ១.៣៦៩.៥៦៣ | ១០០ | ៣,២ | ៦១,៨ | ២៣,៦ | ១០,៦ | ០,៧ | ០,១ |
| ៦០ + | ១៣៥.០២៧ | ១០០ | ១១,១ | ៦៤,៥ | ១៤,៧ | ៩,៤ | ០,២ | ០,០ |
| ២០១៩ | | | | | | | | |
| **ទាំងពីរភេទ** | **១១.៤៨៨.៩៣៤** | **១០០** | **១,១** | **៤២,៣** | **២៩,១** | **២១,៨** | **២,៩** | **២,៨** |
| ៧-១៤ | ២.២៧២.២០៦ | ១០០ | ៥,៥ | ៧៤,៣ | ១៩,៦ | ០,៦ | ០,០ | ០,០ |
| ១៥-១៩ | ១.៣២៤.៨៣៩ | ១០០ | ០,២ | ១៦,៧ | ៤០,៨ | ៣៩,៩ | ២,៤ | ០,០ |
| ២០-២៤ | ១.១៣៧.៩០៩ | ១០០ | ០,១ | ២២,០ | ៣១,៩ | ៣៣,៥ | ៩,៣ | ៣,២ |
| ២៥-៥៩ | ៥.៨០៥.៧៦៧ | ១០០ | ០,០ | ៣៧,៥ | ៣០,៥ | ២៤,០ | ៣,១ | ៤,៨ |
| ៦០ + | ៩៤៨.២១៣ | ១០០ | ០,០ | ៥៥,២ | ២៣,៨ | ១៩,០ | ១,០ | ០,៩ |
| **ប្រុស** | **៥.៧៣២.១៨៧** | **១០០** | **១,២** | **៣៩,៧** | **២៩,១** | **២៣,៤** | **៣,២** | **៣,៥** |
| ៧-១៤ | ១.១៥៥.៤៤៤ | ១០០ | ៥,៨ | ៧៥,៣ | ១៨,៣ | ០,៦ | ០,០ | ០,០ |
| ១៥-១៩ | ៦៦៤.០៧០ | ១០០ | ០,២ | ១៨,៥ | ៤១,២ | ៣៧,៩ | ២,១ | ០,០ |
| ២០-២៤ | ៥៥២.៨៩៤ | ១០០ | ០,១ | ២២,២ | ៣០,៨ | ៣៤,៣ | ៩,៧ | ៣,០ |
| ២៥-៥៩ | ២.៩១៦.៦៦៩ | ១០០ | ០,០ | ៣២,៥ | ៣០,៥ | ២៧,៣ | ៣,៧ | ៦,០ |
| ៦០ + | ៤៤៤.១១០ | ១០០ | ០,០ | ៤៧,៩ | ២៧,៧ | ២១,៥ | ១,៤ | ១,៤ |
| **ស្រី** | **៥.៧៥៦.៧៤៧** | **១០០** | **១,១** | **៤៤,៨** | **២៩,២** | **២០,២** | **២,៥** | **២,២** |
| ៧-១៤ | ១.១១៧.៧៦២ | ១០០ | ៥,២ | ៧៣,២ | ២០,៨ | ០,៧ | ០,០ | ០,០ |
| ១៥-១៩ | ៦៦០.៧៦៩ | ១០០ | ០,២ | ១៤,៨ | ៤០,៥ | ៤១,៨ | ២,៧ | ០,០ |

| តំបន់ | ចំនួនអក្ខរភាព | ភាគរយតាមកម្រិតសិក្សាអប់រំ | | | | | | |
|---|---|---|---|---|---|---|---|---|
| | | សរុប | គ្មាន | មិនបានបញ្ចប់បឋមសិក្សា | បញ្ចប់បឋមសិក្សា | បញ្ចប់មធ្យមសិក្សាបឋមភូមិ | សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ/សញ្ញាប័ត្រ | ក្រោយមធ្យមសិក្សា |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨) | (៩) |
| ២០-២៤ | ៥៨៥.០១៥ | ១០០ | ០,០ | ២១,៨ | ៣៣,០ | ៣២,៨ | ៨,៩ | ៣,៥ |
| ២៥-៥៩ | ២.៨៨៩.០៩៨ | ១០០ | ០,០ | ៤២,៥ | ៣០,៦ | ២០,៨ | ២,៥ | ៣,៦ |
| ៦០ + | ៥០៤.១០៣ | ១០០ | ០,០ | ៦១,៧ | ២០,៣ | ១៦,៨ | ០,៧ | ០,៥ |
| **ទីប្រជុំជន** | **៤.៨៧៩.៧១២** | **១០០** | **០,៩** | **៣២,៩** | **២៨,០** | **២៧,៧** | **៤,៨** | **៥,៧** |
| ៧-១៤ | ៧៧៤.៨៩៨ | ១០០ | ៥,២ | ៧២,៧ | ២១,២ | ០,៨ | ០,០ | ០,០ |
| ១៥-១៩ | ៥២៤.៣២៧ | ១០០ | ០,២ | ១៣,៣ | ៣៦,៣ | ៤៥,៦ | ៤,៦ | ០,០ |
| ២០-២៤ | ៥៣៨.៧២១ | ១០០ | ០,០ | ១៦,៣ | ២៧,៥ | ៣៦,៥ | ១៤,២ | ៥,៥ |
| ២៥-៥៩ | ២.៦៥៧.៦២២ | ១០០ | ០,០ | ២៦,៦ | ២៨,៩ | ៣០,៨ | ៤,៧ | ៩,០ |
| ៦០ + | ៣៨៤.១៤៤ | ១០០ | ០,០ | ៤៦,៣ | ២៥,៥ | ២៤,០ | ២,០ | ២,១ |
| **ប្រុស** | **២.៤១៤.៦០៩** | **១០០** | **០,៩** | **៣០,០** | **២៧,១** | **២៩,៧** | **៥,៣** | **៦,៩** |
| ៧-១៤ | ៣៩៤.០១៦ | ១០០ | ៥,៥ | ៧៣,៦ | ២០,២ | ០,៧ | ០,០ | ០,០ |
| ១៥-១៩ | ២៥៨.៨៥៦ | ១០០ | ០,២ | ១៤,៤ | ៣៦,៧ | ៤៤,៤ | ៤,៣ | ០,០ |
| ២០-២៤ | ២៥៨.៧០៧ | ១០០ | ០,១ | ១៦,១ | ២៦,០ | ៣៧,៧ | ១៥,១ | ៥,១ |
| ២៥-៥៩ | ១.៣២៨.៧៨៨ | ១០០ | ០,០ | ២១,៧ | ២៧,៤ | ៣៤,២ | ៥,៦ | ១១,១ |
| ៦០ + | ១៧៤.២៤២ | ១០០ | ០,០ | ៣៨,៩ | ២៨,០ | ២៦,៩ | ២,៨ | ៣,៤ |
| **ស្រី** | **២.៤៦៥.១០៣** | **១០០** | **០,៨** | **៣៥,៧** | **២៨,៩** | **២៥,៨** | **៤,៣** | **៤,៤** |
| ៧-១៤ | ៣៨០.៨៨២ | ១០០ | ៥,០ | ៧១,៨ | ២២,៣ | ០,៩ | ០,០ | ០,០ |
| ១៥-១៩ | ២៦៥.៤៧១ | ១០០ | ០,២ | ១២,២ | ៣៥,៨ | ៤៦,៨ | ៥,០ | ០,០ |
| ២០-២៤ | ២៨០.០១៤ | ១០០ | ០,០ | ១៦,៥ | ២៨,៨ | ៣៥,៤ | ១៣,៣ | ៥,៩ |
| ២៥-៥៩ | ១.៣២៨.៨៣៤ | ១០០ | ០,០ | ៣១,៥ | ៣០,៣ | ២៧,៤ | ៣,៩ | ៦,៨ |
| ៦០ + | ២០៩.៩០២ | ១០០ | ០,០ | ៥២,៥ | ២៣,៥ | ២១,៦ | ១,៤ | ១,០ |
| **ជនបទ** | **៦.៦០៩.២២២** | **១០០** | **១,៣** | **៤៩,២** | **២៩,៩** | **១៧,៣** | **១,៤** | **០,៨** |
| ៧-១៤ | ១.៤៩៧.៣០៨ | ១០០ | ៥,៧ | ៧៥,១ | ១៨,៧ | ០,៥ | ០,០ | ០,០ |
| ១៥-១៩ | ៨០០.៥១២ | ១០០ | ០,៣ | ១៨,៩ | ៤៣,៨ | ៣៦,១ | ០,៩ | ០,០ |
| ២០-២៤ | ៥៩៩.១៨៨ | ១០០ | ០,១ | ២៧,១ | ៣៦,០ | ៣០,៨ | ៤,៩ | ១,១ |
| ២៥-៥៩ | ៣.១៤៨.១៩៥ | ១០០ | ០,០ | ៤៦,៧ | ៣១,៩ | ១៨,៣ | ១,៧ | ១,៤ |
| ៦០ + | ៥៦៤.០៦៩ | ១០០ | ០,០ | ៦១,៣ | ២២,៦ | ១៥,៦ | ០,៤ | ០,១ |
| **ប្រុស** | **៣.៣១៧.៥៧៨** | **១០០** | **១,៤** | **៤៦,៨** | **៣០,៥** | **១៨,៨** | **១,៦** | **១,០** |
| ៧-១៤ | ៧៦០.៤២៨ | ១០០ | ៦,០ | ៧៦,១ | ១៧,៤ | ០,៥ | ០,០ | ០,០ |
| ១៥-១៩ | ៤០៥.២១៤ | ១០០ | ០,៣ | ២១,២ | ៤៤,០ | ៣៣,៨ | ០,៨ | ០,០ |
| ២០-២៤ | ២៩៤.១៨៧ | ១០០ | ០,១ | ២៧,៦ | ៣៥,០ | ៣១,៣ | ៤,៩ | ១,០ |
| ២៥-៥៩ | ១.៥៨៧.៨៨១ | ១០០ | ០,០ | ៤១,៦ | ៣៣,០ | ២១,៥ | ២,១ | ១,៨ |
| ៦០ + | ២៦៩.៨៦៨ | ១០០ | ០,០ | ៥៣,៦ | ២៧,៦ | ១៨,០ | ០,៦ | ០,១ |
| **ស្រី** | **៣.២៩១.៦៤៤** | **១០០** | **១,២** | **៥១,៧** | **២៩,៤** | **១៥,៩** | **១,២** | **០,៦** |
| ៧-១៤ | ៧៣៦.៨៨០ | ១០០ | ៥,៤ | ៧៣,៩ | ២០,១ | ០,៦ | ០,០ | ០,០ |
| ១៥-១៩ | ៣៩៥.២៩៨ | ១០០ | ០,២ | ១៦,៦ | ៤៣,៦ | ៣៨,៥ | ១,១ | ០,០ |

| តំបន់ | ចំនួនអក្ខរភាព | ភាគរយតាមកម្រិតសិក្សាអប់រំ | | | | | | |
|---|---|---|---|---|---|---|---|---|
| | | សរុប | គ្មាន | មិនបានបញ្ចប់បឋមសិក្សា | បញ្ចប់បឋមសិក្សា | បញ្ចប់មធ្យមសិក្សាបឋមភូមិ | សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ/សញ្ញាប័ត្រ | ក្រោយមធ្យមសិក្សា |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨) | (៩) |
| ២០-២៤ | ៣០៥.០០១ | ១០០ | ០,០ | ២៦,៦ | ៣៦,៩ | ៣០,៤ | ៤,៩ | ១,២ |
| ២៥-៥៩ | ១.៥៦០.២៦៤ | ១០០ | ០,០ | ៥១,៨ | ៣០,៨ | ១៥,១ | ១,៤ | ០,៩ |
| ៦០ + | ២៩៤.២០១ | ១០០ | ០,០ | ៦៨,៣ | ១៨,១ | ១៣,៤ | ០,២ | ០,០ |

**សម្គាល់ ៖** មិនរាប់បញ្ចូលកម្រិតសិក្សាមិនបានរាយការណ៍ និងកម្រិតសិក្សាផ្សេងទៀត។

ក្រុមអាយុ ១៥-១៩ ឆ្នាំ ជាទូទៅគួរបញ្ចប់ថ្នាក់កម្រិតមធ្យមសិក្សាបឋម ប៉ុន្តែពិនិត្យឃើញថា ១៦,៧ ភាគរយក្នុងក្រុមអាយុ ១៥-១៩ ឆ្នាំ នៅមិនទាន់បានបញ្ចប់កម្រិតបឋមសិក្សា អាចដោយមូលហេតុចុះឈ្មោះចូលរៀនយឺត ឬត្រួតថ្នាក់ ឬឈប់រៀន។ ក្នុងក្រុមអាយុដដែល ១៥-១៩ ឆ្នាំ មាន ៤០,៨ ភាគរយ និង ៣៩,៩ ភាគរយ បានបញ្ចប់កម្រិតបឋមសិក្សា និងកម្រិតមធ្យមសិក្សាបឋមភូមិ តាមលំដាប់រៀង។ គួរកត់សម្គាល់ផងដែរ ប្រមាណ ២,៤ ភាគរយ ក្នុងក្រុមអាយុនេះបានបញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិ/សញ្ញាបត្រ។

ចំណោមប្រជាជនក្នុងក្រុមអាយុ ២០-២៤ ឆ្នាំ មិនបានបញ្ចប់កម្រិតបឋមសិក្សាមាន ២២,០ ភាគរយ បានបញ្ចប់កម្រិតបឋមសិក្សា ៣១,៩ ភាគរយ បញ្ចប់មធ្យមសិក្សាបឋមភូមិ ៣៣,៥ ភាគរយ បញ្ចប់មធ្យមសិក្សា/មានសញ្ញាបត្រ (បញ្ចប់មធ្យមសិក្សា/មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សញ្ញាបត្រមធ្យមសិក្សាបឋមភូមិមានបច្ចេកទេស/វិជ្ជាជីវៈ សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិមានបច្ចេកទេស/វិជ្ជាជីវៈ) និងបានបញ្ចប់ក្រោយមធ្យមសិក្សា (សញ្ញាបត្រថ្នាក់មហាវិទ្យាល័យ សញ្ញាបត្រថ្នាក់អនុបណ្ឌិត និងសញ្ញាបត្រថ្នាក់បណ្ឌិត) ៩,៣ និង ៣,២ ភាគរយ តាមលំដាប់រៀង។ ប្រជាជនអក្ខរភាពអាយុ ២៥ ឡើង សង្កេតឃើញថាសមាមាត្រភាគច្រើនលើសលប់ ដែលមិនបានបញ្ចប់បឋមសិក្សា។ បើប្រៀបធៀបទៅឆ្នាំ២០០៨ កម្រិតសិក្សានៃប្រជាជនមានលក្ខណៈប្រសើរឡើងច្រើន ដោយសារការថយចុះគួរឲ្យកត់សម្គាល់ក្នុងកម្រិតមិនបានបញ្ចប់បឋមសិក្សា និងបានបញ្ចប់កម្រិតបឋមសិក្សា ហើយបានកើនឡើងនៅក្រោយកម្រិតមធ្យមសិក្សាបឋមភូមិ។ ប្រុសមានសមាមាត្រខ្ពស់ជាងស្រីនៅកម្រិតមធ្យមសិក្សា និងកម្រិតខ្ពស់ជាងនេះ។

## ៤.៥. អត្រាចូលរៀន

សំណួរអំពីការចូលរៀនសាលា សិប្បគ្រឹះស្ថានក្សាត្រូវបានស្រង់គ្រប់មនុស្សទាំងអស់ទាំងអ្នកចេះអាន និងសរសេរ និងអនក្ខរជន។ សំណួរនេះត្រូវបានរាប់បញ្ចូលផងដែរ សម្រាប់កុមារអាយុក្រោម ៦ ឆ្នាំ។ ចម្លើយសំណួរនេះត្រូវបានចាត់ថ្នាក់ជា (i) "មិនដែលចូលសាលា ឬគ្រឹះស្ថានសិក្សាសោះ" សំដៅលើមនុស្សទាំងឡាយណាដែលមិនធ្លាប់បានចូលរៀនក្នុងសាលា ឬគ្រឹះស្ថានសិក្សាណាមួយពេញលេញ (ii) "បច្ចុប្បន្ន" សំដៅលើមនុស្សទាំងឡាយណាដែលកំពុងរៀននៅសាលា ឬគ្រឹះស្ថានសិក្សាណាមួយក្នុងពេលធ្វើជំរឿន និង (iii) "អតីតកាល" សំដៅលើមនុស្សទាំងឡាយណាដែលធ្លាប់បានរៀននៅសាលា ឬគ្រឹះស្ថានសិក្សាណាមួយកាលពីអតីតកាល។

ផ្អែកលើសំណួរពីជំរឿន តើបច្ចុប្បន្នអ្នកធ្លាប់ចូលសាលា ឬគ្រឹះស្ថានសិក្សាណាមួយដែរឬទេ? អត្រាចូលរៀនមាន ៩០,៦ ភាគរយ និង ៩១,៦ ភាគរយ សម្រាប់កុមារក្មេងក្រុមអាយុ ៦-១១ ឆ្នាំ និង ១២-១៤ ឆ្នាំ តាមលំដាប់រៀង។

**រូប ៤.៥.១. អត្រាចូលរៀនសាលា ឬគ្រឹះស្ថានអប់រំណាមួយ អាយុ ៦ ឆ្នាំឡើង កម្ពុជា ឆ្នាំ២០១៩**




សមាមាត្រដូចគ្នានេះមានតិចជាង តាមគ្រប់ក្រុមអាយុនីមួយៗនៅឆ្នាំ២០០៨ (តារាង ៤.៥.១)។ ទោះជាយ៉ាងណាក៏ដោយ អត្រាចូលរៀនបានចាប់ផ្តើមធ្លាក់ចុះយ៉ាងខ្លាំងបន្ទាប់ពីអាយុ ១៥ ឆ្នាំឡើងទៅ នេះអាចមានសិស្សកាន់តែច្រើនបានបោះបង់ការសិក្សា ឬឈប់រៀន។ ក្នុងឆ្នាំ២០១៩ មាន១៦,៩ ភាគរយនៃក្រុមអាយុ ២៥ ឆ្នាំឡើង មិនដែលចូលសាលា ឬគ្រឹះស្ថានសិក្សាណាមួយសោះ។ អត្រាចូលរៀននៅសាលា ឬគ្រឹះស្ថានសិក្សារបស់ក្មេងស្រីមានអត្រាស្មើគ្នានឹងក្មេងប្រុស នៅក្រុមអាយុ ៦-១១ ឆ្នាំ ហើយអត្រាក្មេងប្រុសទាបជាងក្មេងស្រីបន្តិចនៅក្រុមអាយុ ១២-១៤ ឆ្នាំ និងចាប់ផ្តើមទាបជាងក្មេងប្រុសនៅពេលដែលអាយុកើនឡើង។ ទាំងនេះអាចដោយសារតែឥរិយាបទនៃប្រពៃណីក្នុងការលើកទឹកចិត្តក្មេងប្រុសជាងក្មេងស្រីដើម្បីបន្តការសិក្សា បន្ទាប់ពីអាយុកាន់តែច្រើន។ ក៏បានសង្កេតឃើញនៅក្នុងតារាង ៤.៥.១ ផងដែរថា បច្ចុប្បន្នកុមារនៅតំបន់ទីប្រជុំជនច្រើនជាងកុមារនៅជនបទ កំពុងរៀននៅគ្រប់ក្រុមអាយុ។

## តារាង ៤.៥.១. ស្ថានភាពចូលរៀនក្រុមអាយុ ៦ ឆ្នាំឡើង តាមភេទ អាយុ តំបន់ កម្ពុជា ឆ្នាំ២០០៨-២០១៩

| តំបន់ | ស្ថានភាពចូលរៀន ២០០៨ | | | ស្ថានភាពចូលរៀន ២០១៩ | | |
|---|---|---|---|---|---|---|
| | មិនដែលសោះ | បច្ចុប្បន្ន | អតីតកាល | មិនដែលសោះ | បច្ចុប្បន្ន | អតីតកាល |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) |
| **ទាំងពីរភេទ** | **២១,៥** | **២៨,៩** | **៤៩,៦** | **១២,៥** | **២៥,៨** | **៦១,៦** |
| ០៦ - ១១ | ២៣,១ | ៧៦,៣ | ០,៦ | ៨,០ | ៩០,៦ | ១,៤ |
| ១២ - ១៤ | ៧,៣ | ៨៦,៧ | ៦,០ | ២,៨ | ៩១,៦ | ៥,៦ |
| ១៥ - ១៧ | ៩,១ | ៦២,៣ | ២៨,៦ | ៤,៥ | ៦៧,៦ | ២៧,៩ |
| ១៨ - ២៤ | ១៤,៥ | ២១,៣ | ៦៤,២ | ៧,៥ | ២០,៧ | ៧១,៨ |
| ២៥+ | ២៧,៩ | ១,២ | ៧០,៩ | ១៦,៥ | ០,៧ | ៨២,៧ |
| **ប្រុស** | **១៦,០** | **៣១,៩** | **៥២,១** | **៩,៩** | **២៧,២** | **៦២,៩** |
| ០៦ - ១១ | ២៣,៥ | ៧៥,៩ | ០,៦ | ៨,៤ | ៩០,១ | ១,៥ |
| ១២ - ១៤ | ៧,៥ | ៨៧,០ | ៥,៥ | ៣,២ | ៩០,៤ | ៦,៤ |
| ១៥ - ១៧ | ៨,៨ | ៦៥,៦ | ២៥,៦ | ៥,០ | ៦៦,២ | ២៨,៨ |
| ១៨ - ២៤ | ១១,៩ | ២៦,២ | ៦១,៩ | ៧,៨ | ២២,១ | ៧០,១ |
| ២៥+ | ១៨,០ | ១,៦ | ៨០,៥ | ១២,២ | ០,៨ | ៨៦,៩ |
| **ស្រី** | **២៦,៦** | **២៦,១** | **៤៧,៣** | **១៤,៩** | **២៤,៦** | **៦០,៥** |
| ០៦ - ១១ | ២២,៦ | ៧៦,៨ | ០,៦ | ៧,៦ | ៩១,១ | ១,៣ |
| ១២ - ១៤ | ៧,១ | ៨៦,៣ | ៦,៦ | ២,៤ | ៩២,៨ | ៤,៧ |
| ១៥ - ១៧ | ៩,៤ | ៥៨,៨ | ៣១,៨ | ៣,៩ | ៦៩,១ | ២៧,០ |
| ១៨ - ២៤ | ១៧,១ | ១៦,៥ | ៦៦,៤ | ៧,៤ | ១៩,៣ | ៧៣,៣ |
| ២៥+ | ៣៦,៣ | ០,៩ | ៦២,៨ | ២០,៤ | ០,៦ | ៧៩,០ |
| **ទីប្រជុំជន** | **១០,៩** | **២៩,៥** | **៥៩,៦** | **៧,៩** | **២៤,០** | **៦៨,១** |
| ០៦ - ១១ | ១៥,៦ | ៨៣,៦ | ០,៧ | ៦,៨ | ៩១,៥ | ១,៧ |
| ១២ - ១៤ | ៣,៨ | ៩១,១ | ៥,១ | ២,២ | ៩២,១ | ៥,៧ |
| ១៥ - ១៧ | ៤,៦ | ៧០,៨ | ២៤,៦ | ៣,១ | ៦៩,១ | ២៧,៨ |
| ១៨ - ២៤ | ៦,១ | ៣២,៥ | ៦១,៤ | ៤,៤ | ២៥,៣ | ៧០,៣ |
| ២៥+ | ១៣,៩ | ២,៨ | ៨៣,៣ | ៩,៩ | ១,០ | ៨៩,០ |
| **ជនបទ** | **២៤,១** | **២៨,៨** | **៤៧,១** | **១៥,៦** | **២៧,១** | **៥៧,៣** |
| ០៦ - ១១ | ២៤,៣ | ៧៥,១ | ០,៦ | ៨,៧ | ៩០,២ | ១,២ |
| ១២ - ១៤ | ៧,៩ | ៨៥,៩ | ៦,២ | ៣,១ | ៩១,៤ | ៥,៥ |
| ១៥ - ១៧ | ១០,២ | ៦០,៣ | ២៩,៥ | ៥,៣ | ៦៦,៧ | ២៨,០ |
| ១៨ - ២៤ | ១៧,៥ | ១៧,៣ | ៦៥,២ | ១០,១ | ១៧,០ | ៧២,៩ |
| ២៥+ | ៣១,៧ | ០,៨ | ៦៧,៦ | ២១,២ | ០,៥ | ៧៨,៣ |

**សម្គាល់ ៖** ការគណនាមិនរាប់បញ្ចូលការចូលរៀនសាលា ឬគ្រឹះស្ថានណាមួយមិនបានរាយការណ៍។

# ជំពូក ៥
# កម្លាំងពលកម្ម និងការងារ

## ៥.១. ទស្សនទាន

ការវិភាគសកម្មភាពសេដ្ឋកិច្ចបានឆ្លុះបញ្ចាំងអំពីពលកម្ម និងការងារប្រជាជន ដែលជាមូលដ្ឋានសម្រាប់រៀបចំគោលនយោបាយសេដ្ឋកិច្ច និងផែនការអភិវឌ្ឍ។ នេះជាបញ្ហាចម្បងដែលទំនាក់ទំនងនឹងការកែលម្អគុណភាពធនធានមនុស្សសម្រាប់បង្កើននូវផលិតភាព និងកាត់បន្ថយភាពអត់ការងារធ្វើ និងភាពមានការងារធ្វើមិនគ្រប់គ្រាន់។

ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ បានស្រង់ព័ត៌មានស្តីពីស្ថានភាពការងារពីគ្រប់គ្រួសារសម្ភាសន៍តាមបង្គោលនីមួយៗក្នុងតារាងសំណួរទម្រង់ ខ នៃកម្រងសំណួរគ្រួសារផ្នែក២ ក្នុងនោះបង្គោល ១៨ កត់ត្រាអំពីសកម្មភាពសេដ្ឋកិច្ចចម្បង បង្គោល ១៩ ប្រភេទអាជីព/មុខរបរ បង្គោល ២០ ស្ថានភាពការងារ បង្គោល ២១ សកម្មការងារ/ប្រភេទសកម្មភាពសេដ្ឋកិច្ច (កសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម និងសេវាកម្ម) និងបង្គោល ២២ ផ្នែកនៃការងារ។

គោលបំណងសំខាន់គឺដើម្បីធ្វើចំណាត់ថ្នាក់ប្រជាជនជាពីរប្រភេទផ្សេងគ្នា គឺសកម្មជនសេដ្ឋកិច្ច (សម្រាប់អ្នកដែលស្ថិតក្នុងកម្លាំងពលកម្ម) និងអសកម្មជនសេដ្ឋកិច្ច (សម្រាប់អ្នកដែលមិនស្ថិតក្នុងកម្លាំងពលកម្ម)។ សំណួរបន្ថែមទៀតដែលត្រូវបានសួរ គឺដើម្បីបែងចែកអ្នកដែលមានការងារធ្វើទៅតាមប្រភេទមុខរបរសំខាន់ៗនៃក្រុមអាជីព សកម្មភាពការងារ វិស័យការងារ និងស្ថានភាពការងារ។

រយៈពេលយោងសម្រាប់ប្រមូលទិន្នន័យក្នុងជំរឿន គឺក្នុងរយៈពេល ១២ ខែ មុនពេលធ្វើជំរឿនគឺថ្ងៃទី ៣ ខែមីនា ឆ្នាំ២០១៩។ អ្នកដែលកំណត់ថាមានការងារធ្វើ គឺអ្នកទាំងឡាយណាដែលបានធ្វើការយ៉ាងតិចប្រាំមួយខែ (១៨៣ ថ្ងៃ) ឬលើសប្រាំមួយខែមុនកាលបរិច្ឆេទធ្វើជំរឿន។ កម្លាំងពលកម្មរាប់បញ្ចូលទាំងអ្នកមានការងារធ្វើ និងអ្នកគ្មានការងារធ្វើ។

អ្នកមានការងារធ្វើរួមមាន (១) អ្នកមានការងាធ្វើមានប្រាក់ឈ្នួលក្នុងស្ថាប័នសាធារណៈ ឬឯកជន (២) អ្នកធ្វើការ ដើម្បីប្រាក់ឈ្នួល បៀវត្សរ៍ កម្រៃ ឬចំណូលគ្រួសារជាសាច់ប្រាក់ ឬជារបស់ ក្នុងរយៈពេលយោង (៣) អ្នកមិនបានធ្វើការណាមួយ ដើម្បីប្រាក់ឈ្នួល ឬកម្រៃ ក្នុងរយៈពេលយោង ប៉ុន្តែគាត់មានការងារដែលអាចត្រឡប់ទៅធ្វើការវិញ ឧទាហរណ៍ អ្នកធ្វើតាមរដូវ ដូចជាកសិករ ឬអ្នកនេសាទ អ្នកឈប់សម្រាកពីការងារដោយសារជំងឺ ឬសម្រាកគ្មានប្រាក់ឈ្នួល អ្នកមិនអាចធ្វើការបានដោយសារបាតុកម្ម ឬបិទទ្វារគ្រឹះស្ថានដែលពួកគេកំពុងធ្វើការ និង (៤) អ្នកធ្វើអាជីវកម្មផ្ទាល់ខ្លួន ដូចជាដំណើរការហាងលក់ទំនិញផ្ទាល់ខ្លួន លក់ចំណីហូបចុក ការអនុវត្តរបស់វេជ្ជបណ្ឌិត អ្នកច្បាប់។

អសកម្មជនសេដ្ឋកិច្ច រួមមាន (១) អ្នកធ្វើការងារផ្ទះ សំដៅអ្នកទាំងឡាយដែលបានចំណាយពេលច្រើនក្នុងរយៈពេលយោងធ្វើកិច្ចការផ្ទះ (២) សិស្ស និស្សិតដែលបានចំណាយពេលភាគច្រើនលើការសិក្សានៅសាលារៀន/

គ្រឹះស្ថានសិក្សា (៣) អ្នកនៅក្នុងបន្ទុក សំដៅលើទារក និងកុមារដែលមិនទាន់ចូលរៀននៅសាលា អ្នកពិការអចិន្ត្រៃយ៍ មិនអាចធ្វើការងារបាន អ្នកជំងឺមិនអាចធ្វើការងារបាន ឬចាស់ជរា។ រាប់បញ្ចូលផងដែរ អ្នកដែលមិនអាចចាត់ថ្នាក់ប្រភេទអសកម្មជនសេដ្ឋកិច្ចណាមួយ និងជាអ្នកនៅក្នុងបន្ទុកផ្សេងទៀត។ ទោះជាយ៉ាងណាក៏ដោយ បើអ្នកទាំងនេះបានស្វែងរកការងារធ្វើ ឬអាចធ្វើការងារបាន អ្នកនោះត្រូវបានចាត់ទុកជាអ្នកគ្មានការងារធ្វើ និងមិនមែនជាអ្នកនៅក្នុងបន្ទុកទៀតឡើយ (៤) អ្នកជួលអចលនទ្រព្យ អ្នកចូលនិវត្តន៍ ឬទទួលកម្រៃជើងសារដ៏ទៃទៀត ជាអ្នកដែលបានចូលនិវត្តន៍ពីការងារ ហើយភាគច្រើនមិនបានធ្វើការងារទៀតទេ (ឧទាហរណ៍ ភាគច្រើនមិនធ្វើការងារទៀតឡើយ ឬមិនចូលរួមក្នុងការងារដ៏ទៃទៀត ដូចជាការដាំដុះ អាជីវកម្ម ពាណិជ្ជកម្មជាដើម ឬភាគច្រើនជាអ្នកជួលអចលនទ្រព្យ ឬជាអ្នករស់នៅក្នុងវិស័យសិកម្ម ឬមិនមែនកសិកម្ម ការជួល ឬទទួលភាគលាភដែលមិនមែនជាអ្នកមានការងារធ្វើ ឬអ្នកគ្មានការងារធ្វើ ឬជនដ៏ទៃទៀតដែលឯករាជ្យរស់នៅដោយសុវត្ថិភាពដោយមិនមានធ្វើការអ្វីឡើយ និង (៥) ប្រភេទដ៏ទៃទៀត (បញ្ជាក់) រួមមានអ្នកមិនមែនសកម្មជនសេដ្ឋកិច្ច ដែលមិនចាត់បញ្ចូលក្នុងចំណាត់ថ្នាក់ទាំងបួនប្រភេទខាងលើ។

## ៥.២. សកម្មជនសេដ្ឋកិច្ច និងកំលាំងពលកម្ម

អត្រាចូលរួមកម្លាំងពលកម្ម (LFPR) ត្រូវបានកំណត់ដោយចំនួនមនុស្សដែលស្ថិតក្នុងកម្លាំងពលកម្ម (អ្នកមានការងារធ្វើ និងអ្នកគ្មានការងារធ្វើ) តាមអាយុ ភេទ និងតំបន់ ចែកនឹងចំនួនមនុស្សសរុបតាមចរិតលក្ខណៈដូចគ្នា ហើយគុណនឹង ១០០។

សកម្មជនសេដ្ឋកិច្ចជាផ្នែកមួយនៃកម្លាំងពលកម្មសម្រាប់ផលិតកម្មទំនិញ និងសេវាកម្ម។ ម្យ៉ាងទៀត សកម្មជនសេដ្ឋកិច្ចរាប់បញ្ចូលអ្នកកំពុងធ្វើការងារបច្ចុប្បន្ន និងអ្នកគ្មានការងារធ្វើ ក្នុងរយៈពេលយោងក្នុងពេលស្រង់ទិន្នន័យជំរឿន។ ដូចបានឃើញក្នុងតារាង ៥.២.១ សកម្មភាពសេដ្ឋកិច្ចសរុបនៅថ្នាក់ជាតិបានកើន ៣,៣ ភាគរយ ក្នុងរយៈពេល ឆ្នាំ ២០០៨-២០១៩។ ចំពោះបុរស ភាគរយបានកើន ៥,៩ ភាគរយ ខ្ពស់ជាងធៀបនឹងស្ត្រីកើន ១ ភាគរយ។

## រូប ៥.២.១. ស្ថានភាពសកម្មភាពសេដ្ឋកិច្ចអាយុ ៥ ឆ្នាំឡើង តាមភេទ និងតំបន់កម្ពុជា ឆ្នាំ២០០៨-២០១៩




ដូចបានឃើញក្នុងរូប និងតារាងអសកម្មសេដ្ឋកិច្ចរួមមានមនុស្សដែលមានអាយុចាប់ពី ៥ ឆ្នាំឡើង ដែលមិនធ្វើការហើយមិនមានការងារធ្វើក្នុងរយៈពេលយោង។ អសកម្មជនសេដ្ឋកិច្ចក្នុងចំណោមស្រី (៤១,០ ភាគរយ) ខ្ពស់ជាងប្រុស (៣៤,៨ ភាគរយ)។

## តារាង ៥.២.១. ស្ថានភាពសកម្មភាពសេដ្ឋកិច្ច អាយុ ៥ ឆ្នាំឡើង តាមភេទ និងតំបន់ កម្ពុជា ឆ្នាំ២០០៨-២០១៩

| ស្ថានភាពសកម្មភាព | ២០០៨ | | | ២០១៩ | | |
|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) |
| ចំនួន | | | | | | |
| **សរុប** | | | | | | |
| សកម្មភាពសេដ្ឋកិច្ច | ៧.០៥៣.៣៩៨ | ៣.៤៤៥.០៥៣ | ៣.៦០៨.៣៤៥ | ៨.៧៤៩.៥៨៧ | ៤.៤៥៣.៥៣១ | ៤.២៩៦.០៥៦ |
| មានការងារធ្វើ | ៦.៩៣៥.២៤៦ | ៣.៣៩២.៦៣៧ | ៣.៥៤២.៦០៩ | ៨.៦២៦.៧៧៧ | ៤.៣៩៦.៨៥០ | ៤.២២៩.៩២៧ |
| គ្មានការងារធ្វើ | ១១៨.១៥២ | ៥២.៤១៦ | ៦៥.៧៣៦ | ១២២.៨១០ | ៥៦.៦៨១ | ៦៦.១២៩ |
| អសកម្មជនសេដ្ឋកិច្ច | ៤.៩៦៩.៦៦៩ | ២.៣៦៧.៩៤៣ | ២.៦០១.៧២៦ | ៥.៣៥២.៤៦៥ | ២.៣៧២.៣៤៣ | ២.៩៨០.១២២ |
| **ទីប្រជុំជន** | | | | | | |
| សកម្មភាពសេដ្ឋកិច្ច | ១.២៩១.៥១១ | ៦៧៥.៥៨០ | ៦១៥.៩៣១ | ៣.៤២៥.៧៤៤ | ១.៨០០.២៨៧ | ១.៦២៥.៤៥៧ |
| មានការងារធ្វើ | ១.២៣៣.១៧៤ | ៦៥១.២៩៧ | ៥៨១.៨៧៧ | ៣.៣៦២.៣៥៧ | ១.៧៧១.១៧៤ | ១.៥៩១.១៨៣ |
| គ្មានការងារធ្វើ | ៥៨.៣៣៧ | ២៤.២៨៣ | ៣៤.០៥៤ | ៦៣.៣៨៧ | ២៩.១១៣ | ៣៤.២៧៤ |
| អសកម្មជនសេដ្ឋកិច្ច | ១.១១៥.៩៦៥ | ៤៧៤.០៦១ | ៦៤១.៩០៤ | ២.១៩៧.១២៦ | ៩២៩.៣២៣ | ១.២៦៧.៨០៣ |
| **ជនបទ** | | | | | | |
| សកម្មភាពសេដ្ឋកិច្ច | ៥.៧៦១.៨៨៧ | ២.៧៦៩.៤៧៣ | ២.៩៩២.៤១៤ | ៥.៣២៣.៨៤៣ | ២.៦៥៣.២៤៤ | ២.៦៧០.៥៩៩ |
| មានការងារធ្វើ | ៥.៧០២.០៧២ | ២.៧៤១.៣៤០ | ២.៩៦០.៧៣២ | ៥.២៦៤.៤២០ | ២.៦២៥.៦៧៦ | ២.៦៣៨.៧៤៤ |

| ស្ថានភាពសកម្មភាព | ២០០៨ | | | ២០១៩ | | |
|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) |
| គ្មានការងារធ្វើ | ៥៩.៨១៥ | ២៨.១៣៣ | ៣១.៦៨២ | ៥៩.៤២៣ | ២៧.៥៦៨ | ៣១.៨៥៥ |
| អសកម្មជនសេដ្ឋកិច្ច | ៣.៨៥៣.៧០៤ | ១.៨៩៣.៨៨២ | ១.៩៥៩.៨២២ | ៣.១៥៥.៣៣៩ | ១.៤៤៣.០២០ | ១.៧១២.៣១៩ |
| **ភាគរយ** | | | | | | |
| **សរុប** | | | | | | |
| សកម្មភាពសេដ្ឋកិច្ច | ៥៨,៧ | ៥៩,៣ | ៥៨,១ | ៦២,០ | ៦៥,២ | ៥៩,០ |
| មានការងារធ្វើ | ៥៧,៧ | ៥៨,៤ | ៥៧,០ | ៦១,២ | ៦៤,៤ | ៥៨,១ |
| គ្មានការងារធ្វើ | ១,០ | ០,៩ | ១,១ | ០,៩ | ០,៨ | ០,៩ |
| អសកម្មជនសេដ្ឋកិច្ច | ៤១,៣ | ៤០,៧ | ៤១,៩ | ៣៨,០ | ៣៤,៨ | ៤១,០ |
| **ទីប្រជុំជន** | | | | | | |
| សកម្មភាពសេដ្ឋកិច្ច | ៥៣,៦ | ៥៨,៨ | ៤៩,០ | ៦០,៩ | ៦៦,០ | ៥៦,២ |
| មានការងារធ្វើ | ៥១,២ | ៥៦,៧ | ៤៦,៣ | ៥៩,៨ | ៦៤,៩ | ៥៥,០ |
| គ្មានការងារធ្វើ | ២,៤ | ២,១ | ២,៧ | ១,១ | ១,១ | ១,២ |
| អសកម្មជនសេដ្ឋកិច្ច | ៤៦,៤ | ៤១,២ | ៥១ | ៣៩,១ | ៣៤,០ | ៤៣,៨ |
| **ជនបទ** | | | | | | |
| សកម្មភាពសេដ្ឋកិច្ច | ៥៩,៩ | ៥៩,៤ | ៦០,៤ | ៦២,៨ | ៦៤,៨ | ៦០,៩ |
| មានការងារធ្វើ | ៥៩,៣ | ៥៨,៨ | ៥៩,៨ | ៦២,១ | ៦៤,១ | ៦០,២ |
| គ្មានការងារធ្វើ | ០,៦ | ០,៦ | ០,៦ | ០,៧ | ០,៧ | ០,៧ |
| អសកម្មជនសេដ្ឋកិច្ច | ៤០,១ | ៤០,៦ | ៣៩,៦ | ៣៧,២ | ៣៥,២ | ៣៩,១ |

***សម្គាល់ ៖*** *ភាគរយនៃស្ថានភាពសកម្មភាពសេដ្ឋកិច្ចត្រូវបានគណនាមិនរាប់បញ្ចូលសកម្មភាពសំខាន់ដែលមិនបានរាយការណ៍។*

អត្រាសកម្មភាពសេដ្ឋកិច្ច ឬអត្រាចូលរួមកម្លាំងពលកម្ម (LFPR) ក្នុងចំណោមប្រជាជនអាយុក្រោម ១៥ ឆ្នាំ បានធ្លាក់ចុះពី ៣,១ ភាគរយ នៅឆ្នាំ២០០៨ មក ២,១ ភាគរយ នៅឆ្នាំ២០១៩ អាចមកពីការរីកចម្រើនលើគ្រប់វិស័យរបស់ប្រទេសនាពេលបច្ចុប្បន្ន។ អាយុក្នុងកម្លាំងពលកម្ម ១៥-១៩ បានបង្ហាញពីភាពប្រសើឡើងនៅឆ្នាំ២០១៩ បើធៀបនឹងឆ្នាំ២០០៨។ ជំរឿនឆ្នាំ២០១៩ អត្រាចូលរួមកម្លាំងពលកម្ម (LFPR) ខ្ពស់ ៧៩,១ ភាគរយ សម្រាប់ទាំងពីរភេទ ៨៤,៤ ភាគរយ សម្រាប់ប្រុស និង ៧៤,៣ ភាគរយ សម្រាប់ស្រី បើធៀបនឹងប្រទេសជិតខាង។ ឧទាហរណ៍ អត្រាចូលរួមកម្លាំងពលកម្មប្រុស និងស្រី នៅប្រទេសវៀតណាមមាន ៨២,៣ ភាគរយ និង ៧១,៦ ភាគរយ តាមលំដាប់រៀង និង ៨២,៥ ភាគរយ និង ៦៤,៧ ភាគរយ តាមលំដាប់រៀង សម្រាប់ប្រទេសឡាវ (ប្រភព ៖ លេខាធិការដ្ឋានអាស៊ាន ស្ថិតិអាស៊ាន (ASEAN stats) ២០១៨)។

## តារាង ៥.២.២. អត្រាចូលរួមកម្លាំងពលកម្មអាយុជាក់លាក់ (ភាគរយ) តាមក្រុមអាយុ ភេទ និងតំបន់ កម្ពុជា ឆ្នាំ២០០៨-២០១៩

| ក្រុមអាយុ | អត្រាសកម្មភាពសេដ្ឋកិច្ច | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | សរុប | | | ទីប្រជុំជន | | | ជនបទ | | |
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨) | (៩) | (១០) |
| ២០០៨ | | | | | | | | | |
| ៥ ឆ្នាំឡើង | ៥៨,៧ | ៥៩,៣ | ៥៨,១ | ៥៣,៦ | ៥៨,៨ | ៤៩,០ | ៥៩,៩ | ៥៩,៤ | ៦០,៤ |
| ១៥ ឆ្នាំឡើង | ៧៨,៣ | ៨០,៨ | ៧៦,០ | ៦៥,៨ | ៧៣,៤ | ៥៩,១ | ៨១,៨ | ៨២,៩ | ៨០,៨ |
| ៥ - ១៤ | ៣,១ | ៣,០ | ៣,២ | ១,៨ | ១,៥ | ២,១ | ៣,៣ | ៣,៣ | ៣,៤ |
| ១៥ - ២៤ | ៦០,១ | ៥៧,១ | ៦៣,២ | ៥០,៣ | ៤៦,៤ | ៥៣,៨ | ៦៣,២ | ៦០,១ | ៦៦,៤ |
| ២៥ - ៥៩ | ៩១,៧ | ៩៦,៨ | ៨៧,៣ | ៧៩,៦ | ៩២,៧ | ៦៧,៦ | ៩៥,១ | ៩៨,០ | ៩២,៥ |
| ៦០ ឆ្នាំឡើង | ៦២,៦ | ៧៥,៥ | ៥៣,៧ | ៣៧,៩ | ៥៤,៧ | ២៦,៨ | ៦៧,៧ | ៧៩,៦ | ៥៩,៤ |
| ២០១៩ | | | | | | | | | |
| ៥ ឆ្នាំឡើង | ៦២,០ | ៦៥,២ | ៥៩,០ | ៦០,៩ | ៦៦,០ | ៥៦,២ | ៦២,៨ | ៦៤,៨ | ៦០,៩ |
| ១៥ ឆ្នាំឡើង | ៧៩,១ | ៨៤,៤ | ៧៤,៣ | ៧៤,៧ | ៨១,៨ | ៦៨,១ | ៨២,២ | ៨៦,៣ | ៧៨,៦ |
| ៥ - ១៤ | ២,១ | ២,៥ | ១,៦ | ១,៧ | ២,០ | ១,៤ | ២,៣ | ២,៨ | ១,៨ |
| ១៥ - ២៤ | ៥៨,៤ | ៥៨,៩ | ៥៧,៩ | ៥៥,៨ | ៥៥,៩ | ៥៥,៧ | ៦០,៣ | ៦១,១ | ៥៩,៤ |
| ២៥ - ៥៩ | ៩០,៧ | ៩៦,៣ | ៨៥,៤ | ៨៦,៤ | ៩៤,៤ | ៧៨,៧ | ៩៣,៨ | ៩៧,៨ | ៩០,២ |
| ៦០ ឆ្នាំឡើង | ៦០,៧ | ៧២,៥ | ៥២,៨ | ៤៨,២ | ៦២,០ | ៣៨,៩ | ៦៧,៩ | ៧៨,៧ | ៦០,៨ |

តារាង ៥.២.១ បង្ហាញថា ស្រីនៅតែបន្តចូលរួម និងចាកចេញពីកម្លាំងពលកម្មក្នុងកម្រិតអាយុក្មេងជាងប្រុស។ លទ្ធផលជំរឿនបង្ហាញថាអត្រាចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច ប្រុសចាប់ផ្តើមខ្ពស់ជាងស្រីនៅគ្រប់ក្រុមអាយុបន្ទាប់ពីអាយុ ២០ ឆ្នាំឡើង។ អត្រាចូលរួមសកម្មភាពសេដ្ឋកិច្ចនៅជនបទខ្ពស់ជាងទីប្រជុំជនទាំងប្រុស និងស្រី អាចមកពីអត្រាចូលរួមខ្ពស់ក្នុងការងារកសិកម្មនៅជនបទ និងអត្រាចូលរួមក្នុងការសិក្សាខ្ពស់របស់កុមារនៅទីប្រជុំជន។ ទាំងទីប្រជុំជន និងជនបទ អត្រាចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចប្រុសខ្ពស់ជាងស្រី ដោយឡែកគំលាតអត្រាចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចរវាងប្រុស និងស្រី មានតិចនៅជនបទជាងទីប្រជុំជន។

រូប ៥.២.២. អត្រាអ្នកចូលរួមក្នុងកម្លាំងពលកម្មអាយុជាក់លាក់ តាមភេទ កម្ពុជា ឆ្នាំ២០០៨-២០១៩




## ៥.៣. មានការងារធ្វើ និង គ្មានការងារធ្វើ

មានការងារធ្វើគឺជាសូចនាករដ៏សំខាន់សម្រាប់វាយតម្លៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គម។ ការវិភាគអំពីការផ្លាស់ប្តូរសក្តានុពលនៃការងារបានអនុញ្ញាតឲ្យយើងវាយតម្លៃផលប៉ះពាល់ដល់ការផ្លាស់ប្តូរសេដ្ឋកិច្ច សង្គម និងដាក់ចេញនូវគោលនយោបាយការងារឲ្យសមស្របទៅនឹងលក្ខខណ្ឌសេដ្ឋកិច្ច សង្គម។ សេដ្ឋកិច្ចកម្ពុជាបានផ្លាស់ប្តូរនៅក្នុងប៉ុន្មានទសវត្សរ៍មកនេះ។ ការអភិវឌ្ឍនេះបានចូលរួមចំណែកជាមួយការកែលម្អឲ្យប្រសើរឡើងក្នុងការអប់រំនូវកម្លាំងពលកម្ម ដោយមានការផ្លាស់ប្តូររចនាសម្ព័ន្ធ និងការរៀបចំបែងចែកកម្លាំងពលកម្មការងារ។

ជំរឿនឆ្នាំ២០១៩ ភាគច្រើននៃកម្លាំងពលកម្មគឺអ្នកមានការងារធ្វើ ចំនួនអ្នកគ្មានការងារធ្វើមានចំណែកតិចតួចប៉ុណ្ណោះ។ ដូច្នេះ ការវិភាគចរិតលក្ខណៈមូលដ្ឋាននៃកម្លាំងពលកម្មធ្វើការតាមអាយុ ភេទ ស្ថានភាពអាពាហ៍ពិពាហ៍ វិស័យការងារ ស្ថានភាពការងារ និងស្ថានភាពទូទៅនៃកម្លាំងពលកម្មនៅក្នុងប្រទេស។

អត្រាមានការងារធ្វើត្រូវបានកំណត់ជាភាគរយនៃអ្នកមានការងារធ្វើ ទៅនឹងចំនួនប្រជាជនសរុបនៅក្នុងកម្លាំងពលកម្ម មាន ៩៨,៣ ភាគរយ នៅឆ្នាំ២០០៨ និង ៩៨,៦ ភាគរយ នៅឆ្នាំ២០១៩ នៅប្រទេសកម្ពុជា។

## រូប៥.៣.១. អត្រាមានការងារធ្វើ អាយុ៥ ឆ្នាំឡើង តាមភេទ តំបន់ កម្ពុជា ឆ្នាំ២០០៨- ២០១៩




អត្រាគ្មានការងារធ្វើជាផលធៀបនៃចំនួនអ្នកគ្មានការងារធ្វើ ក្នុងចំណោមកម្លាំងពលកម្មសម្រាប់ ១០០ នាក់។ អត្រាគ្មានការងារធ្វើក្នុងក្រុមអាយុ ១៥ ឆ្នាំឡើង នៅកម្ពុជាមាន ១,៣ ភាគរយ នៅឆ្នាំ២០១៩។ អត្រាអ្នកគ្មានការងារធ្វើធ្លាក់ចុះក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ។ នៅឆ្នាំ២០១៩ អត្រាគ្មានការងារធ្វើក្នុងចំណោមប្រុសមាន ១,២ ភាគរយ និងស្រី ១,៥ ភាគរយ។ នៅថ្នាក់ជាតិ អត្រាគ្មានការងារធ្វើមាន ១៣នាក់ ក្នុងចំណោមកម្លាំងពលកម្ម ១.០០០ នាក់គិតជាចំនួនដាច់ខាតអ្នកគ្មានការងារធ្វើមាន ១២២.៨១០នាក់ ។

## រូប ៥.៣.២. អត្រាគ្មានការងារធ្វើអាយុជាក់លាក់ តាមក្រុមអាយុ តំបន់ កម្ពុជា ឆ្នាំ២០១៩



## ៥.៤. ស្ថានភាពការងារ

ចំណាត់ស្ថានភាពការងារចំនួនប្រាំត្រូវបានប្រមូលក្នុងជំរឿនឆ្នាំ២០១៩ អនុលោមតាមគោលការណ៍សកម្មភាពក្នុងជំរឿន រួមមាននិយោជក និយោជិតមានប្រាក់ឈ្នួល អ្នកធ្វើការដោយទុនផ្ទាល់ខ្លួន អ្នកធ្វើការឲ្យគ្រួសារមិនយកប្រាក់ឈ្នួល និងផ្សេងទៀត (បញ្ជាក់)។ សម្រាប់ការវិភាគទិន្នន័យនៃស្ថានភាពការងារ តារាងទិន្នន័យនឹងបែងចែកតាមតំបន់ទីប្រជុំជន ជនបទ និងភេទ។

លទ្ធផលចុងក្រោយជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ បានឲ្យដឹងថាអ្នកធ្វើការងារឲ្យគ្រួសារមិនយកប្រាក់ឈ្នួល និងអ្នកធ្វើការងារដោយទុនផ្ទាល់ខ្លួន មានប្រមាណ ៦៧,៧ ភាគរយនៃប្រជាជនមានការងារធ្វើនៅកម្ពុជា ឆ្នាំ២០១៩ (តារាង ៥.៤.១)។ សមាមាត្រដូចគ្នានេះមាន ៨២,៦ ភាគរយ នៅឆ្នាំ២០០៨។ ការធ្លាក់ចុះនៃសមាមាត្រក្នុងអំឡុងឆ្នាំ២០០៨-២០១៩ ភាគច្រើនដោយសារការធ្លាក់ចុះនៃសមាមាត្រអ្នកធ្វើការងារឲ្យគ្រួសារមិនយកប្រាក់ឈ្នួល ជាពិសេសចំណោមស្រីនៅជនបទ។ និយោជិតមានប្រាក់ឈ្នួលមានតែ ៣១,៥ ភាគរយ ហើយភាគច្រើននៃអ្នកធ្វើការនេះនៅប្រទេសកម្ពុជា នៅក្នុងវិស័យក្រៅប្រព័ន្ធ។ សមាមាត្រស្រីធ្វើការក្នុងវិស័យក្រៅប្រព័ន្ធខ្ពស់ជាងប្រុស។ ប្រមាណ ៥០,៣ ភាគរយនៃអ្នកធ្វើការប្រុស ជាអ្នកធ្វើការដោយទុនផ្ទាល់ខ្លួន។ ស្រីធ្វើការឲ្យគ្រួសារមិនយកប្រាក់ឈ្នួលមានសមាមាត្រខ្ពស់ (៣៥,៤ ភាគរយ)។ សមាមាត្រអ្នកធ្វើការដោយទុនផ្ទាល់ខ្លួនបានធ្លាក់ចុះ និងសមាមាត្រ និយោជិតមានប្រាក់ឈ្នួលបានកើនឡើងគួរឲ្យកត់សម្គាល់រវាងឆ្នាំ២០០៨-២០១៩។ នៅឆ្នាំ២០១៩ ក៏ដូចឆ្នាំ២០០៨ សមាមាត្រនិយោជិតយកប្រាក់ឈ្នួលក្នុងចំណោមប្រុសខ្ពស់ជាងស្រី។

| ៦០ - ៦៤ | ១៤១.១០៥ | ១០០ | ១៥,៨ | ៨៤,២ | ១១៣.២៨៩ | ១០០ | ០,០ | ៤៥,៤ | ២៤,៣ | ២៥,៣ | ១,៩ | ០,១ | ០,២ | ១,៨ | ០,៩ | ០,១ |
| ៦៥ - ៦៩ | ១០៣.១៧៤ | ១០០ | ១៥,៩ | ៨៤,១ | ៨២.៦១៣ | ១០០ | ០,០ | ៤៤,៥ | ២៥,៣ | ២៥,១ | ២,០ | ០,១ | ០,២ | ១,៩ | ០,៧ | ០,១ |
| ៧០ - ៧៤ | ៦១.៨៤៦ | ១០០ | ១៩,២ | ៨០,៨ | ៤៧.១៤៣ | ១០០ | ០,០ | ៤៨,៥ | ២៥,០ | ២២,៣ | ១,៧ | ០,១ | ០,៣ | ១,៥ | ០,៦ | ០,០ |
| ៧៥ + | ៦៩.៦២០ | ១០០ | ២៩,៥ | ៧០,៥ | ៤៤.៧៦៤ | ១០០ | ០,០ | ៥៣,៣ | ២៣,២ | ២០,០ | ១,៦ | ០,១ | ០,២ | ១,១ | ០,៥ | ០,១ |
| ប្រុស | ១.៧០០.៤៤៤ | ១០០ | ៧,៣ | ៩២,៧ | ១.៥៣៩.២៩៤ | ១០០ | ០,៤ | ២៩,២ | ២៧,៣ | ២៩,៦ | ៤,៥ | ០,៣ | ០,៧ | ៦,០ | ១,៨ | ០,១ |
| ៧-៩ | ២៩.៧២៤ | ១០០ | ១៨,៧ | ៨១,៣ | ២៦.៧២៥ | ១០០ | ២០,៧ | ៧៩,២ | ០,២ | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ |
| ១០ - ១៤ | ៧០.០០៧ | ១០០ | ៤,២ | ៩៥,៨ | ៦៦.៨៥១ | ១០០ | ១,១ | ៧០,៧ | ២៧,០ | ១,១ | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ |
| ១៥ - ១៩ | ១០៥.១៦០ | ១០០ | ៤,៥ | ៩៥,៥ | ៩៨.៥៣៨ | ១០០ | ០,៣ | ២០,៨ | ៣៦,២ | ៣៧,២ | ៤,៦ | ០,៦ | ០,៣ | ០,០ | ០,០ | ០,០ |
| ២០ - ២៤ | ១៥២.៥២១ | ១០០ | ៥,៨ | ៩៤,២ | ១៤០.៨០៦ | ១០០ | ០,០ | ១៩,៨ | ២៧,៥ | ៣៣,០ | ១២,៦ | ០,៤ | ១,៨ | ៤,៥ | ០,២ | ០,០ |
| ២៥ - ២៩ | ២២០.២០៦ | ១០០ | ៥,៨ | ៩៤,២ | ២០៣.២០២ | ១០០ | ០,០ | ២០,៣ | ២៧,៩ | ៣៣,០ | ៦,០ | ០,៣ | ១,០ | ១០,១ | ១,៤ | ០,១ |
| ៣០ - ៣៤ | ២២៥.៤៧៥ | ១០០ | ៦,០ | ៩៤,០ | ២០៧.១៧១ | ១០០ | ០,០ | ២១,៩ | ២៦,៦ | ៣២,៩ | ៤,២ | ០,៣ | ០,៨ | ១០,៧ | ២,៥ | ០,១ |
| ៣៥ - ៣៩ | ២៣២.៨៤៣ | ១០០ | ៦,៦ | ៩៣,៤ | ២១២.៥៨១ | ១០០ | ០,០ | ២៤,៤ | ២៥,៧ | ៣៣,០ | ៣,៨ | ០,៣ | ០,៨ | ៨,៨ | ៣,១ | ០,១ |
| ៤០ - ៤៤ | ១៣៣.៣៣០ | ១០០ | ៧,៩ | ៩២,១ | ១១៩.២៦០ | ១០០ | ០,០ | ២៨,២ | ២៧,៦ | ៣១,០ | ៣,៣ | ០,៣ | ០,៧ | ៦,០ | ២,៩ | ០,១ |
| ៤៥ - ៤៩ | ១៤០.៣៣៩ | ១០០ | ៧,៧ | ៩២,៣ | ១២៦.០៨៥ | ១០០ | ០,០ | ២៦,៨ | ២៧,៦ | ៣១,៥ | ៣,៨ | ០,៥ | ០,៨ | ៥,៨ | ៣,១ | ០,១ |

| ក្រុមអាយុ | អក្ខរភាព | | | | កម្រិតសិក្សា | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចំនួនទេសន្តរប្រវេសន៍ | សរុប | អនក្ខរភាព | អក្ខរភាព | ចំនួនទេសន្តរប្រវេសន៍ | សរុប | គ្មាន | មិនបានបញ្ចប់បឋមសិក្សា | បញ្ចប់បឋមសិក្សា | មធ្យមសិក្សាបឋមភូមិ | មធ្យមសិក្សា/មធ្យមសិក្សាទុតិយភូមិ | សញ្ញាបត្រមធ្យមសិក្សាបឋមភូមិមានបច្ចេកទេស/វិជ្ជាជីវៈ | សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមានបច្ចេកទេស/វិជ្ជាជីវៈ | សញ្ញាបត្រថ្នាក់បរិញ្ញាបត្រ | សញ្ញាបត្រថ្នាក់អនុបណ្ឌិត/បណ្ឌិត | ផ្សេងទៀត |
| ៥០ - ៥៤ | ១១៩.២៤០ | ១០០ | ៨,៧ | ៩១,៣ | ១០៥.៥៧០ | ១០០ | ០,០ | ៣១,៤ | ២៩,៥ | ២៧,៤ | ៣,៦ | ០,៤ | ០,៧ | ៤,៤ | ២,៦ | ០,១ |
| ៥៥ - ៥៩ | ១០០.៨៧៩ | ១០០ | ១១,៣ | ៨៨,៧ | ៨៦.២៤៨ | ១០០ | ០,០ | ៤០,១ | ២៧,៤ | ២៥,៣ | ២,៣ | ០,២ | ០,៣ | ២,៦ | ១,៦ | ០,១ |
| ៦០ - ៦៤ | ៦៥.១៨៦ | ១០០ | ១០,៣ | ៨៩,៧ | ៥៦.១៦៦ | ១០០ | ០,០ | ៣៩,៩ | ២៦,៣ | ២៧,១ | ២,២ | ០,២ | ០,៣ | ២,៤ | ១,៥ | ០,១ |
| ៦៥ - ៦៩ | ៤៧.៦៥៨ | ១០០ | ៨,៨ | ៩១,២ | ៤១.៨៣០ | ១០០ | ០,០ | ៣៧,៩ | ២៧,៤ | ២៧,៦ | ២,៦ | ០,២ | ០,៣ | ២,៧ | ១,២ | ០,១ |
| ៧០ - ៧៤ | ២៧.៩៩១ | ១០០ | ៩,៦ | ៩០,៤ | ២៤.២៧៣ | ១០០ | ០,០ | ៤០,៦ | ២៨,១ | ២៥,៤ | ២,២ | ០,១ | ០,៣ | ២,១ | ០,៩ | ០,០ |
| ៧៥ + | ២៩.៨៨៥ | ១០០ | ១៥,០ | ៨៥,០ | ២៣.៩៨៨ | ១០០ | ០,០ | ៤៥,៩ | ២៦,៨ | ២២,៦ | ២,១ | ០,១ | ០,៣ | ១,៤ | ០,៧ | ០,១ |
| ស្រី | ១.៥៣៦.៥៩៩ | ១០០ | ១២,៦ | ៨៧,៤ | ១.៣០៤.១៩៤ | ១០០ | ០,៤ | ៣៧,០ | ២៨,០ | ២៥,១ | ៣,៧ | ០,៣ | ០,៥ | ៤,២ | ០,៧ | ០,០ |
| ៧-៩ | ២៨.៣៦០ | ១០០ | ១៧,៣ | ៨២,៧ | ២៥.៦៥៩ | ១០០ | ១៨,៦ | ៨១,២ | ០,១ | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ |
| ១០ - ១៤ | ៦៣.៨២៨ | ១០០ | ៣,៣ | ៩៦,៧ | ៦១.៤៥៥ | ១០០ | ០,៧ | ៦៧,១ | ៣០,៨ | ១,៤ | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ |
| ១៥ - ១៩ | ១០៦.២១១ | ១០០ | ៤,១ | ៩៥,៩ | ១០០.០០០ | ១០០ | ០,១ | ១៧,៩ | ៣៦,៥ | ៣៩,១ | ៥,៣ | ០,៦ | ០,៤ | ០,០ | ០,០ | ០,០ |
| ២០ - ២៤ | ១៥៥.៨០៨ | ១០០ | ៥,៥ | ៩៤,៥ | ១៤៤.៤២០ | ១០០ | ០,០ | ២០,៧ | ៣០,៣ | ៣០,៨ | ១០,៦ | ០,៥ | ១,៥ | ៥,២ | ០,២ | ០,០ |
| ២៥ - ២៩ | ១៩៧.៥៧៧ | ១០០ | ៦,៥ | ៩៣,៥ | ១៨១.០១៧ | ១០០ | ០,០ | ២៣,៥ | ៣០,៦ | ២៩,៥ | ៤,៧ | ០,៣ | ០,៨ | ៩,៥ | ០,៩ | ០,១ |
| ៣០ - ៣៤ | ១៨៥.៧៧២ | ១០០ | ៨,៧ | ៩១,៣ | ១៦៥.៧២៩ | ១០០ | ០,០ | ២៩,៣ | ៣០,០ | ២៧,១ | ៣,២ | ០,៣ | ០,៥ | ៨,០ | ១,៥ | ០,១ |
| ៣៥ - ៣៩ | ១៨១.៩៦៤ | ១០០ | ១១,៥ | ៨៨,៥ | ១៥៦.៩១០ | ១០០ | ០,០ | ៣៥,៥ | ២៨,៣ | ២៥,៨ | ២,៨ | ០,២ | ០,៥ | ៥,៤ | ១,៣ | ០,០ |
| ៤០ - ៤៤ | ១០៤.៧៤២ | ១០០ | ១៥,០ | ៨៥,០ | ៨៥.៩៩៧ | ១០០ | ០,០ | ៤០,៨ | ២៨,៨ | ២៣,៩ | ២,៤ | ០,២ | ០,៤ | ២,៧ | ០,៨ | ០,០ |
| ៤៥ - ៤៩ | ១១៤.៣៣៥ | ១០០ | ១៤,៥ | ៨៥,៥ | ៩៤.៥៩៤ | ១០០ | ០,០ | ៤០,៧ | ២៧,៦ | ២៥,២ | ២,៦ | ០,៣ | ០,៥ | ២,៤ | ០,៧ | ០,០ |
| ៥០ - ៥៤ | ១០១.១៨៤ | ១០០ | ១៨,២ | ៨១,៨ | ៧៩.២១៦ | ១០០ | ០,០ | ៤៩,៧ | ២៥,២ | ១៩,៨ | ២,០ | ០,២ | ០,៤ | ២,០ | ០,៧ | ០,១ |
| ៥៥ - ៥៩ | ៩១.៧៩៣ | ១០០ | ២២,៥ | ៧៧,៥ | ៦៧.៦៤៥ | ១០០ | ០,០ | ៥៤,៦ | ២១,៧ | ២០,៦ | ១,២ | ០,១ | ០,២ | ១,១ | ០,៤ | ០,០ |
| ៦០ - ៦៤ | ៧៥.៩១៩ | ១០០ | ២០,៦ | ៧៩,៤ | ៥៧.១២៣ | ១០០ | ០,០ | ៥០,៨ | ២២,៣ | ២៣,៥ | ១,៥ | ០,១ | ០,២ | ១,១ | ០,៤ | ០,០ |
| ៦៥ - ៦៩ | ៥៥.៥១៦ | ១០០ | ២២,០ | ៧៨,០ | ៤០.៧៨៣ | ១០០ | ០,០ | ៥១,៣ | ២៣,២ | ២២,៥ | ១,៤ | ០,១ | ០,២ | ១,១ | ០,៣ | ០,០ |
| ៧០ - ៧៤ | ៣៣.៨៥៥ | ១០០ | ២៧,២ | ៧២,៨ | ២២.៨៧០ | ១០០ | ០,០ | ៥៦,៨ | ២១,៧ | ១៩,០ | ១,២ | ០,១ | ០,២ | ០,៨ | ០,២ | ០,០ |
| ៧៥ + | ៣៩.៧៣៥ | ១០០ | ៤០,៤ | ៥៩,៦ | ២០.៧៣៦ | ១០០ | ០,១ | ៦១,៩ | ១៩,០ | ១៦,៩ | ១,០ | ០,០ | ០,១ | ០,៧ | ០,៣ | ០,០ |

## ៦.៩. អន្តោប្រវេសន៍

ដូចបានបញ្ជាក់ខាងដើមក្នុងផ្នែកនេះ ជនទេសន្តរប្រវេសន៍អន្តរជាតិត្រូវចាត់ថ្នាក់ជាជនអន្តោប្រវេសន៍ និងជននិប្រវេសន៍។ ជនអន្តោប្រវេសន៍គឺអ្នកចំណូលស្រុក និងជននិប្រវេសន៍គឺជាអ្នកចំណាកស្រុកចេញក្រៅប្រទេស។ នៅក្នុងជំរឿនប្រជាជន មានការលំបាកក្នុងការរាប់ជននិប្រវេសន៍ (ចំណាកស្រុក)។ ការប្រមូលទិន្នន័យមួយចំនួនត្រូវបានធ្វើឡើង ប៉ុន្តែទទួលបានជោគជ័យតិចតួចណាស់។ ក្នុងជំរឿនឆ្នាំ២០១៩ ការស្រង់ទិន្នន័យអន្តោប្រវេសន៍ បានប្រមូលព័ត៌មានលំនៅដ្ឋានពីមុន និងទីកន្លែងកំណើត។

តារាង ៦.៩.១ បានបង្ហាញការបែងចែកជនអន្តោប្រវេសន៍ តាមសកម្មភាពសេដ្ឋកិច្ច។ ជនអន្តោប្រវេសន៍ភាគច្រើនធ្វើការក្នុងវិស័យកសិកម្ម ប៉ុន្តែមានចំនួនតិចជាងក្នុងចំណោមប្រជាជនទូទៅ (៣៨,៤ ភាគរយ និង ៥៤,៧ ភាគរយ)។ បើប្រៀបធៀបនឹងចំនួនប្រជាជនសរុប ជនទេសន្តរប្រវេសន៍ភាគច្រើនធ្វើការក្នុងពាណិជ្ជកម្ម សំណង់ និងផលិតកម្ម (ប្រៀបធៀបតារាង ៦.៩.១ ជាមួយតារាង ៥.៦.២)។

ទោះបីទិន្នន័យអំពីនិប្រវេសន៍មិនមានក៏ដោយ ក៏វាមានសារៈសំខាន់ក្នុងការវិភាគពេញលេញមួយអំពីអន្តោប្រវេសន៍នៅក្នុងប្រធានបទវិភាគស៊ីជម្រៅនាពេលអនាគតផងដែរ។

**តារាង ៦.៩.១. ភាគរយជនអន្តោប្រវេសន៍អាយុ ៥ ឆ្នាំឡើង ជាសកម្មសេដ្ឋកិច្ច តាមភេទ និងប្រភេទសកម្មភាព កម្ពុជា ឆ្នាំ២០១៩**

| ប្រភេទសកម្មភាព | ទាំងពីរភេទ | ប្រុស | ស្រី |
|---|---|---|---|
| (១) | (២) | (៣) | (៤) |
| ចំនួនអន្តោប្រវេសន៍ | ៩៨.៦០៥ | ៥៨.៧៤៦ | ៣៩.៨៥៩ |
| សរុប | ១០០ | ១០០ | ១០០ |
| កសិកម្ម ព្រៃឈើ និងនេសាទ | ៣៨,៤ | ៣៨,១ | ៣៨,៩ |
| រុករករ៉ែ និងថ្ម | ០,២ | ០,៣ | ០,២ |
| ផលិតកម្ម | ៧,៥ | ៧,៥ | ៧,៤ |
| អគ្គិសនី ឧស្ម័ន ចំហាយទឹកនិងការផ្គត់ផ្គង់ម៉ាស៊ីនត្រជាក់ | ០,៣ | ០,៣ | ០,២ |
| ការផ្គត់ផ្គង់ទឹក លូទឹក ការគ្រប់គ្រងសំរាម និងសកម្មភាពបង្ការ | ០,២ | ០,២ | ០,២ |
| សំណង់ | ៧,៧ | ៨,៣ | ៦,៨ |
| ពាណិជ្ជកម្មលក់ដុំ និងរាយ ជួសជុលរថយន្ត និងទោចក្រយានយន្ត | ២១,១ | ១៩,៨ | ២៣,០ |
| ដឹកជញ្ជូន និងឃ្លាំង | ២,១ | ២,៥ | ១,៦ |
| សកម្មភាពសេវាកម្មទីស្នាក់អាស្រ័យ និងម្ហូបអាហារ | ៣,៨ | ៣,៥ | ៤,៤ |
| ព័ត៌មាន និងគមនាគមន៍ | ០,៥ | ០,៥ | ០,៤ |
| សកម្មភាពហិរញ្ញវត្ថុ និងធានារ៉ាប់រង | ០,៨ | ០,៩ | ០,៨ |
| អចលនទ្រព្យ | ០,១ | ០,១ | ០,១ |
| សកម្មភាពវិជ្ជាជីវៈ វិទ្យាសាស្ត្រ និងបច្ចេកទេស | ១,៥ | ១,៦ | ១,៥ |
| សកម្មភាពរដ្ឋបាល និងសេវាកម្មគាំទ្រ | ៦,៤ | ៧,១ | ៥,៣ |
| រដ្ឋបាលសាធារណៈ និងការការពារសន្តិសុខសង្គម | ១,៧ | ១,៩ | ១,៣ |
| ការសិក្សាអប់រំ | ២,៣ | ២,២ | ២,៣ |
| សកម្មភាពសុខាភិបាល និងការងារសង្គម | ០,៦ | ០,៥ | ០,៦ |
| សិល្បៈ ការកំសាន្ត និងការសប្បាយ | ១,៦ | ១,៧ | ១,៥ |
| សកម្មភាពសេវាកម្មដទៃទៀត | ៣,៤ | ៣,២ | ៣,៧ |
| សកម្មភាពប្រើប្រាស់គ្រួសារជានិយោជក | ០,០ | ០,០ | ០,០ |
| សកម្មភាពអង្គការ និងអង្គការក្រៅបទេស | ០,០ | ០,០ | ០,០ |

# ជំពូក ៧
# លទ្ធភាពបង្កើតកូន

## ៧.១. ទស្សនទាន

លទ្ធភាពបង្កើតកូនជាចំនួនកូនកើតរស់ដែលស្ត្រីម្នាក់ៗមាន។ លទ្ធភាពបង្កើតកូនផ្សេងពីសមត្ថភាពបង្កើតកូនដែលកំណត់ដោយលក្ខណៈជីវសាស្ត្រអំពីសមត្ថភាពដែលស្ត្រីអាចមានកូន។ លទ្ធភាពបង្កើតកូនកំណត់ដោយកត្តាភូមិសាស្ត្រដែលហៅថាអថេរមធ្យម (អាយុនៅពេលរៀបការ ការប្រើប្រាស់មធ្យោបាយពន្យាកំណើត រយៈពេលបំបៅដោះកូន ។ល។) លទ្ធភាពបង្កើតកូន ប៉ះពាល់ដោយកត្តាចម្បងជាច្រើនទៀត ដូចជាកត្តាសង្គម វប្បធម៌ បរិស្ថាន សេដ្ឋកិច្ច និងសុខភាព។

មានពីរវិធីសាស្ត្រសម្រាប់វាស់វែងលទ្ធភាពបង្កើតកូន គឺបច្ចុប្បន្ន (ឬរយៈពេល ឬផ្នែកឆ្លងកាត់) និងបូកបន្ត (ជំនាន់)។ ការវាស់វែងលទ្ធភាពបង្កើតកូនបច្ចុប្បន្ន សំដៅលើលទ្ធភាពបង្កើតកូនបច្ចុប្បន្នក្នុងចំណោមប្រជាជន ខណៈដែលលទ្ធភាពបង្កើតកូនបន្ត សំដៅលើលទ្ធភាពបង្កើតកូនដែលបានកើតឡើងក្នុងអតីតកាល ពីចំណុចមុនដំបូងដល់បច្ចុប្បន្ន។

ទិន្នន័យលទ្ធភាពបង្កើតកូនបច្ចុប្បន្នច្រើនតែប្រមូលដោយប្រព័ន្ធអត្រានុកូលដ្ឋាន តាមរយៈការចុះបញ្ជីកំណើត។ បើទិន្នន័យប្រភេទនេះមិនត្រូវបានប្រមូល ឬប្រមូលមិនពេញលេញដូចក្នុងករណីកម្ពុជា នោះជំរឿនជាប្រភពតែមួយគត់សម្រាប់ការគណនាលទ្ធភាពបង្កើតកូន។ ជំរឿនឆ្នាំ២០១៩ ក៏ដូចជាជំរឿនឆ្នាំ២០០៨ និងឆ្នាំ១៩៩៨ បានបញ្ចូលផ្នែកមួយដែលអាចគណនាលទ្ធភាពបង្កើតកូននាពេលបច្ចុប្បន្នបាន គឺចំនួនកូនដែលស្ត្រីបង្កើតក្នុងរយៈពេល ១២ ខែមុនពេលធ្វើជំរឿនតាមក្រុមអាយុស្ត្រី។ ពីសំណួរនេះអាចគណនាអត្រាលទ្ធភាពបង្កើតកូនតាមអាយុជាក់លាក់ (ASFR) និងអត្រាលទ្ធភាពបង្កើតកូនសរុប (TFR)។

អត្រាលទ្ធភាពបង្កើតកូនតាមអាយុជាក់លាក់ (ASFR) ជាចំនួនកូនដែលស្ត្រីក្នុងក្រុមអាយុនីមួយៗបានបង្កើតចែកនឹងចំនួនស្ត្រីក្នុងក្រុមអាយុនោះ (គុណនឹងចំនួនថេរគឺ ១០០០)។ ជាទូទៅតំណាងឲ្យអត្រាក្រុមអាយុប្រាំឆ្នាំនីមួយៗនៃ វដ្តជីវិតក្នុងវ័យបន្តពូជ (មើលតារាង ៧.២.១)។ អត្រាលទ្ធភាពបង្កើតកូនសរុប ជាផលបូកនៃអត្រាលទ្ធភាពបង្កើតកូនតាមអាយុជាក់លាក់គុណនឹង ៥។ ជាទស្សនទាន វិធីសាស្ត្រនេះមានលក្ខណៈស្មុគស្មាញ។ អត្រាលទ្ធភាពបង្កើតកូនសរុបជាចំនួនកូនមធ្យមដែលបានកើតលើស្ត្រីម្នាក់ តាមពេលដែលគាត់បានបញ្ចប់វ័យបន្តពូជ ប្រសិនបើគាត់ត្រូវឆ្លងកាត់ឆ្នាំបង្កើតកូនទាំងអស់ ដោយអនុលោមតាមអត្រាលទ្ធភាពបង្កើតកូនតាមអាយុជាក់លាក់។ អត្រាលទ្ធភាពបង្កើតកូនសរុប ជាសូចនាករមួយក្នុងចំណោមសូចនាករសំខាន់ៗស្តីពីលទ្ធភាពបង្កើតកូន ព្រោះវាបានផ្តល់នូវរូបភាពជាក់លាក់អំពីចំនួនស្ត្រីដែលមានលទ្ធភាពបង្កើតកូនបច្ចុប្បន្ន។ អត្រាលទ្ធភាពបង្កើតកូនសរុបជាផលបូកនៃចំនួនកូនរបស់ស្ត្រីទាំងអស់មានក្នុងវ័យបន្តពូជ។ អាចនិយាយបានថាជាចំនួនកូនសរុបដែលស្ត្រីម្នាក់មាន ប្រសិនបើអត្រាលទ្ធភាពបង្កើតកូនសម្រាប់ឆ្នាំផ្តល់ឲ្យអនុវត្តពេញមួយជីវិតក្នុងវ័យបន្តពូជរបស់ពួកគាត់។ អត្រាលទ្ធភាពបង្កើតកូន

សរុបជាវិធានសំយោគ គ្មានស្ត្រីណាម្នាក់អាចឆ្លងកាត់រយៈពេល ៣ ទសវត្សរ៍ ដែលអនុលោមតាមអត្រាលទ្ធភាពបង្កើតកូនតាមអាយុជាក់លាក់នៃឆ្នាំណាមួយឡើយ។ ជាក់ស្តែង អត្រាអាយុជាក់លាក់ផ្លាស់ប្តូរ និងប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ ទោះបីមានបន្តិចបន្តួចក៏ដោយ។

បន្ថែមលើសពីនេះទៀត អត្រាលទ្ធភាពបង្កើតកូនតាមអាយុជាក់លាក់ (ASFR) និងអត្រាលទ្ធភាពបង្កើតកូនសរុប (TFR) មានវិធីសាស្ត្រជាច្រើនសម្រាប់វាស់វែង ប៉ុន្តែការប្រើប្រាស់នៅមានកម្រិតដោយសាររងផលប៉ះពាល់ខ្លាំងដោយសមាសភាពអាយុរបស់ប្រជាជន។ អថេរទាំងពីរនេះទទួលរងនូវការប៉ះពាល់ធ្ងន់ធ្ងរដល់កម្រិតនៃអត្រាលទ្ធភាពបង្កើតកូន មិនមែនដោយសារតែចំនួនកំណើតក្នុងស្ត្រីម្នាក់ប៉ុណ្ណោះទេ ប៉ុន្តែដោយសារចំនួនស្ត្រីក្នុងវ័យបន្តពូជ (ដែលមានឥទ្ធិពលដោយសមាសភាពអាយុរបស់ប្រជាជន)។

អត្រាលទ្ធភាពបង្កើតកូនតាមអាយុជាក់លាក់ (ASFR) និងអត្រាលទ្ធភាពបង្កើតកូនសរុប (TFR) មិនទទួលរងផលប៉ះពាល់ដោយសមាសភាពអាយុរបស់ប្រជាជនឡើយ ប៉ុន្តែវាមានបញ្ហាផ្សេងទៀត ជាសំខាន់គឺការរាប់មិនអស់។ ដូចបានរៀបរាប់ខាងលើ វិធីសាស្ត្រគណនា ASFR និង TFR បានប្រើចំនួនកំណើតដែលស្ត្រីបានបង្កើតក្នុងរយៈពេល ១២ ខែមុនពេលធ្វើជំរឿន។ កាលណាបង្កើតតារាងតាមក្រុមអាយុប្រាំឆ្នាំរបស់ស្ត្រី ព័ត៌មាននេះអាចផ្តល់ការវាស់វែងដោយផ្ទាល់សម្រាប់អត្រាលទ្ធភាពបង្កើតកូនតាមអាយុជាក់លាក់ (ASFR) និងអត្រាលទ្ធភាពបង្កើតកូនសរុប (TFR)។ ទោះជាយ៉ាងណាក៏ដោយ អត្រានេះតែងប៉ាន់ស្មានស្ទើរ ដោយសាររាប់មិនអស់នូវចំនួនកូននៅពេលសម្ភាសន៍ ដោយប្រើសំណួរពីជំរឿន (អំពីចំនួនកូនដែលបានកើតរបស់ស្ត្រី) មានកម្រិតទាបជាងការប៉ាន់ស្មានដែលត្រូវការកែតម្រូវមួយសមស្រប។

## ៧.២. ការប៉ាន់ស្មានលទ្ធភាពបង្កើតកូន

វិធីសាស្ត្រគណនាលទ្ធភាពបង្កើតកូនដោយប្រយោលត្រូវបានអនុវត្តសម្រាប់កែសម្រួលការប្រមូលទិន្នន័យមិនបានពេញលេញ ឬរាប់មិនអស់។ ដូចបានរៀបរាប់ខាងដើម William Brass បានបង្កើតវិធីសាស្ត្រគណនាដោយប្រយោល ដើម្បីកាត់បន្ថយភាពខ្វះខាតនេះ។ អ្នកប្រជាសាស្ត្រផ្សេងទៀតបន្ទាប់ពីគាត់ បានកែលម្អវិធីសាស្ត្រគណនានេះ ក្នុងនោះមាន Eduardo Arriaga ដែលវិធីសាស្ត្រគណនានេះត្រូវបានប្រើប្រាស់សម្រាប់ជំរឿននៅកម្ពុជា (មើលតារាង ៧.២.១)[1]។

[1] E. Arriaga និង Associates. 1994. PAS – ការវិភាគប្រជាសាស្ត្រជាមួយ Microcomputers, U. S ការិយាល័យជំរឿនសហរដ្ឋអាមេរិក, D.C., USA។

## តារាង ៧.២.១. ប៉ានស្មានអត្រាលទ្ធភាពបង្កើតកូនតាមអាយុជាក់លាក់ និងអត្រាលទ្ធភាពបង្កើតកូនសរុប តាមតំបន់ កម្ពុជា ឆ្នាំ២០១៩

| អត្រាលទ្ធភាពបង្កើតកូនតាមអាយុជាក់លាក់ | សរុប | ទីប្រជុំជន | ជនបទ |
|---|---|---|---|
| (១) | (២) | (៣) | (៤) |
| ១៥ - ១៩ | ០,០៣២១៥ | ០,០២២៩៩ | ០,០៣៨០០ |
| ២០ - ២៤ | ០,១២៥៩៥ | ០,០៩៥៩១ | ០,១៥១០៨ |
| ២៥ - ២៩ | ០,១៣៦៦១ | ០,១២៣១៥ | ០,១៥២២៤ |
| ៣០ - ៣៤ | ០,១០៨១១ | ០,១០៦៣០ | ០,១១៤៣២ |
| ៣៥ - ៣៩ | ០,០៦១៩២ | ០,០៦០៥៣ | ០,០៦៥៤៦ |
| ៤០ - ៤៤ | ០,០២៨០០ | ០,០២៦៣២ | ០,០២៩៦៣ |
| ៤៥ - ៤៩ | ០,០០៩៦២ | ០,០០៨៥៩ | ០,០១០៣៤ |
| អត្រាលទ្ធភាពបង្កើតកូនសរុប | ២,៥១ | ២,២២ | ២,៨១ |
| អត្រាកំណើតដុល | ៣៧,៧៣ | ៣១,៨១ | ៤១,៨៣ |
| អត្រាកំណើតទូទៅ | ៥២,១៥ | ៤១,៧៤ | ៥៩,៣២ |
| ផលធៀបកូននិងស្ត្រី | ៣៤១,១៦ | ២៨៧,១៥ | ៣៧៩,៧០ |

យោងតាមតារាង ៧.២.១ អត្រាលទ្ធភាពបង្កើតកូនសរុប (TFR) នៅកម្ពុជាមាន ២,៥ សម្រាប់ស្ត្រីម្នាក់ក្នុងកាលបរិច្ឆេទយោងជំរឿនថ្ងៃទី ៣ ខែមីនា ឆ្នាំ២០១៩ និងរយៈពេល ១២ ខែមុនពេលធ្វើជំរឿន ថ្ងៃទី ៣ ខែមីនា ឆ្នាំ២០១៨ ដល់ ២ ខែមីនា ឆ្នាំ២០១៩។ តម្លៃនេះយោងតាមពេលវេលាជាក់លាក់ថ្ងៃទី ៣ ខែសីហា ឆ្នាំ២០១៩ ។

តាមលទ្ធផលបង្ហាញថាអត្រាលទ្ធភាពបង្កើតកូនសរុប (TFR) បានថយចុះបន្តិច ធៀបនឹងជំរឿនឆ្នាំ២០០៨ មាន ២,៧។ យោងតាមទិន្នន័យប្រជាជនបានបង្ហាញថាកម្ពុជាជិតឈានដល់"កម្រិតជំនួស" (ឧទាហរណ៍. កម្រិតលទ្ធភាពបង្កើតកូនសរុបជាក់លាក់ជំនួសដោយខ្លួនឯងពីមួយជំនាន់ទៅមួយជំនាន់បន្ទាប់)។ ការយល់ច្រឡំជាទូទៅមួយអំពីកំណើនប្រជាជន គឺថាប្រជាជនឈប់មានកំណើននៅពេលដែលកម្រិតនៃការមានកូនជំនួសបានឈានដល់ (ជាមធ្យមកុមារ ២ នាក់ក្នុងស្ត្រីម្នាក់)។ តាមពិត ដោយសារកំណើនចំនួនប្រជាជនដល់ចំណុចខ្ពស់មួយ (population momentum) របស់ប្រទេសមួយអាចបន្តកើនឡើងក្នុងរយៈពេល ៧០ ឆ្នាំទៀត នៅពេលការឈានដល់កម្រិតជំនួសនៃអត្រាលទ្ធភាពបង្កើតកូនសរុប។ លទ្ធភាពបង្កើតកូនមានទំនាក់ទំនងនឹងរចនាសម្ព័ន្ធអាយុរបស់ប្រជាជន។ ភាគរយខ្ពស់នៃប្រជាជន វ័យក្មេង (ជាពិសេសក្មេងអាយុក្រោម ១៥ ឆ្នាំ) ប្រជាជនកាន់តែបន្តកើនឡើងកាន់ច្រើនក្នុងក្រុមធំមួយ (ផ្នែកនៃប្រជាជន) ចូលក្នុងក្រុមអាយុវ័យបន្តពូជ (១៥-៤៩ ឆ្នាំ)។ ម្តងទៀត ក្រុមអាយុក្មេងនេះឈានហួសក្រុមអាយុក្នុងវ័យបន្តពូជ នោះសន្ទុះនឹងថយចុះហើយចំនួនប្រជាជនអាចចាប់ផ្តើមថេរ ដូច្នេះអត្រាកំណើត និងមរណភាពនឹងមានតុល្យភាព (សន្មតថាអត្រាលទ្ធភាពបង្កើតកូនមានស្មើ ឬទាបជាងកម្រិតជំនួស)។

តារាង ៧.២.១ ក៏បង្ហាញផងដែរអំពីភាពខុសគ្នារវាងអត្រាលទ្ធភាពបង្កើតកូនសរុបរវាងតំបន់ទីប្រជុំជន និងជនបទ។ ជាទូទៅ អត្រាលទ្ធភាពបង្កើតកូននៅប្រទេសកម្ពុជាគឺទាបនៅទីប្រជុំជននិងជនបទ។ អត្រាលទ្ធភាពបង្កើត

កូនសរុបខុសគ្នាតិចតួចគឺ ២,២ ទល់នឹង ២,៨ សម្រាប់ស្ត្រីម្នាក់។ ជាទូទៅ ការខុសគ្នាមានកូនម្នាក់ ឬច្រើនជាង (នៅឆ្នាំ ២០០៨ នៅជនបទ TFR មានកូន ២,៩ នាក់ សម្រាប់ស្ត្រីម្នាក់ និង ១,៩នាក់ នៅទីប្រជុំជន)។

បន្ថែមលើភាពខុសគ្នានេះ បានកត់សម្គាល់ថា TFR បានកើនឡើងនៅទីប្រជុំជនតាមជនបទ (ពី ១,៩នាក់ ដល់ ២,២នាក់ សម្រាប់ស្ត្រីម្នាក់)។ និន្នាការនេះមិនមានការផ្លាស់ប្តូរច្រើនទេ ប៉ុន្តែវាសំខាន់ណាស់ក្នុងការពន្យល់ក្នុងការសិក្សាស៊ីជម្រៅ។ កត្តានេះអាចបណ្តាលមកពីទេសន្តរប្រវេសន៍។

តារាង ៧.២.១ ក៏បង្ហាញការវាស់វែងអត្រាកំណើតផ្សេងទៀតផងដែរ។ អត្រាកំណើតដែលមានលក្ខណៈសាមញ្ញ គឺអត្រាកំណើតដុល (CBR) ជាចំនួនកំណើតរស់ក្នុងចំណោមប្រជាជន ១.០០០ នាក់ ក្នុងឆ្នាំផ្តល់ឲ្យ។ ដូចដែលបានបរិយាយខាងដើម អត្រាប្រចាំឆ្នាំភាគច្រើន ដូចជាអត្រាកំណើត ទំនាក់ទំនងព្រឹត្តិការណ៍ប្រជាសាស្ត្រទៅនឹងចំនួនប្រជាជននៅពាក់កណ្តាលឆ្នាំ (ថ្ងៃទី១ ខែកក្កដា) ដែលត្រូវបានចាត់ទុកជាចំនួនប្រជាជនមធ្យមដែលមានហានិភ័យ ទោះបីព្រឹត្តិការណ៍នេះកើតមានទូទាំងឆ្នាំក៏ដោយ។ ករណីកម្ពុជា CBR មាន ៣៧,៧ កំណើតក្នុង ១.០០០ នាក់។ ដោយពិចារណាថាកាលបរិច្ឆេទនៃការធ្វើជំរឿនគឺថ្ងៃទី ៣ ខែមីនា ឆ្នាំ២០១៩ ហើយរយៈពេលដែលត្រូវពិចារណាសម្រាប់កំណើតគឺ ១២ ខែមុនពេលធ្វើជំរឿន ដូច្នេះតម្លៃនេះត្រូវនឹងថ្ងៃទី ៣ ខែសីហា ឆ្នាំ២០១៨។

ការវាស់វែងអត្រាកំណើតបន្ទាប់ គឺអត្រាកំណើតទូទៅ (GFR) ជាចំនួនកំណើតរស់ក្នុងស្ត្រី ១.០០០ នាក់ មានអាយុ ១៥-៤៩ ឆ្នាំ ក្នុងឆ្នាំផ្តល់ឲ្យ។ នៅកម្ពុជាមាន ៥២ កំណើតរស់ក្នុងចំណោមស្ត្រីវ័យបន្តពូជ ១.០០០ នាក់។ អត្រាកំណើតទូទៅត្រូវបានកំណត់ត្រឹមត្រូវជាងអត្រាកំណើតដុល ពីព្រោះវាទាក់ទងនឹងការបង្កើតកូនតាមក្រុមអាយុភេទ ដែលមានហានិភ័យក្នុងការបង្កើតកូន (អាយុពី ១៥-៤៩ ឆ្នាំ)។ ហេតុការណ៍នេះអាចជួយលុបបំបាត់ការបំភាន់ដែលអាចកើតឡើង ដោយសារតែការបែងចែកអាយុ និងភេទខុសគ្នាក្នុងចំណោមប្រជាជន។ ដូច្នេះអត្រាកំណើតទូទៅមានមូលដ្ឋានប្រសើរក្នុងការប្រៀបធៀបកម្រិតនៃការផ្តល់កំណើតក្នុងចំណោមប្រជាជន ជាជាងការប្រើប្រាស់អត្រាកំណើតដុល ប៉ុន្តែវានៅតែមានឥទ្ធិពលដោយសារសមាសភាពអាយុ ភេទរបស់ប្រជាជន។

ជាចុងក្រោយ ផលធៀបកូននិងស្ត្រី (CWR) គឺជាចំនួនក្មេងអាយុក្រោម ៥ ឆ្នាំ ក្នុងចំណោមស្ត្រីវ័យបន្តពូជ ១.០០០នាក់ ក្នុងឆ្នាំផ្តល់ឲ្យ។ ការវាស់វែងនេះត្រូវបានធ្វើឡើង កាលណាអត្រាលទ្ធភាពបង្កើតកូនសរុបមិនអាចរកបាន។ ទោះបីជាយ៉ាងណាក៏ដោយ វាក៏មានឥទ្ធិពលដោយសារការបែងចែកអាយុរបស់ប្រជាជន និងការរាប់សម្ភាសន៍មិនអស់។ ក្នុងករណីកម្ពុជា ផលធៀបកូននិងស្ត្រី (CWR) មានកូន ៣៤១នាក់ ក្នុងចំណោមស្ត្រី ១.០០០នាក់។

ការវាស់វែងនេះត្រូវគ្នាជាមួយអត្រាលទ្ធភាពបង្កើតកូនតាមអាយុជាក់លាក់ (ASFR) និងអត្រាលទ្ធភាពបង្កើតកូនសរុប (TFR) ក្នុងកម្រិតលទ្ធភាពបង្កើតកូនដែលពួកគេបានបញ្ជាក់។ លទ្ធភាពបង្កើតកូនទាបមានអត្រខុសគ្នាតិចតួចរវាងតំបន់ទីប្រជុំជន និងជនបទ។ គួរចងចាំថាគ្រប់ការវាស់វែងទាំងអស់បានត្រូវនឹងថ្ងៃទី ៣ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី ២ ខែមីនា ឆ្នាំ២០១៨ ឬពិតប្រាកដថ្ងៃទី ៣ ខែសីហា ឆ្នាំ២០១៨។

តារាង ៧.២.២ បានបង្ហាញអត្រាលទ្ធភាពបង្កើតកូនសរុប (TFR) តាមវិធីសាស្ត្រដោយប្រយោល និងក៏គណនាដោយផ្ទាល់ផងដែរ។ មានលទ្ធផលខុសគ្នាបន្តិចបន្តួចរវាងវិធីសាស្ត្រផ្សេងៗ។ តាមការវាយតម្លៃពីនិន្នាការអត្រា

លទ្ធភាពបង្កើតកូនសរុប វិធីសាស្ត្រ Brass-Arriaga ត្រូវបានប្រើសម្រាប់ការគណនាអត្រាលទ្ធភាពបង្កើតកូនសរុបនៅកម្ពុជា ដែលសមស្របបំផុត។ វិធីសាស្ត្រ Gompertz ក៏ត្រូវបានពិចារណាផងដែរក្នុងការគណនាអត្រាលទ្ធភាពបង្កើតកូនសរុប (TFR) ប៉ុន្តែការកែតម្រូវអត្រាលទ្ធភាពបង្កើតកូនតាមអាយុជាក់លាក់ (ASFR) មានភាពស្មុគស្មាញបន្តិច។

### តារាង ៧.២.២. ប៉ាន់ស្មានអត្រាលទ្ធភាពបង្កើតកូនប្រើប្រាស់វិធីសាស្ត្រដោយប្រយោលផ្សេងគ្នា កម្ពុជា ឆ្នាំ២០១៩

| វិធីសាស្ត្រគណនា | អត្រាលទ្ធភាពបង្កើតកូនសរុប (TFR) |
|---|---|
| (១) | (២) |
| វិធីសាស្ត្រ Brass-Arriaga | ២,៥១ |
| វិធីសាស្ត្រ Mortara | ២,៩៥ |
| វិធីសាស្ត្រ Rele | ២,៣៥ |
| វិធីសាស្ត្រ Gompertz | ២,៧៤ |
| គណនាដោយផ្ទាល់ | ១,៦៧ |

តាមការសង្កេតអត្រាលទ្ធភាពបង្កើតកូនសរុប (TFR) ការគណនាដោយផ្ទាល់មានកម្រិតមិនសមហេតុផលទាបជាងវិធីសាស្ត្រដោយប្រយោល (ចំនួនកូនកើត ១,៧នាក់ ក្នុងស្ត្រីម្នាក់)។ នេះបង្ហាញពីការរាប់សម្គាសន៍ចំនួនកូនបានកើតក្នុងរយៈពេល ១២ ខែ មុនពេលធ្វើជំរឿនមិនអស់។ បញ្ហានេះបានកើតមាននៅបណ្តាប្រទេសជាច្រើនទាក់ទងទៅនឹងការភ្លេចរាប់ចំនួនកូនដែលបានកើត ក្នុងអំឡុងឆ្នាំមុនពេលធ្វើជំរឿន ដូចជាអ្នកដែលបានស្លាប់ កំហុសមិនបានរាប់ការផ្តល់កំណើតនៅក្នុងទីតាំងមិនឋិតថេរ អបិយជំនឿ ភ្លេចថ្ងៃកំណើតបើអ្នកឆ្លើយសំណួរមិនមែនជាម្តាយបង្កើត។ល។ នៅកម្ពុជាការរាប់សម្គាសន៍មិនអស់មានសារៈសំខាន់ ប៉ុន្តែមិនមានទំហំធំគ្រប់គ្រាន់ដើម្បីបញ្ចៀសពីការកែតម្រូវដ៏គួរឲ្យទុកចិត្តបានឡើយ។

រូប ៧.២.១ បង្ហាញពីអត្រាលទ្ធភាពបង្កើតកូនតាមអាយុជាក់លាក់ ASFR (កែតម្រូវ) សម្រាប់ជំរឿនឆ្នាំ ២០០៨ និងឆ្នាំ២០១៩។ រូបខ្សែកោងបង្ហាញថា អត្រាលទ្ធភាពបង្កើតកូនកើនឡើងជាមួយអាយុ ទៅដល់ចំណុចកំពូលនៅក្នុងក្រុមអាយុ ២៥-២៩ ឆ្នាំ ហើយបន្ទាប់មកថយចុះវិញ។ ខ្សែកោងបង្ហាញសមាមាត្រមធ្យមនៃស្ត្រីមានកូននៅវ័យក្មេងពេកឬចាស់ពេក។ ឧទាហរណ៍ អត្រាលទ្ធភាពបង្កើតកូនយុវវ័យមាន ៣២ កំណើតក្នុងចំណោម ១.០០០ នាក់។ ទោះបីអត្រាទាប កិច្ចខិតខំប្រឹងប្រែងគួរតែត្រូវធ្វើដើម្បីកាត់បន្ថយ នូវភាពអវិជ្ជមានដល់បុគ្គល និងផលវិបាកជាអវិជ្ជមានដល់សង្គមចំពោះការមានកូនរបស់យុវវ័យ។ ជាងនេះទៀត ស្ត្រី ១.០០០ នាក់ ដែលកំពុងបញ្ចប់ជីវិតបន្តពូជរបស់ពួកគេ (៤៥-៤៩ ឆ្នាំ) មានកូន ១០ នាក់ជាមធ្យម។

រូប ៧.២.១. អត្រាលទ្ធភាពបង្កើតកូន តាមអាយុជាក់លាក់ កម្ពុជា ឆ្នាំ២០០៨-២០១៩




រវាងឆ្នាំ២០០៨ និងឆ្នាំ២០១៩ អត្រាលទ្ធភាពបង្កើតកូនតាមអាយុជាក់លាក់ (ASFR) មិនមានការផ្លាស់ប្តូរឡើយ។ ដូចបានបង្ហាញក្នុងរូប ៧.២.១ អត្រាលទ្ធភាពបង្កើតកូនបានថយចុះនៅទូទាំងប្រជាជនទាំងមូល។ ការពិតនេះ គួរធ្វើការស្រាវជ្រាវបន្ថែមទៀត ពីព្រោះនេះមិនមែនតែងតែថយចុះយ៉ាងឆាប់រហ័សនូវចំនួនប្រជាជននោះទេ។

## ៧.៣. ស្ត្រីតាមចំនួនគំលាតកូនកើតរស់

តារាង ៧.៣.១ បង្ហាញការវាស់វែងចម្បងនៃកំណើនលទ្ធភាពបង្កើតកូន ភាគរយស្ត្រីតាមចំនួនកូនកើតរស់ (គំលាតកូនកើតរស់)។ ឧទាហរណ៍ ១៣,៣ ភាគរយនៃស្ត្រីដែលស្ថិតក្នុងក្រុមអាយុ ១៥ ឆ្នាំឡើង មានកូន ២,១នាក់ បើផ្អែកលើលទ្ធផលជំរឿន។ ស្ត្រី ៣១,៦ ភាគរយ មិនមានកូន។ តារាង ៧.៣.១ បង្ហាញផងដែរនូវព័ត៌មានតាមក្រុមអាយុ។ ឧទាហរណ៍ ២៥,៩ ភាគរយនៃស្ត្រីដែលស្ថិតក្នុងក្រុមអាយុ ៣៥-៣៩ ឆ្នាំ មានកូន ៣ នាក់។

បង្គោលចុងក្រោយនៃតារាង ៧.៣.១ បង្ហាញចំនួនកូនជាមធ្យមកើតរស់តាមក្រុមអាយុស្ត្រី។ ឧទាហរណ៍ ស្ត្រីស្ថិតក្នុងក្រុមអាយុ ២០-២៤ ឆ្នាំ មានកូនជាមធ្យម ០,៥នាក់ តាមកាលបរិច្ឆេទយោងនៃជំរឿន ខណៈស្ត្រីស្ថិតក្នុងក្រុមអាយុ ៥០-៥៤ ឆ្នាំ មានកូនជាមធ្យម ៣,៤ នាក់។ ចំនួនកូនកើតរស់សម្រាប់ស្ត្រីក្នុងវ័យបញ្ចប់ការបន្តពូជ (៤៥-៤៩ ឆ្នាំ) ហៅថាវ័យបញ្ចប់កំណើត ក្នុងតារាង ៧.៣.១ មាន ៣,១ នាក់។

ជាទូទៅអាយុស្ត្រីកើន ចំនួនកូនកើតរស់ក៏កើនឡើងផងដែរ។ លើកលែងតែក្នុងក្រុមអាយុវ័យចាស់។ នេះបង្ហាញពីការធ្លាក់ចុះលទ្ធភាពបង្កើតកូនអាចបណ្តាលមកការចងចាំ ពោលគឺស្ត្រីអាចភ្លេចរាប់កូនមួយចំនួន ជាពិសេសកូនដែលបានស្លាប់។

ព័ត៌មាននេះបង្ហាញថាលទ្ធភាពបង្កើតកូននឹងមិនអាចខ្ពស់ខ្លាំងសម្រាប់កម្ពុជា។ ឧទាហរណ៍ចំនួនកូនជាមធ្យមច្រើនបំផុតមាន ៤,០នាក់ ក្នុងក្រុមស្ត្រីអាយុ ៧០-៧៤ ឆ្នាំ តាមកាលបរិច្ឆេទយោងជំរឿន។

## តារាង ៧.៣.១. ស្ត្រីតាមគំលាត និងចំនួនកូនកើតរស់ សរុប កម្ពុជា ឆ្នាំ២០១៩

| ក្រុមអាយុ | គំលាតកូនកើតរស់ | | | | | | | | ចំនួនកូនកើត | |
|---|---|---|---|---|---|---|---|---|---|---|
| | ស្ត្រី | ០ | ១ | ២ | ៣ | ៤ | ៥+ | សរុប | ចំនួន | មធ្យម |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨) | (៩) | (១០) | (១១) |
| **សរុប** | **៥.៧០៤.៦៧៨** | **៣១,៦** | **១៤,៦** | **១៩,៣** | **១៣,៣** | **៨,៣** | **១២,៩** | **១០០** | **១១.៨៩៦.០៦០** | **២,០៩** |
| ១៥ - ១៩ | ៦៩៧.៦៥១ | ៩៣,៨ | ៤,១ | ១,១ | ០,៥ | ០,៣ | ០,២ | ១០០ | ៧០.១៧៧ | ០,១០ |
| ២០ - ២៤ | ៦៣៧.៩២២ | ៦៣,៦ | ២៥,៦ | ៨,៦ | ១,៣ | ០,៤ | ០,៥ | ១០០ | ៣២៧.៣៣១ | ០,៥១ |
| ២៥ - ២៩ | ៧២៣.២៤០ | ៣៦,២ | ៣០,២ | ២៥,៦ | ៦,០ | ១,៣ | ០,៦ | ១០០ | ៧៨៥.៣០៨ | ១,០៩ |
| ៣០ - ៣៤ | ៦៥៩.៨៩២ | ២០,៥ | ១៩,៣ | ៣៦,៦ | ១៧,០ | ៤,៦ | ១,៩ | ១០០ | ១.១៤០.០៤២ | ១,៧៣ |
| ៣៥ - ៣៩ | ៦៥៤.២៧០ | ១៣,៧ | ១១,៨ | ៣៣,០ | ២៥,៩ | ១០,២ | ៥,៤ | ១០០ | ១.៤៨០.៤៩០ | ២,២៦ |
| ៤០ - ៤៤ | ៣៨២.១៤៥ | ១០,៤ | ៩,៦ | ២៥,៤ | ២៧,០ | ១៥,៥ | ១២,១ | ១០០ | ១.០៤២.៨៨៥ | ២,៧៣ |
| ៤៥ - ៤៩ | ៤០០.៥៣៤ | ៩,២ | ៩,២ | ២១,០ | ២៣,៨ | ១៧,៧ | ១៩,២ | ១០០ | ១.២២៨.៨៣០ | ៣,០៧ |
| ៥០ - ៥៤ | ៣៨០.០៩៩ | ៩,៧ | ៩,៣ | ១៧,១ | ១៩,៤ | ១៧,៤ | ២៧,០ | ១០០ | ១.២៨១.២៤៩ | ៣,៣៧ |
| ៥៥ - ៥៩ | ៣៤២.១៨៩ | ៩,៧ | ៩,១ | ១៤,២ | ១៥,៦ | ១៥,៩ | ៣៥,៥ | ១០០ | ១.២៨០.៩៩៨ | ៣,៧៤ |
| ៦០ - ៦៤ | ២៧៦.៨៣៥ | ១០,៤ | ៩,៥ | ១២,៨ | ១៣,០ | ១៤,២ | ៤០,១ | ១០០ | ១.០៨៩.៨០៥ | ៣,៩៤ |
| ៦៥ - ៦៩ | ២១៤.០១៨ | ១២,០ | ១០,៣ | ១២,៦ | ១១,៧ | ១២,៩ | ៤០,៦ | ១០០ | ៨៥០.៨០៧ | ៣,៩៨ |
| ៧០ - ៧៤ | ១៤៤.៧០២ | ១៣,៤ | ៩,៩ | ១១,៨ | ១១,១ | ១២,៧ | ៤១,១ | ១០០ | ៥៧៩.៦៨០ | ៤,០១ |
| ៧៥ - ៧៩ | ៩២.៨២៥ | ១៥,៤ | ៩,២ | ១១,១ | ១០,៩ | ១៣,១ | ៤០,៣ | ១០០ | ៣៦៦.៥៣៣ | ៣,៩៥ |
| ៨០ - ៨៤ | ៥៥.៩៣៣ | ១៧,៨ | ៨,៩ | ១០,៥ | ១០,៣ | ១២,៥ | ៤០,០ | ១០០ | ២១៥.៥៥៧ | ៣,៨៥ |
| ៨៥ + | ៤២.៤២៣ | ២០,៣ | ៩,៣ | ១០,៧ | ៩,៩ | ១២,៤ | ៣៧,៤ | ១០០ | ១៥៦.៣៦៨ | ៣,៦៩ |

ព័ត៌មានអំពីចំនួនកូនកើតរស់ត្រូវបានបែងចែកជាទីប្រជុំជន និងជនបទផងដែរ។ ដូចការរំពឹងទុក កម្រិតលទ្ធភាពបង្កើតកូននៅតំបន់ជនបទខ្ពស់ជាងនៅតំបន់ទីប្រជុំជន។ ឧទាហរណ៍ ចំនួនកូនកើតរស់ជាមធ្យមនៅតំបន់ទីប្រជុំជនមាន ១,៧នាក់ សម្រាប់ស្ត្រីម្នាក់ នៅជនបទមាន ២,៣នាក់។ គួរបញ្ជាក់ផងដែរថាលទ្ធភាពបង្កើតកូនពេញលេញមាន ២,៧នាក់ នៅតំបន់ទីប្រជុំជន និង ៣,៣នាក់ នៅតំបន់ជនបទ។ នៅជនបទក្នុងចំណោមមនុស្សចាស់ជាស្ត្រីច្រើនជាង ៤០ ភាគរយ មានកូន ៥នាក់ ឬច្រើនជាងនេះ ខណៈដែលនៅទីប្រជុំជនភាគរយនេះមានលើសពី ៣០ ភាគរយ។

## តារាង ៧.៣.២. ស្ត្រីតាមគំលាត និងចំនួនកូនកើតរស់ តាមក្រុមអាយុ ទីប្រជុំជន កម្ពុជា ឆ្នាំ២០១៩

| ក្រុមអាយុ | គំលាតកូនកើតរស់ | | | | | | | | ចំនួនកូនកើត | |
|---|---|---|---|---|---|---|---|---|---|---|
| | ស្ត្រី | ០ | ១ | ២ | ៣ | ៤ | ៥+ | សរុប | ចំនួន | មធ្យម |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨) | (៩) | (១០) | (១១) |
| **សរុប** | **២.៣៣៣.០១២** | **៣៧,៤** | **១៥,២** | **១៩,១** | **១២,៤** | **៧,០** | **៨,៩** | **១០០** | **៤.០៥៦.១៩៩** | **១,៧៤** |
| ១៥ - ១៩ | ២៧៤.៩៨ | ៩៥,១ | ៣,១ | ១,០ | ០,៤ | ០,២ | ០,២ | ១០០ | ២២.៤១១ | ០,០៨ |
| ២០ - ២៤ | ២៩០.៥៧៣ | ៧៣,១ | ១៩,២ | ៦,០ | ១,០ | ០,៤ | ០,៣ | ១០០ | ១០៨.៨៧៦ | ០,៣៧ |
| ២៥ - ២៩ | ៣៣៣.២១៥ | ៤៦,៦ | ២៨,២ | ១៩,៥ | ៤,២ | ០,៩ | ០,៥ | ១០០ | ២៨៨.៥១៥ | ០,៨៧ |
| ៣០ - ៣៤ | ២៩៧.៦៧៧ | ២៧,៩ | ២១,៣ | ៣៣,១ | ១៣,៣ | ៣,១ | ១,២ | ១០០ | ៤៣៦.៩៣១ | ១,៤៧ |
| ៣៥ - ៣៩ | ២៨៧.៦១៤ | ១៨,៦ | ១៣,៦ | ៣៣,២ | ២៣,៤ | ៧,៨ | ៣,៤ | ១០០ | ៥៧៦.០២២ | ២,០០ |
| ៤០ - ៤៤ | ១៤៦.៨៦៥ | ១៣,៦ | ១១,១ | ២៧,៤ | ២៦,៧ | ១៣,០ | ៨,៣ | ១០០ | ៣៥៨.៦០៧ | ២,៤៤ |
| ៤៥ - ៤៩ | ១៤៧.១៤៩ | ១១,៥ | ១០,៧ | ២៤,០ | ២៤,៦ | ១៥,៧ | ១៣,៥ | ១០០ | ៤០២.២៥៣ | ២,៧៣ |
| ៥០ - ៥៤ | ១៣៣.៩០៥ | ១១,៣ | ១០,៤ | ២០,៥ | ២១,២ | ១៦,៧ | ១៩,៩ | ១០០ | ៤០១.៨៤០ | ៣,០០ |
| ៥៥ - ៥៩ | ១២១.២៥២ | ១០,៩ | ១០,១ | ១៧,១ | ១៧,៨ | ១៦,៣ | ២៧,៨ | ១០០ | ៤០៦.០១៣ | ៣,៣៥ |
| ៦០ - ៦៤ | ១០២.៣៦៧ | ១១,៥ | ១០,៧ | ១៤,៩ | ១៥,០ | ១៥,២ | ៣២,៩ | ១០០ | ៣៦២.៩៦៩ | ៣,៥៥ |
| ៦៥ - ៦៩ | ៧៨.១៦៨ | ១២,៩ | ១១,៩ | ១៤,៦ | ១៣,៦ | ១៣,៨ | ៣៣,៣ | ១០០ | ២៧៦.៦៩៨ | ៣,៥៤ |
| ៧០ - ៧៤ | ៥២.៧៤៤ | ១៤,៦ | ១២,៤ | ១៣,៨ | ១២,៣ | ១៣,១ | ៣៣,៨ | ១០០ | ១៨៦.៥៣១ | ៣,៥៤ |
| ៧៥ - ៧៩ | ៣២.៣៤៧ | ១៧,០ | ១១,៧ | ១២,៩ | ១២,០ | ១៣,៤ | ៣២,៩ | ១០០ | ១១២.៣១៦ | ៣,៤៧ |
| ៨០ - ៨៤ | ១៩.៣៩៨ | ១៩,៨ | ១០,៧ | ១១,៧ | ១០,៩ | ១២,៦ | ៣៤,៣ | ១០០ | ៦៧.៤៨៩ | ៣,៤៨ |
| ៨៥ + | ១៤.៧៥៨ | ២២,៧ | ១១,៦ | ១១,២ | ១០,១ | ១២,៥ | ៣២,០ | ១០០ | ៤៨.៧២៨ | ៣,៣០ |

ចំនួនកូនកើតរស់នៅជនបទជាក់ស្តែងខ្ពស់ជាងតំបន់ទីប្រជុំជន ករណីនេះកើតមានស្ទើរតែគ្រប់បណ្តាប្រទេសទាំងអស់។ តម្រូវឲ្យមានការស្រាវជ្រាវបន្ថែមទៀត ដើម្បីឆ្លុះបញ្ចាំងពីភាពខុសគ្នា និងនិន្នាការតំបន់ទាំងពីរនេះ ជាពិសេសប្រទេសកម្ពុជា។

## តារាង ៧.៣.៣. ស្ត្រីតាមគំលាត និងចំនួនកូនកើតរស់ តាមក្រុមអាយុ ជនបទ កម្ពុជា ឆ្នាំ២០១៩

| ក្រុមអាយុ | គំលាតកូនកើតរស់ | | | | | | | | ចំនួនកូនកើត | |
|---|---|---|---|---|---|---|---|---|---|---|
| | ស្ត្រី | ០ | ១ | ២ | ៣ | ៤ | ៥+ | សរុប | ចំនួន | មធ្យម |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨) | (៩) | (១០) | (១១) |
| **សរុប** | **៣.៣៧១.៦៦៦** | **២៧,៥** | **១៤,៣** | **១៩,៥** | **១៣,៩** | **៩,២** | **១៥,៧** | **១០០** | **៧.៨៣៩.៨៦១** | **២,៣៣** |
| ១៥ - ១៩ | ៤២២.៦៧១ | ៩២,៩ | ៤,៩ | ១,២ | ០,៥ | ០,៣ | ០,២ | ១០០ | ៤៧.៧៦៦ | ០,១១ |
| ២០ - ២៤ | ៣៤៧.៣៤៩ | ៥៥,៦ | ៣០,៩ | ១០,៨ | ១,៦ | ០,៥ | ០,៦ | ១០០ | ២១៨.៤៥៥ | ០,៦៣ |
| ២៥ - ២៩ | ៣៩០.០២៥ | ២៧,៤ | ៣១,៨ | ៣០,៨ | ៧,៦ | ១,៦ | ០,៨ | ១០០ | ៤៩៦.៧៩៣ | ១,២៧ |
| ៣០ - ៣៤ | ៣៦២.២១៥ | ១៤,៤ | ១៧,៧ | ៣៩,៦ | ២០,១ | ៥,៨ | ២,៥ | ១០០ | ៧០៣.១១១ | ១,៩៤ |
| ៣៥ - ៣៩ | ៣៦៦.៦៥៦ | ៩,៩ | ១០,៣ | ៣២,៨ | ២៧,៩ | ១២,១ | ៦,៩ | ១០០ | ៩០៤.៤៦៨ | ២,៤៧ |
| ៤០ - ៤៤ | ២៣៥.២៨០ | ៨,៤ | ៨,៧ | ២៤,២ | ២៧,២ | ១៧,០ | ១៤,៥ | ១០០ | ៦៨៤.២៧៨ | ២,៩១ |
| ៤៥ - ៤៩ | ២៥៣.៣៨៥ | ៧,៨ | ៨,៤ | ១៩,២ | ២៣,៤ | ១៨,៨ | ២២,៥ | ១០០ | ៨២៦.៥៧៧ | ៣,២៦ |
| ៥០ - ៥៤ | ២៤៦.១៩៤ | ៨,៩ | ៨,៧ | ១៥,២ | ១៨,៤ | ១៧,៨ | ៣០,៩ | ១០០ | ៨៧៩.៤០៩ | ៣,៥៧ |
| ៥៥ - ៥៩ | ២២០.៩៣៧ | ៩,០ | ៨,៥ | ១២,៦ | ១៤,៤ | ១៥,៧ | ៣៩,៨ | ១០០ | ៨៧៤.៩៨៥ | ៣,៩៦ |
| ៦០ - ៦៤ | ១៧៤.៤៦៨ | ៩,៨ | ៨,៨ | ១១,៥ | ១១,៨ | ១៣,៧ | ៤៤,៣ | ១០០ | ៧២៦.៨៣៦ | ៤,១៧ |
| ៦៥ - ៦៩ | ១៣៥.៨៥០ | ១១,៤ | ៩,៣ | ១១,៤ | ១០,៧ | ១២,៤ | ៤៤,៨ | ១០០ | ៥៧៤.១០៩ | ៤,២៣ |
| ៧០ - ៧៤ | ៩១.៩៥៨ | ១២,៧ | ៨,៥ | ១០,៧ | ១០,៣ | ១២,៥ | ៤៥,៣ | ១០០ | ៣៩៣.១៤៩ | ៤,២៨ |
| ៧៥ - ៧៩ | ៦០.៤៧៨ | ១៤,៥ | ៧,៨ | ១០,១ | ១០,៤ | ១២,៩ | ៤៤,៣ | ១០០ | ២៥៤.២១៧ | ៤,២០ |
| ៨០ - ៨៤ | ៣៦.៥៣៥ | ១៦,៨ | ៨,០ | ៩,៨ | ១០,០ | ១២,៥ | ៤៣,០ | ១០០ | ១៤៨.០៦៨ | ៤,០៥ |
| ៨៥ + | ២៧.៦៦៥ | ១៩,០ | ៨,២ | ១០,៤ | ៩,៨ | ១២,៤ | ៤០,២ | ១០០ | ១០៧.៦៤០ | ៣,៨៩ |

នៅក្នុងកថាខណ្ឌចុងក្រោយនេះ ចាំបាច់មានការពិភាក្សាដោយសង្ខេបអំពីផលប៉ះពាល់មួយចំនួននៃការធ្លាក់ចុះលទ្ធភាពបង្កើតកូនដែលកម្ពុជាអាចកើតឡើងនៅពេលអនាគត។ អ្នកប្រជាសាស្ត្រ និងសេដ្ឋវិទូភាគច្រើនបានចាត់ទុកថាលទ្ធភាពបង្កើតកូនខ្ពស់មានផលអវិជ្ជមានសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។ នេះគឺដោយសារតែធនធានអាចត្រូវបានប្រើសម្រាប់ការវិនិយោគក្នុងកំណើនសេដ្ឋកិច្ច និងវឌ្ឍនភាពសង្គមត្រូវចំណាយមួយភាគធំសម្រាប់លើចំនួនទារក និងកុមារដ៏ច្រើនដែលជាប្រជាជនមិនមានផលិតភាព។ អត្រាលទ្ធភាពបង្កើតកូនខ្ពស់ត្រូវបានចាត់ទុកជាដែនកំណត់ដ៏សំខាន់មួយ ដល់កំណើនសេដ្ឋកិច្ច និងសង្គម។ បច្ចុប្បន្នការធ្លាក់ចុះអត្រាលទ្ធភាពបង្កើតកូនគួរឲ្យកត់សម្គាល់នៅបណ្ដាប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន ពួកគេកំពុងជួបប្រទះនូវស្ថានភាពផ្ទុយគ្នា គឺប្រជាជនវ័យចាស់។ ប្រជាជនវ័យចាស់ក៏ជាប្រជាជនមិនមានផលិតភាពផងដែរ និងក្លាយជាបន្ទុកសម្រាប់សង្គម និងជារបាំងក្នុងការអភិវឌ្ឍ។ ទោះជាយ៉ាងណាក៏ដោយ រវាងក្រុមទាំងពីរប្រជាជនវ័យក្មេង និងប្រជាជនវ័យចាស់ ជាស្ថានភាពអន្តរកាលដែលអាចអំណោយផលខ្ពស់សម្រាប់ការអភិវឌ្ឍ។ និន្នាការនេះត្រូវបានគេហៅថាឱកាស ឬភាគលាភប្រជាសាស្ត្រ។ ការបើកឱកាសនេះកើតឡើងបន្ទាប់ពីធ្លាក់ចុះគួរឲ្យកត់សម្គាល់នៃលទ្ធភាពបង្កើតកូន ហើយប្រជាជនស្ថិតក្នុងអាយុធ្វើការជាចំណែកមួយនៃចំនួនប្រជាជនសរុប គឺខ្ពស់ខុសពីធម្មតា។ ដោយសារការធ្លាក់ចុះ អត្រាលទ្ធភាពបង្កើតកូននាពេលបច្ចុប្បន្នក៏ដោយក៏ចំនួនប្រជាជនវ័យចាស់មិនទាន់ខ្ពស់នៅឡើយ។ ដំណើរការនៃកំណើនសេដ្ឋកិច្ច និងសង្គមអាចផ្សារភ្ជាប់នឹងការកើនឡើងសេដ្ឋកិច្ចខ្ពស់ ជាពិសេសបើការអភិវឌ្ឍបានផ្សារភ្ជាប់នឹងការវិនិយោគលើវិស័យសុខាភិបាល និងអប់រំ។ នៅពេលប្រជាជនវ័យចាស់កើនឡើង ការទទួលឱកាស ឬភាគលាភប្រជាសាស្ត្រក៏នឹងត្រូវបិទបន្តិចម្ដងៗដែរ។ វាមានសារៈ

សំខាន់ក្នុងការចង្អុលបង្ហាញអំពីលទ្ធផលវិជ្ជមាននៃការទទួលបានភាគលាភប្រជាសាស្ត្រ ដែលមិនមែនកើតឡើងដោយស្វ័យប្រវត្តិឡើយ។ រាជរដ្ឋាភិបាល និងសង្គមទាំងមូលគួរតែទាញយកផលប្រយោជន៍ពីសមាសភាពអាយុដែលជាអំណោយផលសម្រាប់ការវិនិយោគដើម្បីទទួលបាននូវកំណើនសេដ្ឋកិច្ចខ្ពស់។ ភាគលាភប្រជាសាស្ត្រគួរតែទទួលបានការចាប់អារម្មណ៍ ជាពិសេសក្នុងចំណោមអ្នកធ្វើផែនការ អ្នកគ្រប់គ្រងរដ្ឋបាល និងអ្នកនយោបាយ ក្នុងអំឡុងពេលប៉ុន្មានឆ្នាំខាងមុខនេះ។

# ជំពូក ៨
# មរណភាព

## ៨.១. ទស្សនទាន

មរណភាពសំដៅលើការស្លាប់ដែលកើតឡើងក្នុងចំណោមប្រជាជន។ ប្រូបាប៊ីលីតេនៃការស្លាប់ក្នុងអំឡុងពេលណាមួយទទួលរងដោយឥទ្ធិពលកត្តាជាច្រើនដូចជាអាយុ ភេទ ការអប់រំ និងស្ថានភាពសេដ្ឋកិច្ច។ អត្រាមរណភាពឆ្លុះបញ្ចាំងយ៉ាងច្បាស់អំពីកម្រិតជីវភាពរស់នៅ និងសេវាសុខភាពរបស់ប្រជាជននៃប្រទេសមួយ។

ជាក់ស្តែងកត្តាកំណត់សំខាន់បំផុតនៃមរណភាពគឺអាយុ ។ ជាពិសេសសារៈសំខាន់នៃអត្រាមរណភាពកុមារក្រោមអាយុ ៥ ឆ្នាំ។ សូចនាករមរណភាពមានបីប្រភេទគឺៈ អត្រាមរណភាពទារកជាចំនួនមរណភាពរបស់ទារកដែលមានអាយុក្រោម ១ ឆ្នាំក្នុងចំនួនកំណើតរស់ ១.០០០ នាក់ក្នុងឆ្នាំណាមួយ។ អត្រាមរណភាពរបស់កុមារជាចំនួនមរណភាពរបស់កុមារដែលមានអាយុពី ១ ទៅ ៤ ឆ្នាំក្នុងចំណោមកុមារ ១.០០០ នាក់។ ហើយអត្រាមរណភាពកុមារអាយុក្រោម៥ ឆ្នាំ គឺប្រូបាប៊ីលីតេនៃការស្លាប់ពីកំណើតរហូតដល់អាយុ ៥ ឆ្នាំ។

ដូចដែលបានរៀបរាប់ខាងដើម កម្រិតមរណភាពគឺជាសូចនាករអាចឆ្លុះបញ្ចាំងអំពីកម្រិតជីវភាពរស់នៅ និងការទទួលបានសេវាសុខភាពរបស់ប្រជាជននៃប្រទេសនោះ។ អត្រាមរណភាពកុមារអាយុក្រោម៥ ឆ្នាំ និងជា ពិសេសអត្រាមរណភាពទារក គឺជាសូចនាករមួយដែលស័ក្តិសម និងត្រឹមត្រូវបំផុតសម្រាប់វាស់វែងនេះ ។

នៅឆ្នាំ២០១៥ ក្រោមគំនិតផ្តួចផ្តើមរបស់អង្គការសហប្រជាជាតិ ពិភពលោកបានចាប់ផ្តើមនូវ របៀបវារៈថ្មីមួយសម្រាប់អភិវឌ្ឍន៍ដើម្បីសម្រេចគោលដៅឆ្នាំ២០៣០ គោលដៅថ្មីនេះដែលបានដាក់ចេញ នៅគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដែលហៅថា (SDGs)។ គោលដៅទាំងនេះភាគច្រើន ទាក់ទងនឹងការធ្វើឱ្យប្រសើរឡើងនូវអត្រាមរណភាពកុមារអាយុក្រោម ៥ ឆ្នាំ ជាពិសេសគោលដៅទី ៣ ចំណុចដៅទី ២ ដែលទាក់ទងដោយផ្ទាល់ជាមួយបញ្ហាមរណភាព។ ការស្នើឡើងក្នុង SDG លើចំណុចដៅគឺមានគោលបំណងដើម្បីបញ្ចប់មរណភាពកុមារនៅឆ្នាំ ២០៣០ ប្រាំឡង់នៃការស្លាប់របស់ទារកទើបនឹងកើត និងកុមារអាយុក្រោម៥ ឆ្នាំនៅប្រទេសទាំងអស់ក្នុងគោលបំណងកាត់បន្ថយអត្រាមរណភាពទារក ទើបនឹងកើតបានយ៉ាងហោចណាស់ទាបជាង ១២ នាក់ក្នុង ១.០០០ នៃកំណើតរស់។ អត្រាមរណភាពកុមារអាយុក្រោម ៥ ឆ្នាំបានយ៉ាងហោចណាស់ទាបជាង ២៥ នាក់ក្នុង ១.០០០ នៃកំណើតរស់ ។

ប្រទេសជាច្រើន ក្នុងនោះមានកម្ពុជាផងដែរខ្វះការស្រង់ទិន្នន័យដោយប្រព័ន្ធនៃការចុះបញ្ជីអត្រានុកូលដ្ឋាន ដូច្នេះការគណនាមរណភាពគឺពឹងអាស្រ័យទាំងស្រុងលើទិន្នន័យដែលប្រមូលតាមរយៈការធ្វើជំរឿន និងអង្កេតប្រជាសាស្ត្រមួយចំនួន។ ប៉ុន្តែប្រភពទាំងនេះមិនបានផ្តល់នូវការគណនាមរណភាពត្រឹមត្រូវនោះទេ។ ដើម្បីទទួលបានការគណនាត្រឹមត្រូវតាមនិយាមអន្តរជាតិក្នុងការប្រើប្រាស់មានវិធីសាស្ត្រជាច្រើនក្នុងការគណនានោះ គឺវិធីសាស្ត្រគណនាដោយប្រយោល។ វិធីសាស្ត្រគណនានេះរៀបចំអភិវឌ្ឍន៍ ដោយ William Brass ក្នុងអំឡុងឆ្នាំ ១៩៧០ សម្រាប់សិក្សាអំពីប្រជាសាស្ត្រនៅតំបន់

សាហារ៉ាអាហ្វ្រិក។ ផ្អែកតាមការសិក្សានេះ អ្នកប្រជាសាស្ត្រជាច្រើនបានធ្វើការកែលម្អវិធីសាស្ត្រគណនាថ្មីៗដែលអាចគណនាមរណភាពមនុស្សពេញវ័យ និងតារាងវដ្តជីវិត ។

គោលបំណងនៃជំពូកនេះគឺដើម្បីប៉ាន់ស្មានការគណនាមរណភាពទារក កុមារ និងកុមារអាយុក្រោម ៥ ឆ្នាំ ដោយរាប់បញ្ចូលការគណនាមនុស្សពេញវ័យ(តាមរយៈតារាងវដ្តជីវិត) និងមរណភាពមាតាផងដែរ។ វិធីសាស្ត្រគណនាដោយប្រយោលត្រូវបានប្រើប្រាស់សម្រាប់ការគណនានេះ ។

## ៨.២. មរណភាពទារក កុមារ និងកុមារអាយុក្រោម ៥ឆ្នាំ

មរណភាពនៅអាយុបឋម គឺត្រូវបានវាស់វែងពីសំណួរចំនួនពីរដែលស្រង់ពីជំរឿនគឺៈចំនួនកូនដែលបានកើតលើស្ត្រី និងចំនួនកូនដែលនៅរស់បែងចែកតាមក្រុមអាយុស្ត្រី។ ប្រើបច្ចេកទេសវ័យឆ្លាតទំនើបប្រជាសាស្ត្រ (វិធីសាស្ត្រគណនាដោយប្រយោល) អាចផ្តល់នូវទិន្នន័យដែលអាចជឿជាក់បានសម្រាប់អត្រាមរណភាពទារក និអត្រាមរណកុមារ(ឬប្រូបាប៊ីលីតេស្លាប់)។ វិធីសាស្ត្រចម្បងដើមដែលរៀបចំអភិវឌ្ឍន៍ដោយអ្នកប្រជាសាស្ត្រជនជាតិអង់គ្លេសលោក William Brass។ មានគម្លាតជាច្រើនត្រូវបានស្នើឡើង(Moultrie et al.,២០១៣) ។ វិធីសាស្ត្រដើមរបស់ Brass (វិធីសាស្ត្រកែសម្រួល) ត្រូវបានប្រើប្រាស់។ ភាគច្រើននៃវិធីសាស្ត្រគណនាមរណភាព គឺប្រើប្រាស់តារាងវដ្តជីវិត ។ មានវិធីសាស្ត្រចម្បងពីរត្រូវបានស្នើឡើងគឺ បច្ចេកទេសអភិវឌ្ឍន៍ដោយ Coale-Demeny តាមតំបន់លំនាំតារាងវត្តន៍ជីវិត (ខាងលិច ខាងជើង ខាងកើត និងខាងត្បូង) និងតារាងវដ្តជីវិតអង្គការសហប្រជាជាតិសម្រាប់ ប្រទេសកំពុងអភិវឌ្ឍន៍ដូចជា (អាមេរិកឡាទីន ឈីលី អាស៊ីខាងត្បូង មជ្ឈឹមបូព៌ា និងទូទៅ )[២]។

ករណីកម្ពុជាតារាងវដ្តជីវិតដែលសមស្របបំផុតគឺសម្រាប់គណនាតាមលំនាំភាគខាងជើង ។ ទាំងនេះត្រូវបានកំណត់ ដោយប្រើលំនាំដែលបង្ហាញនៅក្នុងសៀវភៅសិក្សាសម្រង់ខាងក្រោមតារាងយោងទី៣ខាងក្រោមទំព័រ ។

តារាង ៨.២.១ បង្ហាញពីអត្រាមរណភាពទារក កុមារ និងកុមារអាយុក្រោម ៥ ឆ្នាំដែលបានប៉ាន់ស្មានពីទិន្នន័យជំរឿនឆ្នាំ២០១៩។ បើប្រៀបធៀបនឹងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងទៀតនៅក្នុងតំបន់ អត្រាមរណភាពរបស់ទារក គឺមិនមានអត្រាខ្ពស់ប៉ុន្មានឡើយ ប៉ុន្តែមានលក្ខណៈល្អប្រសើរឡើងច្រើន បើធៀបនឹងឆ្នាំកន្លងទៅ។ ឧទាហរណ៍ប្រទេសឥណ្ឌូនេស៊ី ឡាវ និងម៉ាឡេស៊ី មានអត្រាមរណភាព ទារកស្មើនឹង ១៦ ៣៣ និង ៥ (សម្រាប់ទាំងពីរភេទ) តាមលំដាប់រៀង។ នៅប្រទេសមីយ៉ាន់ម៉ា ថៃ និងវៀតណាមអត្រានេះមាន ៣៣ ៧ និង ១៨ តាមលំដាប់រៀងគ្នា (UNITED NATIONS ២០១៩) ។

[2] Model life tables are sets of life tables based on the generalization of empirical relationships derived from a group of observed life tables. The Coale-Demeny Regional Model Life Tables and the United Nations Life Tables for Developing Countries are the two main systems of model life tables. These systems are based on empirical life tables that have been developed on the principle of narrowing the selection of a life table to those considered realistic on the basis of examination of mortality levels and patterns calculated for actual populations. These systems cover a wide variety of mortality experiences, so that one may be more appropriate than other for a particular country. Each system has *families* of life tables. The families in the Coale-Demeny system are: East, West, North and South and the families in the United Nations system are: Latin American, Chilean, South Asian, Far East and General (United Nations, 1983).

### តារាង ៨.២.១ អត្រាមរណភាពអាយុបឋម និងអាយុសង្ឃឹមរស់ តាមភេទ និងតំបន់ កម្ពុជាឆ្នាំ ២០១៩

| តំបន់ | មរណភាព ទារក | មរណភាព កុមារអាយុ ក្រោម ៥ឆ្នាំ | អាយុសង្ឃឹមរស់ | ពេលវេលា យោង |
|---|---|---|---|---|
| (១) | (២) | (៣) | (៤) | (៥) |
| **សរុប** | | | | |
| ទាំងពីរភេទ | ១៧,៦ | ២៨,១ | ៧៥,៥ | ២០១៦.៨ |
| ប្រុស | ២០,៦ | ៣១,៧ | ៧៤,៣ | ២០១៦.៨ |
| ស្រី | ១៤,៦ | ២៤,៣ | ៧៦,៨ | ២០១៦.៨ |
| **ទីប្រជុំជន** | | | | |
| ទាំងពីរភេទ | ១៥,៩ | ២៥,៥ | ៧៥,៦ | ២០១៦.៦ |
| ប្រុស | ១៩,៤ | ២៩,៨ | ៧៣,៥ | ២០១៦.៥ |
| ស្រី | ១២,៦ | ២១,០ | ៧៧,៧ | ២០១៦.៦ |
| **ជនបទ** | | | | |
| ទាំងពីរភេទ | ១៨,៥ | ២៩,៥ | ៧៤,៥ | ២០១៦.៨ |
| ប្រុស | ២១,៣ | ៣២,៨ | ៧២,៨ | ២០១៦.៨ |
| ស្រី | ១៥,៧ | ២៦,១ | ៧៦,៤ | ២០១៦.៨ |

ជាទូទៅ អត្រាមរណភាពមានខ្ពស់នៅក្នុងចំណោមប្រុសជាងស្រីជាពិសេសមរណភាពទារក។ ទម្រង់នេះបានកំណត់ដោយកត្តាជីវសាស្ត្រ។ ផ្ទុយទៅវិញអត្រាមរណភាពកុមារ ជាទូទៅស្រីមានអត្រាខ្ពស់ជាពិសេសនៅបណ្តាប្រទេសដែលមានទំនោរលើភេទ( ទំនោរកូនប្រុស )។ ករណីកម្ពុជាអត្រាទាំងពីរមានប្រហាក់ប្រហែល គ្នាបញ្ជាក់ថាមានទំនោរការចង់បានកូនប្រុស បើក្នុងករណីមានពិតនោះមិនមានផលប៉ះពាល់លើការរស់រានរបស់កុមារទេ។

អនុលោមតាមតារាង ៨.២.១ និងដូចដែលបានសង្ឃឹមទុកអត្រា មរណភាពនៅជនបទមាន អត្រាខ្ពស់ជាងតំបន់ទីប្រជុំជនស្ទើរតែគ្រប់ប្រទេស។ មានកត្តាជាច្រើនដែល បានបកស្រាយអំពីភាពផ្សេងគ្នា នៃអត្រាមរណភាពក្នុងកម្រិតសិក្សាអប់រំរបស់ឪពុកម្តាយ ការទទួលបានសេវាសុខាភិបាល ការអនុវត្តអនាម័យជាដើម។ ទោះជាយ៉ាងណាក៏ដោយភាពខុសគ្នានៅទីប្រជុំជន និងជនបទនៅកម្ពុជា ដែលបង្ហាញក្នុងតារាង ៨.២.១ មានតិចតួច។ នេះអាចបញ្ជាក់បានថាគោលនយោបាយពង្រីកការទទួលបានសេវាសុខភាពមានភាពទូលំទូលាយ និងគ្រប់គ្រាន់។ ចំនុចនេះគួរត្រូវបានចាត់ទុកជាកត្តាសំខាន់ដើម្បីសិក្សា បញ្ហានេះឱ្យបានទូលំទូលាយនិងគ្រប់ជ្រុងជ្រោយ ។

តារាង ៨.២.១ បង្ហាញផងដែរអំពីអាយុកំណើតសង្ឃឹមរស់ដែលជាសូចនាករសំខាន់នៃមរណភាពទូទៅ ប៉ុន្តែវាទទួលរងឥទ្ធិពលខ្លាំងពីមរណភាពទារក។ ការបកស្រាយលម្អិតនឹងពិភាក្សាក្នុងផ្នែកបន្ទាប់ ។

រូប ៨.២.១ បង្ហាញមរណភាពអាយុបឋមយោងតាមលទ្ធផលជំរឿនឆ្នាំ២០០៨ និងឆ្នាំ២០១៩។ មានការថយចុះនៃអត្រាមរណភាពដូចដែលបានឃើញស្រាប់រវាងឆ្នាំ២០០៨ និងឆ្នាំ២០១៩។ គួរកត់សម្គាល់ថាអត្រាមរណភាពកុមារអាយុក្រោម ៥ ឆ្នាំបានថយចុះស្ទើរតែពាក់កណ្តាល។ អាចមានការកែលម្អរលទ្ធផលជាមួយទិន្នន័យតាមការគណនាវិធីសាស្ត្រផ្សេងៗគ្នាជាច្រើន ប៉ុន្តែភាពផ្សេងគ្នានេះមានការខុសគ្នាខ្លាំងដែលសំខាន់សមាសជាតុតម្លៃពិត។ ជាថ្មី

ម្តងទៀតបញ្ហានេះគួរតែម្រូវឱ្យមានការសិក្សាស៊ីជម្រៅ ជាពិសេសដើម្បីវិភាគពីតួនាទីនៃគោលនយោបាយរបស់រដ្ឋាភិបាល។ អត្រាមរណភាពកុមារនៅតែបន្តធ្លាក់ចុះក្នុងអត្រានេះ នោះចំណុចដៅនៃ SDG នឹងសម្រេចបានជោគជ័យ(២៥នាក់ក្នុង១.០០០ កំណើតរស់ ត្រឹមឆ្នាំ២០៣០)។

រូប ៨.២.១. អត្រាមរណភាពអាយុបឋមកម្ពុជាឆ្នាំ ២០០៨ និង ២០១៩




## ៨.៣. មរណភាពមនុស្សពេញវ័យ និងតារាងវដ្តជីវិត

តារាងវដ្តជីវិត គឺជាឧបករណ៍ដែលមានលក្ខណៈសមស្របបំផុតក្នុងការសិក្សាអំពីប្រជាសាស្ត្រ ដែលត្រូវបានប្រើដើម្បីពិនិត្យលើបរិបទនៃទម្រង់មរណភាពរបស់ប្រជាជន។ អត្រាមរណភាពតាមក្រុម អាយុ ត្រូវបានអនុវត្តន៍ធៀបនឹងចំនួនទារក ១០០.០០០ នាក់ដែលកើតក្នុងពេលដូចគ្នានេះ។ សម្រាប់ក្រុមអាយុក្នុងតារាងវដ្តជីវិត បង្ហាញពីការស្លាប់ក្នុងក្រុមអាយុនិមួយៗពីចំណាត់ថ្នាក់នៃប្រជាជនដែលមានក្នុងសម្មតិកម្មទាបបំផុតរហូតនៅជួរខាងលើដល់ជួរក្រោមបំផុត ដែលកំណត់ដោយការស្លាប់របស់ក្រុមមនុស្សវ័យចាស់។ តារាងវដ្តជីវិតនេះត្រូវបានប្រើប្រាស់ដើម្បីវាស់ពីអត្រាមរណភាព និងជាឧបករណ៍វិភាគដើម្បីគណនាសូចនាករផ្សេងទៀតផងដែរ ។

វិធីសាស្ត្រនេះត្រូវបានប្រើប្រាស់ញឹកញាប់បំផុតដើម្បីគណនាអត្រាមរណភាពមនុស្សពេញវ័យតាមវិធីសាស្ត្រដោយប្រយោលនៅពេលដែលស្ថិតិអត្រានុកូលដ្ឋានមិនបានប្រមូល ហើយចាំបាច់ប្រើទិន្នន័យជំរឿន។ វិធីសាស្ត្រទាំងនេះត្រូវបានរៀបចំជាក្រុម ជំរឿនវិធីសាស្ត្ររស់រាន វិធីសាស្ត្រតុល្យភាពកំណើន វិធីសាស្ត្រស្លាប់តាមជំនាន់ទូទៅ និងការគណនាពីព័ត៌មានអំពីការរស់រានរបស់ឪពុកម្តាយ និងការរស់រានរបស់ប្តី/ ប្រពន្ធ។ វិធីសាស្ត្រតុល្យភាពកំណើនត្រូវបានប្រើប្រាស់ច្រើនបំផុត និងមានក្នុងការកែតម្រូវទិន្នន័យពីចំនួនស្លាប់តាមក្រុមអាយុ និងភេទ ដែលបានប្រមូលពីជំរឿនដោយប្រើប្រាស់សំណួរចំនួនសមាជិកគ្រួសារដែលបានស្លាប់ក្នុងអំឡុងពេលកំណត់ដែលជាទូទៅមួយឆ្នាំមុនជំរឿន។ ជំរឿនជាច្រើន រាប់បញ្ចូលជំរឿនទូទៅប្រជាជននៅកម្ពុជាបានបញ្ចូលសំណួរប្រភេទនេះ។ ភេទ និងអាយុ នៃការស្លាប់ត្រូវបានប្រមូលផងដែរ។ ទិន្នន័យដែលប្រមូលពីសំណួរនេះអាចឲ្យយើងគណនាអត្រាស្លាប់តាមអាយុជាក់លាក់ ដែលអត្រាស្លាប់ត្រូវបានគណនាតាមក្រុមអាយុជាក់លាក់។ អត្រានេះអាចមានភាពងាយស្រួលក្នុងការផ្លាស់ប្តូរជាប្រូបាប៊ីលីតេ នៃការ

ស្លាប់នៅអាយុដែលបានកំណត់ និងជាពិសេសក្នុងសូចនាករមរណភាពមនុស្សពេញវ័យ ដែលប្រូបាប៊ីលីតេនៃការស្លាប់រវាងអាយុ ១៥ និង៦០ឆ្នាំ ។

គោលបំណងនៃការគណនាអត្រាមរណភាពមុស្សពេញវ័យសំខាន់បំផុត គឺដើម្បីរៀបចំតារាងវដ្តជីវិត។ តារាងនេះមិនត្រឹមតែជាឧបករណ៍ប្រជាសាស្ត្រដ៏មានសារប្រយោជន៍ប៉ុណ្ណោះទេ តែប្រើសម្រាប់សិក្សាពីមរណភាព សម្រាប់បម្រើឲ្យគោលបំណងនៃការវិភាគផងដែរ ។

ទោះជាយ៉ាងណាក៏ដោយ មុនរៀបចំបង្កើតតារាងវដ្តជីវិត វាមានភាពចាំបាច់ដើម្បីកំណត់បញ្ហានៃព័ត៌មានមរណភាពពីចំនួនសមាជិកស្លាប់ក្នុងគ្រួសារក្នុងអំឡុងពេលកំណត់មួយ។ ជាញឹកញាប់មនុស្សច្រើន មិនបានឆ្លើយពីសមាជិកស្លាប់ដោយសារបំរាម ជំនឿ ទំនៀមទំលាប់ប្រពៃណី ឬមូលហេតុនៃការរំជួលអារម្មណ៍។ ការទទួលមរណភាពរបស់សមាជិកថ្មី អាចជាបទពិសោធន៍ដ៏លំបាកធ្វើឲ្យមានការរំជួលអារម្មណ៍ក្នុងការទទួលយកជាហេតុការស្លាប់មិនត្រូវបានឆ្លើយ។ បញ្ហាទាំងពីរនេះជាហេតុផលធ្វើឲ្យមានការគណនានៅក្រោមតម្លៃពិតជាក់ស្តែងនៃមរណភាពមាតា។ ទោះជាយ៉ាងណាក៏ដោយអ្នកផ្តល់ចម្លើយអាចមានការភ័ន្តច្រឡំអំពីសមាជិកស្លាប់ក្នុងគ្រួសារ ស្លាប់ដដែលនេះរាប់លើសម្តង។ ក្នុងករណីនេះអត្រាមរណភាពរាប់លើសតម្លៃពិតជាក់ស្តែង។ លំអៀងក្នុងការរាប់សមាជិកស្លាប់ក្នុងអំឡុងពេល ១២ ខែ មុនពេលធ្វើជំរឿន អាចលើស ឬខ្វះនៃចំនួនមរណភាពមាតា ។

វិធីសាស្ត្រដែលបានរៀបរាប់ខាងដើម គឺដើម្បីស្វែងរកដំណោះស្រាយបញ្ហាដែលកើត តែងតែកើតមានឡើងនៅពេលសម្ភាសន៍ជំរឿន។ សម្រាប់កម្ពុជាសមីការតុល្យភាពកំណើតត្រូវបានប្រើ។ តែលទ្ធផលមិនឆ្លុះបញ្ចាំងពីទិដ្ឋភាពជាក់ស្តែងដែលតម្រូវឲ្យមានការសិក្សាលម្អិតជាងអ្វីដែលបានរកឃើញក្នុងរបាយការណ៍នេះ។

វិធីសាស្ត្រជំនួសដែលត្រូវបានប្រើគឺ៖ ការគណនាតារាងវដ្តជីវិតសម្រាប់ប៉ាន់ស្មានមរណភាពទារក ប្រើការគណនាប៉ាន់ស្មានដោយប្រយោលនៃមរណភាពអាយុក្រោម ៥ ឆ្នាំ (តារាង ៨.២.១) និងតារាងលំនាំវដ្តជីវិត។ ការគណនាទាំងនេះត្រូវប្រើវិធីសាស្ត្រ MATCH ពីកម្មវិធី MORTPAR[៣] របស់អង្គការសហប្រជាជាតិ និងតារាងវដ្តជីវិតតាមលំនាំតំបន់ភាគខាងជើង ។

តារាង ៨.៣.១ បង្ហាញតារាងវដ្តជីវិតយោងតាមទិន្នន័យជំរឿន និងវិធីសាស្ត្រដែលបានប្រើ។ ប្រយោគខាងក្រោមតារាងពន្យល់ពីអត្ថន័យនៃបង្គោលនិមួយៗ និងមុខងាររបស់វា។ ភាពសំខាន់បំផុតនៃតារាងវដ្តជីវិត និងលក្ខណៈពិសេសគឺអាយុសង្ឃឹមរស់។ អាយុសង្ឃឹមរស់ពិព៌ណនាអំពីបរិបទនៃប្រវត្តិមរណភាពក្នុងចំណោមប្រជាជន ប្រសិនបើកម្រិតនិងទម្រង់និន្នាការក្នុងតារាងស្ថិតនៅថេរក្នុងពេលអនាគត។ ឧទាហរណ៍ប្រុសអាយុក្រោម ១ ឆ្នាំក្នុងចំណោមប្រជាជនក្នុងឆ្នាំ ២០១៩ នឹងមិនអាចរស់នៅបានត្រឹមអាយុ ៧៤,៣ ឆ្នាំ ប៉ុន្តែប្រហែលអាចលើសនេះ។ អាយុសង្ឃឹមរស់នៅបានត្រឹមអាយុ ៧៤,៣ ឆ្នាំប្រសិនបើលក្ខខ័ណ្ឌនៃទម្រង់មរណភាពស្ថិតនៅថេរក្នុងពេលអនាគត។ អាយុសង្ឃឹមរស់នៅក្រុមអាយុផ្សេងទៀតអាចបកស្រាយដូចគ្នានេះ។ ឧទាហរណ៍ អាយុសង្ឃឹមរស់របស់ស្ត្រីនៅអាយុ ៤០ ឆ្នាំអាចបន្តរស់បានរហូតដល់ ៣៩,៣ ឆ្នាំ ទៀត ប្រសិនបើលក្ខខ័ណ្ឌនៃទម្រង់មរណភាពនៅកម្ពុជាឆ្នាំ២០១៩ ស្ថិតនៅថេរក្នុងពេលអនាគត ។

[3] United Nations Population Division (2013), *MORTPAK for Windows*, Version 4.3, United Nations, New York.

## តារាង ៨.៣.១. តារាងវដ្តជីវិតប្រុស កម្ពុជា ឆ្នាំ២០១៩

| អាយុ | m(x,n) | q(x,n) | l(x) | d(x,n) | L(x,n) | S(x,n) | T(x) | e(x) | a(x,n) |
|---|---|---|---|---|---|---|---|---|---|
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨) | (៩) | (១០) |
| ០ | ០,០១៧៧៩ | ០,០១៧៥១ | ១០០០០០ | ១៧៥១ | ៩៨៤១២ | ០,៩៨១២៨ | ៧៤៣០០០០ | ៧៤,៣០ | ០,០៩ |
| ១ | ០,០០០៨១ | ០,០០៣២៥ | ៩៨២៤៩ | ៣២០ | ៣៩២២៣០ | ០,៩៩៦៨២ | ៧៣៣១៥៨៨ | ៧៤,៦២ | ១,៦០ |
| ៥ | ០,០០០៤៦ | ០,០០២៣១ | ៩៧៩៣០ | ២២៦ | ៤៨៩០៨២ | ០,៩៩៧៨៧ | ៦៩៣៩៣៥៨ | ៧០,៨៦ | ២,៥០ |
| ១០ | ០,០០០៣៩ | ០,០០១៩៤ | ៩៧៧០៣ | ១៩០ | ៤៨៨០៤១ | ០,៩៩៦៩៦ | ៦៤៥០២៧៦ | ៦៦,០២ | ២,៥០ |
| ១៥ | ០,០០០៩៣ | ០,០០៤៦២ | ៩៧៥១៣ | ៤៥០ | ៤៨៦៥៥៦ | ០,៩៩៤២២ | ៥៩៦២២៣៥ | ៦១,១៤ | ២,៧៦ |
| ២០ | ០,០០១៣៤ | ០,០០៦៦៩ | ៩៧០៦៣ | ៦៤៩ | ៤៨៣៧៤៣ | ០,៩៩៣២០ | ៥៤៧៥៦៧៩ | ៥៦,៤១ | ២,៥៨ |
| ២៥ | ០,០០១៣៦ | ០,០០៦៧៧ | ៩៦៤១៤ | ៦៥៣ | ៤៨០៤៥៣ | ០,៩៩២៨៦ | ៤៩៩១៩៣៦ | ៥១,៧៨ | ២,៥២ |
| ៣០ | ០,០០១៥៣ | ០,០០៧៦០ | ៩៥៧៦១ | ៧២៨ | ៤៧៧០២២ | ០,៩៩១៩២ | ៤៥១១៤៨៤ | ៤៧,១១ | ២,៥៥ |
| ៣៥ | ០,០០១៧៤ | ០,០០៨៦៩ | ៩៥០៣៣ | ៨២៦ | ៤៧៣១៦៨ | ០,៩៩០១៧ | ៤០៣៤៤៦២ | ៤២,៤៥ | ២,៥៨ |
| ៤០ | ០,០០២២៧ | ០,០១១២៧ | ៩៤២០៨ | ១០៦១ | ៤៦៨៥១៥ | ០,៩៨៦៧៥ | ៣៥៦១២៩៣ | ៣៧,៨០ | ២,៦២ |
| ៤៥ | ០,០០៣១៩ | ០,០១៥៨៤ | ៩៣១៤៧ | ១៤៧៥ | ៤៦២៣០៧ | ០,៩៧៨៩៧ | ៣០៩២៧៧៨ | ៣៣,២០ | ២,៦៨ |
| ៥០ | ០,០០៥៤៧ | ០,០២៧០២ | ៩១៦៧១ | ២៤៧៧ | ៤៥២៥៨៤ | ០,៩៦៨២២ | ២៦៣០៤៧២ | ២៨,៦៩ | ២,៦៧ |
| ៥៥ | ០,០០៧៥៨ | ០,០៣៧២៤ | ៨៩១៩៥ | ៣៣២២ | ៤៣៨២០០ | ០,៩៥១៨១ | ២១៧៧៨៨៨ | ២៤,៤២ | ២,៦៦ |
| ៦០ | ០,០១២៧៣ | ០,០៦១៨១ | ៨៥៨៧៣ | ៥៣០៨ | ៤១៧០៨៣ | ០,៩២០៥២ | ១៧៣៩៦៨៨ | ២០,២៦ | ២,៦៩ |
| ៦៥ | ០,០២១០៥ | ០,១០០៣២ | ៨០៥៦៥ | ៨០៨២ | ៣៨៣៩៣៤ | ០,៨៧៣៣៧ | ១៣២២៦០៥ | ១៦,៤២ | ២,៦៦ |
| ៧០ | ០,០៣៤២៧ | ០,១៥៨៥២ | ៧២៤៨៣ | ១១៤៩០ | ៣៣៥៣១៥ | ០,៧៩៧២២ | ៩៣៨៦៧២ | ១២,៩៥ | ២,៦៤ |
| ៧៥ | ០,០៥៨៤៦ | ០,២៥៦២០ | ៦០៩៩៣ | ១៥៦២៧ | ២៦៧៣២១ | ០,៥៥៦៩៤ | ៦០៣៣៥៧ | ៩,៨៩ | ២,៥៩ |
| ៨០ | ០,១៣៥០០ | ,,, | ៤៥៣៦៦ | ៤៥៣៦៦ | ៣៣៦០៣៦ | ,,, | ៣៣៦០៣៦ | ៧,៤១ | ៧,៤១ |

***សម្គាល់:*** *m(x,n) =អាយុជាក់លាក់នៅចំណុចកណ្តាលអត្រាមរណភាព*

*a(x,n) = ចំនួននាក់-ឆ្នាំមធ្យមដែលនៅរស់សម្រាប់អ្នកដែលបានស្លាប់រវាងអាយុ **x** និង **x+n***

*nqx = ប្រូបាប៊ីលីតេនៃការស្លាប់អាយុជាក់លាក់ **x** និង **x+n** (អត្រាស្លាប់នៅអាយុជាក់លាក់)*

*l(x) = ចំនួនអ្នកនៅរស់នៃអាយុ **x,***

*ndx = ចំនួនអ្នកស្លាប់ដែលកើតមានឡើងរវាងអាយុ **x** និង **x+n,***

*nLx = ចំនួននាក់-ឆ្នាំដែលបានរស់រវាងអាយុ **x** និង **x+n,***

*៥Sx = ផលធៀបរស់រានមានជីវិតសម្រាប់អ្នកមានអាយុ **x** ដល់ **x+៥** រស់រានជីវិត **៥** ឆ្នាំដល់អាយុ x+៥ to x+១០ = ៥Lx+៥/៥Lx*

*Tx = ចំនួនអ្នករស់-ឆ្នាំបន្ទាប់ពីអាយុ **x,***

***e(x)** = អាយុសង្ឃឹមរស់នៅអាយុ **x,***

*ដំបូងត្រូវបញ្ចូលទិន្នន័យ **S(x,n)** សម្រាប់ការរស់រាមានជីវិតអាយុ **៥** ជំនាន់ ក្នុងក្រុម **0-៤ = L(0,៥) / ៥00000***

*បន្ទាប់ត្រូវបញ្ចូលទិន្នន័យ S(x,n) is for S(0,៥) = L(៥,៥) / L(0,៥)*

*ចុងក្រោយត្រូវបញ្ចូលទិន្នន័យ S(x,n) is S( ៧៥+,៥) = T( ៨0) / T( ៧៥)*

កម្រិតមរណភាពរបស់ប្រទេសជាទូទៅបញ្ជាក់ដោយអាយុកំណើតសង្ឃឹមរស់ និងត្រូវបានគណនាដាច់ដោយឡែករវាងប្រុស និងស្រី។ ករណីកម្ពុជាកម្រិតមរណភាពក្នុងតារាងវដ្តជីវិតមានភាព ស៊ីសង្វាក់គ្នានឹងមរណភាពកុមារអាយុក្រោម ៥ ឆ្នាំ និងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងទៀត ។

## តារាង ៨.៣.១. តារាងវដ្តជីវិតស្រី កម្ពុជា ឆ្នាំ២០១៩

| អាយុ | m(x,n) | q(x,n) | l(x) | d(x,n) | L(x,n) | S(x,n) | T(x) | e(x) | a(x,n) |
|---|---|---|---|---|---|---|---|---|---|
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨) | (៩) | (១០) |
| ០ | ០,០១៤៨៧ | ០,០១៤៦៨ | ១០០០០០ | ១៤៦៨ | ៩៨៦៧០ | ០,៩៨៤២៥ | ៧៦៨០០០០ | ៧៦,៨០ | ០,០៩ |
| ១ | ០,០០០៦៩ | ០,០០២៧៥ | ៩៨៥៣២ | ២៧១ | ៣៩៣៤៥២ | ០,៩៩៧៦៩ | ៧៥៨១៣២៩ | ៧៦,៩៤ | ១,៥០ |
| ៥ | ០,០០០២៦ | ០,០០១៣១ | ៩៨២៦១ | ១២៩ | ៤៩០៩៨៤ | ០,៩៩៨៧០ | ៧១៨៧៨៧៧ | ៧៣,១៥ | ២,៥០ |
| ១០ | ០,០០០២៦ | ០,០០១២៩ | ៩៨១៣២ | ១២៧ | ៤៩០៣៤៤ | ០,៩៩៨៣០ | ៦៦៩៦៨៩៣ | ៦៨,២៤ | ២,៥០ |
| ១៥ | ០,០០០៤៦ | ០,០០២២៩ | ៩៨០០៥ | ២២៥ | ៤៨៩៥១០ | ០,៩៩៧១៤ | ៦២០៦៥៤៩ | ៦៣,៣៣ | ២,៧០ |
| ២០ | ០,០០០៦៨ | ០,០០៣៤១ | ៩៧៧៨០ | ៣៣៣ | ៤៨៨១១០ | ០,៩៩៦២០ | ៥៧១៧០៣៩ | ៥៨,៤៧ | ២,៦២ |
| ២៥ | ០,០០០៨៣ | ០,០០៤១៤ | ៩៧៤៤៧ | ៤០៣ | ៤៨៦២៥៤ | ០,៩៩៥៦៦ | ៥២២៨៩២៩ | ៥៣,៦៦ | ២,៥៦ |
| ៣០ | ០,០០០៩១ | ០,០០៤៥៦ | ៩៧០៤៤ | ៤៤៣ | ៤៨៤១៤៣ | ០,៩៩៥០១ | ៤៧៤២៦៧៥ | ៤៨,៨៧ | ២,៥៦ |
| ៣៥ | ០,០០១១៣ | ០,០០៥៦២ | ៩៦៦០២ | ៥៤៣ | ៤៨១៧២៥ | ០,៩៩២៨៨ | ៤២៥៨៥៣២ | ៤៤,០៨ | ២,៦៤ |
| ៤០ | ០,០០១៧៩ | ០,០០៨៩០ | ៩៦០៥៨ | ៨៥៥ | ៤៧៨២៩៥ | ០,៩៨៩៤៥ | ៣៧៧៦៨០៨ | ៣៩,៣២ | ២,៦៦ |
| ៤៥ | ០,០០២៥១ | ០,០១២៤៨ | ៩៥២០៤ | ១១៨៨ | ៤៧៣២៥០ | ០,៩៨៣៨២ | ៣២៩៨៥១២ | ៣៤,៦៥ | ២,៦៧ |
| ៥០ | ០,០០៤១២ | ០,០២០៤១ | ៩៤០១៦ | ១៩១៩ | ៤៦៥៥៩៤ | ០,៩៧៥៩៩ | ២៨២៥២៦២ | ៣០,០៥ | ២,៦៦ |
| ៥៥ | ០,០០៥៧២ | ០,០២៨២១ | ៩២០៩៧ | ២៥៩៨ | ៤៥៤៤១៤ | ០,៩៦៣៥៤ | ២៣៥៩៦៦៨ | ២៥,៦២ | ២,៦៦ |
| ៦០ | ០,០០៩៦០ | ០,០៤៦៩៤ | ៨៩៤៩៨ | ៤២០១ | ៤៣៧៨៤៨ | ០,៩៣៧៨៣ | ១៩០៥២៥៤ | ២១,២៩ | ២,៧០ |
| ៦៥ | ០,០១៦៨០ | ០,០៨០៨៥ | ៨៥២៩៧ | ៦៨៩៧ | ៤១០៦២៨ | ០,៨៩២៩៧ | ១៤៦៧៤០៦ | ១៧,២០ | ២,៧០ |
| ៧០ | ០,០២៩៧២ | ០,១៣៩០០ | ៧៨៤០១ | ១០៨៩៧ | ៣៦៦៦៧៩ | ០,៨១៨២៨ | ១០៥៦៧៧៨ | ១៣,៤៨ | ២,៦៨ |
| ៧៥ | ០,០៥២៦៥ | ០,២៣៤០៤ | ៦៧៥០៣ | ១៥៧៩៩ | ៣០០០៤៧ | ០,៥៦៥២១ | ៦៩០០៩៩ | ១០,២២ | ២,៦៣ |
| ៨០ | ០,១៣២៥៦ | ,,, | ៥១៧០៥ | ៥១៧០៥ | ៣៩០០៥២ | ,,, | ៣៩០០៥២ | ៧,៥៤ | ៧,៥៤ |

រូប ៨.៣.១ បង្ហាញពីទម្រង់អាយុមរណភាពយោងតាម lx (ចំនួនអ្នកនៅរស់នៃអាយុ x) ។ បន្ទាប់ពីការចាប់ផ្ដើមធ្លាក់ចុះនៃអត្រាមរណភាពសន្សឹមៗ គឺជាអំឡុងពេលមានស្ថេរភាពហើយក៏មានការ ធ្លាក់ចុះយ៉ាងយ៉ាងលឿនក្នុងអត្រាមរណភាព។ នេះជាប្រភេទមរណភាព។ ចំណុចសំខាន់គួរកត់សម្គាល់ថា ទម្រង់នៃមរណភាពក្នុងចំណោមប្រជាជនទាំងមូលជាទូទៅអត្រាខ្ពស់មានក្នុងចំណោមប្រុស(អត្រារស់រានមានជីវិតខ្ពស់ក្នុងចំណោមស្រី) ។

### រូប ៨.៣.១. សមាសភាពអាយុ ភាពរស់រានមានជីវិត តាមភេទ កម្ពុជា ឆ្នាំ២០១៩




## ៨.៤. មរណភាពមាតា

ក្នុងអំឡុងបីទស្សវត្សន៍ចុងក្រោយ អត្រាមរណភាពមាតាមានអត្រាខ្ពស់ក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ត្រូវបានទទួលស្គាល់កាន់តែខ្លាំងឡើងថាជាបញ្ហាប្រឈមក្នុងវិស័យសុខភាពសាធារណៈ។ ការពិតគួរឱ្យចាប់អារម្មណ៍នោះគឺផលធៀបនៃមរណភាពមាតា (កំណត់ដោយចំនួនមរណភាពមាតាក្នុងកំឡុងពេលផ្តល់ ១០០.០០០ កំណើតរស់នៅក្នុងអំឡុងពេលដូចគ្នា) នៅប្រទេសកំពុងអភិវឌ្ឍន៍ផលធៀបនេះ គឺមានចំនួនច្រើនជាង ១០០ ដងធៀបនឹងប្រទេសអភិវឌ្ឍន៍។ មរណភាពមាតាត្រូវបានកំណត់ជាសូចនាករ សុខភាពដែលមានភាពខុស គ្នាខ្លាំងរវាងប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសអភិវឌ្ឍន៍។ ការស្លាប់របស់មាតាក្នុងអំឡុងពេលមានគ៌រ គឺជាសូចនាករបញ្ជាក់ពីគុណភាពសេវាសុខភាព។ បញ្ហាចម្បងភាគច្រើននៃមរណភាពមាតាគឺអាចបង្ការបាន។ បន្ថែមលើសពីនេះទៀតមរណភាពមាតា គឺជាសោកនាដកម្មមួយក្នុងចំណោមសោកនាដកម្មធំបំផុតដែលអាចកើតមាននៅក្នុងគ្រួសារ ដែលអាចបង្កជាផលវិបាកជាយ៉ាងធំធេងសម្រាប់កុមារកំព្រា ប្តី/ប្រពន្ធនិងសមាជិកគ្រួសារដ៏ទៃទៀត និងសង្គមជាតិផងដែរ។

បញ្ហាមរណភាពមាតាត្រូវបានលើកយកមកពិភាក្សានៅសន្និសិទ្ធជាច្រើន និងជាបញ្ហាថ្មីៗដែលមានសារសំខាន់ជាផ្នែកមួយនៃគោលដៅ SDG ដែលបានរៀបរាប់ខាងលើ។ ចំណុចដៅចំនួន ៦ ដែលទាក់ទងនឹងមរណភាពមាតាដែលមានក្នុងគោលដៅទី ៣ នៅក្នុងរបៀបវៀរៈឆ្នាំ ២០៣០ នោះគឺ កាត់បន្ថយជាសកលនូវផលធៀបមរណមាតាឲ្យបានទាបជាង ៧០ ក្នុង ១០០.០០០ កំណើតរស់ ។

មានវិធីសាស្រ្តជាច្រើនដើម្បីគណនាមរណមាតា ប៉ុន្តែដែលសមស្រប និងជឿជាក់បំផុតនោះគឺផ្អែកលើសំណួរដោយផ្ទាល់ដែលដាក់បញ្ចូលក្នុងជំពូកពីសេសក្នុងផ្នែកមរណភាពមនុស្សពេញវ័យ។ សម្រាប់ស្ត្រីក្នុងអាយុ ១៥-៤៩

ដែលបានស្លាប់ក្នុងអំឡុងពេល ១២ ខែមុនពេលធ្វើជំរឿន ត្រូវបានសួរថាតើស្ត្រីនោះបានស្លាប់ក្នុងពេលមានគ៌ភ ឬពេលសម្រាលកូន ឬ ៤២ ថ្ងៃក្រោយពេលសម្រាលកូន។ ជួនកាលសំណួរ អាចរាប់បញ្ចូលតើស្ត្រីនោះស្លាប់នៅកន្លែងណា (មន្ទីរពេទ្យ មណ្ឌលសុខភាព នៅផ្ទះ) ហើយមាននរណាម្នាក់ជួយនាងពេលមុនពេលស្លាប់ដែរឬទេ (វេជ្ជបណ្ឌិត គ្រូពេទ្យ ឆ្មបឯកទេស ឆ្មបបុរាណ) ។

ជាទូទៅ ករណីមរណមនុស្សពេញវ័យ ត្រូវបានស្រង់រាប់មិនអស់ទៅតាមការរំពឹងទុកឡើយ។ មានវិធីសាស្ត្រជាច្រើនត្រូវបានកែតម្រូវលើទិន្នន័យដើម្បីទទួលបានភាពប្រសើរ។ ករណីនេះការគណនាមានការលំបាក និងកម្រិតជឿជាក់ទាប ។

ការលើកឡើងខាងលើនូវបណ្តាសំណួរ រាប់បញ្ចូលក្នុងចំណោមចំនួនសមាជិកគ្រួសារដែលបានស្លាប់ក្នុងរយៈពេល ១២ កន្លងមក។ ដូចដែលបានពន្យល់ខាងដើមព័ត៌មាននេះត្រូវបានស្រង់សម្ភាសន៍ មិនអស់នូវចំនួនអ្នកស្លាប់ដោយរាប់បញ្ចូលទាំងអ្នកស្លាប់ដែលចាត់ទុជាមរណភាពមាតាផងដែរ ។

យោងតាមជំរឿនឆ្នាំ២០១៩ ទិន្នន័យគណនាដោយផ្ទាល់ (មិនមានការកែតម្រូវ) ត្រូវបានគណនាឃើញផលធៀប ឬអត្រាមរណភាពមាតា មាន ១៤០,៨ ក្នុងចំណោម ១០០.០០០ កំណើតរស់ ។ សូចនាករនេះហាក់បង្ហាញពីការរាប់សម្ភាសន៍មិនអស់នូវចំនួនមរណភាពមាតា។ ទោះជាយ៉ាងណាក៏ដោយការកែតម្រូវត្រូវបានធ្វើឡើងដើម្បីវាយតម្លៃគុណភាពនៃការធ្វើចំណាត់ថ្នាក់ការស្លាប់របស់មាតាក្នុងករណីអវត្តមាននៃវិធីសាស្ត្រផ្លូវការ។ ក្នុងករណីនេះជាទូទៅមិនផ្តល់អនុសាសន៍សម្រាប់ធ្វើការកែតម្រូវមរណភាពតាមក្រុមអាយុឡើយ ។ មានការស៊ីសង្វាក់នៅក្នុងការវាយតម្លៃមរណភាពមាតា តម្រូវឲ្យមានការវិភាគជាពិសេសជាងការរកឃើញបឋមនេះ។ ករណីមរណភាពមាតានឹងត្រូវបានវិភាគស៊ីជម្រៅ ក្នុងរបាយការណ៍វិភាគស៊ីជម្រៅដែលគ្រោងធ្វើ។ ទោះបីយ៉ាងណា មិនមានការកែតម្រូវ ឬកែសម្រួលទៅលើការគណនាអត្រាមរណភាពមាតាឡើយ ហើយអត្រានេះមានទាបជាងក្នុងឆ្នាំ២០០៨ ដែលបានរកឃើញកាលនោះមាន ៤៦០,៨ ក្នុង ១០០.០០០កំណើតរស់ ។

## រូបភាព ៨.៤.១. អត្រាមរណភាពមាតា កម្ពុជាឆ្នាំ ២០០៨ ២០១៤ និង ២០១៩



# ជំពូក ៩
# ពិការភាព

## ៩.១. ទស្សនទាន

ជាលើកទីមួយហើយដែលសំណួរអំពីពិការក្នុងសកម្មភាពរស់នៅប្រចាំថ្ងៃ សម្រាប់មនុស្ស អាយុ ៥ ឆ្នាំឡើង ត្រូវបានបញ្ចូលទៅក្នុងតារាងសំណួរជំរឿនប្រជាជនទូទៅ ឆ្នាំ២០១៩។ មានមូលហេតុបីប្រភេទសំខាន់សម្រាប់ធ្វើការវាស់វែងពិការនៅក្នុងជំរឿននេះគឺ៖

(ក) ដើម្បីផ្តល់សេវាកម្មនានា រាប់បញ្ចូលទាំងការអភិវឌ្ឍន៍នៃកម្មវិធីអោយបានច្បាស់លាស់ គោលនយោបាយសម្រាប់ការផ្តល់សេវាកម្មជាក់លាក់ និងការវាយតម្លៃនៃកម្មវិធី ឬសេវាកម្មទាំងនោះ។ ការផ្តល់សេវាកម្មនានារាប់បញ្ចូលតម្រូវការសម្រាប់លំនៅដ្ឋាន ការដឹកជញ្ជូន ឧបករណ៍ និតិសម្បទាវិជ្ជាជីវៈ ការអប់រំ ក្នុងរយៈពេលវែង។

(ខ) ដើម្បីតាមដានកិច្ចដំណើរការ ការថែទាំបឋម ដែលជាសូចនាករបង្ហាញអំពីស្ថានភាពទូទៅរបស់សង្គម។ ដើម្បីពិនិត្យមើលពីវឌ្ឍនភាព រាប់បញ្ចូលទាំងការប៉ាន់ស្មានអត្រាពិការភាព និងវិភាគពីនិន្នាការផ្លាស់ប្តូរ។

(គ) ដើម្បីពិនិត្យវាយតម្លៃលើវិសមភាពដែលទទួលរងដោយជនពិការ និងដើម្បីវាយតម្លៃផលប៉ះពាល់ នៃច្បាប់ និងគោលនយោបាយស្តីពីការលើសអើងជនពិការ។ ទិន្នន័យពិការភាព អាចជួយដល់ការវាយតម្លៃ សេវាកម្ម និងកម្មវិធីនានា ដើម្បីសម្រេចបានឱកាសស្មើគ្នាក្នុងគ្រប់វិស័យ ជាពិសេសគឺអ្នកដែលជួបប្រទះការលំបាកក្នុងការរស់នៅប្រចាំថ្ងៃ។

ទិន្នន័យអំពីពិការភាពទាំងប្រាំមួយប្រភេទ ដែលបានប្រមូលក្នុងជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៩ មានដូចខាងក្រោម៖

(១) ពិការភាពក្នុងការមើល (ភ្នែក)៖ មនុស្សម្នាក់ដែលមានពិការភាពក្នុងការមើលក្នុងកម្រិតណាមួយ បើទោះបីជាប្រើវ៉ែនតាក៏ដោយ ហើយនៅតែមិនអាចមើលអ្វីឃើញ ឬភ្នែកងងឹត ឬ មិនអាចមើលឃើញអ្វីទាំងអស់ (សូម្បីតែពន្លឺ) ត្រូវបានចាត់ទុកថា អសមត្ថភាពក្នុងការមើល ឬពិការភ្នែក។ មនុស្សម្នាក់ដែលមើលច្បាស់តែភ្នែកម្ខាង ឬ មើលឃើញតែចំពោះមុខក៏ត្រូវបានចាត់ទុកថាពិការភាពក្នុងការមើលផងដែរ។ មនុស្សម្នាក់មានបញ្ហានៅក្នុងការមើលជិតឬឆ្ងាយ ប៉ុន្តែអាចមើលបានច្បាស់ដោយពាក់វ៉ែនតា គឺមិនត្រូវបានចាត់ទុកថាពិការភាពក្នុងការមើលនោះទេ។

(២) ពិការភាពក្នុងការស្តាប់ឮ (ថ្លង់)៖ មនុស្សម្នាក់ដែលមានកម្រិតណាមួយក្នុងការស្តាប់ឮ ទោះបីជាប្រើឧបករណ៍ជំនួយការស្តាប់ក៏ដោយ ត្រូវបានចាត់ទុកថា អសមត្ថភាពក្នុងការស្តាប់ឮ ឬពិការភាពក្នុងការស្តាប់ឮ។ ពិការភាពប្រភេទនេះ រួមទាំងមនុស្សម្នាក់ដែលស្តាប់អ្វីមិនឮទាំងអស់ ឬអាចឮតែសម្លេងខ្លាំងតែប៉ុណ្ណោះ ឬអាចស្តាប់ឮនៅពេលដែលពួកគេស្ថិតនៅក្នុងបរិយាកាសដែលមានសំឡេងអឺងកងមួយ ឬពួកគេមានបញ្ហាក្នុងការសម្គាល់សំឡេងចេញពីប្រភពផ្សេងៗ។ លើសពីនេះទៀត មនុស្សម្នាក់ដែលស្តាប់ឮតាមរយៈ ត្រចៀកម្ខាង ប៉ុន្តែត្រចៀកម្ខាងទៀតរបស់គាត់

ស្តាប់មិនឮ ក៏ត្រូវចាត់ទុកថាពិការភាពក្នុងការស្តាប់ឮផងដែរ។ មនុស្សម្នាក់ដែលអាចស្តាប់ឮដោយឧបករណ៍ជំនួយការស្តាប់ មិនត្រូវបានចាត់ទុកថា អសមត្ថភាពក្នុងការស្តាប់ឮនោះទេ។

(៣) ពិការភាពក្នុងការដើរ ឬឡើងជណ្តើរ : មនុស្សម្នាក់មានការលំបាក ទោះក្នុងកម្រិតណាមួយនៅពេលធ្វើចលនាក្នុងបរិស្ថានជុំវិញខ្លួនដោយប្រើជើងត្រូវបានចាត់ទុកថា ពិការភាព។ ពិការភាពប្រភេទនេះរួមទាំង មនុស្សម្នាក់ដែលមានបញ្ហាខ្លះក្នុងការដើរជិតឬឆ្ងាយ ឬឡើង ឬចុះជណ្តើរ មនុស្សម្នាក់ដែលមិនអាចដើរចំងាយណាមួយ ដោយគ្មានឈប់សម្រាក ហើយពួកគេមិនអាចដើរបានដោយគ្មានឧបករណ៍ជំនួយក្នុងការដើរដូចជា ដំបងឈើច្រត់ ឈើឆ្កាប។ លើសពីនេះ មនុស្សម្នាក់ដែលមិនអាចឈរបានយូរជាងមួយឬពីរនាទី ឬត្រូវការកៅអីកង់ដើម្បីផ្លាស់ទីពីកន្លែងមួយទៅកន្លែង ក៏ត្រូវបានគេចាត់ទុកថាស្ថិតនៅក្នុង ពិការភាពប្រភេទនេះផងដែរ។

(៤) ពិការភាពក្នុងការចងចាំ ឬការផ្តោតអារម្មណ៍ : មនុស្សម្នាក់ត្រូវបានរកឃើញថា មានបញ្ហាខ្លះក្នុងការចងចាំ ឬផ្តោតអារម្មណ៍ លើសកម្មភាពប្រចាំថ្ងៃ ត្រូវបានចាត់ទុកថា ពិការភាពក្នុងការចងចាំ ឬការផ្តោតអារម្មណ៍។ ពិការភាពប្រភេទនេះរួមទាំង មនុស្សម្នាក់ដែលមានបញ្ហាក្នុងការស្វែងរកផ្លូវ ផ្តោតអារម្មណ៍លើអ្វីដែលពួកគេកំពុងធ្វើ ឬចងចាំកន្លែងដែលខ្លួនរស់នៅប៉ុន្មានខែកន្លងទៅ។ លើសពីនេះទៀត មនុស្សម្នាក់មិនអាចនឹកឃើញនូវអ្វីដែលអ្នកណាម្នាក់ទើបនិយាយមកកាន់ខ្លួន ឬហាក់ច្រឡំ ឬមានអារម្មណ៍ភ័យខ្លាច ក៏ត្រូវបានទុកថាពិការភាពក្នុងការចងចាំ ឬផ្តោតអារម្មណ៍ផងដែរ។ ទាំងនេះអាចបណ្តាលមកពី ស្ថានភាពប្រចាំថ្ងៃ រួមមានបន្ទុកការងារខ្ពស់ ឬជាលទ្ធផលការប្រើប្រាស់សារជាតុញៀនណាមួយ ឬមូលហេតុចម្បងណាផ្សេងទៀត ដែលបង្ករអោយមានពិការភាពក្នុងប្រភេទនេះ។

| **ចំនួនគ្រួសារ** | **២.១៦២.០៨៦** | **២.៨១៧.៦៣៧** | **៣.៥៥៣.០២១** | **៣៦៤.៥៨១** | **៥០៦.៥៧៩** | **១.៣២៨.៥០១** | **១.៧៩៧.៥០៥** | **២.៣១១.០៥៨** | **២.២២៤.៥២០** |
| **សរុប** | **១០០** | **១០០** | **១០០** | **១០០** | **១០០** | **១០០** | **១០០** | **១០០** | **១០០** |
| ទឹកម៉ាស៊ីនបណ្ដាញ | ៥,៨ | ១៣,៨ | ២៥,៥ | ២៦,៨ | ៥៦,៨ | ៤៦,៧ | ១,៥ | ៤,៤ | ១២,៨ |
| ទឹកបំពងបណ្ដាញក្នុងទីធ្លា/បរិវេណផ្ទះ | - | - | ៣,៦ | - | - | ៤,៩ | - | - | ២,៩ |
| ទឹកបំពង់សាធារណៈ | - | - | ៣,៩ | - | - | ៥,៧ | - | - | ២,៨ |
| ទឹកអណ្ដូងស្នប់ | ១៥,០ | ២៦,៨ | ២៥,២ | ១២,៥ | ១៤,៧ | ១២,៩ | ១៥,៥ | ២៩,៥ | ៣២,៦ |
| អណ្ដូងជីកមានគម្រប | - | ៥,២ | ៤,៥ | - | ៣,៨ | ២,២ | - | ៥,៥ | ៥,៩ |
| អណ្ដូងជីកគ្មានគម្រប | ៤០,៣ | ២០,៧ | ៥,៩ | ១៦,៧ | ៤,៥ | ១,៤ | ៤៥,១ | ២៤,២ | ៨,៦ |
| ទឹកចេញក្រោមដីមានការការពារ | - | - | ០,៣ | - | - | ០,២ | - | - | ០,៤ |
| ទឹកចេញក្រោមដីគ្មានការការពារ | - | - | ០,៣ | - | - | ០,១ | - | - | ០,៥ |
| ទឹកភ្លៀង | - | ១,០ | ២,៨ | - | ០,៥ | ១,៥ | - | ១,១ | ៣,៥ |
| ទឹកចេញក្រោមដី ទន្លេ អូរ បឹង ត្រពាំង។ល។ | ២៨,២ | ២៣,១ | ១០,៦ | ១៣,៣ | ៦,២ | ៥,៤ | ៣១,២ | ២៦,៨ | ១៣,៧ |
| ទឹកទិញ | ៨,៣ | ៨,២ | - | ២៩,២ | ១៣,០ | - | ៤,១ | ៧,១ | - |
| ទិញទឹកឡានស៊ីទែន | - | - | ៤,៩ | - | - | ៤,៨ | - | - | ៥,០ |
| ទិញទឹកធុងរទេះ | - | - | ៤,៨ | - | - | ៤,០ | - | - | ៥,៣ |
| ទឹកដប/ទឹកពិសារដប | - | - | ៧,១ | - | - | ៩,៨ | - | - | ៥,៤ |
| ប្រភពទឹកផ្សេងទៀត | ២,៥ | ១,៣ | ០,៦ | ១,៥ | ០,៥ | ០,៦ | ២,៧ | ១,៤ | ០,៧ |

**សម្គាល់ ៖** ១. *នៅឆ្នាំ ២០០៨ ព័ត៌មានប្រមូលតែទឹកម៉ាស៊ីនបណ្ដាញ ហើយមិនបានបំបែកសម្រាប់អណ្ដូង "ទឹកបំពងបណ្ដាញក្នុងក្នុងទីធ្លា/បរិវេណផ្ទះ" និង "ទឹកបំពង់សាធារណៈ" ឡើយ។

២. *នៅឆ្នាំ ២០០៨ មិនបានព័ត៌មានទាក់ទងនឹង "ទឹកចេញក្រោមដីមានការការពារ " និង "ចេញក្រោមដីគ្មានការការពារ" ឡើយ។

៣. *នៅឆ្នាំ ២០០៨ ព័ត៌មានប្រមូលតែទឹកទិញ ហើយមិនបានបំបែកសម្រាប់ "ទិញទឹកឡានស៊ីទែន" "ទិញទឹកធុងរទេះ" និង "ទឹកដប/ទឹកពិសាដប" ឡើយ។

៤. *នៅឆ្នាំ ១៩៩៨ ព័ត៌មានប្រមូលតែអណ្ដូងជីក ហើយមិនបានបំបែកសម្រាប់អណ្ដូង "មានគម្រប" និង "គ្មានគម្រប" ឡើយ។

៥. *នៅឆ្នាំ ១៩៩៨ "ទឹកចេញក្រោមដី ទន្លេ អូរ បឹង ត្រពាំង និងទឹកភ្លៀង" មានតែមួយប្រភេទ។

## ១០.៣.២. ប្រភពបំភ្លឺសំខាន់ៗ

តាមលទ្ធផលការធ្វើជំរឿនឆ្នាំ២០១៩ គ្រួសារនៅកម្ពុជាភាគច្រើនបានប្រើប្រាស់អគ្គិសនីបណ្តាញសម្រាប់បំភ្លឺ។ តារាង ១០.៣.២ បានបង្ហាញថាប្រមាណ ៨៤,០ ភាគរយនៃគ្រួសារនៅកម្ពុជាប្រើប្រាស់អគ្គិសនី (រួមមាន អគ្គិសនីបណ្តាញ ម៉ាស៊ីនភ្លើង និងទាំងពីរប្រភព) នៅឆ្នាំ២០១៩ បានកើនឡើងខ្លាំង ប្រៀបធៀបនឹងឆ្នាំ២០០៨ និង១៩៩៨ មាន ២៦,៤ និង ១៥,១ ភាគរយ តាមលំដាប់រៀង។ ដោយឡែក ប្រមាណ ៩៧ ភាគរយនៃគ្រួសារនៅតំបន់ទីប្រជុំជនប្រើប្រាស់អគ្គិសនីសម្រាប់បំភ្លឺ ចំណែកគ្រួសារនៅជនបទមាន ៧៦ ភាគរយ។ តាមតួលេខខាងលើបញ្ជាក់ថា រយៈពេលជាងមួយទសវត្សរ៍នេះ ភាគច្រើនលើសលប់នៃគ្រួសារកម្ពុជាបានប្រើប្រាស់អគ្គិសនីជាប្រភពបំភ្លឺ ។

### រូប ១០.៣.២. ភាគរយនៃគ្រួសារ តាមប្រភពបំភ្លឺចម្បង និងតំបន់ កម្ពុជា ឆ្នាំ២០១៩




### តារាង ១០.៣.២. ភាគរយនៃគ្រួសារ តាមប្រភពបំភ្លឺចម្បងប្រើប្រាស់ កម្ពុជា ឆ្នាំ១៩៩៨ ២០០៨ និង ២០១៩

| តំបន់ | ឆ្នាំ | ចំនួនគ្រួសារ | សរុប | អគ្គិសនី បណ្តាញ | ម៉ាស៊ីន ភ្លើង | អគ្គិសនីបណ្តាញ និងម៉ាស៊ីនភ្លើង | ប្រេងកាត | ទៀន | អាគុយ ថ្មពិល | ផ្សេងទៀត |
|---|---|---|---|---|---|---|---|---|---|---|
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨) | (៩) | (១០) | (១១) |
| សរុប | ២០១៩ | ៣.៥៥៣.០២១ | ១០០ | ៧៩,៦ | ១,៦ | ២,៨ | ០,៦ | ០,៣ | ១៣,៤ | ១,៦ |
| | ២០០៨ | ២.៨១៧.៦៣៧ | ១០០ | ២២,៥ | ១,៧ | ២,២ | ៣៨,៦ | ០,៤ | ៣៤,១ | ០,៥ |
| | ១៩៩៨ | ២.១៦២.០៨៦ | ១០០ | ១២,៦ | ១,០ | ១,៦ | ៧៩,៩ | - | ៣,៦ | ១,៥ |
| ទីប្រជុំជន | ២០១៩ | ១.៣២៨.៥០១ | ១០០ | ៩២,៣ | ២,០ | ២,៦ | ០,៤ | ០,២ | ២,៤ | ០,២ |
| | ២០០៨ | ៥០៦.៥៧៩ | ១០០ | ៨២,៥ | ១,៩ | ២,៧ | ៧,៤ | ០,៤ | ៥,០ | ០,២ |
| | ១៩៩៨ | ៣៦៤.៥៨១ | ១០០ | ៥៦,៩ | ២,១ | ៣,៩ | ៣៣,៥ | - | ៣,០ | ០,៧ |
| ជនបទ | ២០១៩ | ២.២២៤.៥២០ | ១០០ | ៧២,១ | ១,៣ | ៣,០ | ០,៨ | ០,៤ | ២០,១ | ២,៤ |
| | ២០០៨ | ២.៣១១.០៥៨ | ១០០ | ៩,៣ | ១,៧ | ២,១ | ៤៥,៥ | ០,៤ | ៤០,៤ | ០,៦ |
| | ១៩៩៨ | ១.៧៩៧.៥០៥ | ១០០ | ៣.៦ | ០,៨ | ១,១ | ៨៩,៣ | - | ៣,៧ | ១,៦ |

**សម្គាល់ ៖** នៅឆ្នាំ១៩៩៨ "ទៀន" មិនត្រូវបានបង្ហាញដោយឡែកជាប្រភពបំភ្លឺឡើយ។ វាត្រូវបានបញ្ចូលក្នុង "ប្រភពដ៏ទៃទៀត" ។

## ១០.៣.៣. បង្គន់អនាម័យ

តាមលទ្ធផលជំរឿនឆ្នាំ២០១៩ ការប្រើប្រាស់បង្គន់អនាម័យនៅកម្ពុជាមានការរីកចម្រើនខ្លាំងក្នុងរយៈពេលមួយទសវត្សរ៍។ តារាង ១០.៣.៣ បានបង្ហាញថានៅឆ្នាំ២០១៩ មាន ៨២,៨ ភាគរយនៃគ្រួសារកម្ពុជាមានបង្គន់អនាម័យប្រើប្រាស់ ប្រៀបធៀបនឹងឆ្នាំ២០០៨ និង១៩៩៨ បានកើនឡើងយ៉ាងខ្លាំង ៣៣,៧ ភាគរយ និង ១៤,៥ ភាគរយ តាមលំដាប់រៀង។ គ្រួសារកម្ពុជាឆ្នាំ២០១៩ មានបង្គន់អនាម័យប្រើប្រាស់ ៩ គ្រួសារ ក្នុងចំណោម ១០ គ្រួសារ នៅតំបន់ទីប្រជុំជន និង៨ គ្រួសារនៅជនបទ។ ក្នុងនោះប្រមាណ ៤៩,៦ ភាគរយនៃគ្រួសារមានបង្គន់អនាម័យនៅតំបន់ទីប្រជុំជន ប្រើប្រាស់បង្គន់ចាក់ទឹក ឬ(ចុចបង្ហូរទឹក) តភ្ជាប់ទៅប្រព័ន្ធលូ ចំណែកឯនៅជនបទមានត្រឹមតែ ២៤,៨ ភាគរយ ប្រមាណ ៣៨,៤ ភាគរយនៃគ្រួសារនៅទីប្រជុំជនបានប្រើប្រាស់បង្គន់ចាក់ទឹក ឬ(ចុចបង្ហូរទឹក) តភ្ជាប់អាងស្តុក ឬរណ្តៅ និងនៅ ជនបទមាន ៥០,៦ ភាគរយ។

ក្នុងឆ្នាំ២០១៩ គ្រួសារកម្ពុជា មានប្រើប្រាស់ទាំងបីប្រភេទនេះ គឺប្រភពទឹកស្អាត និងអគ្គិសនីបណ្តាញ និងបង្គន់អនាម័យនៅក្នុងផ្ទះ មានប្រមាណ ៥៦,៧ ភាគរយ។ នេះបង្ហាញពីភាពប្រសើរឡើងជាងជំរឿនមុនៗ។ នៅឆ្នាំ២០០៨ មានត្រឹមតែ ១៧,៤ ភាគរយ ដែលមានប្រើប្រាស់ទាំងបីប្រភេទនេះ និង ៨,០ ភាគរយ នៅឆ្នាំ១៩៩៨។ នៅឆ្នាំ២០១៩ ប្រមាណ ៧៥,៥ ភាគរយនៃគ្រួសារនៅទីប្រជុំជនបានប្រើប្រាស់ទាំងបីប្រភេទនេះ ចំណែកឯនៅជនបទមានត្រឹមតែ ៤៥,៤ ភាគរយ (តារាង ១០.៣.៤)។

រូប ១០.៣.៣. ការបែងចែកភាគរយនៃគ្រួសារ ដែលមាន ឬមិនមានបង្គន់ប្រើប្រាស់ កម្ពុជា ឆ្នាំ២០១៩



## រូប ១០.៣.៤. ភាគរយនៃគ្រួសារមានបង្គន់ប្រើប្រាស់ តាមប្រភេទ និងតំបន់ កម្ពុជា ឆ្នាំ២០១៩



## តារាង ១០.៣.៣. ការបែងចែកភាគរយនៃគ្រួសារ តាមការប្រើប្រាស់បង្គន់ និងប្រភេទបង្គន់ កម្ពុជា ឆ្នាំ១៩៩៨ ២០០៨ និង២០១៩

| តំបន់ | ឆ្នាំ | ចំនួនគ្រួសារ | សរុប | គ្រួសារ | | គ្រួសារដែលមានបង្គន់ | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | គ្រួសារគ្មានបង្គន់ប្រើប្រាស់ | គ្រួសារមានបង្គន់ប្រើប្រាស់ | បង្គន់ចាក់ទឹក ឬចុចបង្ហូរទឹកតភ្ជាប់ប្រព័ន្ធលូ | បង្គន់ចាក់ទឹក ឬចុចបង្ហូរទឹក តភ្ជាប់អាងស្តុក ឬរណ្តៅ | បង្គន់ចាក់ទឹក ឬចុចបង្ហូរទឹក ទៅកន្លែងផ្សេង (បង្ហូរទឹក តភ្ជាប់អាងស្តុក ឬរណ្តៅ) | រណ្តៅ | បង្គន់រណ្តៅមានចានបង្គន់សម្រាប់បត់ជើង | បង្គន់រណ្តៅគ្មានផែនបង្គន់សម្រាប់បត់ជើង | បង្គន់បទជើងទន្លាក់ ឬក្នុងទឹក (ត្រពាំង/ បឹង/ទន្លេ/សមុទ្រ) | បង្គន់ផ្សេងទៀត |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨) | (៩) | (១០) | (១១) | (១២) | (១៣) | (១៤) |
| សរុប | **២០១៩** | **១.៣២៨.៥០១** | **១០០** | **១៧,២** | **៨២,៨** | **៣៤,៩** | **៤៥,៦** | **១០,៤** | **-** | **៥,២** | **២,០** | **១,០** | **១,០** |
| | ២០០៨ | ២.៨១៧.៦៣៧ | ១០០ | ៦៦,៣ | ៣៣,៧ | ៤០,១ | ៤២,៨ | - | ១៤,៦ | - | - | - | ២,៦ |
| | ១៩៩៨ | ២.១៦២.០៨៦ | ១០០ | ៨៥,៥ | ១៤,៥ | - | - | - | - | - | - | - | - |
| ទីប្រជុំជន | ២០១៩ | ១.៣២៨.៥០១ | ១០០ | ៩,៦ | ៩០,៤ | ៤៩,៦ | ៣៨,៤ | ៧,៩ | - | ២,៧ | ០,៦ | ០,៥ | ០,៤ |
| | ២០០៨ | ៥០៦.៥៧៩ | ១០០ | ១៨,៥ | ៨១,៥ | ៥៦,១ | ៤០,០ | - | ៣,១ | - | - | - | ០,៨ |
| | ១៩៩៨ | ៣៦៤.៥៨១ | ១០០ | ៤៣,៩ | ៥៦,១ | - | - | - | - | - | - | - | - |
| ជនបទ | ២០១៩ | ២.២២៤.៥២០ | ១០០ | ២១,៧ | ៧៨,៣ | ២៤,៨ | ៥០,៦ | ១២,១ | - | ៦,៩ | ២,៩ | ១,៣ | ១,៤ |
| | ២០០៨ | ២.៣១១.០៥៨ | ១០០ | ៧៦,៨ | ២៣,២ | ២៧,៧ | ៤៤,៩ | - | ២៣,៤ | - | - | - | ៤,០ |
| | ១៩៩៨ | ១.៧៩៧.៥០៥ | ១០០ | ៩៤,០ | ៦,០ | - | - | - | - | - | - | - | - |

**សម្គាល់ ៖** ១.*នៅឆ្នាំ ២០០៨ មិនមានព័ត៌មាន "បង្គន់ចាក់ទឹក ឬ(មិនបង្ហូរទៅអាងស្តុក ឬរណ្តៅ) បង្ហូរទៅកន្លែងផ្សេង (ចុចបង្ហូរទឹក)" និង "បង្គន់បទជើងទន្លាក់ ឬក្នុងទឹក (ត្រពាំង/បឹង/ទន្លេ/សមុទ្រ)" ឡើយ។
២.*នៅឆ្នាំ ២០០៨ ព័ត៌មានប្រមូលតែបង្គន់ប្រភេទរណ្តៅ ហើយមិនបានបំបែកសម្រាប់ "បង្គន់រណ្តៅមានចានបង្គន់សម្រាប់បត់ជើង" និង "បង្គន់រណ្តៅគ្មានផែនបង្គន់សម្រាប់បត់ជើង" ឡើយ។
៣.*នៅឆ្នាំ ១៩៩៨ ព័ត៌មានអំពីប្រភេទបង្គន់មិនមានឡើយ។

### តារាង ១០.៣.៤. ភាគរយនៃគ្រួសារដែលមានប្រភពទឹកស្អាត អគ្គិសនី និងបង្គន់ក្នុងបរិវេណផ្ទះ កម្ពុជា ឆ្នាំ១៩៩៨ ២០០៨ និង២០១៩

| តំបន់ | ភាគរយនៃគ្រួសារ | | |
|---|---|---|---|
| | ១៩៩៨ | ២០០៨ | ២០១៩ |
| (១) | (២) | (៣) | (៤) |
| **សរុប** | **៨.០** | **១៧,៤** | **៥៦,៧** |
| ទីប្រជុំជន | ៤២,៩ | ៧២,៥ | ៧៥.៥ |
| ជនបទ | ០,៩ | ៥,៣ | ៤៥,៤ |

## ១០.៣.៤. ឥន្ធនៈសម្រាប់ចម្អិន

តាមរយៈការធ្វើជំរឿនឆ្នាំ១៩៩៨ ២០០៨ និង២០១៩ បានបង្ហាញថានិន្នាការនៃគ្រួសារកម្ពុជាប្រើប្រាស់ឧសសម្រាប់ចម្អិនអាហារមានការថយចុះ ចំណែកឯគ្រួសារដែលប្រើប្រាស់ឧស្ម័នហ្គាសបានកើនឡើងជាលំដាប់។ ទោះបីជាយ៉ាងណាក៏ដោយ ឧសនៅតែជាឥន្ធនៈចម្បងសម្រាប់ចម្អិនអាហារនៅតំបន់ជនបទ។ តារាង ១០.៣.៥ បានបង្ហាញថាប្រមាណ ៦០,៩ ភាគរយនៃគ្រួសារកម្ពុជាបានប្រើប្រាស់ឧសសម្រាប់ចម្អិនអាហារ នៅតំបន់ទីប្រជុំជនមានតែ ៣១,០ ប៉ុណ្ណោះ ប៉ុន្តែបើនៅតំបន់ជនបទ ៧៨,៨ ភាគរយ ច្រើនជាងជិតបីដង បើប្រៀបធៀបនឹងតំបន់ទីប្រជុំជន។ ប្រមាណ ២៧,៧ នៃប្រជាជនកម្ពុជាប្រើប្រាស់ឧស្ម័នហ្គាសសម្រាប់ចម្អិនអាហារ ចំណែកឯនៅតំបន់ទីប្រជុំជនវិញមាន ៥៦,២ ភាគរយ និងតំបន់ជនបទមានតែ ១០,៧ ភាគរយ ប៉ុណ្ណោះ។

### តារាង ១០.៣.៥. គ្រួសារតាមប្រភេទឥន្ធនៈប្រើប្រាស់ចម្អិនអាហារតាមលំនៅដ្ឋាន កម្ពុជា ឆ្នាំ១៩៩៨ ២០០៨ និង២០១៩

| តំបន់ | ឆ្នាំ | ចំនួនគ្រួសារ | គ្រួសារប្រើប្រាស់ | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | សរុប | ឧស | ធ្យូងឈើ ធ្យូងថ្ម | ប្រេងកាត | ឧស្ម័ន ហ្គាស | អគ្គិសនី | គ្មាន | ផ្សេងទៀត |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨) | (៩) | (១០) | (១១) |
| សរុប | **២០១៩** | **៣.៥៥៣.០២១** | **១០០** | **៦០,៩** | **៧,៨** | **០,៣** | **២៧,៧** | **៣,០** | **០,១** | **០,១** |
| | ២០០៨ | ២.៨១៧.៦៣៧ | ១០០ | ៨៣,៦ | ៧,៥ | ០,៤ | ៧,៩ | ០,៤ | ០,២ | ០,១ |
| | ១៩៩៨ | ២.១៦២.០៨៦ | ១០០ | ៩០,០ | ៥,៣ | ១,៨ | ១,៧ | - | - | ១,១ |
| ទីប្រជុំជន | **២០១៩** | **១.៣២៨.៥០១** | **១០០** | **៣១,០** | **៧,៩** | **០,៤** | **៥៦,២** | **៤,២** | **០,២** | **០,២** |
| | ២០០៨ | ៥០៦.៥៧៩ | ១០០ | ៣៤,៧ | ២៥,៦ | ០,៤ | ៣៧,៣ | ១,៥ | ០,៤ | ០,១ |
| | ១៩៩៨ | ៣៦៤.៥៨១ | ១០០ | ៦២,៩ | ២៤,៦ | ២,៨ | ៨,៨ | - | - | ០,៩ |
| ជនបទ | **២០១៩** | **២.២២៤.៥២០** | **១០០** | **៧៨,៨** | **៧,៧** | **០,៣** | **១០,៧** | **២,៣** | **០,១** | **០,១** |
| | ២០០៨ | ២.៣១១.០៥៨ | ១០០ | ៩៤,៣ | ៣,៥ | ០,៣ | ១,៥ | ០,១ | ០,២ | ០,១ |
| | ១៩៩៨ | ១.៧៩៧.៥០៥ | ១០០ | ៩៥,៦ | ១,៣ | ១,៦ | ០,៣ | - | - | ១,២ |

**សម្គាល់ ៖** នៅឆ្នាំ១៩៩៨ ព័ត៌មានអំពី "អគ្គិសនី" និង "គ្មាន" សម្រាប់ប្រភេទឥន្ធនៈមិនមានឡើយ។ ប្រភេទទាំងនេះត្រូវបានរាប់បញ្ចូលក្នុង "ផ្សេងទៀត"។

រូប ១០.៣.៥. ភាគរយនៃគ្រួសារ តាមប្រភេទថាមពលប្រើប្រាស់ចម្អិនអាហារ តាមលំនៅដ្ឋាន កម្ពុជា ឆ្នាំ២០១៩




## ១០.៣.៥. ការប្រើប្រាស់អ៊ីនធឺណិត

ជំរឿនឆ្នាំ២០១៩ គ្រួសារនៅក្នុងប្រទេសកម្ពុជាមានការកើនឡើងក្នុងការប្រើប្រាស់អ៊ីនធឺណិតដោយសារតែពិភពលោកមានភាពរីកចម្រើនខ្លាំងនូវវិស័យបច្ចេកវិទ្យា ជាពិសេសទូរស័ព្ទចល័តដែលអាចប្រើប្រាស់ជាមួយនឹងប្រព័ន្ធអ៊ីនធឺណិតបាន ម្យ៉ាងវិញទៀត ប្រជាជនកម្ពុជាទាំងពីរភេទ ភាគច្រើនបានប្រើប្រាស់អ៊ីនធឺណិត។ រូប ១០.៣.៦ បានបង្ហាញឲ្យឃើញថា ៤៥,៤ ភាគរយនៃគ្រួសារនៅកម្ពុជាប្រើប្រាស់អ៊ីនធឺណិតនៅផ្ទះ និង ២៨,២ ភាគរយ ប្រើប្រាស់អ៊ីនធឺណិតនៅទីសាធារណៈ។ ភាគរយនៃគ្រួសារនៅតំបន់ទីប្រជុំជនប្រើប្រាស់អ៊ីនធឺណិតនៅផ្ទះ ឬនៅទីសាធារណៈខ្ពស់ជាង បើប្រៀបធៀប ទៅនឹងភាគរយនៃគ្រួសារនៅតំបន់ជនបទ។

## រូប ១០.៣.៦. ការបែងចែកភាគរយនៃគ្រួសារតាមការប្រើប្រាស់អ៊ីនធឺណិត តំបន់ កម្ពុជា ឆ្នាំ២០១៩




## ១០.៣.៦. សម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួន

ព័ត៌មានអំពីប្រភេទ និងចំនួនសម្ភារៈប្រើប្រាស់ក្នុងគ្រួសារត្រូវបានប្រមូលក្នុងជំរឿននៅឆ្នាំ ២០០៨ និងឆ្នាំ ២០១៩ ព័ត៌មាននេះបានផ្តល់នូវសូចនាករនៃលក្ខខ័ណ្ឌសេដ្ឋកិច្ចរបស់ប្រជាជនកម្ពុជា។ លទ្ធផលជំរឿន ឆ្នាំ២០១៩ បានបង្ហាញថា ភាគរយនៃគ្រួសារទូទាំងប្រទេសដែលមានទូរទស្សន៍ផ្ទាល់ខ្លួនសម្រាប់ប្រើប្រាស់ មាន ៦៧,៥ ភាគរយ នៅទីប្រជុំជន មាន ៧៧,៤ ភាគរយ និងនៅជនបទមាន ៦១,៧ ភាគរយ (តារាង ១០.៣.៦)។ ទន្ទឹមនឹងនេះ ប្រមាណ ៩១,៩ ភាគរយនៃគ្រួសារមានទូរសព្ទ័ដៃនៅទូទាំងប្រទេស ខណៈដែលគ្រួសារនៅទីប្រជុំជនមាន ៩៤,៨ ភាគរយ និងគ្រួសារនៅជនបទមាន ៩០,២ ភាគរយ។ នៅទីប្រជុំជន គ្រួសារដែលមានម៉ូតូប្រើប្រាស់ផ្ទាល់ខ្លួនប្រមាណ ៨៥,១ ភាគរយ និងប្រមាណ ៧៧,១ ភាគរយនៅជនបទ។ ចំណែកឯគ្រួសារដែលមានរថយន្ត(រថយន្តដឹកទំនិញធុនតូចឬធំ ឬរថយន្តសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន) មានតែ ១០,១ ភាគរយប៉ុណ្ណោះនៅថ្នាក់ជាតិ។ កង់ជាកម្មសិទ្ធិប្រើប្រាស់ផ្ទាល់ខ្លួនមាន ៤៩,២ ភាគរយនៃគ្រួសារនៅទីប្រជុំជន និងនៅជនបទមាន ៥៨,៨ ភាគរយ។ យោងតាមលទ្ធផលខាងលើអាចនិយាយបានថា ម៉ូតូនៅតែជាមធ្យោបាយធ្វើដំណើរពេញនិយមរបស់ប្រជាជនកម្ពុជា ជាពិសេសនៅទីប្រជុំជន។ ចំណែកឯ ទូរទស្សន៍ នៅតែជាការពេញនិយមរបស់ប្រជាជនកម្ពុជា ទាំងនៅទីប្រជុំជន និងជនបទ ដោយសារតែមានការកើនឡើងនៃភាគរយគ្រួសារបានប្រើប្រាស់អគ្គិសនីនៅទូទាំងប្រទេស នេះបង្ហាញឲ្យឃើញពីការផ្លាស់ប្តូរជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា។

## តារាង ១០.៣.៦. ការបែងចែកគ្រួសារ តាមប្រភេទ និងចំនួនឧបករណ៍ប្រើប្រាស់ផ្ទាល់ខ្លួន កម្ពុជា ឆ្នាំ២០១៩

| ប្រភេទសម្ភារៈប្រើប្រាស់ | គ្រួសារដែលមានសម្ភារៈប្រើប្រាស់ | | ចំនួនសម្ភារៈប្រើប្រាស់ដែលគ្រួសារមានខាងក្រោម | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចំនួន | ភាគរយធៀបនឹងសរុប | សរុប | ០ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០+ |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨) | (៩) | (១០) | (១១) | (១២) | (១៣) | (១៤) | (១៥) |
| **កម្ពុជា** | | | | | | | | | | | | | | |
| វិទ្យុ/ម៉ាញ៉េ | ៥៧៦.២៧១ | ១៦,២២ | ១០០ | ៨៣,៧៨ | ១៥,៧៣ | ០,២៨ | ០,០៣ | ០,០១ | ០,០១ | ០,០០ | ០,០០ | ០,០០ | ០,០០ | ០,១៦ |
| ទូរទស្សន៍ | ២.៣៩៩.៤១៨ | ៦៧,៥៣ | ១០០ | ៣២,៤៧ | ៦២,៨០ | ៣,៥៤ | ០,៧២ | ០,២០ | ០,០៩ | ០,០៤ | ០,០១ | ០,០១ | ០,០០ | ០,១១ |
| ទូរស័ព្ទលើតុ | ៥៧.៤៣៥ | ១,៦២ | ១០០ | ៩៨,៣៨ | ១,២១ | ០,២០ | ០,០៧ | ០,០៤ | ០,០២ | ០,០២ | ០,០០ | ០,០០ | ០,០០ | ០,០៥ |
| ទូរស័ព្ទដៃ | ៣.២៦៦.៥៤៤ | ៩១,៩៣ | ១០០ | ៨,០៧ | ៣៤,៦៨ | ៣០,៨៣ | ១៣,០៦ | ៦,៩៥ | ៣,៤០ | ១,៥២ | ០,៦៩ | ០,៤០ | ០,១៧ | ០,២៤ |
| កុំព្យូទ័រផ្ទាល់ខ្លួន | ២៨២.៨០៤ | ៧,៩៦ | ១០០ | ៩២,០៤ | ៥,៩៤ | ១,៣៣ | ០,៣៧ | ០,១៥ | ០,០៧ | ០,០៣ | ០,០១ | ០,០១ | ០,០០ | ០,០៥ |
| កង់ | ១.៩៦២.៥៣០ | ៥៥,២៣ | ១០០ | ៤៤,៧៧ | ៤២,៦១ | ៩,៩៩ | ២,០៤ | ០,៣៩ | ០,១០ | ០,០២ | ០,០១ | ០,០០ | ០,០០ | ០,០៧ |
| ម៉ូតូ | ២.៨៤៦.៩៥៥ | ៨០,១១ | ១០០ | ១៩,៨៩ | ៥៤,២២ | ១៨,៦១ | ៥,១៣ | ១,៤២ | ០,៤១ | ០,១១ | ០,០៤ | ០,០១ | ០,០១ | ០,១៥ |
| ទូរទឹកកក | ៥៨២.០៣០ | ១៦,៣៨ | ១០០ | ៨៣,៦២ | ១៥,១៨ | ០,៨៧ | ០,១៦ | ០,០៥ | ០,០២ | ០,០១ | ០,០០ | ០,០០ | ០,០០ | ០,០៨ |
| ម៉ាស៊ីនបោក | ៣៣៧.៥៣៨ | ៩,៥០ | ១០០ | ៩០,៥០ | ៨,៨៩ | ០,៣៦ | ០,១២ | ០,០៥ | ០,០៣ | ០,០២ | ០,០១ | ០,០០ | ០,០០ | ០,០២ |
| កង្ហារ | ២.៨១៧.៨២១ | ៧៩,៣០ | ១០០ | ២០,៧០ | ៣៣,៧៧ | ២៥,៣៩ | ១១,៦៧ | ៤,៥២ | ២,៣៥ | ០,៧៤ | ០,៣០ | ០,១៨ | ០,០៧ | ០,៣១ |
| ម៉ាស៊ីនត្រជាក់ | ២៥៤.៥៥១ | ៧,១៦ | ១០០ | ៩២,៨៤ | ៤,១៨ | ១,៦០ | ០,៦៧ | ០,៣៤ | ០,១៧ | ០,០៨ | ០,០៣ | ០,០៣ | ០,០១ | ០,០៥ |
| រថយន្ត/រថយន្តដឹកទំនិញធុនតូច/ធំ | ៣៦០.២៥៨ | ១០,១៤ | ១០០ | ៨៩,៨៦ | ៨,៤៦ | ១,២២ | ០,២៩ | ០,០៩ | ០,០៤ | ០,០២ | ០,០១ | ០,០០ | ០,០០ | ០,០២ |
| ទូក/កាណូត | ១១៤.៤១៣ | ៣,២២ | ១០០ | ៩៦,៧៨ | ២,៧២ | ០,៣៦ | ០,០៨ | ០,០៣ | ០,០១ | ០,០០ | ០,០០ | ០,០០ | ០,០០ | ០,០១ |
| ត្រាក់ទ័រធុនធំ/តូច | ៣៦.៣៧៩ | ១,០២ | ១០០ | ៩៨,៩៨ | ០,៩២ | ០,០៧ | ០,០១ | ០,០០ | ០,០០ | ០,០០ | ០,០០ | ០,០០ | ០,០០ | ០,០១ |
| គោយន្ត | ៥០០.២៦៣ | ១៤,០៨ | ១០០ | ៨៥,៩២ | ១៣,៧៦ | ០,២៩ | ០,០២ | ០,០០ | ០,០០ | ០,០០ | ០,០០ | ០,០០ | ០,០០ | ០,០១ |
| **ទីប្រជុំជន** | | | | | | | | | | | | | | |
| វិទ្យុ/ម៉ាញ៉េ | ១៨៨.២៩៩ | ១៤,១៩ | ១០០ | ៨៥,៨១ | ១៣,៥៧ | ០,៣៩ | ០,០៦ | ០,០១ | ០,០១ | ០,០១ | ០,០០ | ០,០០ | ០,០០ | ០,១៥ |
| ទូរទស្សន៍ | ១.០២៦.៩៦៨ | ៧៧,៣៩ | ១០០ | ២២,៦១ | ៦៧,១៤ | ៧,៥១ | ១,៧៦ | ០,៥១ | ០,២២ | ០,០៨ | ០,០៣ | ០,០២ | ០,០១ | ០,១២ |
| ទូរស័ព្ទលើតុ | ២៨.៤៤១ | ២,១៤ | ១០០ | ៩៧,៨៦ | ១,៥៨ | ០,២៦ | ០,១១ | ០,០៧ | ០,០៤ | ០,០៣ | ០,០១ | ០,០១ | ០,០០ | ០,០៤ |
| ទូរស័ព្ទដៃ | ១.២៥៨.២០៥ | ៩៤,៨១ | ១០០ | ៥,១៩ | ២០,៧០ | ៣២,៧៨ | ១៧,៤៦ | ១១,៣៤ | ៦,២៩ | ៣,០៥ | ១,៤៦ | ០,៨៨ | ០,៣៩ | ០,៤៧ |

| ប្រភេទសម្ភារៈប្រើប្រាស់ | គ្រួសារដែលមានសម្ភារៈប្រើប្រាស់ | | ចំនួនសម្ភារៈប្រើប្រាស់ដែលគ្រួសារមានខាងក្រោម | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចំនួន | ភាគរយធៀបនឹងសរុប | សរុប | ០ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០+ |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨) | (៩) | (១០) | (១១) | (១២) | (១៣) | (១៤) | (១៥) |
| កុំព្យូទ័រផ្ទាល់ខ្លួន | ២០១.៣១២ | ១៥,១៧ | ១០០ | ៨៤,៨៣ | ១០,៩៦ | ២,៧៨ | ០,៨១ | ០,៣២ | ០,១៤ | ០,០៧ | ០,០២ | ០,០២ | ០,០១ | ០,០៤ |
| កង់ | ៦៥២.៥៥៣ | ៤៩,១៧ | ១០០ | ៥០,៨៣ | ៣៧,៣៨ | ៩,១៨ | ១,៩៧ | ០,៤១ | ០,១៣ | ០,០៣ | ០,០១ | ០,០០ | ០,០០ | ០,០៥ |
| ម៉ូតូ | ១.១២៩.៣២៩ | ៨៥,១០ | ១០០ | ១៤,៩០ | ៤៩,០៥ | ២៣,៤៥ | ៨,៥០ | ២,៧៤ | ០,៨៨ | ០,២៣ | ០,០៩ | ០,០៣ | ០,០២ | ០,១១ |
| ទូរទឹកកក | ៤២៥.៤៤៥ | ៣២,០៦ | ១០០ | ២៩,៧០ | ១,៧៨ | ០,៣៤ | ០,១១ | ០,០៤ | ០,០២ | ០,០១ | ០,០០ | ០,០០ | ០,០៧ | ០,០៧ |
| ម៉ាស៊ីនបោក | ២៦៨.៣៧៣ | ២០,២២ | ១០០ | ៧៩,៧៨ | ១៩,០៣ | ០,៧០ | ០,២៣ | ០,១១ | ០,០៧ | ០,០៣ | ០,០១ | ០,០១ | ០,០០ | ០,០៣ |
| កង្ហារ | ១.២១៤.០៣៤ | ៩១,៤៩ | ១០០ | ៨,៥១ | ២៩,៧២ | ៣០,០០ | ១៧,០៨ | ៧,៥៤ | ៤,១៩ | ១,៣៧ | ០,៥៧ | ០,៣៥ | ០,១៤ | ០,៥១ |
| ម៉ាស៊ីនត្រជាក់ | ២២០.៥៥១ | ១៦,៦២ | ១០០ | ៨៣,៣៨ | ៩,៣៨ | ៣,៨៥ | ១,៦៦ | ០,៨៦ | ០,៤៤ | ០,១៩ | ០,០៨ | ០,០៧ | ០,០៣ | ០,០៧ |
| រថយន្ត/រថយន្តដឹកទំនិញធុនតូច/ធំ | ២៤៥.១៣០ | ១៨,៤៧ | ១០០ | ៨១,៥៣ | ១៥,១១ | ២,៤២ | ០,៥៩ | ០,១៩ | ០,០៨ | ០,០៣ | ០,០២ | ០,០១ | ០,០០ | ០,០៣ |
| ទូក/កាណូត | ១៧.០១៣ | ១,២៨ | ១០០ | ៩៨,៧២ | ១,០៥ | ០,១៦ | ០,០៤ | ០,០១ | ០,០១ | ០,០០ | ០,០០ | ០,០០ | ០,០០ | ០,០១ |
| ត្រាក់ទ័រធុនធំ/តូច | ៥.៦៩៤ | ០,៤៣ | ១០០ | ៩៩,៥៧ | ០,៣៧ | ០,០៤ | ០,០១ | ០,០០ | ០,០០ | ០,០០ | ០,០០ | ០,០០ | ០,០០ | ០,០០ |
| គោយន្ត | ៥៥.៤៤៩ | ៤,១៨ | ១០០ | ៩៥,៨២ | ៤,០៤ | ០,១២ | ០,០១ | ០,០០ | ០,០០ | ០,០០ | ០,០០ | ០,០០ | ០,០០ | ០,០១ |
| **ជនបទ** | | | | | | | | | | | | | | |
| វិទ្យុ/ម៉ាញ៉េ | ៣៨៧.៩៧២ | ១៧,៤៣ | ១០០ | ៨២,៥៧ | ១៧,០១ | ០,២២ | ០,០២ | ០,០១ | ០,០០ | ០,០០ | ០,០០ | ០,០០ | ០,០០ | ០,១៦ |
| ទូរទស្សន៍ | ១.៣៧២.៤៥០ | ៦១,៦៥ | ១០០ | ៣៨,៣៥ | ៦០,២២ | ១,១៨ | ០,១០ | ០,០៣ | ០,០១ | ០,០១ | ០,០០ | ០,០០ | ០,០០ | ០,១១ |
| ទូរស័ព្ទលើតុ | ២៨.៩៩៤ | ១,៣០ | ១០០ | ៩៨,៧០ | ១,០០ | ០,១៧ | ០,០៥ | ០,០២ | ០,០១ | ០,០១ | ០,០០ | ០,០០ | ០,០០ | ០,០៥ |
| ទូរស័ព្ទដៃ | ២.០០៨.៣៣៩ | ៩០,២១ | ១០០ | ៩,៧៩ | ៤៣,០១ | ២៩,៦៦ | ១០,៤៤ | ៤,៣៤ | ១,៦៨ | ០,៦០ | ០,២៣ | ០,១០ | ០,០៤ | ០,១១ |
| កុំព្យូទ័រផ្ទាល់ខ្លួន | ៨១.៤៩២ | ៣,៦៦ | ១០០ | ៩៦,៣៤ | ២,៩៥ | ០,៤៦ | ០,១១ | ០,០៥ | ០,០២ | ០,០២ | ០,០០ | ០,០០ | ០,០០ | ០,០៦ |
| កង់ | ១.៣០៩.៩៧៧ | ៥៨,៨៤ | ១០០ | ៤១,១៦ | ៤៥,៧៣ | ១០,៤៨ | ២,០៧ | ០,៣៧ | ០,០៩ | ០,០២ | ០,០១ | ០,០០ | ០,០០ | ០,០៨ |
| ម៉ូតូ | ១.៧១៧.១៦៦ | ៧៧,១៣ | ១០០ | ២២,៨៧ | ៥៧,៣០ | ១៥,៧២ | ៣,១២ | ០,៦៤ | ០,១៣ | ០,០៣ | ០,០១ | ០,០០ | ០,០០ | ០,១៧ |
| ទូរទឹកកក | ១៥៦.៥៨៥ | ៧,០៣ | ១០០ | ៩២,៩៧ | ៦,៥២ | ០,៣៣ | ០,០៦ | ០,០១ | ០,០០ | ០,០១ | ០,០០ | ០,០០ | ០,០០ | ០,០៩ |
| ម៉ាស៊ីនបោក | ៦៩.១៦៥ | ៣,១១ | ១០០ | ៩៦,៨៩ | ២,៨៥ | ០,១៦ | ០,០៥ | ០,០២ | ០,០១ | ០,០១ | ០,០០ | ០,០០ | ០,០០ | ០,០១ |
| កង្ហារ | ១.៦០៣.៧៨៧ | ៧២,០៤ | ១០០ | ២៧,៩៦ | ៣៦,១៨ | ២២,៦៥ | ៨,៤៤ | ២,៧១ | ១,២៥ | ០,៣៦ | ០,១៤ | ០,០៨ | ០,០៣ | ០,១៩ |
| ម៉ាស៊ីនត្រជាក់ | ៣៤.០០០ | ១,៥៣ | ១០០ | ៩៨,៤៧ | ១,០៨ | ០,២៦ | ០,០៩ | ០,០៣ | ០,០២ | ០,០១ | ០,០០ | ០,០០ | ០,០០ | ០,០៣ |

| ប្រភេទសម្ភារៈប្រើប្រាស់ | គ្រួសារដែលមានសម្ភារៈប្រើប្រាស់ | | ចំនួនសម្ភារៈប្រើប្រាស់ដែលគ្រួសារមានខាងក្រោម | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចំនួន | ភាគរយធៀបនឹងសរុប | សរុប | ០ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០+ |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨) | (៩) | (១០) | (១១) | (១២) | (១៣) | (១៤) | (១៥) |
| រថយន្ត/រថយន្តដឹកទំនិញធុនតូច/ធំ | ១១៥.១២៨ | ៥,១៧ | ១០០ | ៩៤,៨៣ | ៤,៥០ | ០,៥០ | ០,១១ | ០,០៣ | ០,០២ | ០,០១ | ០,០០ | ០,០០ | ០,០០ | ០,០១ |
| ទូក/កាណូត | ៩៧.៤០០ | ៤,៣៨ | ១០០ | ៩៥,៦២ | ៣,៧២ | ០,៤៨ | ០,១០ | ០,០៤ | ០,០១ | ០,០១ | ០,០០ | ០,០០ | ០,០០ | ០,០១ |
| ត្រាក់ទ័រធុនធំ/តូច | ៣០.៦៨៥ | ១,៣៨ | ១០០ | ៩៨,៦២ | ១,២៦ | ០,០៩ | ០,០១ | ០,០០ | ០,០០ | ០,០០ | ០,០០ | ០,០០ | ០,០០ | ០,០១ |
| គោយន្ត | ៤៤៤.៨១៤ | ១៩,៩៨ | ១០០ | ៨០,០២ | ១៩,៥៥ | ០,៣៩ | ០,០២ | ០,០១ | ០,០០ | ០,០០ | ០,០០ | ០,០០ | ០,០០ | ០,០១ |

# ជំពូក ១១

# សេចក្តីសង្ខេប និងការសន្និដ្ឋាន

## ១១.១. សូចនាករប្រជាសាស្ត្រ

តាមលទ្ធផលចុងក្រោយនៃជំរឿនឆ្នាំ២០១៩ កម្ពុជាមានប្រជាជន ១៥.៥៥២.២១១នាក់ នៅយប់ម៉ោង ០០ ថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៩។ ប្រុសមានចំនួន ៧.៥៧១.៨៣៧នាក់ (៤៨,៧ ភាគរយ) និងស្រី ៧.៩៨០.៣៧៤នាក់ (៥១,៣ ភាគរយ)។ បើយោងតាមជំរឿនប្រជាជនឆ្នាំ២០១៩ ប្រជាជនកម្ពុជាមានចំនួនទាបជាងការព្យាករណ៍ដែលមានចំនួនប្រជាជន ១៦,២ លាននាក់ នៅឆ្នាំដូចគ្នានោះ។ ការព្យាករណ៍ចំនួនប្រជាជន និងត្រូវធ្វើឡើងវិញឲ្យបានឆាប់ដោយផ្អែកទៅលើលទ្ធផលជំរឿនឆ្នាំ២០១៩។

ប្រជាជនកម្ពុជាបានកើនឡើងក្នុងរង្វង់ ២,២លាន ក្នុងរយៈពេល១១ ឆ្នាំ គឺពីឆ្នាំ២០០៨-២០១៩។ អត្រាកំណើនប្រចាំឆ្នាំមាន ១,៤ ភាគរយ គឺទាបជាងឆ្នាំ២០០៨ ដែលមាន (១,៥ ភាគរយ) ការធ្លាក់ចុះនេះអាចដោយសារអត្រានៃលទ្ធភាពបង្កើតកូនធ្លាក់ចុះ និងការធ្វើចំណាកស្រុករបស់ប្រជាជនកម្ពុជាទៅកាន់ប្រទេសផ្សេងៗ ជាពិសេសប្រទេសថៃ និងសាធារណៈរដ្ឋកូរ៉េ។ នៅប្រទេសកម្ពុជា អត្រាកំណើតដុល (CBR) មាន ៣៧,៧ កំណើតក្នុង ១.០០០ កំណើតរស់។ អត្រាមរណភាពទារកគឺ ១៩ នាក់ ក្នុង១.០០០ កំណើតរស់ និងអត្រាមរណភាពមាតាធ្លាក់ចុះមក ១៤១ ក្នុងចំណោម ១០០.០០០ កំណើតរស់ បើប្រៀបធៀបទៅនឹងឆ្នាំ២០០៨ មាន ៤៦១នាក់ ក្នុងចំណោម ១០០.០០០ កំណើតរស់។

## ១១.២. ការបែងចែកប្រជាជន

ដង់ស៊ីតេប្រជាជនកម្ពុជា កើនឡើង ១២ នាក់ក្នុងបរិវេណដីក្នុងមួយគីឡូម៉ែត្រការ៉េរវាងឆ្នាំ២០០៨ និងឆ្នាំ២០១៩ (៧៥ ទៅ ៨៧ នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ តាមលំដាប់រៀង)។ ចំនួនប្រជាជននៅទីប្រជុំជនឆ្នាំ១៩៩៨ ២០០៨ និង២០១៩ ត្រូវបានផ្អែកលើនិយមន័យដែលបានកែតម្រូវចុងក្រោយស្តីពីការធ្វើចំណាត់ថ្នាក់ទីប្រជុំជន។ ភាគរយនៃប្រជាជននៅទីប្រជុំជនក្នុងចំណោមប្រជាជនសរុប មានការកើនឡើងតិចតួចពី ១៨,២ ភាគរយ នៅឆ្នាំ១៩៩៨ ទៅ ១៩,៥ ភាគរយ នៅឆ្នាំ២០០៨ លើកលែងតែនៅឆ្នាំ២០១៩ មានការឡើងខ្ពស់រហូតដល់ ៣៩,៥ ភាគរយ។

ការបែងចែកភាគរយនៃអ្នកនិយាយភាសាកំណើតបានបង្ហាញថា ភាសាខ្មែរគឺជាភាសាកំណើតដែលបាននិយាយច្រើនជាងគេនៅក្នុងប្រទេស។ មានប្រជាជនកម្ពុជាតិចជាង ១ ភាគរយនិយាយភាសាផ្សេងទៀត គឺភាសាមួយនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ អត្រាអ្នកនិយាយភាសាជនជាតិភាគតិច ២,៩ ភាគរយនៃប្រជាជនសរុប។

ព្រះពុទ្ធសាសនាគឺជាសាសនានាំមុខគេរបស់ប្រទេសកម្ពុជា (៩៦,៩ ភាគរយ)។ ប្រមាណ ៩៩,៤ ភាគរយនៃប្រជាជនសរុបបានឆ្លើយថាពួកគេបានកើតនៅក្នុងប្រទេសកម្ពុជា។

## ១១.៣. អត្រាភេទ និងរចនាសម្ព័ន្ធអាយុ

យោងតាមជំរឿនឆ្នាំ២០១៩ អត្រាភេទសរុប ឬអត្រាភេទនៃចំនួនប្រជាជនកម្ពុជាសរុបមាន ៩៥,៧ ភាគរយ។ សមាមាត្រក្មេង (អាយុ ១៥ ឆ្នាំ) បានធ្លាក់ចុះពី ៤២,៨ ភាគរយ នៅឆ្នាំ១៩៩៨ មក ៣៣,៧ ភាគរយ នៅឆ្នាំ២០០៨ និង ២៩,៤ ភាគរយ នៅឆ្នាំ២០១៩ ដែលបណ្តាលមកពីការធ្លាក់ចុះកំណើតក្នុងទសវត្សន៍ចុងក្រោយនេះ។ ក្រុមអាយុ ៥៥ ឆ្នាំឡើង មានសមាមាត្រខ្ពស់ដែលឆ្លុះបញ្ចាំងពីការធ្លាក់ចុះនៃមរណភាពរបស់មនុស្សពេញវ័យ។ អាយុមេដ្យានរបស់ប្រជាពលរដ្ឋកម្ពុជាមាន ២៧ឆ្នាំ នៅឆ្នាំ២០១៩ មានការកើនឡើងប្រមាណ ៦ ឆ្នាំ បើប្រៀបធៀបនឹងឆ្នាំ ២០០៨ (២២ ឆ្នាំ) ដោយឡែក អាយុមេដ្យានរបស់ប្រជាជនកម្ពុជានៅឆ្នាំ២០០៨ បានកើនឡើងប្រហែល ៤ ឆ្នាំ បើប្រៀបធៀបឆ្នាំ១៩៩៨ មាន ១៧ ឆ្នាំ។ ប្រជាជនកម្ពុជាដែលមានអាយុ "វ័យក្មេង" ហាក់បានវិវដ្តមកដល់ "អាយុវ័យកណ្តាល" និងដំណាក់កាលចុងក្រោយ ប្រហែលនឹងមកដល់កម្រិតអាយុ "វ័យចាស់"។

អត្រាអាយុក្នុងបន្ទុកនៃប្រជាជនកម្ពុជាបានបង្ហាញនិន្នាការធ្លាក់ចុះក្នុងរវាងឆ្នាំ១៩៩៨ និងឆ្នាំ២០១៩។ សមាមាត្រអត្រាក្នុងបន្ទុកនៅតំបន់ទីប្រជុំជន មាន ៥១,២ នាក់ ក្នុង១០០ ក្នុងអាយុធ្វើការ (ក្រុមអាយុ ១៥-៥៩)។ អត្រាអ្នកនៅក្នុងបន្ទុកនៅជនបទខ្ពស់។

## ១១.៤. ស្ថានភាពអាពាហ៍ពិពាហ៍

ស្ត្រីភាគច្រើនអាចរៀបការមុនបុរស។ នៅក្រុមអាយុ ៣០-៣៤ ឆ្នាំ សមាមាត្រ រៀបការរបស់ស្ត្រីខ្ពស់ជាងបុរសក្នុងគ្រប់ក្រុមអាយុក្រោមអាយុ ៣០ ឆ្នាំ។ នៅក្រុមអាយុ ៣០-៣៤ ឆ្នាំ របត់មួយបានបង្ហាញភាពខុសគ្នារវាងសមាមាត្ររបស់ប្រុស និងស្រី។ បន្ទាប់ពីក្រុមអាយុនេះ បុរសមានសមាមាត្រខ្ពស់ជាងស្ត្រី ដែលបានរៀបការ ហើយគំលាតនៃសមាមាត្រនេះកាន់តែធំ។ អត្រាមេម៉ាយ ឬពោះម៉ាយមានលក្ខណៈវិជ្ជមានទៅនឹងអាយុ ជាមួយអត្រាកើនឡើងបន្តិចនៅពេលអាយុកើនឡើង។ អត្រាមេម៉ាយ ឬពោះម៉ាយ លែងលះគ្នា និងរស់នៅផ្សេងគ្នាមានប្រមាណ ៦,៣ ភាគរយ ក្នុងចំណោមប្រជាជនពេញវ័យអាយុ ១៥ ឆ្នាំឡើង បុរសមាន ២,៩ ភាគរយ ធៀបនឹងស្ត្រី ៩,៤ ភាគរយ។

## ១១.៥. អក្ខរភាព និងការអប់រំ

អត្រាអក្ខរភាពនៅកម្ពុជាត្រូវបានកែលំអរធ្វើឲ្យប្រសើរឡើងរវាងឆ្នាំ១៩៩៨-២០១៩។ នេះឆ្លុះបញ្ចាំងការអនុវត្តប្រកបដោយជោគជ័យក្នុងកម្មវិធីអប់រំ ក្នុងគោលបំណងធ្វើឲ្យកើនឡើងអត្រាអក្ខរភាពក្នុងចំណោមប្រជាជនវ័យក្មេង។

ចំនួនអ្នកចេះអក្សរអាយុ ៧ ឆ្នាំឡើង នៅក្នុងប្រទេសបានកើនឡើងគួរឲ្យកត់សម្គាល់ប្រមាណ ៥,៨ លាននាក់ដល់ជាង ១១,៩ លាននាក់ ក្នុងរវាងឆ្នាំ១៩៩៨-២០១៩។ អត្រាអ្នកចេះអក្សរសរុប ជាភាគរយនៃមនុស្សចេះអក្សរធៀបនឹងមនុស្សសរុបដែលមានអាយុចាប់ពី ៧ ឆ្នាំឡើង ហើយអត្រានេះបានកើនឡើងជាលំដាប់ពី ៦២,៨ ភាគរយ នៅឆ្នាំ ១៩៩៨ ដល់ ៧៨,៤ ភាគរយ នៅឆ្នាំ២០០៨ និងកើនដល់ ៨៨,៥ ភាគរយ នៅឆ្នាំ២០១៩។ កម្រិតអ្នកចេះអក្សរនៅទីប្រជុំជនក៏មាននិន្នាការកើនឡើងដូចថ្នាក់ជាតិដែរ ពី ៧៨,៥ ភាគរយ នៅឆ្នាំ១៩៩៨ ដល់ ៩០,២ ភាគរយ នៅឆ្នាំ ២០០៨ និងកើនដល់ ៩៣,៣ ភាគរយ នៅឆ្នាំ២០១៩។ អត្រាអ្នកចេះអក្សរនៅជនបទកើនពី ៥៩,១ ភាគរយ នៅឆ្នាំ ១៩៩៨ ដល់ ៧៥,៣ ភាគរយ និងកើនដល់ ៨៥,៤ ភាគរយ នៅឆ្នាំ២០១៩។

គួរកត់សម្គាល់ថាមានការកើនឡើងនៃចំនួនមនុស្សពេញវ័យចេះអក្សរដែលមានអាយុ ១៥ ឆ្នាំឡើង មាន ៧៧,៦ ភាគរយ នៅឆ្នាំ២០០៨ និង ៨៧,៧ ភាគរយ នៅឆ្នាំ២០១៩។ ក្នុងរយៈពេលជាងមួយទសវត្សរ៍នេះ អត្រាមនុស្សពេញវ័យចេះអក្សរ កើនឡើងពី ៨៥,១ ភាគរយ នៅឆ្នាំ២០០៨ ទៅ ៩០,៩ ភាគរយ ក្នុងឆ្នាំ២០១៩ សម្រាប់ប្រុស ហើយពី ៧០,៩ ភាគរយ ទៅ ៨៤,៨ ភាគរយ សម្រាប់ស្រី តាមលំដាប់រៀង។ លើសពីនេះ ការកើនឡើងនេះមានទាំងនៅទីប្រជុំជន និងជនបទ។ អត្រាកំណើនអក្ខរភាពនៃមនុស្សទាំងពីរភេទនៅតំបន់ទីប្រជុំជនខ្ពស់ជាងអត្រាកំណើននៅជនបទ។

ប្រទេសកម្ពុជាបានបង្ហាញកំណើនល្អប្រសើរក្នុងក្របខណ្ឌអត្រាអក្ខរភាពនៃមនុស្សពេញវ័យក្នុងរយៈពេលជាងពីរទសវត្សរ៍ ចាប់ពីឆ្នាំ១៩៩៨ រហូតដល់ ២០១៩។ ដោយឡែក អត្រាកំណើនអក្ខរភាពនៃមនុស្សពេញវ័យនៅកម្ពុជាជាងមួយទសវត្សរ៍ចុងក្រោយនេះ ២០០៨- ២០១៩ មានប្រមាណ ៣៤,៦ ភាគរយ។

កម្រិតអប់រំរបស់ប្រជាជនត្រូវបានគិតទៅលើកម្រិតនៃការទទួលបានការសិក្សានៃមនុស្សដែលមានអាយុពី ២៥ឆ្នាំឡើងទៅបានចូលសិក្សា ហើយបានបញ្ចប់កម្រិតសិក្សារបស់ខ្លួន។ ភាគរយនេះបានកើនឡើងជាលំដាប់ ពីកម្រិតបញ្ចប់បឋមសិក្សាទៅដល់មធ្យមសិក្សា។ រវាងឆ្នាំ២០០៨ និង២០១៩ ភាគរយស្រីបានកើនឡើងតិចតួចជាងប្រុស។ ជាទូទៅករណីការបោះបង់ការសិក្សាមានចំនួនច្រើនទាំងប្រុស និងស្រី នៅពេលដែលពួកគេរៀនបានកម្រិតខ្ពស់។ ទោះជាយ៉ាងណាក៏ដោយទម្រង់ទិន្នន័យពីឆ្នាំ២០០៨ និងឆ្នាំ២០១៩ ស្រី បានបោះបង់ការសិក្សាច្រើនជាងប្រុស។

លទ្ធផលជំរឿនឆ្នាំ២០១៩ តម្រូវឲ្យមានកិច្ចខំប្រឹងប្រែង កែលម្អវិស័យអប់រំនៅកម្ពុជា។ ជាទូទៅជំរឿនទាំងបីអត្រាអ្នកចេះអក្សរនៅជនបទ ទាបជាងនៅតំបន់ទីប្រជុំជន។ ផែនការអភិវឌ្ឍន៍ត្រូវតែយកចិត្តទុកដាក់ខ្ពស់ចំពោះអត្រានៃការបញ្ចប់ថ្នាក់បឋមសិក្សា និងកាត់បន្ថយគំលាតអត្រាអក្ខរភាពរវាងតំបន់ទីប្រជុំជននិងជនបទ។ ការផ្តោតជាចម្បងត្រូវតែបញ្ឈប់ ឬកាត់បន្ថយឲ្យបានជាអប្បរមាការបោះបង់ចោលការសិក្សា ជាពិសេសក្នុងចំណោមក្មេងស្រីនៅកម្រិតបឋមសិក្សា និងកែលម្អកម្រិតអប់រំ និងអក្ខរភាពស្ត្រី។

## ១១.៦. ការចូលរៀន

ផ្អែកលើលទ្ធផលជំរឿនឆ្នាំ២០១៩ អត្រាចុះឈ្មោះចូលរៀនមាន ៩០,៦ ភាគរយ និង ៩១,៦ ភាគរយសម្រាប់កុមារអាយុពី ៦-១១ និង ១២-១៤ តាមលំដាប់រៀង។

ដោយឡែក អត្រានៃការបោះបង់ការសិក្សា ឬការឈប់រៀនមានការកើនឡើង ដែលនាំឲ្យមានការធ្លាក់ចុះនូវអត្រាចុះឈ្មោះចូលរៀនយ៉ាងខ្លាំងសម្រាប់ប្រជាជនអាយុ ១៥ ឆ្នាំឡើងទៅ។ ជិតមួយភាគបួននៃក្រុមអាយុ ២៥ ឆ្នាំឡើង មិនដែលចូលសាលារៀន ឬគ្រឹះស្ថានសិក្សាណាមួយសោះ។ អត្រាចុះឈ្មោះចូលរៀននៅសាលារៀន ឬគ្រឹះស្ថានសិក្សាណាមួយរបស់ក្មេងស្រី មានអត្រាស្មើគ្នានឹងក្មេងប្រុសដែលនៅក្រុមអាយុ ៦-១១ ឆ្នាំ ហើយអត្រាក្មេងប្រុសទាបជាងស្រីបន្តិចនៅក្រុមអាយុ ១២-១៤ ឆ្នាំ។ ទោះបីជាយ៉ាងណាក៏ដោយ អត្រាក្មេងស្រីចាប់ផ្តើមទាបជាងក្មេងប្រុសវិញនៅពេលដែលមានអាយុកើនឡើង។ នេះអាចដោយសារអត្រាបោះបង់ការសិក្សារបស់ក្មេងស្រីដែលមានអាយុកាន់តែច្រើនទៅធ្វើការងារដើម្បីជួយរកចំណូលឲ្យគ្រួសារ។

## ១១.៧. ការចូលរួមសកម្មភាពសេដ្ឋកិច្ច (កម្លាំងពលកម្ម)

អត្រាសកម្មភាពសេដ្ឋកិច្ចសរុបនៅថ្នាក់ជាតិបានកើនឡើង ៣,៣ ភាគរយ ក្នុងរយៈពេលជាងមួយទសវត្សរ៍ចុងក្រោយនេះ ឆ្នាំ២០០៨-២០១៩ ។ ចំពោះបុរសកើនឡើង ៥,៩ ភាគរយ ខ្ពស់ជាងធៀបនឹងស្ត្រី។ អត្រាចូលរួមសកម្មភាពសេដ្ឋកិច្ចនៅថ្នាក់ជាតិសម្រាប់មនុស្សអាយុ ៥ ឆ្នាំឡើង បានកើនឡើងជាងទសវត្សរ៍ឆ្នាំ ២០០៨-២០១៩ ចាប់ពី ៥៨,៧ ភាគរយ ដល់ ៦២,០ ភាគរយ។ ម្យ៉ាងវិញទៀត ភាគរយនៃការកើនឡើងសម្រាប់បុរស ចាប់ពី ៥៩,៣ ភាគរយ ដល់ ៦៥,២ ភាគរយ និងសម្រាប់ស្ត្រីមានចាប់ពី ៥៨,១ ភាគរយ ដល់ ៥៩,០ភាគរយ។ បើវិភាគទៅលើមនុស្សអាយុចាប់ពី ១៥ ឆ្នាំឡើងទៅ ស្ត្រីហាក់ដូចជាចាប់ផ្តើមចូលរួម និងចាកចេញពីសកម្មភាពសេដ្ឋកិច្ច (កម្លាំងពលកម្ម) នៅអាយុក្មេងជាងបុរស។ អត្រាចូលរួមកម្លាំងពលកម្មក្នុងសម្មភាពសេដ្ឋកិច្ចនៅតំបន់ជនបទ មានអត្រាខ្ពស់ជាងនៅតំបន់ទីប្រជុំជនទាំងបុរស និងស្ត្រី អាចមកពីការចូលរួមកម្លាំងពលកម្មក្នុងសកម្មភាពស្រែចម្ការនៅតំបន់ជនបទមានអត្រាខ្ពស់ និងភាគរយនៃការចូលរៀននៅទីប្រជុំជនមានអត្រាខ្ពស់។ បាតុភូតនេះត្រូវបានគេកត់សម្គាល់ផងដែរនៅឆ្នាំ ១៩៩៨។ នៅតំបន់ទីប្រជុំជននៃប្រទេសកម្ពុជា អត្រាចូលរួមសកម្មភាពសេដ្ឋកិច្ចនៃបុរសខ្ពស់ជាងស្ត្រី ដែលដូចគ្នាទៅនឹងជនបទផងដែរ។ អត្រាគ្មានការងារធ្វើក្នុងក្រុមអាយុ ១៥ ឆ្នាំឡើង នៅប្រទេសកម្ពុជាមាន ១,៣ ភាគរយនៅឆ្នាំ ២០១៩ អត្រានេះទាបជាងឆ្នាំ២០០៨។ អត្រាគ្មានការងារធ្វើក្នុងចំណោមបុរសមាន ១,២ ភាគរយ និងស្ត្រីមាន ១,៥ ភាគរយ។ អត្រាអ្នកគ្មានការងារធ្វើនៅជនបទមានកម្រិតទាបជាងនៅតំបន់ទីប្រជុំជន ដោយសារតែវិស័យកសិកម្មបានស្រូបទាញយកកម្លាំងពលកម្មច្រើនជាងគេនៅជនបទ។

គួរកត់សម្គាល់ថា អត្រាសកម្មភាពសេដ្ឋកិច្ចអាយុ ១៥ ឆ្នាំឡើង សម្រាប់ស្ត្រីបានធ្លាក់ចុះតិចតួចពី ៧៦,០ ភាគរយក្នុងឆ្នាំ២០០៨ មក ៧៤,៣ ភាគរយ ឆ្នាំ២០១៩ ឯសម្រាប់បុរស អត្រានេះបានកើនឡើងពី៨០,៨ ឆ្នាំ២០០៨មក ៨៤,៤ នៅឆ្នាំ២០១៩។ ចំណាត់ថ្នាក់ក្រុមអាយុនៃសកម្មភាពសេដ្ឋកិច្ចនេះ មានសមាមាត្រត្រឹមត្រូវបំផុតស្របទៅតាមស្តង់ដារពិភពលោក។

ការវិភាគលើស្ថានភាពការងារ បានបង្ហាញឲ្យដឹងថាទាំងអ្នកធ្វើការឲ្យគ្រួសារដោយគ្មានប្រាក់ឈ្នួល និងអ្នកធ្វើការងារដោយទុនផ្ទាល់ខ្លួនមាន ៦៧,៧ ភាគរយនៃមនុស្សដែលមានការងារធ្វើទាំងអស់ក្នុងប្រទេសកម្ពុជា ឆ្នាំ២០១៩។ អត្រានេះបានបង្ហាញថា ភាគច្រើននៃអ្នកមានការងារធ្វើនៅកម្ពុជាគឺស្ថិតក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឬវិស័យសេដ្ឋកិច្ចមិនរៀបរយ។ កុមារធ្វើការងារ (អាយុតិចជាង ១៥ ឆ្នាំ) មាន ០,៧ ភាគរយ ក្នុងចំណោមចំនួនអ្នកមានការងារធ្វើសរុបឆ្នាំ ២០១៩ ខុសពីឆ្នាំ២០០៨ មាន១,៤ ភាគរយ និងឆ្នាំ១៩៩៨ មាន ១,៥ ភាគរយ។ នៅកម្រិតជាតិ មនុស្សភាគច្រើន (៧៨,៧ ភាគរយ) គឺមានការងារធ្វើក្នុងសហគ្រាសឯកជនក្នុងស្រុក។ ក្នុងក្រុមអាយុ ១៥-៥៩ ឆ្នាំ បុរសដែលមានការងារធ្វើ មានភាគរយខ្ពស់ជាងស្ត្រី ស្ទើរតែគ្រប់វិស័យការងារ ចំណែកឯភាគរយមានការងារធ្វើរបស់ស្ត្រី ខ្ពស់ជាងបុរសនៅតំបន់ទីប្រជុំជន ដោយសារសហគ្រាសបរទេសបានផ្តល់ការងារឲ្យស្ត្រី។

គួរកត់សម្គាល់ផងដែរ សមាមាត្រនៃអ្នកមានការងារធ្វើក្នុងវិស័យសេដ្ឋកិច្ចបឋម (វិស័យកសិកម្ម ព្រៃឈើ និងនេសាទ) បានធ្លាក់ចុះក្នុងរយៈពេលមួយទសវត្សរ៍ (៧២,៣ ភាគរយ ឆ្នាំ២០០៨ មក ៥៤,៧ ភាគរយ ឆ្នាំ២០១៩)។ លើសពីនេះទៀត សមាមាត្រក្នុងវិស័យសេដ្ឋកិច្ចទីពីរ ឬវិស័យឧស្សាហកម្ម មានការកើនឡើង (ពី ៨,៥ ភាគរយ ដល់

១៨,៨ ភាគរយ) និងវិស័យសេដ្ឋកិច្ចទីបី ឬវិស័យសេវាកម្មក៏មានការកើនឡើងផងដែរ (ពី ១៩,២ ភាគរយ និងរហូតដល់ ២៦,៥ ភាគរយ)។ នេះមានន័យថា កម្លាំងពលកម្មច្រើនលើសលប់ក្នុងវិស័យកសិកម្ម បានធ្លាក់ចុះជាលំដាប់ ហើយវិស័យសេដ្ឋកិច្ចផ្សេងទៀតបានកើនឡើង។ ដោយឡែក ភាគរយស្ត្រី (៥៦,៥ ភាគរយ) ដែលមានការងារធ្វើនៅក្នុងវិស័យកសិកម្ម ខ្ពស់ជាងបុរស (៥៣,០ ភាគរយ)។

មានភាពខុសគ្នារវាងតំបន់ទីប្រជុំជន និងជនបទ។ វិស័យសេដ្ឋកិច្ចទីបី ឬវិស័យសេវាកម្មមានប្រមាណ ៦០,៧ ភាគរយ នៅឆ្នាំ២០០៨ និងប្រមាណ ៤៧,៥ ភាគរយ នៅឆ្នាំ២០១៩ នៃអ្នកដែលមានការងារធ្វើនៅតំបន់ទីប្រជុំជន។ បន្ថែមពីនេះ វិស័យសេដ្ឋកិច្ចបឋម ឬវិស័យកសិកម្មមានប្រមាណ ៨៤,៩ ភាគរយ (៨៧,០ ភាគរយ ស្ត្រី) នៅឆ្នាំ ២០០៨ នៃអ្នកមានការងារធ្វើនៅជនបទ និងឆ្នាំ២០១៩ ប្រមាណ ៧៧,៦ ភាគរយ។

ក្នុងចំណោមអាជីពការងារទាំងអស់ ប្រមាណ ៥៣,៤ ភាគរយនៃអ្នកមានការងារធ្វើ នៅក្នុងជំនាញការងារកសិកម្ម ព្រៃឈើ និងនេសាទ។ នៅក្នុងសកម្មភាពសេដ្ឋកិច្ចចម្បង និងអ្នកធ្វើការងារតាមជំនាញ និងការងារពាក់ព័ន្ធនឹងជំនាញមាន ១៦,៦ ភាគរយ។ អ្នកធ្វើការងារផ្នែកសេវាកម្ម និងលក់ដូរមានប្រមាណ ១២,៦ ភាគរយ។ បើយោងទៅតាមតម្រូវការអប់រំកម្រិតខ្ពស់ និងការបណ្តុះបណ្តាលជំនាញក៏ដូចជាការមានឱកាសតិចតួចសម្រាប់មនុស្សដែលធ្វើការជាអាជីពមានជំនាញ អ្នកបច្ចេកទេស អ្នកគ្រប់គ្រង ។ល។ គឺមានសមាមាត្រតិចតួចបំផុតក្នុងចំណោមមនុស្សធ្វើការងារទាំងអស់។ សមាមាត្រស្ត្រី (ប្រហែល ៧,០ ភាគរយ) ក្នុងការងារគ្រប់គ្រង ផ្នែកបច្ចេកទេស និងវិជ្ជាជីវៈ រួមទាំងស្មៀន មានតិចជាងបុរស (ប្រមាណ ១១,១ ភាគរយ) ទោះជាយ៉ាងណាក៏ដោយ ក៏ទាំងពីរភេទនៅតែមានកម្រិតទាបនៅឡើយ។

## ១១.៨. បម្លាស់ទី និងទេសន្តរប្រវេសន៍

ជំរឿនផ្តល់នូវប្រភពព័ត៌មានដ៏សំខាន់ស្តីពីទេសន្តរប្រវេសន៍។ ទេសន្តរប្រវេសន៍ត្រូវបានកំណត់ជាដំណើរការផ្លាស់ប្តូរទីកន្លែងរស់នៅពីទីតាំងភូមិសាស្ត្រមួយទៅភូមិសាស្ត្រមួយទៀត។ នៅពេលដែលចលនាស្ថិតនៅក្នុងប្រទេសតែមួយត្រូវបានចាត់ទុកថាជាការធ្វើទេសន្តរប្រវេសន៍ក្នុងស្រុក ហើយករណីពាក់ព័ន្ធនឹងការផ្លាស់ប្តូរប្រទេសហៅថាការធ្វើទេសន្តរប្រវេសន៍អន្តរជាតិ។

ទេសន្តរប្រវេសន៍នៅកម្ពុជាមាន ២១,៥ ភាគរយ ដែលនៅតំបន់ទីប្រជុំជនមាន ៣៥,៣ ភាគរយហើយនៅជនបទមានតែ ១២ ភាគរយប៉ុណ្ណោះ។ យោងតាមលទ្ធផលជំរឿនឆ្នាំ២០១៩ ចំនួនទេសន្តរប្រវេសន៍ ភាគច្រើនទាំងប្រុសទាំងស្រីមានទីលំនៅពីមុននៅខេត្តមួយផ្សេងទៀតមាន ៥៨,៨ ភាគរយ។ ម៉្យាងទៀត ចលនាទេសន្តរប្រវេសន៍ដែលកំពុងលេចធ្លោនាបច្ចុប្បន្នគឺរវាងខេត្ត និងខេត្ត។ ទោះយ៉ាងណាក៏ដោយ ជំរឿនពីរលើកមុនបានបង្ហាញថានៅឆ្នាំ២០០៨ និងឆ្នាំ១៩៩៨ ចលនាចំណាកស្រុកដែលលេចធ្លោជាងគេ គឺស្ថិតនៅក្នុងខេត្តបានធ្វើសម្ភាសន៍ (ក្នុងខេត្តសម្ភាសន៍)។

មូលហេតុចម្បងនៃការធ្វើទេសន្តរប្រវេសន៍ ដែលបានសម្ភាសន៍ដោយមន្ត្រីសម្ភាសន៍នៅក្នុងជំរឿនទាំងបី គឺការផ្លាស់ទីលំនៅរបស់គ្រួសារ។ ហេតុផលនៃការធ្វើទេសន្តរប្រវេសន៍នេះអនុវត្តចំពោះសមាជិកគ្រួសារដែលត្រូវផ្លាស់ទីលំនៅពីមុនដោយសមាជិកគ្រួសារទាំងមូលបានផ្លាស់ទីលំនៅ។ ភាគរយនៃទេសន្តរប្រវេសន៍ដោយសារមូលហេតុប្តូរទៅ

កន្លែងធ្វើការ ដើម្បីស្វែងរកការងារ និងអាពាហ៍ពិពាហ៍ មានខ្ពស់ក្នុងចំណោមបុរស។ ជំរឿនឆ្នាំ២០១៩ បានបង្ហាញពីការធ្វើទេសន្តរប្រវេសន៍គួរឲ្យកត់សម្គាល់នោះ គឺទេសន្តរប្រវេសន៍ពីជនបទទៅទីប្រជុំជនបានក្លាយជាចរន្តដ៏សំខាន់នាពេលបច្ចុប្បន្ន ហើយការធ្វើទេសន្តរប្រវេសន៍ទីប្រជុំជនទៅទីប្រជុំជនក៏មាននិន្នាការដូចគ្នាផងដែរ។ និន្នាការនេះផ្ទុយពីឆ្នាំ២០០៨ ដែលការធ្វើទេសន្តរប្រវេសន៍ ពីជនបទ ទៅជនបទ និងជនបទទៅតំបន់ទីប្រជុំជន ស្ថិតក្នុងលំដាប់ទី២។ ការធ្វើទេសន្តរប្រវេសន៍ នេះបង្ហាញពីការវិវត្តន៍យ៉ាងលឿននៃការធ្វើនគរូបនីយកម្មទីប្រជុំជន។

យោងទៅតាមជំរឿនឆ្នាំ២០១៩ ភាគច្រើននៃទេសន្តរប្រវេសន៍រស់នៅក្នុងមណ្ឌលជំរឿន យ៉ាងហោចណាស់ ១០ ឆ្នាំមុនជំរឿន (៤៥,៣ ភាគរយ)។ ភាគច្រើននៃទេសន្តរប្រវេសន៍បានធ្វើការផ្លាស់ប្តូរទីលំនៅរបស់ពួកគេពី ១-៤ ឆ្នាំ មុនពេលធ្វើជំរឿនមាន ២៨,១ ភាគរយ។

ប្រជាជនភាគច្រើនបានធ្វើទេសន្តរប្រវេសន៍ ក្នុងអំឡុងពេលចាប់ផ្តើមធ្វើការដំបូងដែលក្នុងអាយុចន្លោះពី ២០ ទៅ ៣៩ ឆ្នាំ។ យោងតាមលទ្ធផលជំរឿនឆ្នាំ២០១៩ ជាងពាក់កណ្តាលនៃទេសន្តរប្រវេសន៍បានស្ថិតក្នុងក្រុមអាយុនេះ (៤៨,៧ ភាគរយ) ដែលក្នុងនោះប្រុស(៤៩,៧ ភាគរយ) និងស្រី (៤៧,៨ ភាគរយ)។ ជាង៩០ ភាគរយនៃទេសន្តរប្រវេសន៍ មាន ៨៨,២ ភាគរយ ស្ថិតក្នុងក្រុមអាយុពី ១៥ ទៅ ៦៤ ឆ្នាំ ទាំងប្រុស ទាំងស្រី។

ភាគច្រើននៃទេសន្តរប្រវេសន៍មានមុខរបរពាណិជ្ជកម្មលក់ដុំ និងលក់រាយ ជួសជុលរថយន្ត និងទោចក្រយានយន្ត (១៧,២ ភាគរយ) ផលិតកម្ម (១៤,០ ភាគរយ) និងសេវាកម្មគាំទ្រ និងសកម្មភាពរដ្ឋបាល (៤,៥ ភាគរយ) ដែលជាសកម្មភាពសេដ្ឋកិច្ចសំខាន់នៅទីប្រជុំជន។

ជាទូទៅ ទេសន្តរប្រវេសន៍ភាគច្រើនមានកម្រិតសិក្សាអប់រំទាបជាងប្រជាជនដែលមិនបានធ្វើទេសន្តរប្រវេសន៍។ ក្នុងចំណោមប្រជាជនសរុបមាន ២៩,១ ភាគរយ បានបញ្ចប់ការសិក្សាបឋមដែលក្នុងចំណោមទេសន្តរប្រវេសន៍មានតែ ២៧,៦ ភាគរយ។ ២១,៨ ភាគរយនៃចំនួនប្រជាជនទូទៅបានបញ្ចប់កម្រិតសិក្សាមធ្យមសិក្សាបឋមភូមិ ហើយ ២៧,៥ ភាគរយ សម្រាប់ជនទេសន្តប្រវេសន៍។ ភាគរយអក្ខរភាពមានអត្រាខ្ពស់ក្នុងចំណោមអ្នកធ្វើទេសន្តរប្រវេសន៍ជាងអ្នកដែលមិនបានធ្វើទេសន្តរប្រវេសន៍។ អក្ខរភាពមិនមែនជាហេតុផលសំខាន់ដែលធ្វើឲ្យមានការធ្វើទេសន្តរប្រវេសន៍ឡើយ សំខាន់គឺដោយសារខ្វះការទទួលបានព័ត៌មានសម្រាប់ការធ្វើទេសន្តរប្រវេសន៍។

## ១១.៩. លទ្ធភាពបង្កើតកូន

លទ្ធភាពបង្កើតកូនជាចំនួនកូនកើតរស់ដែលស្ត្រីម្នាក់ៗមាន។ លទ្ធភាពបង្កើតកូនផ្សេងពីសមត្ថភាពបង្កើតកូនដែលកំណត់ដោយលក្ខណៈជីវសាស្ត្រអំពីសមត្ថភាពដែលស្ត្រីអាចមានកូន។ លទ្ធភាពបង្កើតកូនកំណត់ដោយកត្តាភូមិសាស្ត្រដែលត្រូវបានហៅថាអថេរមធ្យម (intermediate variables) (អាយុនៅពេលរៀបការ ការប្រើប្រាស់មធ្យោបាយពន្យាកំណើត រយៈពេលបំបៅដោះកូន) លទ្ធភាពបង្កើតកូនប៉ះពាល់ដោយកត្តាជាចម្បងច្រើនទៀត មានដូចជាកត្តាសង្គម វប្បធម៌ បរិស្ថាន សេដ្ឋកិច្ច និងសុខភាព។

អត្រាកំណើតដុលនៅកម្ពុជាឆ្នាំ២០១៩ មាន ៣៧,៧ កំណើតក្នុងប្រជាជន ១.០០០នាក់ និង ៥២ កំណើតរស់ក្នុងចំណោមស្ត្រីវ័យបន្តពូជ (១៥-៤៩ ឆ្នាំ) ១.០០០នាក់។ អត្រាលទ្ធភាពបង្កើតកូនសរុបនៅកម្ពុជា ឆ្នាំ២០១៩ មាន ២,៥ សម្រាប់ស្ត្រីម្នាក់ ហើយអត្រាលទ្ធភាពបង្កើតកូនសរុបនៅតំបន់ទីប្រជុំជន ២,២ ទាបជាងជនបទ ២,៨។

បច្ចុប្បន្ន ការធ្លាក់ចុះអត្រាលទ្ធភាពបង្កើតកូនគួរឲ្យកត់សម្គាល់នៅបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន បានកំពុងជួបប្រទះស្ថានភាពផ្ទុយគ្នានឹងប្រជាជនវ័យចាស់។ ដោយឡែកនៅកម្ពុជា កំណើនទារកនៅទសវត្សន៍ ឆ្នាំ១៩៨០ ១៩៩០ និង ២០០០ បានក្លាយជាចលករជម្រុញកំណើនកម្លាំងពលកម្មនាពេលបច្ចុប្បន្ន ដែលហៅថាឱកាស ឬភាគលាភប្រជាសាស្ត្រ។ ការបើកឱកាសនេះបានកើតឡើងបន្ទាប់ពីមានការធ្លាក់ចុះគួរឲ្យកត់សម្គាល់នៃលទ្ធភាពបង្កើតកូនក្នុងចំណោមប្រជាជន ហើយបានកើនឡើងនូវសមាមាត្រប្រជាជនអាយុស្ថិតក្នុងកម្លាំងពលកម្មដែលជាផ្នែកមួយនៃចំនួនប្រជាជនសរុបខុសពីធម្មតា។ ដោយសារការធ្លាក់ចុះនៃលទ្ធភាពបង្កើតកូននាបច្ចុប្បន្ន ក៏នៅមិនទាន់ស្ថិតក្នុងកម្រិតភាគរយនៃចំនួនប្រជាជនវ័យចាស់ខ្ពស់ឡើយ។ ដំណើរការកំណើនសេដ្ឋកិច្ច និងសង្គមត្រូវផ្សារភ្ជាប់នឹងការកើនឡើងសេដ្ឋកិច្ចខ្ពស់ ជាពិសេសប្រសិនបើការអភិវឌ្ឍបានផ្សារភ្ជាប់នឹងការវិនិយោគលើវិស័យសុខាភិបាល និងការអប់រំ។ នៅពេលរចនាសម្ព័នអាយុផ្លាស់ទៅក្នុងបរិបទដែលប្រជាជនវ័យចាស់កើនឡើងក្នុងកម្រិតមួយខ្ពស់នោះ ការទទួលឱកាស ឬភាគលាភប្រជាសាស្ត្រក៏នឹងត្រូវបានបិទបន្តិចម្តងៗផងដែរ ។

រាជរដ្ឋាភិបាល និងសង្គមទាំងមូលគួរតែទាញយកផលប្រយោជន៍ពីសមាសភាពអាយុ ដែលជាអំណោយផលសម្រាប់ការវិនិយោគដើម្បីទទួលបាននូវកំណើនសេដ្ឋកិច្ចខ្ពស់។ ភាគលាភប្រជាសាស្ត្រគួរតែងទទួលបានការចាប់អារម្មណ៍ ជាពិសេសក្នុងចំណោមអ្នករៀបចំផែនការ អ្នកគ្រប់គ្រង និងអ្នកនយោបាយក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ។

## ១១.១០. មរណភាព

មរណភាពសំដៅលើការស្លាប់ដែលកើតឡើងក្នុងចំណោមប្រជាជន។ ប្រូបាប៊ីលីតេនៃការស្លាប់ក្នុងរយៈពេលផ្តល់ឲ្យបានទទួលរងនូវកត្តាឥទ្ធិពលមួយចំនួន ដូចជាអាយុ ភេទ ការអប់រំ និងស្ថានភាពសេដ្ឋកិច្ច។ អត្រាមរណភាពឆ្លុះបញ្ចាំងយ៉ាងច្បាស់អំពីកម្រិតជីវភាពរស់នៅ និងសេវាសុខភាពរបស់ប្រជាជននៃប្រទេសមួយ។

អត្រាមរណភាពទារកផ្អែកតាមលទ្ធផលជំរឿនឆ្នាំ២០១៩ មាន ១៧,៦ នាក់ ក្នុងចំណោម ១.០០០ កំណើតរស់។ អត្រាមរណភាពនៅជនបទមាន ១៨,៥ នាក់ ខ្ពស់ជាងនៅតំបន់ទីប្រជុំជនមានតែ ១៥,៩ នាក់ ក្នុងចំណោម ១.០០០ កំណើតរស់។ អត្រាមរណភាពទារកបានថយចុះគួរឲ្យកត់សម្គាល់ បើប្រៀបធៀបនឹងឆ្នាំ២០០៨ ដោយអត្រានេះបានថយចុះពី ២៦ នាក់ ក្នុងចំណោម ១.០០០ កំណើតរស់នៅឆ្នាំ២០០៨។

ការថយចុះនៃអត្រាមរណភាពកុមារអាយុក្រោម ៥ ឆ្នាំ បានថយចុះស្មើរតែពាក់កណ្តាលនៅឆ្នាំ២០០៨ និង ២០១៩។ អត្រាមរណភាពកុមារអាយុក្រោម ៥ ឆ្នាំ ពិសេសអត្រាមរណភាពទារកនៅតែបន្តធ្លាក់ចុះ ដែលចំណុចដៅនៃ CSDGs សម្រាប់មរណភាពកុមារនឹងសម្រេចបានជោគជ័យ។ ផ្អែកតាមលទ្ធផលជំរឿនឆ្នាំ២០១៩ ផលធៀប ឬអត្រាមរណភាពមាតានៅកម្ពុជាមាន ១៤១ ក្នុងចំណោម ១០០.០០០ កំណើតរស់។ ដោយឡែកអាយុកំណើតសង្ឃឹម

រស់កើនដល់ ៧៥,៥ ឆ្នាំ សម្រាប់ប្រជាជនទូទៅ ប្រុស ៧៤,៣ ឆ្នាំ និងស្រី ៧៦,៨ ឆ្នាំ ដែលនេះជាមោទនភាពរបស់រាជរដ្ឋាភិបាល ដែលបានខិតខំកន្លងមក។

## ១១.១១. ពិការភាព

ជាលើកទីមួយហើយដែលសំណួរអំពីពិការក្នុងសកម្មភាពរស់នៅប្រចាំថ្ងៃ សម្រាប់មនុស្សអាយុ ៥ ឆ្នាំឡើង ត្រូវបានបញ្ចូលទៅក្នុងតារាងសំណួរជំរឿនទូទៅប្រជាជនព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ (បង្គោល ១៧ នៃតារាងសំណួរតាមគ្រួសារផ្នែក២)។ ក្នុងចំណោមប្រជាជនពិការទាំងអស់ ៦៨៩.៥៣២ នាក់ក្នុងនោះពិការខ្លះៗមាន ៧៤,៣ ភាគរយ ពិការខ្លាំងមាន ១៩,៤ ភាគរយ និងពិការមិនអាចធ្វើអ្វីបានសោះមាន ៦,៣ ភាគរយ ។

ជំរឿនឆ្នាំ២០១៩ អត្រាពិការភាពនៅកម្ពុជាកើនឡើងនៅគ្រប់កម្រិតនៃពិការ ពេលអាយុកើនឡើង (រូប ៩.២.១) អត្រាពិការកើនពី ១,២ ភាគរយ សម្រាប់ក្រុមអាយុ ៥-១៤ ឆ្នាំ ទៅ ២៥,៦ ភាគរយ សម្រាប់ក្រុមអាយុ ៦០ ឆ្នាំឡើង។ អត្រាជនពិការបានចាប់ផ្តើមកើនយ៉ាងខ្លាំងនៅក្នុងក្រុមអាយុវ័យកណ្តាលពី ១,៤ ភាគរយសម្រាប់ក្រុមអាយុ ១៥-៣៤ ឆ្នាំ ទៅ ៥,២ ភាគរយសម្រាប់អាយុ ៣៥-៥៩ ឆ្នាំ និងកើនឡើងដល់ ២៥,៦ ភាគរយ ក្នុងចំណោមប្រជាជនអាយុ ៦០ ឆ្នាំឡើង ។

ស្ថានភាពអាពាហ៍ពិពាហ៍ក្នុងចំណោមប្រជាជនមានពិការណាមួយ អាយុ ១៥ ឆ្នាំឡើង ភាគច្រើនបានរៀបការមានក្នុងអត្រា ៦៨,៦ ភាគរយ មេម៉ាយប្តីស្លាប់ ឬពោះម៉ាយប្រពន្ធស្លាប់មាន ១៧,៤ ភាគរយ មេម៉ាយ ឬពោះម៉ាយលែងលះមាន ៣,៩ ភាគរយ និងទំនាស់រស់នៅផ្សេងគ្នាមាន ០,២ ភាគរយ ។ ទោះយ៉ាងណាក៏ដោយមានស្ត្រីមេម៉ាយប្តីស្លាប់ លែងលះគ្នា និងទំនាស់រស់នៅផ្សេងគ្នាច្រើនជាងបុរសនៅគ្រប់កម្រិតតំបន់ ។

អត្រាប្រជាជនជាបុរសចេះភាសាខ្មែរខ្ពស់ជាងស្ត្រីទាំងក្នុងស្ថានភាពទូទៅ និងស្ថានភាពមានពិការណាមួយ ។ អត្រានៃប្រជាជនដែលមានពិការណាមួយ ដែលបានបញ្ចប់ថ្នាក់ពេញលេញមានលក្ខណៈទាបនៅឡើយ។ ប្រមាណជា ៥៥,៧ ភាគរយនៃប្រជាជនកម្ពុជា មានពិការណាមួយមិនបានបញ្ចប់ថ្នាក់បឋមសិក្សា ខណៈដែលមានសមាមាត្រតិចតួច (១,៤ ភាគរយ) នៃប្រជាជនអក្ខរភាពមិនធ្លាប់បានបញ្ចប់ថ្នាក់ណាមួយ។

ភាគរយនៃប្រជាជនមានពិការណាមួយមានការងារធ្វើមាន ៥២,៩ ភាគរយ ក្នុងនោះបុរសមាន ៦២,៧ ភាគរយ ដែលខ្ពស់ជាងស្ត្រីមានតែ ៤៥,៩ ភាគរយ។ លើសពីនេះ អត្រាសកម្មសេដ្ឋកិច្ចដុលនៃប្រជាជនទូទៅមាន ៦២,០ ភាគរយ ដែលខ្ពស់ជាងអត្រាសកម្មសេដ្ឋកិច្ចដុលនៃប្រជាជនដែលមានពិការណាមួយ។

## ១១.១២. លក្ខណៈផ្ទះសំបែង និងគ្រួសារ

ចំនួនខ្នងផ្ទះក្នុងប្រទេសកម្ពុជាបានកើនឡើងពី ១.៩៨៩.៨២៨ នៅឆ្នាំ១៩៩៨ ទៅ ២.៦៣៧.៦៥៤ នៅឆ្នាំ ២០០៨ និងដល់ ៣.១៨១.៣៧២ នៅឆ្នាំ២០១៩។ កំណើននេះ គិតជាភាគរយ មាន ៣២,៦ ភាគរយ ក្នុងទសវត្សរ៍ឆ្នាំ ១៩៩៨-២០០៨ ដោយឡែកជាងទសវត្សរ៍ចុងក្រោយនេះឆ្នាំ២០០៨-២០១៩ មាន ២០,៦ភាគរយ។ នៅប្រទេស

កម្ពុជាទាំងមូល សំណង់សម្រាប់ប្រើប្រាស់ជាលំនៅដ្ឋាន មាននិន្នាការធ្លាក់ចុះពី ៩៥,៨ ភាគរយ នៅឆ្នាំ២០០៨ មក ៩៣,២ ភាគរយ នៅឆ្នាំ២០១៩ ។

ផ្នែកទៅលើសម្ភារៈសំណង់ដំបូល និងជញ្ជាំងមាន ៩១,១ ភាគរយនៃលំនៅដ្ឋាន និងផ្នែកនៃអាគារ គឺជាប្រភេទអាគារអចិន្ត្រៃយ៍ជាប់បានយូរ។ ប្រមាណ ៧,៤ ភាគរយនៃអាគារគឺជាប្រភេទសំណង់ជាប់បានមធ្យម និង ១,៦ ភាគរយនៃអាគារគឺជាប្រភេទបណ្ដោះអាសន្ន។ នៅតំបន់ជនបទ ប្រមាណ ៩,៤ ភាគរយនៃរចនាសម្ព័នសំណង់លំនៅដ្ឋានប្រើសម្ភារៈជាប់ជាមធ្យម និង ២,០ ភាគរយនៃរចនាសម្ព័នសំណង់លំនៅដ្ឋានប្រើសម្ភារៈបណ្ដោះអាសន្ន។

## គ្រួសារប្រក្រតី ឬធម្មតា

នៅថ្នាក់ជាតិ គ្រួសារប្រក្រតី ឬធម្មតាមានសមាមាត្រកើនឡើង ២៦,១ ភាគរយ ជាងទសវត្សរ៍ចុងក្រោយនេះ (២០០៨-២០១៩) បើប្រៀបធៀបនឹងទសវត្សរ៍មុន ពីឆ្នាំ១៩៩៨-២០០៨ មាន ៣០,៣ ភាគរយ គឺបានធ្លាក់ចុះ។ ទំហំគ្រួសារគិតជាមធ្យមក្នុងមួយគ្រួសារបានថយចុះពី ៥,២ នាក់ នៅឆ្នាំ១៩៩៨ ដល់ ៤,៧ នាក់ នៅឆ្នាំ២០០៨ និងដល់ ៤,៣ នាក់ នៅឆ្នាំ២០១៩។ នៅទីប្រជុំជន ទំហំសមាជិកគ្រួសារបានថយចុះ ០,៥ នាក់ ក្នុងរយៈពេលជាងទសវត្សរ៍នេះដែលខ្ពស់ជាងពីការថយ ចុះនៅតំបន់ជនបទ (០,៤ នាក់)។ និន្នាការថយចុះនៃទំហំគ្រួសារនេះ អាចដោយសារតែការកើនឡើង ចំនួនគ្រួសារនៅក្នុងប្រទេសដែលមានការផ្លាស់ប្តូរពីប្រព័ន្ធគ្រួសាររស់នៅរួមគ្នា ទៅជាប្រភេទគ្រួសារមានឪពុកម្តាយ និងកូន។

ភាគរយនៃគ្រួសារមានស្ត្រីជាមេគ្រួសារពុំមានការប្រែប្រួលឡើយ ជាងពីទសវត្សរ៍នេះ បានស្ថិតនៅក្នុងរង្វង់ប្រមាណ ២៦ ភាគរយ។ ភាគច្រើនស្ត្រីជាមេគ្រួសារទាំងនោះ មានក្នុងក្រុមអាយុ ៣០ ដល់ ៥៩ឆ្នាំ។ ស្ត្រីដែលជាមេគ្រួសារនៅលំដាប់អាយុនេះបានថយចុះ ពីឆ្នាំ១៩៩៨ មាន ៦៨,០ ភាគរយ នៅឆ្នាំ២០០៨ មាន ៦៤,០ ភាគរយ និងនៅឆ្នាំ ២០១៩ មាន ៥៧,៧ ភាគរយ។ ជំរឿនឆ្នាំ២០១៩ បានបង្ហាញថាប្រមាណ ១០,២ ភាគរយនៃមេគ្រួសារជាពោះម៉ាយ លែងលះ ទំនាស់រស់នៅផ្សេងគ្នា ហើយមានប្រមាណ ៤,៣ ភាគរយ មិនដែលរៀបការ និងប្រមាណ ៨៥,៥ ភាគរយ រៀបការរួច។

សមាមាត្រគ្រួសារធម្មតានៅតំបន់ទីប្រជុំជនមាន ៩៨,០ ភាគរយ និងនៅជនបទមាន ៩៩,៤ ភាគរយ។ ជាទូទៅគ្រួសារភាគច្រើន (៦២,៦ ភាគរយ) កាន់កាប់លំនៅដ្ឋានមួយបន្ទប់តែប៉ុណ្ណោះ ហើយគ្រួសារដែលកាន់កាប់លំនៅដ្ឋានពីរបន្ទប់មាន ២៦,៣ ភាគរយ គ្រួសារកាន់កាប់លំនៅដ្ឋានមានបីបន្ទប់ ៧,០ ភាគរយ និងគ្រួសារកាន់កាប់លំនៅដ្ឋានមានបួនបន្ទប់ឡើងទៅ មាន ៤,១ ភាគរយ។

## ប្រភពទឹកស្អាតសម្រាប់ពិសា

ដូចនៅក្នុងជំរឿនឆ្នាំ២០០៨ ព័ត៌មានស្ដីពីសម្ភារៈ និងប្រដាប់ប្រដាប្រើប្រាស់ដែលគ្រួសារមានក៏ត្រូវប្រមូលក្នុងជំរឿនឆ្នាំ២០១៩ ដែរ។ មានប្រមាណ ៧៣,០ ភាគរយនៃគ្រួសារកម្ពុជាមានប្រភពទឹកស្អាតសម្រាប់ប្រើប្រាស់ នៅឆ្នាំ២០១៩។ ដោយឡែក សមាមាត្រនេះមាន ៤៧,០ ភាគរយ នៅឆ្នាំ២០០៨ និង ២១,០ ភាគរយ នៅឆ្នាំ១៩៩៨។ នៅ

តំបន់ទីប្រជុំជនមានភាគរយច្រើនជាងគេនៃគ្រួសារដែលមានប្រភពទឹកស្អាតសម្រាប់ទទួលទាន។ ម្យ៉ាងទៀត ប្រមាណ ៧៣,២ ភាគរយនៃគ្រួសារនៅទីប្រជុំជន មានប្រភពផ្គត់ផ្គង់ទឹកស្អាតសម្រាប់ទទួលទាននៅក្នុងបរិវេណគេហដ្ឋានរបស់ពួកគេ។ ដោយឡែក នៅជនបទមានតែ ៥៨,០ ភាគរយ ប៉ុណ្ណោះ ដែលមានប្រភពទឹកស្អាតសម្រាប់ទទួលទាននៅក្នុងគេហដ្ឋាន។ ដូច្នេះ វាជាបញ្ហាអាទិភាពខ្ពស់ ដើម្បីផ្តល់នូវប្រភពទឹកបរិភោគដែលមានសុវត្ថិភាពឲ្យបានទៅដល់គ្រប់មនុស្សទាំងអស់(នៅក្នុង ឬជិតបំផុតពីកន្លែងដែលពួកគេរស់នៅ)។

## ប្រភពបំភ្លឺ

អគ្គិសនី (រួមមានថាមពលអគ្គិសនី ម៉ាស៊ីនភ្លើង និងទាំងពីរប្រភេទ) ដែលត្រូវប្រើប្រាស់ធ្វើជាប្រភពបំភ្លឺមាន ៨៤,០ ភាគរយនៃគ្រួសារនៅកម្ពុជាឆ្នាំ២០១៩ បានកើនឡើងខ្ពស់ ប្រៀបធៀបនឹងឆ្នាំ២០០៨ និង ១៩៩៨ មាន ២៦,៤ និង ១៥,១ ភាគរយ តាមលំដាប់រៀង។ ប្រមាណ ៩៧,០ ភាគរយ នៃគ្រួសារនៅតំបន់ទីប្រជុំជនប្រើអគ្គិសនីសម្រាប់បំភ្លឺ ចំណែកឯគ្រួសារនៅជនបទមានប្រមាណ ៧៦,០ ភាគរយ។

## ការប្រើប្រាស់បង្គន់អនាម័យ

ប្រមាណ ៨២,៨ ភាគរយនៃគ្រួសារសរុបនៅក្នុងប្រទេសកម្ពុជាឆ្នាំ ២០១៩ មានការកែលម្អស្ថានភាពក្នុងការប្រើប្រាស់បង្គន់អនាម័យនៅតាមទីកន្លែងដែលគេរស់នៅ ចំណែកឯឆ្នាំ២០០៨ មាន ៣៣,៧ ភាគរយ និងឆ្នាំ១៩៩៨ មាន១៤,៥ ភាគរយប៉ុណ្ណោះ។ សម្រាប់នៅទីប្រជុំជនក្នុងឆ្នាំ ២០១៩ ការប្រើប្រាស់បង្គន់មាន ៩០,៤ ភាគរយនៃគ្រួសារ និង ៧៨,៣ ភាគរយ នៅជនបទ។ ចំណែកឯគ្រួសាររស់នៅតាមជនបទប្រមាណ ២៤,៨ ភាគរយនៃគ្រួសារមានបង្គន់អនាម័យប្រើបង្គន់ចាក់ទឹក ឬចុចបង្ហូរទឹក តភ្ជាប់ទៅប្រព័ន្ធលូ។ ប្រមាណ ៥០,៦ ភាគរយនៃគ្រួសារនៅជនបទប្រើបង្គន់ចាក់ទឹក ឬចុចបង្ហូរទឹក តភ្ជាប់ទៅអាងស្តុក ឬរណ្តៅ។

## ឥន្ធនៈចម្អិនអាហារ

ជំរឿនទាំងបី បានបង្ហាញថាការប្រើឧសសម្រាប់ចម្អិនអាហារ មានការធ្លាក់ចុះជាលំដាប់នៅថ្នាក់ជាតិ ក៏ដូចជានៅតំបន់ទីប្រជុំជន និងជនបទផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ឧសនៅតែជាថាមពលចម្បងសម្រាប់ប្រជាជនដែលរស់នៅតំបន់ជនបទមាន ៧៨,៨ ភាគរយ នៅឆ្នាំ២០១៩។

## ទ្រព្យសម្បត្តិរបស់គ្រួសារ

ព័ត៌មានអំពីប្រភេទ និងចំនួនសម្ភារៈ ប្រើប្រាស់ក្នុងគ្រួសារត្រូវបានប្រមូលក្នុងជំរឿនឆ្នាំ២០០៨ និងឆ្នាំ២០១៩។ ព័ត៌មាននេះផ្តល់នូវការប៉ាន់ស្មានសូចនាករនៃស្ថានភាពសេដ្ឋកិច្ចរបស់ប្រជាជន។ ជំរឿនឆ្នាំ២០១៩ បង្ហាញថាភាគរយនៃគ្រួសារដែលមានទូរទស្សន៍ប្រើមាន ៦៧,៥ ភាគរយ ទោចក្រយានយន្តមាន ៨០,១ ភាគរយ និងកង់មាន ៥៥,២ ភាគរយ។ ការប្រើប្រាស់អ៊ីនធឺណិតនៅផ្ទះមាន ៤៥,៤ ភាគរយ និង ២៨,២ ភាគរយនៃគ្រួសារប្រើប្រាស់អ៊ីនធឺណិតនៅក្រៅផ្ទះ។ ការកើនឡើងនៃភាពជាម្ចាស់របស់គ្រួសារលើកម្មសិទ្ធទ្រព្យសម្បត្តិដែលរៀបរាប់ខាងលើឆ្លុះបញ្ចាំងនូវការផ្លាស់ប្តូរជាវិជ្ជមាននូវជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា។

# សន្ទានុក្រម

### *អាគារ*

ជារចនាសម្ព័ន្ធទោលមួយដែលសង់លើដី។ ជួនកាលផ្ដុំឡើងដោយវត្ថុធាតុជាច្រើនហើយប្រើប្រាស់សម្រាប់ជាលំនៅដ្ឋានស្នាក់នៅ ឬសហគ្រាស ដូចជាហាងលក់ទំនិញ កន្លែងពាណិជ្ជកម្ម ការិយាល័យ រោងជាង រោងចក្រ សាលារៀន កន្លែងកំសាន្ត កន្លែងធ្វើការ ឃ្លាំង ។ល។ អាគារអាចប្រើប្រាស់ក្នុងគោលបំណងច្រើនប្រភេទ ដូចជាលំនៅដ្ឋានស្នាក់នៅផង និងហាងលក់ទំនិញ ឬអាចជារោងជាងផង ឬជាលំនៅដ្ឋានស្នាក់នៅផង និងកន្លែងធ្វើការផង។

### *ទីប្រជុំជន*

ការធ្វើចំណាត់ថ្នាក់តំបន់ទីប្រជុំជនឡើងវិញនៅកម្ពុជាឆ្នាំ២០២០ ត្រូវបានអនុវត្តដោយវិទ្យាស្ថានជាតិស្ថិតិក្នុងអំឡុងខែមិថុនា ដល់ខែកក្កដាឆ្នាំ២០២០ ដោយប្រើប្រាស់សំណុំទិន្នន័យចុងក្រោយនៃជំរឿនប្រជាជនទូទៅនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩។ ការសិក្សានេះបានត្រូវបានផ្ដល់អនុសាសន៍អំពីចំណាត់ថ្នាក់នៃទីប្រជុំជននេះ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យបីយ៉ាងគឺលើទំហំប្រជាជន ដង់ស៊ីតេប្រជាជន និងអ្នកធ្វើការក្នុងវិស័យមិនមែនកសិកម្មនៅកម្រិតឃុំ។ បន្ទាប់ពីបានគិតគ្រប់ជ្រុងជ្រោយយ៉ាងយកចិត្តទុកដាក់លើគ្រប់ទិដ្ឋភាពពាក់ព័ន្ធក្នុងការសិក្សា និងពិគ្រោះយោបល់ជាមួយអាជ្ញាធថ្នាក់ក្រោមជាតិ ផ្អែកលក្ខណៈវិនិច្ឆ័យដូចខាងក្រោមទៅលើឃុំនីមួយៗ ដើម្បីចាត់ថ្នាក់ជាទីប្រជុំជន ឬជនបទ ៖

#### ១. ទិដ្ឋភាពសេដ្ឋកិច្ច និងប្រជាសាស្ត្រ

- ទំហំប្រជាជនសរុបក្នុងឃុំចាប់ពី ២០០០ នាក់ឡើង
- ដង់ស៊ីតេប្រជាជនក្នុងឃុំចាប់ពី ២០០ នាក់ក្នុង ១ គីឡូម៉ែត្រការ៉េ
- អ្នកធ្វើការក្នុងវិស័យមិនមែនវិស័យកសិកម្មលើសពី ៥០ ភាគរយ

#### ២. ទិដ្ឋភាពលក្ខខណ្ឌរដ្ឋបាល

ទីប្រជុំជនដែលបានកំណត់ផ្អែកលើមូលដ្ឋាននៃរដ្ឋបាលតាមច្បាប់ ឬត្រូវបានទទួលស្គាល់ដោយអនុក្រឹត និងច្បាប់។ ប្រភេទទី ១ ជាទីប្រជុំជនត្រូវបានគេស្គាល់ថាជាទីប្រជុំជនដែលជាក្រុង។ ទីប្រជុំជនទាំងនេះត្រូវបានទទួលស្គាល់ដោយច្បាប់របស់រាជរដ្ឋាភិបាលដូចជារាជធានី និងក្រុងជាដើម ដោយមិនគិតពីទិដ្ឋភាពសេដ្ឋកិច្ច និងប្រជាសាស្ត្រឡើយ។

#### ៣. ទិដ្ឋភាពជាក់ស្តែង និងការពិគ្រោះយោបល់

បន្ទាប់ពីបានគិតគូគ្រប់ជ្រុងជ្រោយយ៉ាងយកចិត្តទុកដាក់ លើគ្រប់ទិដ្ឋភាពពាក់ព័ន្ធក្នុងការសិក្សាខាងលើ មន្ត្រីវិទ្យាស្ថានជាតិស្ថិតិបានចុះពិនិត្យស្ថានភាពជាក់ស្តែងលើបណ្តាឃុំដែលចាត់ចូលក្នុងលក្ខណៈវិនិច្ឆ័យ និងបានចូលរួមពិគ្រោះយោបល់ជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិ ជាពិសេសប្រធានមន្ទីរផែនការ និងមន្ត្រីបច្ចេកទេសពាក់ព័ន្ធមួយចំនួនជាពិសេសក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងមហាផ្ទៃ អង្គការ UNICEF អង្គការ UNFPA និង UNHABTAT ។

### *អត្រាកំណើនប្រចាំឆ្នាំបែប Exponential*

$$r_{EXP} = \ln\left(\frac{X_n}{X_0}\right) / n$$

$X_0$ = ចំនួនប្រជាជនឆ្នាំគោល
$X_n$ = ចំនួនប្រជាជនឆ្នាំចុងក្រោ
n = ចំនួនឆ្នាំរវាង $X_0$ and $X_n$

### *ដង់ស៊ីតេប្រជាជន*

ត្រូវបានគណនាដោយផលចែកនៃចំនួនប្រជាជន ទៅនឹងផ្ទៃដីសរុបនៅក្នុងតំបន់ជាក់លាក់មួយ។ ដង់ស៊ីតេប្រជាជន គឺជាសន្ទស្សន៍ដ៏សំខាន់មួយនៃសូចនាករប្រជាសាស្ត្រដែលត្រូវបានវាស់វែង សិក្សាពីការប្រមូលផ្តុំរបស់ប្រជាជន។ សន្ទស្សន៍នេះគិតពីចំនួនមនុស្សរស់ក្នុងបរិវេណដីក្នុងមួយគីឡូម៉ែត្រការ៉េ។

### *សន្ទស្សន៍ Myer*

សន្ទស្សន៍ Myer គឺជារង្វាស់ពិនិត្យលើអាយុ លេខខ្ទង់ចុងក្រោយ។ ការកត់ត្រា ឬរាយការណ៍អាយុជំនួសអ្នកដ៏ទៃត្រូវបានសំដៅទៅលើអាយុដែលជាចំណង់ចំណូលចិត្តនៃអាយុខ្ទង់ (ដូចជាអាយុ ដែលបញ្ចប់នៅលេខ ០ ឬ ៥)។ ទ្រឹស្តីសន្ទស្សន៍ Myer លាតសន្ធឹងពីអប្បបរមា "0" នៅពេលដែលមិនមានចំណូលចិត្ត និងចៀសវាងតួលេខជាក់លាក់ណាមួយដល់ចំនួនអតិបរមា "៩0" នៅពេលដែលមនុស្សគ្រប់រូបត្រូវបានគេរាយការណ៍នៅក្នុងខ្ទង់តែមួយ។

### *តម្លៃសន្ទស្សន៍សន្ទស្សន៍ Myer*

ទិន្នន័យមានភាពត្រឹមត្រូវខ្ពស់បើតូចជាង ១0,0
ទិន្នន័យត្រឹមត្រូវត្រឹមត្រូវ ១0,0 – ១៩,៩
ទិន្នន័យមានគុណភាពទាប ២0,00 – ៣៩,៩
ទិន្នន័យមិនអាចប្រើការបានបើធំជាង ៤0,0

### *សន្ទស្សន៍ Whipple*

ទិន្នន័យអាយុជាទូទៅមិនមានភាពត្រឹមត្រូវ ១00 ភាគរយនោះទេ ដោយសារហេតុផលជាច្រើនចាំបាច់ត្រូវវាយតម្លៃវាមុនពេលប្រើប្រាស់។ យោងតាមលទ្ធផលអង្កេតក្រោយជំរឿនមួយចំនួនភាពមិនស៊ីគ្នានៅកម្ពុជាមានកម្រិតទាប។ សន្ទស្សន៍ Whipple ត្រូវបានគណនាសម្រាប់ពិនិត្យគុណភាពទិន្នន័យអាយុ។ សន្ទស្សន៍របស់ Whipple គឺជារង្វាស់ចំណង់ចំណូលចិត្តសម្រាប់អាយុដែលបញ្ចប់នៅក្នុងលេខ 0 និង ៥។ ជួររបស់វាគឺចាប់ពី ១00 បង្ហាញថាគ្មានចំណូលចិត្ត លេខ 0 និង ៥ ដល់ ៥00 បង្ហាញថាមានតែ 0 និង ៥ ប៉ុណ្ណោះដែលត្រូវបានគេរាយការណ៍។

### *តម្លៃសន្ទស្សន៍ Whipple*

ទិន្នន័យមានភាពត្រឹមត្រូវខ្ពស់បើតូចជាង ១០៥
ទិន្នន័យត្រឹមត្រូវត្រឹមត្រូវ ១០៥ – ១០៩,៩
ទិន្នន័យប្រហាក់ប្រហែល ១១០ – ១២៤,៩
ទិន្នន័យមានគុណភាពទាប ១២៥ – ១៧៤,៩
ទិន្នន័យមិនអាចប្រើការបានបើធំជាង ១៧៥

### *សន្ទស្សន៍អាយុពិតប្រាកដតាម UN*

ជាការសរុប (i) ផលបូកនៃលំអៀងមធ្យមនៃអត្រាមនុស្សប្រុសពីចំនួន ១០០ (ii) លំអៀងមធ្យមនៃអត្រាអាយុស្រីពីចំនួន ១០០ (iii) បីដងនៃមធ្យមនៃការដកបន្តគ្នាក្នុងអត្រាអាយុទទួលបាន។ នៅក្នុងវិធីសាស្ត្រនេះអត្រាអាយុមាននិយមន័យតាមរូមន្ត ផលចែកប្រជាជននៅក្នុងក្រុមអាយុជាមួយពាក់កណ្តាលនៃផលបូកប្រជាជនក្នុងក្រុមអាយុមុន និងក្រុមអាយុបន្ទាប់។

### *អាយុ*

ជាចំនួនឆ្នាំពេញលេញនៃអាយុគិតដល់ថ្ងៃខួបកំណើតចុងក្រោយ។

### *ពីរ៉ាមីតប្រជាជន*

ពីរ៉ាមីតប្រជាជនបង្ហាញជាលក្ខណៈក្រាហ្វិកតាមក្រុមអាយុ និងភេទប្រជាជន។ ជួរផ្តេកបង្ហាញពីចំនួន ឬសមាមាត្រនៃបុរស និងស្ត្រីសម្រាប់ក្រុមអាយុនីមួយៗ ផលបូកនៃក្រុមអាយុ និងភេទទាំងអស់ ពីរ៉ាមីតប្រជាជនស្មើនឹង ១០០ ភាគរយ។

### *មេដ្យានអាយុ*

មុនពេលគណនាមេដ្យានអាយុ យើងត្រូវបែងចែកចំនួនប្រជាជនជាចំនួនពីរក្រុមដែលមានទំហំស្មើៗគ្នា (៥០ ភាគរយ ទល់នឹង ៥០ភាគរយ) គឺក្រុមដែលអាយុតិចជាង និងក្រុមមួយទៀតមានអាយុច្រើនជាងមេដ្យាន។

$$\text{មេដ្យាន} = L + \frac{(N/2-C)}{F_m} \times I$$

N = ចំនួនប្រជាជនសរុប
L = ដែនកំណត់ទាបនៃថ្នាក់មេដ្យាន
Fm = ចំនួននៃថ្នាក់មេដ្យាន (frequency of median class)
C = ប្រេកង់តគ្នានៃថ្នាក់មុនមេដ្យាន
I = ចន្លោះថ្នាក់

### *ផលធៀបភេទ ឬអត្រាភេទ*

ជាផលចែកនៃចំនួនបុរស និងចំនួនស្ត្រីគុណនឹង ១០០ បកស្រាយពីចំនួនបុរសក្នុងចំណើមស្ត្រី ១០០ នាក់។

### *ផលធៀបអាយុក្នុងបន្ទុក*

ជាភាគរយនៃប្រជាជនក្នុងក្រុមអាយុក្មេង (អាយុ ០-១៤ ឆ្នាំ) និងក្រុមអាយុចាស់ (៦០+) ឆ្នាំធៀបទៅនឹងចំនួនប្រជាជនដែលមានអាយុកម្លាំងពលកម្មពី ១៥-៥៩ ឆ្នាំ។ (ផលធៀបអាយុក្នុងបន្ទុកនេះអាចគណនាដាច់ដោយឡែកពីគ្នារវាងផលធៀបអាយុក្នុងបន្ទុកវ័យក្មេង និងអាយុក្នុងបន្ទុកវ័យចាស់)។

### *អាយុមធ្យមនៃការរៀបការ Singulate Mean Age at Marriage (SMAM)*

អាយុមធ្យមនៃការរៀបការលើកដំបូងត្រូវបានប្រើប្រាស់សម្រាប់ប្រជាជនដែលបានចាត់ថ្នាក់តាមអាយុ និងស្ថានភាពអាពាហ៍ពិពាហ៍ផ្តល់នូវទិន្នន័យតែមួយគត់ស្តីពីស្ថានភាពអាពាហ៍ពិពាហ៍។ វាប្រៀបធៀបសមាមាត្រអាយុជាក់លាក់របស់អ្នកដែលមិនដែលរៀបការជាមួយអ្នកដែលរៀបការហើយ គិតពីអាយុមធ្យមដែលការផ្លាស់ប្តូរត្រូវបានធ្វើឡើង។ សម្រាប់ព័ត៌មានលម្អិតនៃវិធីសាស្ត្រដែលបង្កើតឡើងដោយ John Hajnal ។

$$SMAM = \frac{d + \sum 5_5 S_x - 50 * S_{50}}{1 - S_{50}}$$

d = អាយុរៀបការទាបបំផុត = 15

$\sum 5_5 S_x$ = សរុបសមាមាត្រប្រជាជនមិនដែលរៀបការក្រុមអាយុ 5 ឆ្នាំ

$S_{50}$ = សមាមាត្រប្រជាជនមិនដែលរៀបការនៅអាយុ ៥០ ឆ្នាំ

### *អក្ខរភាព*

មនុស្សម្នាក់ដែលចេះអាន និងសរសេរប៉ុន្តែនៅពេលជំរឿនគាត់មិនអាចអាន និងសរសេរបានទៀតទេ ដោយសារតែមានបញ្ហារាងកាយ ឬជំងឺ ត្រូវបានចាត់ទុកថាជាមនុស្សចេះអក្សរផងដែរ។ មនុស្សត្រូវបានចាត់ទុកថាមិនចេះអក្សរផងដែរ បើមនុស្សនោះមានសមត្ថភាពអានសរសេរតែឈ្មោះ ឬលេខផ្ទាល់ខ្លួន ក៏ដូចជាមនុស្សដែលចេះអានតែមិនចេះសរសេរ ឬក៏ផ្ទុយទៅវិញ។

ជនពិការដែលអាចអាន និងសរសេរតាមរយៈមធ្យោបាយណាមួយ ដូចជាប្រព័ន្ធប្រៃលសម្រាប់អ្នកពិការភ្នែកត្រូវបានចាត់ទុកថាជាអ្នកចេះអក្សរ។ តាមនិយមន័យកុមារទាំងអស់ដែលមានអាយុតិចជាង ៦ ឆ្នាំទាំងអស់ត្រូវបានចាត់ទុកថាអនក្ខរភាព។ ឧទាហរណ៍ មនុស្សវ័យចំណាស់ដែលចេះអាន និងសរសេរ ប៉ុន្តែមិនអាចអនុវត្តសកម្មភាពទាំងនេះបានទៀតដោយសារបញ្ហាភ្នែកខ្សោយ។

*អត្រាអក្ខរភាពទូទៅ*

ជាភាគរយនៃប្រជាជនចេះអក្សរធៀបទៅនឹងចំនួនសរុបប្រជាជនទាំងអស់ ដោយមិនរាប់បញ្ចូលចំនួនក្មេងដែលមានអាយុ ០-៦ ឆ្នាំ។

*អត្រាអក្ខរភាពមនុស្សពេញវ័យ*

ជាភាគរយប្រជាជនអក្ខរភាពមានអាយុ ១៥ ឆ្នាំឡើង ធៀបនឹងចំនួនសរុបប្រជាជនអាយុ ១៥ ឆ្នាំឡើង។

*កម្រិតសិក្សាអប់រំ*

កម្រិតថ្នាក់ដែលបានបញ្ចប់ពេញលេញត្រូវបានធ្វើចំណាត់ដូចជា ១= មិនបានបញ្ចប់ថ្នាក់ណាមួយ (០ និង ៨៨) ២= មិនបានបញ្ចប់បឋមសិក្សា (ថ្នាក់ទី ១ ដល់ ៥) ៣= បានបញ្ចប់បឋមសិក្សា (ថ្នាក់ទី ៦ ដល់ ៨) ៤= មធ្យមសិក្សាបឋមភូមិ (ថ្នាក់ទី ៩ ដល់ ១៣) ៥= បានបញ្ចប់មធ្យមសិក្សា/មានសញ្ញាបត្រ (បានបញ្ចប់មធ្យមសិក្សា/មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិមានបច្ចេកទេស/វិជ្ជាជីវៈ សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិមានបច្ចេកទេស/វិជ្ជាជីវៈ ១៤ ដល់ ១៦) ៦= ក្រោយមធ្យមសិក្សា (សញ្ញាបត្រថ្នាក់មហាវិទ្យាល័យ សញ្ញាបត្រថ្នាក់អនុបណ្ឌិត និងសញ្ញាបត្រថ្នាក់បណ្ឌិត ១៧ ដល់ ១៩)។

*ប្រជាជនសកម្មសេដ្ឋកិច្ច*

ជាចំនួនប្រជាជនមានការងារធ្វើ និងប្រជាជនគ្មានការងារធ្វើ ដោយឈរលើមូលដ្ឋានសកម្មភាពសំខាន់ៗរបស់គាត់នៅក្នុងរយៈពេលមួយឆ្នាំមុនពេលជំរឿន។

*ប្រជាជនអសកម្មសេដ្ឋកិច្ច*

ប្រជាជនផ្សេងក្រៅពីប្រជាជនសកម្មសេដ្ឋកិច្ច នៅក្នុងរយៈពេលមួយឆ្នាំមុនជំរឿន។

*អត្រាចូលរួមកម្លាំងពលកម្ម*

អត្រាចូលរួមកម្លាំងពលកម្ម (LFPR) ត្រូវបានកំណត់ជាចំនួនមនុស្សដែលស្ថិតក្នុងកម្លាំងពលកម្ម នការងារមាធ្វើ និងគ្មានការងារធ្វើ តាមអាយុ ភេទ និងតំបន់ ចែកនឹងចំនួនមនុស្សសរុបក្នុងចរិតលក្ខណៈដូចគ្នា ហើយគុណនឹង ១០០។

*អត្រាសកម្មជនសេដ្ឋកិច្ចនៃក្រុមអាយុធ្វើការងារ*

ភាគរយប្រជាជនសកម្មសេដ្ឋកិច្ចធៀបទៅនឹងចំនួនសរុបប្រជាជនអាយុ ១៥-៥៩ ឆ្នាំ។

## *អត្រាសកម្មជនសេដ្ឋកិច្ចតាមអាយុ*

ជាភាគរយប្រជាជនដែលជាសកម្មជនសេដ្ឋកិច្ចក្នុងក្រុមអាយុណាមួយ ធៀបទៅនឹងចំនួនប្រជាជនសរុបនៅក្នុងក្រុមអាយុតាមអាយុជាក់លាក់។

## *មានការងារធ្វើ*

រួមមានប្រជាជនដែលដូចនៅក្នុងប្រភេទខាងក្រោមបានធ្វើក្នុងរយៈពេល ៦ ខែ (១៨៣ថ្ងៃ) ឬលើស ក្នុងរយៈពេលមួយឆ្នាំ មុនជំរឿន ៖

(i) ប្រជាជនដែលមានការងារមានប្រាក់ឈ្នួល(ឧទាហរណ៍ ធ្វើការងារនៅផ្នែកសាធារណៈ ឬអង្គភាពឯកជន ជាដើម) (ii) ប្រជាជនដែលនៅក្នុងពេលធ្វើជំរឿន កំពុងមានការងារធ្វើ និងបានធ្វើពីមុនមក ដោយទទួលប្រាក់ឈ្នួល ប្រាក់ខែ ប្រាក់ចំណេញ ឬទទួលបានពីគ្រួសារ ជាប្រាក់ ឬជារបស់។ (iii) ប្រជាជនដែលមិនមានការងារធ្វើ ដើម្បីទទួលប្រាក់ឈ្នួល ឬប្រាក់ចំណេញ នៅក្នុងអំឡុងពេលជំរឿន ទោះបីពួកគេមានការងារធ្វើពីមុន តែអាចត្រឡប់ទៅធ្វើការវិញ (ឧទាហរណ៍ ចប់រដូវ ដូចជាកសិករ ឬអ្នកនេសាទ) ប្រជាជនឈប់សម្រាកដោយមានជំងឺ ឬឈប់សម្រាកដោយគ្មានប្រាក់ ប្រជាជនមិនធ្វើការដោយសារមានបញ្ហាកូដកម្ម ឬអង្គភាពដែលពួកគេធ្វើការត្រូវបានបិទ (iv) ប្រជាជនធ្វើការដោយខ្លួនឯង (ឧទាហរណ៍ បើកហាងលក់ទំនិញដោយខ្លួនឯង លក់គ្រឿងហូបចុក ជាវេជ្ជបណ្ឌិត មេធាវី ជាដើម)។

## *អត្រាមានការងារធ្វើ*

អត្រាមានការងារធ្វើ ជាផលធៀបនៃចំនួនអ្នកមានការងារធ្វើក្នុងចំណោមកម្លាំងពលកម្ម (សកម្មជនសេដ្ឋកិច្ច) សម្រាប់ ១០០នាក់។

## *គ្មានការងារធ្វើ*

ជាមនុស្សដែលគ្មានការងារ ប៉ុន្តែបានស្វែងរកការងារ ឬត្រៀមធ្វើការងារបានរយៈពេល ៦ ខែ ឬលើស (១៨៣ថ្ងៃ) នៅក្នុងអំឡុងពេលមួយឆ្នាំ មុនពេលជំរឿន។

## *អត្រាគ្មានការងារធ្វើ*

អត្រាគ្មានការងារធ្វើ ជាផលធៀបនៃចំនួនអ្នកគ្មានការងារធ្វើ (បានធ្វើការពីមុនបូកមិនដែលធ្វើការសោះ) ក្នុងចំណោមកម្លាំងពលកម្ម (សកម្មជនសេដ្ឋកិច្ច) សម្រាប់ ១០០នាក់។

## *អាជីពការងារ ឬ វិស័យឧស្សាហកម្ម សេដ្ឋកិច្ច*

- ជំរឿនប្រជាជន សំដៅដល់ការរាប់ចំនួនប្រជាជនទាំងប្រុស ទាំងស្រី ទាំងក្មេង ទាំងចាស់ និងទាំងជនជាតិខ្មែរ ទាំងជនបរទេស លើកលែងតែមន្ត្រីអង្គទូតនិងក្រុមជនដូចគ្នានឹងអង្គទូត ដែលកំពុងរស់នៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។
- ប្រជាជន សំដៅដល់មនុស្សដែលរស់នៅក្នុងប្រទេសណាមួយឬលក្ខណៈសម្គាល់ ប្រជាសាស្ត្រ សង្គម ឬសេដ្ឋកិច្ច (ភេទ អាយុ ប្រភេទកន្លែងរស់នៅ។ល។)
- ប្រជាសាស្ត្រ សំដៅដល់ការសិក្សាស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រអំពីប្រជាជន រួមមានទំហំ សមាសភាព របាយដង់ស៊ីតេ កំណើន និងលក្ខណៈសម្គាល់ផ្សេងៗទៀតរបស់ប្រជាជន ព្រមទាំងហេតុនិងផលវិបាកនៃការប្រែប្រួលកត្តាទាំងនេះ។

## ជំពូកទី២

## កាលបរិច្ឆេទ

**មាត្រា៥ .-**

កំណត់កាលបរិច្ឆេទសម្រាប់ដំណើរការជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា នៅម៉ោងសូន្យ ថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៩។

## ជំពូកទី៣

## យន្តការនិងនីតិវិធី

**មាត្រា៦ .-**

ត្រូវបានបង្កើតគណៈកម្មាធិការជាតិជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១- រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ប្រធាន |
| ២- រដ្ឋមន្ត្រីក្រសួងផែនការ | អនុប្រធាន |
| ៣- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ១រូប | សមាជិក |

៤- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប សមាជិក
៥- រដ្ឋលេខាធិការក្រសួងការពារជាតិ ១រូប សមាជិក
៦- រដ្ឋលេខាធិការក្រសួងផែនការ ១រូប សមាជិក
៧- រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ១រូប សមាជិក
៨- រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ១រូប សមាជិក
៩- រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ១រូប សមាជិក
១០- រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ ១រូប សមាជិក
១១- រដ្ឋលេខាធិការក្រសួងសុខាភិបាល ១រូប សមាជិក
១២- រដ្ឋលេខាធិការក្រសួងព័ត៌មាន ១រូប សមាជិក
១៣- រដ្ឋលេខាធិការក្រសួងកិច្ចការនារី ១រូប សមាជិក
១៤- រដ្ឋលេខាធិការក្រសួងឧស្សាហកម្មនិងសិប្បកម្ម ១រូប សមាជិក
១៥- រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល ១រូប សមាជិក
១៦- រដ្ឋលេខាធិការក្រសួងទេសចរណ៍ ១រូប សមាជិក
១៧- រដ្ឋលេខាធិការក្រសួងបរិស្ថាន ១រូប សមាជិក
១៨- អនុរដ្ឋលេខាធិការក្រសួងផែនការ ១រូប សមាជិក
១៩- អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ លេខាធិការ។

សមាសភាពជាក់ស្តែងនៃគណៈកម្មាធិការជាតិជំរឿនទូទៅប្រជាជនត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៧ ៈ**

គណៈកម្មាធិការជាតិជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ មានភារកិច្ចៈ

- ណែនាំនិងអនុម័តរាល់កិច្ចការទូទៅដែលពាក់ព័ន្ធនឹងជំរឿនទូទៅប្រជាជន
- រៀបចំនិងបង្កើតគណៈកម្មការបច្ចេកទេសជំរឿនទូទៅប្រជាជននិងគណៈកម្មការឃោសនាជំរឿនទូទៅប្រជាជន មានទីស្នាក់ការនៅក្រសួងផែនការនិងស្ថិតក្រោមការដឹកនាំរបស់រដ្ឋមន្ត្រីក្រសួងផែនការ សម្រាប់អនុវត្តផ្ទាល់រាល់ការងារបច្ចេកទេសជំរឿនទូទៅប្រជាជន
- រៀបចំនិងបង្កើតគណៈកម្មាធិការជំរឿនទូទៅប្រជាជនគ្រប់រាជធានីខេត្ត
- តែងតាំងមន្ត្រីឲ្យចូលរួមជំរឿនទូទៅប្រជាជន តាមការស្នើសុំពីគណៈកម្មការបច្ចេកទេសជំរឿនទូទៅប្រជាជន
- ប្រជុំការងារតាមរបបប្រជុំត្រីមាស តាមការអញ្ជើញរបស់ប្រធានគណៈកម្មាធិការឬអនុប្រធានគណៈកម្មាធិការ នៅពេលដែលប្រធានគណៈកម្មាធិការអវត្តមាន
- ត្រូវធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាលពីការប្រព្រឹត្តទៅនិងលទ្ធផលនៃជំរឿនទូទៅប្រជាជន។

**មាត្រា៨ ៈ**

គណៈកម្មាធិការជាតិជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ។

គណៈកម្មការបច្ចេកទេសជំរឿនទូទៅប្រជាជននិងគណៈកម្មការឃោសនាជំរឿនទូទៅប្រជាជន មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងផែនការ។

គណៈកម្មាធិការជំរឿនទូទៅប្រជាជនគ្រប់រាជធានីខេត្ត មានសិទ្ធិប្រើប្រាស់ត្រារបស់រាជធានី ខេត្ត។

**មាត្រា៩ ៈ**

ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ ត្រូវមានដំណាក់កាលដូចតទៅៈ

១- កិច្ចប្រតិបត្តិការដំបូងនៃការជំរឿនមានៈ
- ការរៀបចំផែនទី
- ការរាប់និងចុះបញ្ជីលំនៅឋាន
- ការធ្វើអង្កេតនិងជំរឿនសាកល្បង
២- ការធ្វើសម្ភាសន៍សម្រាប់ជំរឿន
៣- កិច្ចប្រតិបត្តិការចុងក្រោយនៃជំរឿនមានៈ
- ការធ្វើអង្កេតសម្រាប់វាយតម្លៃលើជំរឿនដែលបានធ្វើហើយ
- ការធ្វើអង្កេតផ្សេងទៀត ក្នុងករណីចាំបាច់។

**មាត្រា១០ .-**

អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ជាអគ្គនាយកជំរឿន ត្រូវមានមន្ត្រីបច្ចេកទេស មន្ត្រីរដ្ឋបាលនៃវិទ្យាស្ថានជាតិស្ថិតិនិងមន្ទីរផែនការរាជធានីខេត្ត ជួយរាល់ការងារក្នុងដំណើរការជំរឿន។

**មាត្រា១១ .-**

មន្ត្រីបំពេញការងារជំរឿនរួមមាន អ្នកសម្ភាសស្រង់យកព័ត៌មាន អ្នកត្រួតពិនិត្យ និងភ្នាក់ងារជំនួយការដល់កិច្ចសហប្រតិបត្តិការជំរឿន ត្រូវតែងតាំងដោយរដ្ឋមន្ត្រីក្រសួងផែនការ តាមការស្នើសុំរបស់អគ្គនាយកជំរឿន។ ការចាត់ចែងនេះ អនុវត្តបានតែក្នុងកំលុងពេលជំរឿនតែប៉ុណ្ណោះ។

**មាត្រា១២ .-**

រដ្ឋមន្ត្រីក្រសួងផែនការ មានសិទ្ធិស្នើសុំមន្ត្រីពីបណ្តាក្រសួងស្ថាប័នសាធារណៈ និងជនសាមញ្ញដើម្បីសហការជួយធ្វើកិច្ចការជំរឿនទូទៅប្រជាជន។

**មាត្រា១៣ .-**

ត្រូវធ្វើជំរឿនជនគ្រប់រូប ដែលស្ថិតនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា វៀរលែងតែសមាជិកអង្គទូតបរទេសនិងក្រុមជនដូចគ្នានឹងអង្គទូតដែរ តាមកិច្ចព្រមព្រៀងដែលត្រូវកំណត់ឡើងជាមួយនឹងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ។

**មាត្រា១៤ .-**

ម្ចាស់លំនៅឋានគ្រប់ប្រភេទនិងអ្នកគ្រប់គ្រងទីកន្លែងនានា ត្រូវអនុញ្ញាតឲ្យមន្ត្រីបំពេញការងារជំរឿនបានចូលលំនៅឋានឬទីកន្លែងរបស់ខ្លួន ក្នុងគោលដៅនៃជំរឿន និងអនុញ្ញាតឲ្យមន្ត្រីទាំងនោះបានលាបពណ៌ បិទអក្សរ បិទសញ្ញា ឬលេខសម្គាល់នៅតាមកន្លែងចាំបាច់សម្រាប់បម្រើដល់ការងារជំរឿនទូទៅប្រជាជន។

**មាត្រា១៥ .-**

រដ្ឋមន្ត្រីក្រសួងផែនការអាចប្រកាសតែងតាំងអ្នកគ្រប់គ្រង តាមទីកន្លែងដែលមានលក្ខណៈពិសេសធ្វើសម្ភាសន៍អ្នកនៅក្នុងរង្វង់គ្រប់គ្រងរបស់ខ្លួន។

អ្នកគ្រប់គ្រងតាមទីកន្លែងពិសេសទាំងនោះមានៈ

ក- មេបញ្ជាការយោធា នគរបាល ដែលគ្រប់គ្រងនៅតាមអង្គភាពប្រមូលផ្តុំ។

ខ- នាយនាវាដែលគ្រប់គ្រងនៅតាមនាវារបស់ខ្លួន។

គ- នាយកមន្ទីរពេទ្យសាធារណៈនិងឯកជន ប្រធានពន្ធនាគារ ប្រធានមណ្ឌលអប់រំកែប្រែ នាយកមជ្ឈមណ្ឌលសង្គ្រោះ នាយកគ្រឹះស្ថានសិក្សា ដែលមានមនុស្សរស់នៅប្រមូលផ្តុំ ហើយនិងចៅអធិការវត្ត អ្នកគ្រប់គ្រងវិហារសាសនានានា។

ឃ- អ្នកគ្រប់គ្រងសណ្ឋាគារ អ្នកគ្រប់គ្រងផ្ទះសំណាក់ នាយកមជ្ឈមណ្ឌលសម្រាកកាយ។

ង- អ្នកចាត់ការខ្សែរថភ្លើង អ្នកចាត់ការក្នុងគ្រឹះស្ថានពាណិជ្ជកម្ម អ្នកចាត់ការក្នុងគ្រឹះស្ថានឧស្សាហកម្ម។

**មាត្រា១៦ ..**

មន្ត្រីដែលគ្មានកាតព្វកិច្ចទទួលខុសត្រូវក្នុងដំណើរការជំរឿន មិនមានសិទ្ធិត្រួតពិនិត្យរាល់សៀវភៅបញ្ជីឬសំណៅកត់ត្រាដែលបានធ្វើឡើងដោយមន្ត្រីបំពេញការងារជំរឿនបានឡើយ។

## ជំពូកទី៤
## ប្រភពធនធាន

**មាត្រា១៧ ..**

ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ មានប្រភពធនធានដូចតទៅៈ

- ថវិកាជាតិ
- ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍ
- អំណោយពីសប្បុរសជននានា
- ប្រភពធនធានស្របច្បាប់ផ្សេងៗ។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា១៨ ..**

អនុក្រឹត្យលេខ០៨ អនក្រ.បក ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៦ ស្តីពីការកំណត់កាលបរិច្ឆេទ ការរៀបចំ និងការប្រព្រឹត្តទៅនៃការធ្វើជំរឿនទូទៅទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជា ឆ្នាំ២០០៨ និងអនុក្រឹត្យលេខ៩៩ អនក្រ.បក ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការកំណត់កាលបរិច្ឆេទ ការរៀបចំ និង ការប្រព្រឹត្តទៅនៃការធ្វើជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៨ ព្រមទាំងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៩ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**

**ឆាយ ថន**

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិជំរឿន**
**ទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា**
**លេខ:** ៥២២៥ ស.ស.រ

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ២០១៧

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការបច្ចេកទេសជំរឿនទូទៅប្រជាជន នៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩

## គណៈកម្មាធិការជាតិជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៨ ចុះថ្ងៃទី២៤ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីស្ថិតិ
- បានឃើញអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០១០ ស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៧១ អនក្រ.បក ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកំណត់កាលបរិច្ឆេទ ការរៀបចំ និងការប្រព្រឹត្តទៅនៃជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩
- យោងតាមការសំណូមពរចាំបាច់ក្នុងការជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា

## សម្រេច

**ប្រការ១៖**

បង្កើតគណៈកម្មការបច្ចេកទេសជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ ដែលមានសមាសភាព៖

| | |
|---|---|
| ១- ឯកឧត្តម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ | ប្រធាន |
| ២- ឯកឧត្តម រដ្ឋលេខាធិការ ក្រសួងផែនការ | អនុប្រធាន |
| ៣- ឯកឧត្តម អនុរដ្ឋលេខាធិការ ក្រសួងផែនការ | សមាជិក |
| ៤- ឯកឧត្តម អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានប្រជាជន និងអភិវឌ្ឍ | សមាជិក |
| ៥- លោកជំទាវប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ | សមាជិកអចិន្ត្រៃយ៍ |
| ៦- ឯកឧត្តមអគ្គនាយកនៃអគ្គនាយកដ្ឋានសុរិយោដី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៧- លោកអគ្គនាយករង អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ | សមាជិក |
| ៨- ឯកឧត្តម នាយកខុទ្ទកាល័យ ក្រសួងផែនការ | សមាជិក |
| ៩- លោកអគ្គនាយករងវិទ្យាស្ថានជាតិស្ថិតិ ទទួលបន្ទុកការងារជំរឿន | លេខា |

**ប្រការ២៖**

គណៈកម្មការបច្ចេកទេសជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ មានភារកិច្ច៖

ក. រៀបចំ និងអនុវត្តរាល់កាលបរិច្ឆេទសម្រាប់ការរៀបចំកិច្ចការ និងការអនុវត្តខ្លឹមសាររបស់ការងារក្នុងជំហាននិមួយៗ របស់ជំរឿនទូទៅប្រជាជន។

ខ. រៀបចំ រាល់សំណុំឯកសារ សម្ភារៈ បរិក្ខា សម្រាប់កិច្ចការជំរឿនទូទៅប្រជាជន។

គ. រៀបចំ និងអនុវត្ត កម្មវិធីបណ្តុះបណ្តាលមន្ត្រី សម្រាប់ការងារជំរឿនទូទៅប្រជាជន។

ឃ. ដោះស្រាយរាល់ការងារបច្ចេកទេស ដែលកើតមានឡើងនៅពេលរៀបចំធ្វើជំរឿន ក្នុងពេលធ្វើជំរឿន និងក្រោយពេលធ្វើជំរឿន។

**ប្រការ៣៖**

គណៈកម្មការបច្ចេកទេសជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ មានទីប្រឹក្សាបច្ចេកទេស ជាច្រើនរូប ពីអង្គការ UNFPA និងដៃគូអភិវឌ្ឍន៍ផ្សេងទៀត ជួយផ្នែកបច្ចេកទេសនានានៃការធ្វើជំរឿន។

**ប្រការ៤៖**

គណៈកម្មការបច្ចេកទេសជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ មានសិទ្ធិបង្កើតក្រុមជំនាញការងារ តបតាមតម្រូវការជាក់ស្តែង ក្នុងការធ្វើជំរឿនទូទៅប្រជាជន។

**ប្រការ ៥៖**

ក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន គណៈកម្មការបច្ចេកទេសជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រ កម្ពុជា ឆ្នាំ២០១៩ មានសិទ្ធិប្រើប្រាស់ត្រា របស់ក្រសួងផែនការ។

**ប្រការ ៦៖**

គណៈកម្មការបច្ចេកទេសជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ ត្រូវមានរបាយការណ៍ជាទៀងទាត់ប្រចាំត្រីមាស មកគណៈកម្មាធិការជាតិជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា អំពីលទ្ធផល ការងារដែលបានអនុវត្តកន្លងមក។

**ប្រការ ៧៖**

ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលមានរៀបរាប់ក្នុងប្រការ ១ ព្រមទាំងក្រសួងស្ថាប័នពាក់ព័ន្ធ នានា មាន ភារកិច្ចអនុវត្ត ប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**ប្រធានគណៈកម្មាធិការជាតិ**
**ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩**

**សម្តេចក្រឡាហោម ស ខេង**

**ចម្លងជូន:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងផែនការ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដៃគូអភិវឌ្ឍន៍
  "ដើម្បីជូនជ្រាប"
- ដូចប្រការ៧
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិជំរឿន**
**ទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា**
**លេខ:** ០៥៩ សលស/គជសក

ថ្ងៃ អង្គារ ៨កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០១៨

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការឃោសនាជំរឿនទូទៅប្រជាជន នៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩

## គណៈកម្មាធិការជាតិជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៨ ចុះថ្ងៃទី២៤ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីស្ថិតិ
- បានឃើញអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០១០ ស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៧១ អនក្រ.បក ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកំណត់កាលបរិច្ឆេទ ការរៀបចំ និងការប្រព្រឹត្តទៅនៃជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩
- យោងតាមការសំណូមពរចាំបាច់ក្នុងការជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា

## សម្រេច

**ប្រការ១._**

បង្កើតគណៈកម្មការឃោសនាជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាព៖

| | | |
|---|---|---|
| ១- | រដ្ឋមន្ត្រីក្រសួងផែនការ | ប្រធាន |
| ២- | រដ្ឋលេខាធិការក្រសួងផែនការ | អនុប្រធាន |
| ៣- | រដ្ឋលេខាធិការក្រសួងព័ត៌មាន | អនុប្រធាន |
| ៤- | អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ | អនុប្រធានអចិន្ត្រៃយ៍ |
| ៥- | អគ្គនាយកវិទ្យុ | សមាជិក |
| ៦- | អគ្គនាយកទូរទស្សន៍ | សមាជិក |
| ៧- | តំណាងក្រសួងមហាផ្ទៃ | សមាជិក |
| ៨- | តំណាងក្រសួងអប់រំយុវជននិងកីឡា | សមាជិក |
| ៩- | តំណាងក្រសួងសុខាភិបាល | សមាជិក |
| ១០- | តំណាងក្រសួងធម្មការនិងសាសនា | សមាជិក |
| ១១- | តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១២- | តំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១៣- | ប្រធានសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា | សមាជិក |
| ១៤- | តំណាងក្រុមហ៊ុនទូរស័ព្ទចល័តវីតែល | សមាជិក |
| ១៥- | តំណាងទីភ្នាក់ងារសារព័ត៌មានខ្មែរ | សមាជិក |
| ១៦- | តំណាងក្រុមហ៊ុនទូរស័ព្ទចល័តម៉ូប៊ីថែល | សមាជិក |
| ១៧- | តំណាងក្រុមហ៊ុនទូរស័ព្ទចល័តស្មាត | សមាជិក |
| ១៨- | អគ្គនាយករងវិទ្យាស្ថានជាតិស្ថិតិ | លេខាធិការ |

**ប្រការ២._**

គណៈកម្មការឃោសនាជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ មានភារកិច្ច៖

ក. រៀបចំ និងអនុវត្តរាល់ការបរិច្ឆេទ សម្រាប់ការរៀបចំ និងការអនុវត្តខ្លឹមសារ របស់ការងារឃោសនាផ្សព្វផ្សាយតាមជំហានការងារនីមួយៗសម្រាប់ការជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩

ខ. រៀបចំរាល់សំណុំឯកសារ សំភារៈ ថវិកា សម្រាប់ការឃោសនាជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា

គ. ដឹកនាំឃោសនា ផ្សព្វផ្សាយពីការងារជំរឿនទូទៅប្រជាជន ឲ្យបានទូលំទូលាយក្នុងទូទាំងប្រទេស។

**ប្រការ៣._**

ប្រធានគណៈកម្មការឃោសនាជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩មានសិទ្ធិបង្កើតក្រុមការងារជំនាញនានាតាមតម្រូវការជាក់ស្តែងក្នុងការផ្សព្វផ្សាយជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤._**

ក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន គណៈកម្មការឃោសនាជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាមានសិទ្ធប្រើប្រាស់ត្រារបស់ក្រសួងផែនការ។

**ប្រការ៥._**

គណៈកម្មការឃោសនាជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ត្រូវធ្វើរបាយការណ៍មកគណៈកម្មាធិការជាតិជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ពីលទ្ធផលការងារដែលសម្រេចបាន។

**ប្រការ៦._**

រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីនៃក្រសួង ស្ថាប័នពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងប្រការ១ត្រូវអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។ ៧ ៨

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**ប្រធានគណៈកម្មាធិការជាតិ**
**ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩**

**សម្តេចក្រឡាហោម ស ខេង**

**ចម្លងជូន:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងផែនការ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដៃគូអភិវឌ្ឍន៍
  "ដើម្បីជូនជ្រាប"
- ដូចប្រការ៦
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

សំងាត់បំផុត

**តារាង ក**

# រាជរដ្ឋាភិបាលកម្ពុជា

## ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ខែមីនា ឆ្នាំ២០១៩

ទំព័រលេខ.........................................................

ចំនួនទំព័រសរុបដែលបានប្រើសម្រាប់មណ្ឌលនេះEA..........

### ព័ត៌មានសំគាល់

| ឈ្មោះ | រាជធានី/ខេត្ត | | ក្រុង/ស្រុក/ខណ្ឌ | | ឃុំ/សង្កាត់ | | ភូមិ | | មណ្ឌលជំរឿនលេខ | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | |
| លេខកូដ | | | | | | | | | | |

### ព័ត៌មានអគារ/សំណង់ និងគ្រួសារ

| លេខបន្ទាត់ | អគារ/សំណង់លេខ | សម្ភារៈសំខាន់ក្នុងការសាងសង់អគារ/សំណង់ * ជញ្ជាំង | ដំបូល | កំរាល | គោលដៅក្នុងការប្រើប្រាស់អគារ/សំណង់<br>1. លំនៅដ្ឋាន<br>2. លំនៅដ្ឋាន & ហាងលក់ទំនិញ<br>3. លំនៅដ្ឋាន & រោងជាង<br>4. លំនៅដ្ឋាន & គ្រឹះស្ថានណាមួយ<br>5. គ្រួសារស្ថាប័ន | គ្រួសារលេខ | ព័ត៌មានអំពីលក្ខណៈនៃមេគ្រួសារ ឈ្មោះ | ភេទ<br>1. ប្រុស<br>2. ស្រី<br>(ចុះលេខកូដ) | ចំនួនមនុស្សដែលរស់នៅជាប្រចាំក្នុងគ្រួសារ ប្រុស | ស្រី | សរុប | សេចក្ដីផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 |
| 1 | | | | | | | | | | | | |
| 2 | | | | | | | | | | | | |
| 3 | | | | | | | | | | | | |
| 4 | | | | | | | | | | | | |
| 5 | | | | | | | | | | | | |
| 6 | | | | | | | | | | | | |
| 7 | | | | | | | | | | | | |
| 8 | | | | | | | | | | | | |
| 9 | | | | | | | | | | | | |
| 0 | | | | | | | | | | | | |
| | | (**រាប់ចំនួនដែលកត់ចូលនិងរកចំនួនសរុប) | | | **សរុប | | សរុប | | | | | |

*កំណត់សំគាល់លេខកូដ

| បង្គោល 3. សម្ភារៈធ្វើជញ្ជាំង | បង្គោល 4. សម្ភារៈធ្វើដំបូល | បង្គោល 5. សម្ភារៈធ្វើកំរាល |
|---|---|---|
| 1. ឬស្សី / ស្លឹក / ស្បូវ / ស្មៅ / ក្រែង ប្របុស | 1. ឬស្សី / ស្លឹក / ស្បូវ / ស្មៅ | 1. ដី / ដីឥដ្ឋ |
| 2. ដី | 2. ក្បឿង | 2. ក្ដារឈើ/រនាបឫស្សី |
| 3. ក្ដារឈើ/ក្ដារបន្ទះ | 3. ក្ដារឈើ/ក្ដារបន្ទះ | 3. បេតុង / ឥដ្ឋ / ថ្ម |
| 4. បេតុង / ឥដ្ឋ / ថ្ម | 4. បេតុង / ឥដ្ឋ / ថ្ម | 4. ថ្មផុស |
| 5. ស័ង្កសី / អាលុយមីញ៉ូម / បន្ទះលោហៈធាតុផ្សេងៗ | 5. ស័ង្កសី /អាលុយមីញ៉ូម /បន្ទះលោហៈធាតុផ្សេងៗ | 5. ក្ដារខាត់ |
| 6. ហ្វីប្រូស៊ីម៉ង់ត៍ | 6. ហ្វីប្រូស៊ីម៉ង់ត៍ | 6. ឥដ្ឋ ក្បាច់/ឥដ្ឋការូ |
| 7. សម្ភារៈប្រើប្រាស់ហើយ / ជំនួស បន្ថែម បិទបាំង | 7. បន្ទះប្លាស្ទិក/បន្ទះជ័រ | 7. ផ្សេងទៀត (សូមបញ្ជាក់) |
| 8. ផ្សេងទៀត (សូមបញ្ជាក់) | 8. ផ្សេងទៀត (សូមបញ្ជាក់) | |

ឈ្មោះអ្នកសម្ភាសន៍ ..........................................

ហត្ថលេខា ____ ថ្ងៃ ___ / ខែ ___ / ឆ្នាំ ___

ឈ្មោះអ្នកត្រួតពិនិត្យ ..........................................

ហត្ថលេខា ____ ថ្ងៃ ___ / ខែ ___ / ឆ្នាំ ___

ព័ត៌មានសំគាល់

# ព្រះរាជាណាចក្រកម្ពុជា (?) រាជរដ្ឋាភិបាលកម្ពុជា

## ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ខែមីនា ឆ្នាំ២០១៩

សំងាត់បំផុត

តារាង ខ តារាងសំណួរគ្រួសារផ្នែក 1

| | រាជធានី/ខេត្ត | ក្រុង/ស្រុក/ខណ្ឌ | ឃុំ/សង្កាត់ | ភូមិ | មណ្ឌលជំរឿនលេខ | អគារលេខ | គ្រួសារលេខ | នាមត្រកូល និង នាមខ្លួនរបស់មេគ្រួសារ |
|---|---|---|---|---|---|---|---|---|
| ឈ្មោះ | | | | | | | | |
| លេខកូដ | | | | | | | | |

## ព័ត៌មានប្រជាសាស្ត្រ

ប្រភេទគ្រួសារ/ប្រជាជន
(ចុះលេខកូដក្នុងប្រអប់ខាងក្រោម)

1. គ្រួសារធម្មតា ឬគ្រួសារប្រក្រតី
2. គ្រួសារស្ថាប័ន *
3. គ្រួសារគ្មានផ្ទះសំបែង *
4. ប្រជាជនរស់នៅលើទូក កាណូត នាវា *
5. ប្រជាជនឆ្លងកាត់ *
(សូមបញ្ជាក់ទីកន្លែង)

..............................

តារាងសំណួរ1.1: សមាជិកអចិន្ត្រៃយ៍ដែលមានវត្តមានក្នុងយប់ធ្វើជំរឿន

| លេខរៀង | នាមត្រកូល និង នាមខ្លួន (សរសេរនាមត្រកូលនិងនាមខ្លួន ដោយផ្តើមពីមេគ្រួសារ) | ទំនាក់ទំនងជាមួយមេគ្រួសារ (សរសេរជាអក្សរ) | ភេទ (សរសេរជាអក្សរ) |
|---|---|---|---|
| 1 | 2 | 3 | 4 |
| 1 | | | |
| 2 | | | |
| 3 | | | |
| 4 | | | |
| 5 | | | |
| 6 | | | |
| 7 | | | |
| 8 | | | |
| 9 | | | |
| 0 | | | |

តារាងសំណួរ 1.2: ភ្ញៀវដែលមានវត្តមានក្នុងយប់ធ្វើជំរឿន

| លេខរៀង | នាមត្រកូល និង នាមខ្លួន (សរសេរនាមត្រកូល និងនាមខ្លួន) | ទំនាក់ទំនងជាមួយមេគ្រួសារ (សរសេរជាអក្សរ) | ភេទ (សរសេរជាអក្សរ) | លំនៅដ្ឋានតាំងនៅពិតប្រាកដ: នៅក្នុងប្រទេសកម្ពុជា សរសេរឈ្មោះ ឃុំ/សង្កាត់ ស្រុក/ខណ្ឌឈ្មោះខេត្ត ក្នុងបង្គោល 5 (ក) | | លំនៅដ្ឋានតាំងនៅពិតប្រាកដ: នៅក្រៅប្រទេសកម្ពុជា សរសេរឈ្មោះប្រទេស ក្នុងបង្គោល 6 (ក) | |
|---|---|---|---|---|---|---|---|
| 1 | 2 | 3 | 4 | 5(ក) | 5 (ខ) | 6 (ក) | 6 (ខ) |
| 1 | | | | | | | |
| 2 | | | | | | | |
| 3 | | | | | | | |
| 4 | | | | | | | |
| 5 | | | | | | | |
| 6 | | | | | | | |
| 7 | | | | | | | |
| 8 | | | | | | | |
| 9 | | | | | | | |
| 0 | | | | | | | |

តារាងសំណួរ 1.3: សមាជិកអចិន្ត្រៃយ៍ដែលអវត្តមានក្នុងយប់ធ្វើជំរឿន

| លេខរៀង | នាមត្រកូល និង នាមខ្លួន (សរសេរនាមត្រកូល និងនាមខ្លួន) | ទំនាក់ទំនងជាមួយមេគ្រួសារ (សរសេរជាអក្សរ) | ភេទ (សរសេរជាអក្សរ) | អាយុ គិតជាឆ្នាំពេញ | អាសយដ្ឋានក្នុងយប់ធ្វើជំរឿន: នៅក្នុងប្រទេសកម្ពុជា សរសេរឈ្មោះឃុំ/សង្កាត់ ស្រុក/ខណ្ឌ ខេត្ត ក្នុងបង្គោល 6 (ក) | កូដទីតាំង | មូលហេតុ | នៅក្រៅប្រទេសកម្ពុជា: សរសេរឈ្មោះប្រទេស ក្នុងបង្គោល 7 (ក) | កូដទីតាំង | មូលហេតុ | តើអវត្តមានក្នុងរយៈពេលប៉ុន្មាន? (គិតជាខែពេញ) ចុះលេខ 0 បើតិចជាង 1 ខែ |
|---|---|---|---|---|---|---|---|---|---|---|---|
| 1 | 2 | 3 | 4 | 5 | 6 (ក) | 6 (ខ) | 6(គ) | 7 (ក) | 7 (ខ) | 7(គ) | 8 |
| 1 | | | | | | | | | | | |
| 2 | | | | | | | | | | | |
| 3 | | | | | | | | | | | |
| 4 | | | | | | | | | | | |
| 5 | | | | | | | | | | | |

ចំនួនមនុស្សសរុបក្នុងតារាងសំណួរ1.1

ចំនួនមនុស្សសរុបក្នុងតារាងសំណួរ1.2

ចំនួនមនុស្សសរុបក្នុង តារាងសំណួរ 1.1 & 1.2

បង្គោល 5 អាយុ
000: តិចជាង1 ឆ្នាំ 001: 1 ឆ្នាំ 002: 2 ឆ្នាំ
097: 97 ឆ្នាំ 099: 99 ឆ្នាំ 120:120 ឆ្នាំ

តារាងសំណួរ 1.3 បង្គោល 6(គ) និងបង្គោល7 (គ)
1. ការងារ 2. ពាណិជ្ជកម្ម 3. ទេសចរណ៍
4. អប់រំ 5. រៀបការ 6. ព្យាបាលរោគ 7. ផ្សេងទៀត

| | ឈ្មោះ | ហត្ថលេខា | ថ្ងៃ / ខែ / ឆ្នាំ |
|---|---|---|---|
| អ្នកសម្ភាសន៍ | ............ | ............ | ..../..../.... |
| អ្នកត្រួតពិនិត្យ | ............ | ............ | ..../..../.... |

សរុបចំនួនតារាង ខ ដែលបានប្រើប្រាស់

# តារាង ខ តារាង សំណួរគ្រួសារផ្នែក 2: ព័ត៌មានផ្ទាល់ខ្លួន

| ព័ត៌មានសម្រាប់មនុស្សគ្រប់រូប | | | | | សម្រាប់កុមារអាយុ 0-14 ឆ្នាំ | សម្រាប់មនុស្សទាំងអស់ | សម្រាប់មនុស្សទាំងអស់ក្រៅពីអ្នកមិនទាន់រៀបការ | ព័ត៌មានសម្រាប់មនុស្សគ្រប់រូប | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| លេខរៀង | នាមត្រកូល និង នាមខ្លួន | ទំនាក់ទំនង | ភេទ | អាយុ | | | | ភាសាកំណើត | សាសនា | ទីកន្លែងកំណើត | | លំនៅដ្ឋានពីមុន តើពីមុនមនុស្សនេះរស់នៅទីណា ? | | រយៈពេលស្នាក់នៅ | មូលហេតុនៃការផ្លាស់លំនៅដ្ឋាន |
| | ឈ្មោះសមាជិក អចិន្ត្រៃយ៍ និងភ្ញៀវ ដែលមានវត្តមានក្នុងយប់ធ្វើជំរឿន (ស្រង់ចេញពីតារាងសំណួរ 1.1 និង 1.2 *ក្នុងផ្នែក 1)* | ទំនាក់ទំនងជាមួយមេគ្រួសារ *(ចុះលេខកូដតាមតារាងខាងក្រោម)* | 1. ប្រុស<br>2. ស្រី *(ចុះលេខកូដ)* | គិតជាឆ្នាំពេញ | តើកូនរស់នៅជាមួយម្ដាយបង្កើតរបស់ខ្លួនដែរឬទេ? (មើលសំគាល់ខាងក្រោម) | ស្ថានភាពអាពាហ៍ពិពាហ៍ ចុះលេខកូដតាមខាងក្រោម | អាយុនៅពេលរៀបការលើកទីមួយជាឆ្នាំពេញ *(សួរតែមនុស្សរៀបការហើយ មេម៉ាយ/ពោះម៉ាយ លែងលះ ឬ រស់នៅជួរគ្នា)* | ចុះលេខកូដតាមតារាងខាងក្រោម | ចុះលេខកូដតាមតារាងខាងក្រោម | - បើកើតក្នុងភូមិនេះសូមចុះលេខកូដ 1<br>- បើកើតក្នុងភូមិផ្សេងទៀតសូមសរសេរឈ្មោះ ឃុំ/សង្កាត់ ស្រុក/ខណ្ឌ ខេត្ត<br>- បើកើតនៅក្រៅប្រទេសកម្ពុជា សូមសរសេរឈ្មោះប្រទេសនោះ | | - បើរស់នៅនិរន្តក្នុងភូមិនេះតាំងពីកើតមកសូមចុះលេខកូដ 1 រួចរំលងទៅបង្គោល 15(ក)<br>- បើកើតក្នុងភូមិផ្សេង'ទៀត សូមសរសេរឈ្មោះ ឃុំ/សង្កាត់ ស្រុក/ខណ្ឌ ខេត្ត<br>- បើកើតនៅក្រៅប្រទេសកម្ពុជាសូមសរសេរឈ្មោះប្រទេសនោះ | | តើមនុស្សនេះបានស្នាក់នៅភូមិនេះបានប៉ុន្មានឆ្នាំហើយ *ចុះលេខកូដតាមតារាងខាងក្រោម* | *ចុះលេខកូដតាមតារាងខាងក្រោម* |
| | | | | | | | | | | សរសេរឈ្មោះឃុំ/សង្កាត់/ស្រុក/ខណ្ឌ ខេត្ត ឬប្រទេសក្នុងបង្គោល 11 (ក) | កូដទីតាំង | សរសេរឈ្មោះឃុំ/សង្កាត់/ស្រុក/ខណ្ឌ ខេត្ត ឬប្រទេសក្នុងបង្គោល 12 (ក) | កូដទីតាំង | | |
| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11(ក) | 11(ខ) | 12(ក) | 12(ខ) | 13 | 14 |
| 1 | | | | | | | | | | | | | | | |
| 2 | | | | | | | | | | | | | | | |
| 3 | | | | | | | | | | | | | | | |
| 4 | | | | | | | | | | | | | | | |
| 5 | | | | | | | | | | | | | | | |
| 6 | | | | | | | | | | | | | | | |
| 7 | | | | | | | | | | | | | | | |
| 8 | | | | | | | | | | | | | | | |
| 9 | | | | | | | | | | | | | | | |
| 0 | | | | | | | | | | | | | | | |

**លេខកូដសម្រាប់បង្គោល 3 ទំនាក់ទំនងជាមួយមេគ្រួសារ**
1. មេគ្រួសារ
2. ប្រពន្ធ/ប្តី
3. កូនប្រុស/កូនស្រី
4. ឪពុក/ម្តាយ
5. ចៅ
6. សាច់ញាតិផ្សេងទៀត
7. អ្នកដែលមិនមែនជាសាច់ញាតិ'រាប់បញ្ចូលទាំងអ្នកផ្ញើខ្លួន

**អាយុគិតជាឆ្នាំពេញ បង្គោល 5**
000: តិចជាង1ឆ្នាំ
001: 1ឆ្នាំ
002: 2ឆ្នាំ
:
:
:
120 :120 ឆ្នាំ

**បង្គោល 6**
សរសេរលេខរៀងរបស់ម្តាយបង្កើត បើសិនរស់នៅក្នុងគ្រួសារនេះសម្រាប់កុមារអាយុ0-14ឆ្នាំ
បើសិនមិនរស់នៅជាមួយទេ សរសេរ "0"

**បង្គោល 7**
1. មិនដែលរៀបការ ឬ នៅលីវ
2. រៀបការហើយ (កំពុងរស់នៅជាមួយគ្នា)
3. មេម៉ាយប្តីស្លាប់ ពោះម៉ាយប្រពន្ធស្លាប់
4. មេម៉ាយ ពោះម៉ាយ លែងគ្នា
5. ទំនាស់រស់នៅផ្សេង

**លេខកូដសម្រាប់បង្គោល 9 ភាសាកំណើត**

| | | |
|---|---|---|
| 01. ខ្មែរ | 11. ចាម | 21. ចារ៉ាយ |
| 02. វៀតណាម | 12. កាវ៉ែត | 22. គ្រុល |
| 03. ចិន | 13. គ្រឹង | 23. រដែរ |
| 04. ឡាវ | 14. គួយ | 24. លួន |
| 05. ថៃ | 15. គ្រឹង | 25. ម៉ិល |
| 06. បាភាំង | 16. លុន | 26. ខូញ |
| 07. អង់គ្លេស | 17. ភ្នង | 27. ព័រ |
| 08. កូរ៉េ | 18. ព្រៅ | 28. ស៊្មែយ |
| 09. ជប៉ុន | 19. ទុំពួន | 29. ភាសាកំណើតផ្សេងទៀត......) |
| 10. ចារ៉ាយ | 20. ស្ទៀង | |

**បង្គោល 10**
1. ព្រះពុទ្ធ
2. ឥស្លាម
3. គ្រីស្តសាសនា
4. សាសនាផ្សេងទៀត

**លេខកូដសម្រាប់បង្គោល 13 រយៈពេលស្នាក់នៅពេញលេញ**
00. តិចជាង 1 ឆ្នាំ
01. 1 ឆ្នាំដល់តិចជាង 2 ឆ្នាំ
02. 2 ឆ្នាំដល់តិចជាង 3 ឆ្នាំ
.............................
10. 10 ឆ្នាំដល់តិចជាង 11ឆ្នាំ
.............................
20. 20 ឆ្នាំដល់តិចជាង 21 ឆ្នាំ
.............................
.............................
120. ដល់តិចជាង121ឆ្នាំ

**លេខកូដសម្រាប់បង្គោល 14 មូលហេតុសម្រាប់ការផ្លាស់ប្តូរលំនៅដ្ឋាន**
01. ប្តូរកន្លែងធ្វើការ
02. ស្វែងរកការងារធ្វើ
03. បន្តការសិក្សា
04. រៀបអាពាហ៍ពិពាហ៍
05. គ្រួសារផ្លាស់លំនៅដ្ឋាន
06. បាត់បង់ដីធ្លី/បាត់បង់លំនៅដ្ឋាន
07. គ្រោះថ្នាក់ធម្មជាតិ
08. ត្រូវបានធ្វើឱ្យផ្លាស់ទីកន្លែងមកពីសាងសង់ទំនប់
09. ត្រូវបានធ្វើឱ្យផ្លាស់ទីកន្លែងមកពីគំរោងធំប្រភេទផ្សេងទៀត
10. អសន្តិសុខ
11. មាតុភូមិនិវត្ត ឬមកស្រុកកំណើតវិញ
12. កូនកំព្រា
13. មកលេង
14. មូលហេតុផ្សេងទៀត (សូមបញ្ជាក់.....)

2/6

| លេខរៀង | ព័ត៌មានសម្រាប់មនុស្សគ្រប់រូប | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | អក្ខរភាព | | រយៈពេលសិក្សាពេញលេញ | | | | ការលំបាក សម្រាប់មនុស្សអាយុ 5 ឆ្នាំ ឡើង | សកម្មភាពការងារចំបង | អាជីព | ស្ថានភាពការងារ | សកម្មភាពការងារ | ផ្នែកនៃការងារ |
| | 15(ក) | 15(ខ) | 16 (ក) | 16 (ខ) | 16 (គ) | 16(ឃ) | 17 | 18 | 19 | 20 | 21 | 22 |
| | តើមនុស្សនេះចេះអាននិងសរសេរ និងយល់ភាសាខ្មែរដែរឬទេ?<br>1. ចេះ<br>2. មិនចេះ<br>(ចុះលេខកូដ) | តើមនុស្សនេះចេះអាន/សរសេរនិងយល់ភាសាផ្សេងទៀតដែរឬទេ?<br>បើមានតើភាសាអ្វី?<br>(ចុះលេខកូដពីបញ្ជីខាងក្រោម) | តើមនុស្សនេះធ្លាប់បានចូលសិក្សាក្នុងសាលា/គ្រឹះស្ថានអប់រំណាមួយដែរឬទេ? | តើបច្ចុប្បន្ននេះកំពុងរៀនថ្នាក់ទីប៉ុន្មាន?<br>(ចុះលេខកូដតាមតារាងខាងក្រោម) | តើមនុស្សនេះទទួលកំរិតសិក្សាពេញលេញខ្ពស់បំផុតត្រឹមថ្នាក់ទីប៉ុន្មាន?<br>(ចុះលេខកូដតាមតារាងខាងក្រោម) | ប្រធានបទសំខាន់នៃការសិក្សា សម្រាប់លេខកូដ 15ដល់ 20 ក្នុងបង្គោល 16(ខ) ឬ16(គ)<br>សម្រាប់កូដផ្សេងទៀតក្នុងបង្គោល 16(ខ) និង16(គ) រំលងទៅបង្គោល17 | **លេខកូដសម្រាប់ការលំបាក**<br>1. ទេ. មិនពិបាកអ្វីទេ<br>2. បាទ/ចាស់ ពិបាកខ្លះដែរ<br>3. បាទ/ចាស់ ពិបាកខ្លាំង<br>4. មិនអាចធ្វើបានសោះតែម្តង<br>សូមមើលកំណត់សំគាល់ខាងក្រោម | សកម្មភាពចំបងក្នុងអំឡុងឆ្នាំកន្លងមក សម្រាប់អាយុ 5 ឆ្នាំឡើង<br>ចុះលេខកូដតាមតារាងខាងក្រោម | ប្រភេទអាជីព/មុខរបរ<br>សម្រាប់មនុស្សអាយុ 5 ឆ្នាំ ឡើង<br>សូមសរសេរឈ្មោះអាជីព/មុខរបរជាអក្សរ | ស្ថានភាពការងារ/ឋានៈការងារ<br>(ចុះលេខកូដតាមតារាងខាងក្រោម) | ប្រភេទសកម្មភាពសេដ្ឋកិច្ច (កសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម ឬសេវាកម្ម)<br>សម្រាប់មនុស្សអាយុ 5 ឆ្នាំ ឡើង<br>សូមសរសេរឈ្មោះសកម្មភាពការងារជាអក្សរ | ការងារក្នុងផ្នែកណាមួយដែលបានបំរើ<br>(ចុះលេខកូដតាមតារាងខាងក្រោម) |
| | | | | | | ការពិពណ៌នា / លេខកូដ | 1 2 3 4 5 6 | | ឈ្មោះអាជីព/មុខរបរ / កូដមុខរបរ | | ឈ្មោះសកម្មភាពការងារ / កូដសកម្មភាព | |
| 1 | | | | | | | | | | | | |
| 2 | | | | | | | | | | | | |
| 3 | | | | | | | | | | | | |
| 4 | | | | | | | | | | | | |
| 5 | | | | | | | | | | | | |
| 6 | | | | | | | | | | | | |
| 7 | | | | | | | | | | | | |
| 8 | | | | | | | | | | | | |
| 9 | | | | | | | | | | | | |
| 0 | | | | | | | | | | | | |

**លេខកូដសម្រាប់បង្គោល 15(ខ)**
1. គ្មានភាសាផ្សេងទៀតទេ
2. វៀតណាម
3. ចិន
4. ឡាវ
5. ថៃ
6. បារាំង
7. អង់គ្លេស
8. ចាម
9. ភាសាផ្សេងទៀត

**លេខកូដសម្រាប់បង្គោល 16(ក)**
1. មិនដែលសោះ
2. បច្ចុប្បន្នកំពុងសិក្សា
3. សិក្សាពីអតីតកាល

**លេខកូដសម្រាប់បង្គោល 16 (ខ) កំរិតថ្នាក់កំពុងរៀនបច្ចុប្បន្ន**

សម្រាប់លេខកូដ 1 និងលេខកូដ 3 ក្នុងបង្គោល 16 (ក) សូមគូសសញ្ញា(-) ក្នុងបង្គោល16 (ខ)
សម្រាប់លេខកូដ 2 ក្នុងបង្គោល 16 (ក) ចុះលេខកូដដូចតទៅក្នុងបញ្ជីខាងក្រោម
លេខកូដសម្រាប់បង្គោល 16(គ) កំរិតសិក្សាពេញលេញខ្ពស់បំផុត
សម្រាប់លេខកូដ 1 ក្នុងបង្គោល 16(ក) សូមគូសសញ្ញា(-) ក្នុងបង្គោល16 (ខ) និងបង្គោល 16 (គ)
សម្រាប់លេខកូដ 2 និងលេខកូដ 3 ក្នុងបង្គោល 16(ក) ចុះលេខកូដដូចតទៅក្នុងបញ្ជីខាងក្រោម៖

**បញ្ជីលេខកូដសម្រាប់បង្គោល 16(ខ) និង16 (គ)**
00. មតេយ្យ
01. បញ្ចប់ថ្នាក់ទី 1
02. បញ្ចប់ថ្នាក់ទី 2
:
:
11.បញ្ចប់ថ្នាក់ទី 11
12.បញ្ចប់ថ្នាក់ទី 12
17. កំពុងរៀនថ្នាក់មហាវិទ្យាល័យ
18. កំពុងរៀនថ្នាក់អនុបណ្ឌិត
19.កំពុងរៀនថ្នាក់បណ្ឌិត
20. កំពុងរៀនមុខវិជ្ជាណាមួយផ្សេងទៀត

**លេខកូដដាច់ដោយឡែកសម្រាប់បង្គោល 16(ខ)**
15.កំពុងរៀនសញ្ញាបត្រមធ្យមសិក្សាបឋមភូមិមានបច្ចេកទេស/វិជ្ជាជីវៈ
16. កំពុងរៀនសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមានបច្ចេកទេស/វិជ្ជាជីវៈ

**លេខកូដដាច់ដោយឡែកសម្រាប់បង្គោល 16(គ)**
13. មានសញ្ញាបត្របឋមភូមិ
14.បានបញ្ចប់មធ្យមសិក្សា/មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ
15. សញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិមានបច្ចេកទេស/វិជ្ជាជីវៈ
16. សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិមានបច្ចេកទេស/វិជ្ជាជីវៈ
17. សញ្ញាបត្រថ្នាក់មហាវិទ្យាល័យ
18. សញ្ញាបត្រថ្នាក់អនុបណ្ឌិត
19. សញ្ញាបត្រថ្នាក់បណ្ឌិត
20. សញ្ញាបត្រមុខវិជ្ជាណាមួយផ្សេងទៀត
88. មិនបានបញ្ចប់ថ្នាក់ណាមួយ

**បង្គោល 17 សម្រាប់ប្រភេទនៃការលំបាក**
តើអ្នកមានការលំបាក.........
17.1 ក្នុងការមើលដែរឬទេ សូម្បីតែពាក់វ៉ែនតា?
17.2 ក្នុងការស្តាប់ដែរឬទេសូម្បីតែប្រើឧបករណ៍ជំនួយ?
17.3 ក្នុងការផ្លាស់ទី ឬឡើងជណ្តើរដែរឬទេ ?
17.4 ក្នុងការចងចាំឬផ្តង់អារម្មណ៍ដែរឬទេ?
17.5 ក្នុងការថែទាំខ្លួនឯងដែរឬទេ ដូចជាការងូតទឹក ឬស្លៀកពាក់?
17.6 ក្នុងការនិយាយដែរឬទេ ឧ. ដូចជាយល់អ្នកដទៃ ឬឱ្យអ្នកដទៃយល់ពីអ្នក?

**លេខកូដសម្រាប់បង្គោល 18**
សកម្មភាពការងារចម្បងក្នុងឆ្នាំកន្លងមក
1. មានការងារធ្វើ (សូមបំពេញបង្គោល 19 ដល់ 22)
2. គ្មានការងារធ្វើ (បានធ្វើការងារនៅពេលណាមួយពីមុនមក) (សូមបំពេញបង្គោល19 ដល់ 22 សម្រាប់ការងារចុងក្រោយ)
3. គ្មានការងារធ្វើ (ពីមុនមកពុំដែលធ្វើការងារណាមួយសោះ)
4. អ្នកធ្វើការងារផ្ទះ
5. សិស្ស និស្សិត
6. អ្នកនៅក្នុងមន្ទុក
7. អ្នករស់នៅដោយការជួលអចលនវត្ថុ ជនចូលនិវត្តន៍ ឬអ្នកទទួលប្រាក់ចំណូលផ្សេងទៀត
8. ផ្សេងទៀត (សម្រាប់លេខកូដ 3 ដល់ 8 សូមគូសសញ្ញា (-) ក្នុងបង្គោល 19 ដល់22)

**លេខកូដសម្រាប់បង្គោល 20**
**ស្ថានភាពការងារ**
1. និយោជក
2. និយោជិកទទួលប្រាក់ឈ្នួល
3. អ្នកធ្វើការងារដោយប្រើខ្លួនផ្ទាល់ខ្លួន
4. អ្នកធ្វើការងារសម្រាប់គ្រួសារដោយគ្មានប្រាក់ឈ្នួល
5. ផ្សេងទៀត (សូមបញ្ជាក់.......)

**លេខកូដសម្រាប់បង្គោល22**
**ផ្នែកនៃការងារ**
1. រដ្ឋាភិបាល
2. អង្គភាពស្វយ័ត
3. ផ្នែកឯកជនខ្មែរ
4. ផ្នែកឯកជនបរទេស
5. ស្ថាប័នមិនយកប្រាក់ចំណេញ
6. ផ្នែកគ្រួសារ
7. ស្ថានទូត / ស្ថាប័នអន្តរជាតិ និងភ្នាក់ងារអភិវឌ្ឍន៍ និងជំនួយបរទេស
8. ផ្សេងទៀត (សូមបញ្ជាក់....)

តារាង ខ តារាងសំណួរគ្រួសារផ្នែក 3 : ព័ត៌មានស្តីអំពីភាពបង្កើតកូនបានរបស់ស្ត្រីអាយុពី 15ឆ្នាំឡើង ដែលបានកត់ត្រាក្នុងបង្គោល 2 ផ្នែក 2

| លេខរៀង | នាមត្រកូល និងនាមខ្លួន | លេខរៀងស្ត្រីក្នុងបង្គោល 1 ផ្នែក 2 | ព័ត៌មានអំពីភាពបង្កើតកូនបាន | | | | | | ព័ត៌មានបង្កើតកូនគិតក្នុងរយៈពេល12 ខែកន្លងមក ចំពោះស្ត្រី អាយុ 15-49 ឆ្នាំ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ចំនួនក្មេងកើត *(ចុះចំនួនជាលេខពីរខ្ទង់ដូចជា 01, 02. ...10,11 ។ល។ បើគ្មាន ចុះ 00)* | | | | | | ព័ត៌មានបង្កើតកូនគិតក្នុងរយៈពេល 12 ខែកន្លងមក ចំពោះស្ត្រីអាយុ 15 - 49 ឆ្នាំ | | | |
| | | | តើអ្នកស្រីបានបង្កើតកូនរស់បានប៉ុន្មាននាក់ ? | | មានកូនប៉ុន្មាននាក់ដែលនៅរស់ ? | | មានកូនប៉ុន្មាននាក់ដែលបានស្លាប់ ? | | តើក្នុង 12 ខែកន្លងមកអ្នកស្រីបានបង្កើតកូនប៉ុន្មាននាក់ ? សូមចុះចំនួនកូនដែលបានកើត បើមិនបានបង្កើតកូនសូមចុះ *លេខ 0 រួចសួរទៅស្ត្រីបន្ទាប់* | | តើមានអ្នកណាជួយក្នុងពេលសំរាលកូននេះដែរឬទេ? (ចុះលេខកូដ *តាមតារាងខាងក្រោម)* | តើអ្នកបានចុះសំបុត្រកំណើតកូនដែលទើបកើតនេះជាមួយអាជ្ញាធរឃុំ/សង្កាត់ដែរឬទេ? (ចុះលេខកូដខាងក្រោម) |
| 1 | 2 | 3 | 4 | | 5 | | 6 | | 7 | | 8 | 9 |
| | | | (ក) ប្រុស | (ខ) ស្រី | (ក) ប្រុស | (ខ) ស្រី | (ក) ប្រុស | (ខ) ស្រី | (ក) ប្រុស | (ខ) ស្រី | | |
| 1 | | | | | | | | | | | | |
| 2 | | | | | | | | | | | | |
| 3 | | | | | | | | | | | | |
| 4 | | | | | | | | | | | | |
| 5 | | | | | | | | | | | | |
| 6 | | | | | | | | | | | | |
| 7 | | | | | | | | | | | | |
| 8 | | | | | | | | | | | | |
| 9 | | | | | | | | | | | | |
| 0 | | | | | | | | | | | | |

**លេខកូដសម្រាប់បង្គោល 8**

1: វេជ្ជបណ្ឌិត
2: គិលានុបដ្ឋាក/យិកា
3: ពេទ្យឆ្មប
4: ឆ្មបបុរាណ (TBA)
5: ផ្សេងទៀត(បញ្ជាក់..)
6: គ្មាន

**លេខកូដសម្រាប់បង្គោល 9**

បាទ=1
ទេ =2

តារាង ខ តារាងសំណួរគ្រួសារផ្នែក 4 : ស្ថានភាពលំនៅដ្ឋាន និង ប្រដាប់ប្រើប្រាស់នៅក្នុងផ្ទះ (ផ្នែក 4 មិនបាច់បំពេញចំពោះគ្រួសារស្ថាប័ន គ្រួសារគ្មានផ្ទះសំបែង ប្រជាជនរស់នៅលើទូក និងប្រជាជនឆ្លងកាត់)

*(ចុះលេខកូដក្នុងប្រអប់ខាងក្រោម)*

| តើលោកអ្នកកាន់កាប់លំនៅដ្ឋាននេះ តាមមូលដ្ឋានមួយណា ? | ប្រភពបំភ្លឺចម្បង | ប្រភពថាមពលប្រើប្រាស់សម្រាប់ចំអិនអាហារ | ប្រភេទបង្គន់ប្រើប្រាស់ដោយគ្រួសារ | ការប្រើប្រាស់បង្គន់អនាម័យរួមជាមួយគ្រួសារដ៏ទៃទៀត | ប្រភពផ្គត់ផ្គង់ទឹកសម្រាប់ទទួលទាន (ផឹក) | រយៈពេលទៅមកដើម្បីយកទឹកមកប្រើប្រាស់ (ផឹក)សម្រាប់គ្រួសារ | ចំនួនបន្ទប់ដែលគ្រប់គ្រងដោយគ្រួសារ (មិនរាប់បញ្ចូលផ្ទះបាយ បន្ទប់ទឹក និងឃ្លាំង) | មានប្រើប្រាស់បន្ទប់ផ្ទះបាយដាច់ដោយឡែកដែរឬទេ? |
|---|---|---|---|---|---|---|---|---|
| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 |
| 1. ផ្ទះផ្ទាល់ខ្លួន<br>2. ផ្ទះជួល<br>3. មិនមែនជាម្ចាស់ផ្ទះ តែជួលមិនបាច់បង់ប្រាក់ឈ្នួល<br>4. មូលដ្ឋានផ្សេងទៀត *(សូមបញ្ជាក់)..* | 1. អគ្គិសនីបណ្តាញ<br>2. ម៉ាស៊ីនភ្លើង<br>3. អគ្គិសនីបណ្តាញ និងម៉ាស៊ីនភ្លើង<br>4. ប្រេងកាត<br>5. ទៀន<br>6. អាគុយ ថ្មពិល<br>7. ផ្សេងទៀត *(សូមបញ្ជាក់)* | 1. អុស<br>2. ធ្យូងឈើ ធ្យូងថ្ម<br>3. ប្រេងកាត<br>4. ឧស្ម័ន ហ្គាស<br>5. អគ្គិសនី<br>6. គ្មាន<br>7. ផ្សេងទៀត *(សូមបញ្ជាក់)* | 1. មិនប្រើបង្គន់(**រំលងទៅបង្គោល 6**)<br>2. បង្គន់ចាក់ទឹក ឬ(ចុចបង្ហូរទឹក) តភ្ជាប់ទៅប្រព័ន្ធលូ<br>3. បង្គន់ចាក់ទឹក ឬ(ចុចបង្ហូរទឹក) តភ្ជាប់ទៅអាងស្តុក ឬរណ្តៅ<br>4. បង្គន់ចាក់ទឹក ឬ(ចុចបង្ហូរទឹក) បង្ហូរទៅកន្លែងផ្សេង(មិនបង្ហូរទៅអាងស្តុក ឬរណ្តៅ<br>5. បង្គន់រណ្តៅមានចានបង្គន់សម្រាប់បត់ជើង<br>6. បង្គន់រណ្តៅគ្មានផែនបង្គន់សម្រាប់បត់ជើង<br>7. បង្គន់បទជើងទន្លាក់ ឬក្នុងទឹក (ត្រពាំង/បឹង/ទន្លេ/សមុទ្រ<br>8. បង្គន់ផ្សេងទៀត<br>(សូមបញ្ជាក់) | 1. បាទ/ចាស, ប្រើរួមជាមួយសមាជិកគ្រួសារផ្សេងទៀត<br>2. ទេ, ប្រើប្រាស់តែសមាជិកគ្រួសារផ្ទាល់ខ្លួន | 1. ទឹកបំពងបណ្តាញក្នុងលំនៅដ្ឋាន<br>2.ទឹកបំពងបណ្តាញក្នុងទីធ្លា/បរិវេណលំនៅដ្ឋាន<br>3. ទឹកបំពង់សាធារណៈ<br>4. អណ្តូងស្នប់/អណ្តូងខួង<br>5. អណ្តូងជីកមានគម្របការពារ<br>6. អណ្តូងជីកគ្មានគម្របការពារ<br>7. ទឹកចេញក្រោមដីមានការការពារ<br>8. ទឹកចេញក្រោមដីគ្មានការការពារ<br>9. ទឹកភ្លៀង<br>10. ទិញទឹកឡានស៊ីទែន<br>11. ទិញទឹកធុងរទេះ<br>12. ទឹកលើដី (ទឹកទន្លេ/ស្ទឹង/ព្រែក/បឹង/ស្រះ/អូរ/ត្រពាំង)<br>13. ទឹកដប/ទឹកពិសាដប<br>14. ផ្សេងៗ (សូមបញ្ជាក់) | 1.ទឹកនៅក្នុងលំនៅដ្ឋាន<br>2.ចំណាយតិចជាង 30នាទី<br>3.ចំណាយច្រើនជាង 30នាទី<br>4.មិនដឹង | 1. មួយបន្ទប់<br>2. ពីរបន្ទប់<br>3. បីបន្ទប់<br>4. បួនបន្ទប់<br>5. ប្រាំបន្ទប់<br>6. ប្រាំមួយបន្ទប់<br>7. ប្រាំពីរបន្ទប់<br>8. ប្រាំបីបន្ទប់ឡើងទៅ | 1. បាទ/ចាស<br>2. មិនមាន |
| *(សូមចុះលេខកូដ)* | *(សូមចុះលេខកូដ)* | *(សូមចុះលេខកូដ)* | *(សូមចុះលេខកូដ)* | *(សូមចុះលេខកូដ)* | *(សូមចុះលេខកូដ)* | *(សូមចុះលេខកូដ)* | *(សូមចុះលេខកូដ)* | *(សូមចុះលេខកូដ)* |

ព័ត៌មានអំពីលទ្ធភាពនៃឧបករណ៍ប្រើប្រាស់នៅក្នុងគ្រួសារ (តាមមុខនីមួយៗ បើគ្មានសូមសរសេរលេខសូន្យ "00" បើមានសូមសរសេរចំនួនក្នុងប្រអប់)

| វិទ្យុ/ម៉ាញ៉េ | ទូរទស្សន៍ | ទូរស័ព្ទលើតុ | ទូរស័ព្ទដៃ | កុំព្យូទ័រផ្ទាល់ខ្លួន និងកុំព្យូទ័រលើតុ | កង់ | ម៉ូតូ | ទូរទឹកកក | ម៉ាស៊ីនបោកខោអាវ | កង្ហារ | ម៉ាស៊ីនត្រជាក់ | រថយន្ត/រថយន្តដឹកទំនិញធុនតូច/ធំ |
|---|---|---|---|---|---|---|---|---|---|---|---|
| 10 | 11 | 12 | 13 | 14 | 15 | 16 | 17 | 18 | 19 | 20 | 21 |
| | | | | | | | | | | | |

| ទូក/កាណូត | ត្រាក់ទ័រ | |
|---|---|---|
| | (ក) ត្រាក់ទ័រធុនធំ/តូច | (ខ) គោយន្ត |
| 22 | 23 | |
| | | |

តើគ្រួសារមានប្រើប្រាស់អ៊ីនធើណែតដែរឬទេ?

| នៅផ្ទះ | សាធារណៈ (នៅក្រៅផ្ទះ) |
|---|---|
| 24 | 25 |
| 1. មាន<br>2. គ្មាន *(ចុះលេខកូដ )* | 1. មាន<br>2. គ្មាន *(ចុះលេខកូដ )* |

## តារាង ខ តារាងសំណួរគ្រួសារផ្នែក 5 : មនុស្សស្លាប់នៅក្នុងគ្រួសារ

មនុស្សស្លាប់នៅក្នុងគ្រួសារ ក្នុងរយៈពេល 12 ខែ កន្លងមក : ចំនួនមនុស្សស្លាប់សរុប [ ][ ]

| ព័ត៌មានអំពីអ្នកស្លាប់ | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| លេខរៀង | នាមត្រកូល និង នាមខ្លួនរបស់អ្នកស្លាប់ | ភេទ 1:ប្រុស 2:ស្រី *ចុះលេខកូដ* | ទំនាក់ទំនងជាមួយមេគ្រួសារ *ចុះលេខកូដតាមតារាងខាងក្រោម* | អាយុនៅពេលស្លាប់ មើលកំណត់សំគាល់ខាងក្រោម *ចុះលេខកូដតាមតារាងខាងក្រោម* | មូលហេតុនៃការស្លាប់? តើការស្លាប់នេះបណ្តាលមកពីមូលហេតុអ្វី? (ចុះលេខកូដតាមតារាងខាងក្រោម) | ចុះសំបុត្រមរណភាព តើអ្នកបានចុះសំបុត្រមរណភាពមនុស្សដែលស្លាប់នេះជាមួយអាជ្ញាធរឃុំ/សង្កាត់ដែរឬទេ? 1. បាទ/ចាស 2. ទេ | សម្រាប់តែស្ត្រីអាយុ 15-49 ឆ្នាំដែលបានស្លាប់: តើស្ត្រីបានស្លាប់នៅពេលមានផ្ទៃពោះ/អំឡុងពេលសំរាលកូន ឬក្នុងរយៈពេល 42 ថ្ងៃ ក្រោយពេលសំរាលកូនមែនដែរ ឬទេ ? 1: បាទ/ចាសមែន 2: មិនមែនទេ | បើបាទ/ចាស នៅក្នុងបង្គោល 8(ក): តើស្លាប់នៅកន្លែងណា? *(ចុះលេខកូដតាមតារាងខាងក្រោម )* | បើបាទ/ចាស នៅក្នុងបង្គោល 8(ក): តើមានអ្នកវិជ្ជាជីវៈជំនាញខាងសុខាភិបាលណាម្នាក់មានវត្តមានយកចិត្តទុកដាក់ចំពោះនាងមុនស្លាប់ដែរឬទេ? *(ចុះលេខកូដតារាងខាងក្រោម )* |
| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 (ក) | 8(ខ) | 8 (គ) |
| 1 | | | | | | | | | |
| 2 | | | | | | | | | |
| 3 | | | | | | | | | |
| 4 | | | | | | | | | |
| 5 | | | | | | | | | |
| 6 | | | | | | | | | |
| 7 | | | | | | | | | |
| 8 | | | | | | | | | |
| 9 | | | | | | | | | |
| 0 | | | | | | | | | |

**លេខកូដសម្រាប់បង្គោល 4**

1. មេគ្រួសារ
2. ប្រពន្ធ/ប្តី
3. កូនប្រុស/កូនស្រី
4. ឪពុក/ម្តាយ
5. ចៅ
6. សាច់ញាតិផ្សេងទៀត
7. អ្នកដែលមិនមែនជាសាច់ញាតិរាប់បញ្ចូលទាំងអ្នកផ្ញើខ្លួន

**លេខកូដសម្រាប់បង្គោល 5**

ចុះអាយុជាឆ្នាំពេញនៅពេលស្លាប់
000: តិចជាង1ឆ្នាំ
001: 1ឆ្នាំ
002: 2ឆ្នាំ
:
:
:
:

**លេខកូដសម្រាប់មូលហេតុនៃការស្លាប់សម្រាប់បង្គោល 6**

| ជម្ងឺ | | គ្រោះថ្នាក់ | មិនដឹង |
|---|---|---|---|
| 01: គ្រុនក្តៅ | 09: បញ្ហាពេលមានផ្ទៃពោះ | 13: មីនកប់ក្នុងដី | 17: មិនដឹង |
| 02: រាគ | 10: បញ្ហានៅពេលសំរាលកូន | 14: គ្រោះថ្នាក់ចរាចរ | |
| 03: របេង | 11: ក្រោយពេលសំរាល 42 ថ្ងៃ | 15: លង់ទឹក | |
| 04: ជម្ងឺបេះដូង | 12: ជម្ងឺផ្សេងទៀត | 16: គ្រោះថ្នាក់ផ្សេងទៀត | |
| 05: គ្រុនឈាម | | | |
| 06: គ្រុនចាញ់ | | | |
| 07: តេតាណូស៍ | | | |
| 08: អេដស៍ | | | |

**លេខកូដសម្រាប់បង្គោល 8 (ខ)**

ទីកន្លែងស្លាប់
1. មន្ទីរពេទ្យ
2. មណ្ឌលសុខភាព
3. នៅផ្ទះ
4. ផ្សេងទៀត (បញ្ជាក់.........)

**លេខកូដសម្រាប់បង្គោល 8 (គ)**

1: វេជ្ជបណ្ឌិត
2: គិលានុបដ្ឋាក/យិកា
3: ពេទ្យឆ្មប
4: ឆ្មបបុរាណ(TBA)
5: ផ្សេងទៀត (បញ្ជាក់.)
6: គ្មាន

6/6

# ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩

## បញ្ជីឈ្មោះតារាងអាទិភាព

| លេខរៀង | លេខតារាង | ឈ្មោះ |
|---|---|---|
| | (i) | **ក- ស៊េរី តារាងប្រជាជនទូទៅ** |
| ១ | A1 | ចំនួនប្រជាជនតាមឆ្នាំវាយអាយុ និងភេទ |
| ២ | A2 | ចំនួនប្រជាជនតាមស្ថានភាពអាពាហ៍ពិពាហ៍ តាមក្រុមអាយុ ៥ ឆ្នាំ និងភេទ |
| ៣ | A3 | ចំនួនប្រជាជនតាមភាសាកំណើតតាមក្រុមអាយុ ៥ ឆ្នាំ និងភេទ |
| ៤ | A3A | ចំនួនប្រជាជនតាមភាសាកំណើត (ភាសាជនជាតិភាគតិច) តាមក្រុមអាយុ ៥ ឆ្នាំ និងភេទ |
| ៥ | A4 | ចំនួនប្រជាជនតាមសាសនាតាមក្រុមអាយុ ៥ ឆ្នាំ និងភេទ |
| ៦ | A5 | ចំនួនប្រជាជនតាមទំនាក់ទំនងជាមួយមេគ្រួសារ តាមក្រុមអាយុ ៥ ឆ្នាំ និងភេទ |
| ៧ | A6 | ចំនួនប្រជាជនតាមទីកន្លែងសម្គាល់ (ចាត់តាមកម្ពុជាទីប្រជុំជន ជនបទ) តាមទីកន្លែងកំណើត និងភេទ |
| | (ii) | **ខ-ស៊េរី តារាងអក្ខរភាព និងកម្រិតសិក្សាអប់រំ** |
| ៨ | B1 | ចំនួន ប្រជាជនអាយុ ៧ ឆ្នាំឡើងចែកតាមអក្ខរភាពនៃភាសាណាមួយ កម្រិតសិក្សាអប់រំ ក្រុមអាយុ និងភេទ |
| ៩ | B1A | ចំនួនប្រជាជនអាយុ ៧ ឆ្នាំឡើង ចែកតាមអក្ខរភាពនៃភាសា ក្រុមអាយុ និងភេទ |
| ១០ | B2 | ចំនួនប្រជាជនអាយុ ៥ ឆ្នាំឡើងចូលរៀនក្នុងសាលា/គ្រឹះស្ថានសិក្សាចែកតាមអក្ខរភាព កម្រិតសិក្សាអប់រំ ក្រុមអាយុ និងភេទ |
| ១១ | B3 | ចំនួនសិស្សរៀនពេញម៉ោងដែលមានអាយុ ៥ ឆ្នាំឡើង តាមក្រុមអាយុ និងភេទ |

### (iii) គ-ស៊េរី តារាងសេដ្ឋកិច្ច

| | | |
|---|---|---|
| ១២ | C1 | ចំនួនប្រជាជនបែងចែកតាមសកម្មភាពចម្បងតាមក្រុមអាយុ និងភេទ |
| ១៣ | C2 | ចំនួនប្រជាជនមានការងារធ្វើអាយុ ៥ឆ្នាំឡើង បែងចែកតាមស្ថានភាពការងារ ក្រុមអាយុ និងភេទ |
| ១៤ | C3 | ចំនួនប្រជាជនអាយុ ៥ឆ្នាំឡើង មានការងារធ្វើ បែងចែកតាមវិស័យការងារ ក្រុមអាយុ និងភេទ |
| ១៥ | C4 | ចំនួនប្រជាជនអាយុ ៥ឆ្នាំឡើង គ្មានការងារធ្វើ បែងចែកតាមវិស័យការងារ ក្រុមអាយុ និងភេទ |
| ១៦ | C5 | ចំនួនប្រជាជនអាយុ ៥ឆ្នាំឡើងមានការងារធ្វើបែងចែកតាមស្ថានភាពការងារ ក្រុមអាយុ និងភេទ |
| ១៧ | C5A | ចំនួនប្រជាជនអាយុ ៥ ឆ្នាំឡើងមានការងារធ្វើបែងចែកតាមក្រុមអាយុ ភេទ និងតំបន់ |
| ១៨ | C6 | ចំនួនប្រជាជនអាយុ ៥ឆ្នាំឡើងសកម្មសេដ្ឋកិច្ចសកម្មភាពសេដ្ឋកិច្ចបែងចែកតាមក្រុមមុខរបរ និងភេទ |
| ១៩ | C7 | ចំនួនប្រជាជនអាយុ ៥ឆ្នាំឡើង អសកម្មសេដ្ឋកិច្ចបែងចែកតាមប្រភេទមុខងារ តាមក្រុមអាយុ និងភេទ |
| ២០ | C8 | ចំនួនប្រជាជនអាយុ ៥ឆ្នាំឡើងមានការងារធ្វើបែងចែកតាមសកម្មភាពសេដ្ឋកិច្ច ក្រុមអាយុ និងភេទ |
| ២១ | C9 | ចំនួនប្រជាជនអាយុ ៥ឆ្នាំឡើងមានការងារធ្វើបែងចែកតាមក្រុមមុខរបរចម្បង ក្រុមអាយុ និងភេទ |
| ២២ | C10 | ចំនួនប្រជាជនអាយុ ៥ឆ្នាំឡើងមានការងារធ្វើបែងចែកតាមស្ថានភាពចម្បងនៃការងារ ឧស្សាហកម្ម និង ភេទ |
| ២៣ | C11 | ចំនួនប្រជាជនអាយុ ៥ឆ្នាំឡើងមានការងារធ្វើបែងចែកតាមស្ថានភាពចម្បងនៃការងារ មុខរបរ និងភេទ |
| ២៤ | C12 | ចំនួនប្រជាជនអាយុ ៥ ឆ្នាំឡើងមានការងារធ្វើបែងចែកតាមអក្ខរភាពនៃភាសាណាមួយ កម្រិតសិក្សាអប់រំ មុខរបរ និងភេទ |
| ២៥ | C15 | ចំនួនស្ត្រីអាយុ ៥ ឆ្នាំ មានការងារធ្វើបែងចែកតាមសកម្មភាពសេដ្ឋកិច្ច ស្ថានភាពអាពាហ៍ពិពាហ៍ និងភេទ |
| ២៦ | C16 | ចំនួនស្ត្រីអាយុ ៥ឆ្នាំ មានការងារធ្វើបែងចែកតាមក្រុមមុខរបរ ស្ថានភាពអាពាហ៍ពិពាហ៍ និងភេទ |

| | | |
|---|---|---|
| ២៧ | C17 | ចំនួនប្រជាជនអាយុ ៥ឆ្នាំ ឡើងដល់ ២០ឆ្នាំ មានការងារធ្វើបែងចែកតាមការចូលសាលារៀន អាយុរាយ និងភេទ |
| | (iv) | **ឃ-ស៊េរីតារាងទេសន្តប្រវេសន៍** |
| ២៨ | D1 | ចំនួនប្រជាជនទេសន្តប្រវេសន៍បែងចែកតាមលំនៅដ្ឋានចុងក្រោយ រយៈពេលស្នាក់នៅ និងភេទ |
| ២៩ | D2 | ចំនួនប្រជាជនទេសន្តប្រវេសន៍ពីខេត្តផ្សេងបែងចែកតាមខេត្តសម្ភាសន៍ លំនៅដ្ឋានពីមុន រយៈពេលស្នាក់នៅ និងភេទ |
| ៣០ | D3 | ចំនួនប្រជាជនទេសន្តប្រវេសន៍បែងចែកតាមទីតាំងលំនៅដ្ឋានចុងក្រោយ មូលហេតុ រយៈពេលស្នាក់នៅ និងភេទ |
| ៣១ | D4 | ចំនួនប្រជាជនអាយុ ៥ ឆ្នាំឡើងសកម្មសេដ្ឋកិច្ចទេសន្តប្រវេសន៍បែងចែកតាមលំនៅដ្ឋានចុងក្រោយ សកម្មភាពសេដ្ឋកិច្ច និងភេទ |
| ៣២ | D5 | ចំនួនប្រជាជនអាយុ ៥ឆ្នាំឡើងសកម្មសេដ្ឋកិច្ចទេសន្តប្រវេសន៍បែងចែកតាមលំនៅដ្ឋានចុងក្រោយ ក្រុមមុខរបរចម្បង និងភេទ |
| ៣៣ | D6 | ចំនួនប្រជាជនអាយុ ៧ឆ្នាំឡើង ទេសន្តប្រវេសន៍ពីលំនៅដ្ឋានចុងក្រោយបែងចែកតាមកម្រិតសិក្សាអប់រំតាមស្ថានភាពសកម្មភាពចម្បងតាមក្រុមអាយុ និងភេទ |
| ៣៤ | D7 | ចំនួនប្រជាជនទេសន្តប្រវេសន៍ក្នុងរយៈពេល៥ឆ្នាំមុន ចែកតាមក្រុមអាយុ និងភេទ |
| | (v) | **ង-ស៊េរីតារាងពិការភាព** |
| ៣៥ | E1 | ចំនួនប្រជាជនពិការអាយុ ៥ ឆ្នាំឡើងបែងចែកតាមស្ថានភាពពិការ ភេទ និងរាជធានីខេត្ត |
| ៣៦ | E2 | ចំនួនប្រជាជនពិការអាយុ ៥ ឆ្នាំឡើង បែងចែកតាមប្រភេទពិការ កម្រិតពិការ ភេទ និងក្រុមអាយុ |
| ៣៧ | E3 | ចំនួនប្រជាជនពិការអាយុ ៥ ឆ្នាំឡើង បែងចែកតាមប្រភេទពិការ កម្រិតពិការ និងរាជធានីខេត្ត |
| ៣៨ | E4 | ចំនួនប្រជាជនពិការអាយុ ៥ ឆ្នាំឡើង បែងចែកតាមប្រភេទពិការ កម្រិតពិការ និងតំបន់ |
| ៣៩ | E5 | ចំនួនប្រជាជនពិការអាយុ ៥ ឆ្នាំឡើង បែងចែកតាមប្រភេទគ្រួសារ កម្រិតពិការ ភេទ និងក្រុមអាយុ |

៤០ E6 ចំនួនប្រជាជនពិការអាយុ ៥ ឆ្នាំឡើង បែងចែកតាមទំនាក់ទំនងមេគ្រួសារ និងភេទ

៤១ E7 ចំនួនប្រជាជនពិការអាយុ ១០ ឆ្នាំឡើង តាមប្រភេទពិការ ស្ថានភាពអាពាហ៍ពិពាហ៍ ភេទ និងតំបន់

៤២ E8a ចំនួនប្រជាជនពិការបែងចែកតាមកម្រិតពិការ ស្ថានភាពចូលរៀន ក្រុមអាយុ ភេទ និងតំបន់

៤៣ E8b ចំនួនប្រជាជនពិការអាយុ ៥ ឆ្នាំឡើង បែងចែកតាមកម្រិតពិការ ភាពអក្ខរភាពភាសាណាមួយ ក្រុមអាយុ ភេទ និងតំបន់

៤៤ E9 ចំនួនប្រជាជនពិកាអាយុ ៥ ឆ្នាំឡើង បែងចែក តាមកម្រិតសិក្សាអប់រំ ភេទ និងតំបន់

៤៥ E10aE11a ចំនួនប្រជាជនពិការអាយុ ៥ ឆ្នាំឡើង បែងចែកកម្រិតំពិការ សកម្មភាពចម្បង ក្រុមអាយុ ភេទ និងតំបន់

៤៦ E10b E11b ចំនួនប្រជាជនពិការអាយុ ១៥-៤៩ បែងចែកកម្រិតពិការ សកម្មភាពចម្បង ក្រុមអាយុ ភេទ និងតំបន់

៤៧ E12a ចំនួនប្រជាជនពិការអាយុ ១៥-៤៩ បែងចែកប្រភេទពិការ កម្រិតពិការ ក្រុមមុខរបរចម្បង ភេទ និងតំបន់

៤៨ E12b ចំនួនប្រជាជនពិការអាយុ ១៥-៤៩ បែងចែកប្រភេទពិការ កម្រិតពិការ ក្រុមសកម្មភាពសេដ្ឋកិច្ចចម្បង ភេទ និងតំបន់

**(vi) ច-លទ្ធភាពបង្កើតកូន**

៤៩ F1 ចំនួនកូនបង្កើតដោយស្ត្រីអាយុ១៥-៤៩ អំឡុងពេល១២ខែកន្លងមក បែងចែកតាមក្រុមអាយុ កម្រិតសិក្សាអប់រំ តាមលំដាប់កំណើត ភេទ និងតំបន់

៥០ F2 ចំនួនកូនបង្កើតដោយស្ត្រីអាយុ១៥-៤៩ អំឡុងពេល១២ខែកន្លងមក បែងចែកតាមក្រុមអាយុ សកម្មភាពចម្បង តាមលំដាប់កំណើត ភេទ និងតំបន់

៥១ F3 ចំនួនកូនបង្កើតដោយស្ត្រីអាយុ១៥ឡើង បែងចែកតាមលំដាប់កំណើត ក្រុមអាយុ កម្រិតសិក្សាអប់រំ ភេទ និងតំបន់

៥២ F4 ចំនួនកូនបង្កើតដោយស្ត្រីអាយុ១៥ឡើងបែងចែកតាមលំដាប់កំណើត ក្រុមអាយុ សកម្មភាពចម្បង ភេទ និងតំបន់

៥៣ F5 ចំនួនកូនបង្កើតដោយស្ត្រីអាយុ១៥ឡើងបែងចែកតាមលំដាប់ចំនួននៅរស់ ក្រុមអាយុ កម្រិតសិក្សាអប់រំ ភេទ និងតំបន់

៥៤ F6 ចំនួនកូនបង្កើតដោយស្ត្រីអាយុ១៥ឡើងបែងចែកតាមលំដាប់ចំនួននៅរស់ ក្រុមអាយុ សកម្មភាពចម្បង ភេទ និងតំបន់

៥៥ F7 ចំនួនកូនបង្កើតដោយស្ត្រីអាយុ ១៥-៤៩ អំឡុងពេល១២ខែកន្លងមក បែងចែកតាម ក្រុមអាយុ និងប្រភេទនៃអ្នកជួយនៅពេលកើត ភេទ និងតំបន់

(vii) **ឆ-ស៊េរីតារាងមរណៈភាព**

៥៦ G1 ចំនួនសមាជិកគ្រួសារស្លាប់ក្នុងអំឡុងពេល ១២ ខែ កន្លងមកបែងចែកតាមក្រុមអាយុ ភេទ និងតំបន់

៥៧ G2 ចំនួនសមាជិកគ្រួសារស្លាប់ក្នុងអំឡុងពេល ១២ ខែ កន្លងមកបែងចែកតាមមូលហេតុនៃការស្លាប់ ក្រុមអាយុ និងភេទ

៥៨ G3 ចំនួនមរណភាពមាតាបែងចែកតាមប្រភេទអ្នកជួយនៅពេលស្លាប់តាមទីកន្លែងស្លាប់ និងក្រុមអាយុ

៥៩ G4 ចំនួនសមាជិកគ្រួសារស្លាប់ក្នុងអំឡុងពេល ១២ ខែ កន្លងតាមក្រុមអាយុ ការចុះសំបុត្រមរណភាព

(viii) **ជ-ស៊េរីតារាងគ្រួសារ និងការប្រើប្រាស់ក្នុងលំនៅដ្ឋាន**

៦០ H1 ចំនួនអគារ/រចនាសម្ព័ន្ធកម្មសិទ្ធិគ្រួសារបែងចែកតាមប្រភេទនៃការប្រើប្រាស់

៦១ H2 ចំនួនអគារ/រចនាសម្ព័ន្ធ (លំនៅដ្ឋាន)បែងចែកតាមប្រភេទសម្ភារៈសំខាន់សំរាប់ដំបូល ជញ្ជាំង និងកំរាល

៦២ H3 ចំនួនគ្រួសារចែកតាមស្ថានភាពលកាន់កាប់លំនៅដ្ឋាន ទំហំគ្រួសារ និងចំនួនបន្ទប់ដែលមាន

៦៣ H4 ចំនួនគ្រួសារចែកតាមទំហំគ្រួសារតាមចំនួនសមាជិកសកម្មសេដ្ឋកិច្ច និងតាមភេទរបស់មេគ្រួសារ

៦៤ H5 ចំនួនមេគ្រួសារ(អាយុ១០ឆ្នាំឡើង)ចែកតាមស្ថានភាពសកម្មភាពចម្បងតាមក្រុមអាយុ៥ឆ្នាំ និងតាមភេទ

៦៥ H6 ចំនួនគ្រួសារចែកតាមប្រភពសំខាន់សំរាប់បំភ្លឺ និងតាមទំហំគ្រួសារ

៦៦ H7 ចំនួនគ្រួសារចែកតាមប្រភេទឥន្ធនៈប្រើប្រាស់សំរាប់ចំអិនអាហារ និងតាមទំហំគ្រួសារ

៦៧ H8 ចំនួនគ្រួសារចែកតាមប្រភពទឹកសំខាន់សំរាប់ទទួលទានតាមទីតាំងប្រភព និតតាមទំហំគ្រួសារ

៦៨ H9 ចំនួនគ្រួសារចែកតាមស្ថានភាពកាន់កាប់លំនៅដ្ឋាន និងតាមប្រភេទបង្គន់អនាម័យ

| | | |
|---|---|---|
| ៦៩ | H10 | ចំនួនគ្រួសារនិងប្រជាជន(ក្នុង១០.០០០នាក់)ចែកតាមស្ថានភាពកាន់កាប់លំនៅដ្ឋានតាមការប្រើប្រាស់អគ្គីសនី និងបង្គន់អនាម័យ |
| ៧០ | H11 | ចំនួនគ្រួសារចែកតាមប្រភពទឹកសំរាប់ទទួលទាន ការប្រើប្រាស់អគ្គីសនី និងអនាម័យ |
| ៧១ | H12 | ចំនួនគ្រួសារចែកតាមប្រភេទ និងចំនួនទ្រព្យសម្បត្តិដែលគ្រួសារមាន |
| ៧២ | H13 | ចំនួនគ្រួសារចែកតាមទំហំគ្រួសារ និងការប្រើប្រាស់អ៊ីនធឺណែត |
| ៧៣ | H14 | ចំនួនគ្រួសារ និងប្រជាជនចែកតាមប្រភេទគ្រួសារ |

# ឯកសារយោង


Arriaga, Eduardo and Associates (1994). *PAS - Population Analysis with Microcomputers*. Washington D.C.: U.S. Bureau of the Census.

Haupt, Arthur, Thomas T. Kane and Carl Haup (2011). *Population Reference Bureau's Population Handbook (Sixth Edition).* Washington D.C.: Population Reference Bureau.

Moultrie, TA. (2013). Introduction to fertility analysis. In TA Moultrie, RE Dorrington, AG Hill, K Hill, IM Timæus and B Zaba (eds). *Tools for Demographic Estimation*. Paris: International Union for the Scientific Study of Population. http://demographicestimation.iussp.org

Rowland, D. (2003). *Demographic Methods and Concepts*. Oxford: Oxford University Press.

United Nations (2008). Principles and Recommendations for Population and Housing Censuses. Revision 2. *Statistical Papers Series M No. 67/Rev.2*. New York: Department of Social and Economics Affaires.
United Nations (1983). Manual X. Indirect Techniques for Demographic Estimation. *Population Studies No. 81*. New York: Department of International Economic and Social Affairs.

United Nations (2013). *MORTPAK for Windows. Version 4.3*. New York: United Nations Population Division.

United Nations (2019). *World Population Prospects 2019.* New York: Department of Economic and Social Affairs. https://population.un.org/wpp/

Weeks, John. (2006). *Population, an introduction to concept and issues.* USA: Wadsworth.

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងផែនការ
វិទ្យាស្ថានជាតិស្ថិតិ

UNFPA

កិច្ចសហប្រតិបត្តិការ
អាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

សហភាពអឺរ៉ុប

ស៊ុយអែត
Sverige

中 国 援 助
CHINA AID